## សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន

# អរិយធម៌ខ្មែរ




រៀបរៀងដោយ

ទូច ជារ៉ា

ឆាន់ គឹមសឿន

សុខ ឈន



គ.ស. ២០២៤ ព.ស. ២៥៦៧

# អារម្ភកថា

សៀវភៅ «អរិយធម៌ខ្មែរ» នេះ ត្រូវបានរៀបចំចងក្រងឡើងសម្រាប់កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន នៅគ្រឹះស្ថានឧត្តមសិក្សា ជាពិសេសក្នុងគោលបំណងអភិរក្សនិងអភិវឌ្ឍវប្បធម៌ អរិយធម៌ជាតិនាសម័យសាកលភាវូបនីយកម្ម។ ទន្ទឹមនឹងចរន្តសាកលភាវូបនីយកម្មនេះ បានធ្វើឱ្យមានការប្រែប្រួលយ៉ាងច្រើនចំពោះវប្បធម៌ អរិយធម៌ខ្មែរយើង ដែលជាហេតុធ្វើឱ្យកូនខ្មែរមួយចំនួនធំមិនយល់ ឬមិនស្គាល់ពីតម្លៃដ៏ល្អផូរផង់នៃវប្បធម៌ អរិយធម៌របស់ជាតិសាសន៍ខ្លួន ហើយក៏ទទួលយកវប្បធម៌បរទេសទាំងស្រុង។ សៀវភៅនេះ គ្រាន់តែជាសេចក្ដីសង្ខេបខ្លីបំផុត ដើម្បីឱ្យងាយយល់ពីទិដ្ឋភាពទូទៅនៃវប្បធម៌ អរិយធម៌ ជំនឿ ទំនៀមទម្លាប់ ប្រពៃណី សាសនា សិល្បៈ សំណង់ប្រាសាទ ពិធីបុណ្យផ្សេងៗ និងសុជីវធម៌ក្នុងសង្គមខ្មែរប៉ុណ្ណោះ។ បើសិនជាចង់យល់ឱ្យកាន់ស៊ីជម្រៅពីវប្បធម៌ អរិយធម៌ខ្មែរគឺត្រូវធ្វើការអានឯកសារជាច្រើនថែមទៀត ទាំងភាសាខ្មែរនិងបរទេស។ ដូចនេះ យើងជាខ្មែរគ្រប់រូបគប្បីមានករណីយកិច្ចខិតខំព្យាយាមសិក្សាពីអរិយធម៌របស់ខ្លួន ដើម្បីឱ្យបានស្គាល់ច្បាស់ពីលក្ខណៈនិងជាតុផ្សំផ្សេងៗ នៃអរិយធម៌ខ្មែរ។ បើយើងបានស្គាល់ច្បាស់ពីអរិយធម៌ជាតិខ្លួនហើយនោះ ប្រាកដជាយើងមានមោទនភាពជាតិ ហើយមើលឃើញអត្តសញ្ញាណជាតិ លើកតម្កើងកិត្យានុភាពជាតិ និងខិតខំរិះរកមធ្យោបាយថែរក្សា ការពារ កេរមរតកសម្បត្តិវប្បធម៌ដែលបុព្វបុរសយើងបានបន្សល់ទុកមក ខិតខំច្នៃផ្សាយអរិយធម៌ ព្រមទាំងមានគំនិតរៀបចំអរិយធម៌របស់ខ្លួនឱ្យមានសម្ទុះយ៉ាងលឿនស្របតាមដំណើរវិវត្តនៃពិភពលោក។

ប៉ុន្តែទោះបីជាយើងខ្ញុំខិតខំរៀបចំយ៉ាងណាក្តី ក៏ស្នាដៃនេះនៅមានកង្វះខាតដោយចេតនា ឬអចេតនាក្តី ហើយដែលត្រូវបំពេញបន្ថែមនាពេលក្រោយៗទៀត។ ម្យ៉ាងទៀត យើងខ្ញុំក៏សូមអធ្យាស្រ័យពីមិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ សិស្ស និស្សិតដែលជាអ្នកស្នេហាវប្បធម៌ អរិយធម៌ជាតិ មេត្តាជួយរិះគន់ ផ្តល់យោបល់កែលម្អស្នាដៃនេះឱ្យកាន់តែល្អប្រសើរថែមទៀត។

# មាតិកា


**អារម្ភកថា** i
**សេចក្ដីផ្ដើម** ២
**មេរៀនទី១ សញ្ញាណទូទៅនៃអរិយធម៌**
១. អត្ថន័យនៃពាក្យអរិយធម៌ ៣
១.១. តាមន័យស័ព្ទជាតិ ៣
១.២. តាមទស្សនៈអ្នកប្រាជ្ញ ៣
២. មែកជាងអរិយធម៌ ៤
២.១. និយមន័យនៃពាក្យវប្បធម៌ ៤
២.២. និយមន័យនៃពាក្យសង្គមធម៌ ៧
២.៣. ទំនាក់ទំនងវប្បធម៌និងសង្គមធម៌ ៨
៣. អរិយធម៌សំខាន់ៗក្នុងលោក ៩
៤. ឥទ្ធិពលអរិយធម៌បរទេសមកលើសង្គមខ្មែរ ៩
**មេរៀនទី២ ដំណើរវិវត្តនៃអរិយធម៌ខ្មែរ**
១. អរិយធម៌ខ្មែរសម័យបុរេប្រវត្តិសាស្ត្រ ១១
១.១. កាលប្រវត្តិប្រទេសកម្ពុជា ១១
១.២. ពាក្យថា «ខ្មែរ-កម្ពុជា» និងដើមកំណើតជាតិខ្មែរ ១២
១.៣. ការរស់នៅតាមរូងភ្នំ ១៧
២. អរិយធម៌ខ្មែរសម័យប្រវត្តិសាស្ត្រ ២០
២.១. អរិយធម៌ខ្មែរសម័យមុនអង្គរ ២០
២.២. អរិយធម៌ខ្មែរសម័យមហានគរ ២៧
២.៣. អរិយធម៌ខ្មែរសម័យកណ្ដាល ៣៣
២.៤. អរិយធម៌ខ្មែរសម័យទំនើប ៤០
**មេរៀនទី៣ ប្រវត្តិនិងឥទ្ធិពលសាសនានៅក្នុងសង្គមខ្មែរ**
១. ប្រភពជំនឿសាសនា ៤៣
១.១. និយមន័យសាសនា ៤៣
១.២. សាសនាធំៗលើលោក ៤៤
២. ព្រហ្មញ្ញសាសនា ឬសាសនាព្រាហ្មណ៍ ៤៤
២.១. ប្រភព ៤៤
២.២. ការវិវត្ត ៤៤
២.៣. គម្ពីរវេទ ៤៥

២.៤. គោលទ្រឹស្តីសំខាន់ៗក្នុងព្រហ្មញ្ញសាសនា ៤៥
២.៥. អាទិទេពត្រីមូរ្តិ ៤៥
២.៦. ភារកិច្ចនិងតួនាទីទេវៈនៅក្នុងទស្សនៈពហុទេវនិយម ៤៧
២.៧. ឥទ្ធិពលព្រហ្មញ្ញសាសនាក្នុងសង្គមខ្មែរ ៤៩
៣. ព្រះពុទ្ធសាសនា ៥០
៣.១. ពុទ្ធប្រវត្តិសង្ខេប ៥១
៣.២. គម្ពីរព្រះត្រៃបិដក ៥១
៣.៣. គោលទ្រឹស្តីសំខាន់ៗក្នុងព្រះពុទ្ធសាសនា ៥២
៣.៤. ឥទ្ធិពលព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ ៥៤
**មេរៀនទី៤ ប្រវត្តិសិល្បៈខ្មែរ**
១. សិល្បៈស្ថាបត្យកម្មខ្មែរ ៥៦
១.១. និយមន័យ ៥៦
១.២. ស្ថាបត្យកម្មខ្មែរ ៥៦
១.៣. ការវិវត្តនៃសំណង់ស្ថាបត្យកម្មខ្មែរ ៥៧
១.៤. រចនាសម្ព័ន្ធនិងសិល្បៈសំណង់ប្រាសាទខ្មែរ ៦១
១.៥. តម្លៃនៃស្ថាបត្យកម្មខ្មែរ ៦២
២. សិល្បៈចម្លាក់ខ្មែរ ៦២
២.១. មុខងារនៃចម្លាក់ ៦២
២.២. ប្រភេទចម្លាក់ ៦២
២.៣. ប្រធានចម្លាក់ ៦៣
៣. សិល្បៈគំនូរ ៦៩
៤. សិល្បៈតន្ត្រី ៧០
៤.១. តន្ត្រីខ្មែរ ៧០
៤.២. តន្ត្រីខ្មែរលើ ៧២
៤.៣. តន្ត្រីសម័យ ៧៤
៥. សិល្បៈរបាំ ៧៤
៥.១. របាំប្រជាប្រិយ ៧៥
៥.២. របាំប្រពៃណី ៧៦
៥.៣. របាំព្រះរាជទ្រព្យ ឬរបាំក្បាច់បុរាណ ៧៦
៦. សិល្បៈអក្សរសិល្ប៍ ៧៨
៦.១. ប្រភពនិងកម្មវត្ថុអក្សរសិល្ប៍ ៧៨

៦.២. មុខងារអក្សរសិល្ប៍ ៨០
៦.៣. លក្ខណៈអក្សរសិល្ប៍ ៨១
៧. សិល្បៈភាពយន្ត ៨២
៧.១. ប្រវត្តិភាពយន្ត ៨២
៧.២. ប្រភេទភាពយន្ត ៨៤
៧.៣. ធាតុភាពយន្ត ៨៤
៧.៤. រចនាសម្ព័ន្ធភាពយន្ត ៨៤
**មេរៀនទី៥ ទំនៀមទម្លាប់ ប្រពៃណីខ្មែរ «ពិធីឆ្លងវ័យ»**
១. ពិធីទាក់ទងនឹងកំណើត «បង្កក់ធ្មប» ៨៥
១.១. រណ្ដាប់ ៨៦
១.២. អ្នកធ្វើកិច្ច ៨៦
១.៣. កិច្ចពិធី ៨៦
២. ពិធីនៅពេលរៀបពេញវ័យ «កោរជុក ឬកោរសក់» ៨៨
២.១. រណ្ដាប់ ៨៨
២.២. អ្នកធ្វើកិច្ច ៨៩
២.៣. កិច្ចពិធី ៨៩
៣. ពិធីនៅពេលពេញវ័យ «ចូលម្លប់» ៩០
៣.១. ការសង្កេតទូទៅ ៩០
៣.២. រណ្ដាប់ ៩០
៣.៣. កិច្ចពិធី ៩០
៤. ពិធីនៅពេលពេញវ័យ «បំបួសនាគ» ៩១
៤.១. លក្ខណៈទូទៅ ៩១
៤.២. ភាពជានាគ ៩១
៤.៣. ភាពជាបព្វជិត ៩១
៤.៤. ការលាចាកសិក្ខាបទ ៩១
៥. ពិធីអាពាហ៍ពិពាហ៍ ឬមង្គលការ ៩២
៥.១. ប្រភពអាពាហ៍ពិពាហ៍ ៩២
៥.២. មុនពេលរៀបអាពាហ៍ពិពាហ៍ ៩២
៥.៣. ពេលរៀបអាពាហ៍ពិពាហ៍ ៩៤
៦. ពិធីឆ្លងទៅភាពជាម្ដាយ «ឆ្លងទន្លេ» ៩៨
៦.១. ពពោះ ៩៨

៦.២. ឆ្លងទន្លេ ៩៩
៧. ពិធីចម្រើនអាយុ ឬចម្រើនព្រះជន្ម ១០០
៧.១. សាមីពិធី ១០១
៧.២. អត្ថន័យ ១០១
៨. ពិធីបុណ្យសព ១០១
៨.១. មុនពេលស្លាប់ ១០១
៨.២. ក្រោយពេលស្លាប់ ១០២
៨.៣. ពិធីដង្ហែនិងរំលាយសព ១០៣
**មេរៀនទី៦ ពិធីបុណ្យធំៗក្នុងប្រពៃណីខ្មែរ**
១. ពិធីបុណ្យចូលឆ្នាំខ្មែរ ១០៦
១.១. ប្រវត្តិបុណ្យចូលឆ្នាំ ១០៦
១.២. ពិធីសង្រ្កាន្តចូលឆ្នាំ ១០៦
១.៣. សកម្មភាពពេលបុណ្យចូលឆ្នាំ ១០៧
២. ពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក សំពះព្រះខែ ១០៩
២.១. ប្រភពពិធីបុណ្យប្រណាំងទូក ១០៩
២.២. ប្រភពពិធីបណ្តែតប្រទីប ១១០
២.៣. ប្រវត្តិពិធីអកអំបុក សំពះព្រះខែ ១១០
៣. ពិធីបុណ្យភ្ជុំបិណ្ឌ ១១១
៣.១. ប្រវត្តិបុណ្យភ្ជុំបិណ្ឌ ១១២
៣.២. រដូវបុណ្យភ្ជុំបិណ្ឌ ១១២
៣.៣. ការប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ ១១៣
៤. ពិធីបុណ្យច្រត់ព្រះនង្គ័ល ១១៤
៤.១. ប្រវត្តិពិធីច្រត់ព្រះនង្គ័ល ១១៤
៤.២. អ្នកតែងខ្លួនតំណាងឱ្យព្រះអង្គ ១១៥
៤.៣. ក្បួនហែច្រត់ព្រះនង្គ័ល ១១៦
៤.៤. ការផ្សងគោឧសភរាជ ១១៦
**មេរៀនទី៧ សុជីវធម៌ក្នុងសង្គម «ពិធីការខ្មែរ»**
១. ការងារពិធីការ ១១៨
១.១. និយមន័យ ១១៨
១.២. ប្រភេទពិធីការ ១១៨
១.៣. ភារកិច្ចពិធីការ ១១៩

១.៤. សារប្រយោជន៍នៃពិធីការ ១១៩
២. ពិធីការក្នុងគារវកិច្ច ១១៩
២.១. ប្រភពសំពះនិងថ្វាយបង្គំ ១១៩
២.២. អត្ថន័យនិងសារប្រយោជន៍ ១១៩
២.៣. ប្រភេទនិងខ្នាតនៃសំពះខ្មែរ ១២០
២.៤. ខ្នាតសំពះខ្មែរ ១២០
៣. ពិធីការក្នុងបដិសណ្ឋារកិច្ច ១២០
៤. ពិធីការក្នុងការទំនាក់ទំនង ១២១
៤.១. ទំនាក់ទំនងផ្ទៃក្នុង ១២១
៤.២. ទំនាក់ទំនងការងារខាងក្រៅ ១២១
៤.៣. ទំនាក់ទំនងជាផ្លូវការ ឬពាក់កណ្តាលផ្លូវការ ១២១
៥. ពិធីការក្នុងការប្រើប្រាស់ភាសា ១២១
៥.១. ការប្រើប្រាស់ភាសានិយាយ ១២១
៥.២. ធាតុសំខាន់ៗក្នុងការនិយាយ ១២២
៦. ពិធីការក្នុងការងារ ១២៤
៦.១. ពីអ្នកធំទៅអ្នកតូច ១២៤
៦.២. ពីអ្នកតូចទៅអ្នកធំ ១២៥
៦.៣. រវាងអ្នកស្មើគ្នា ១២៥
៧. ពិធីការក្នុងការប្រជុំ ១២៥
៧.១. មុនពេលប្រជុំ ១២៦
៧.២. ពេលប្រជុំ ១២៦
៧.៣. ក្រោយពេលប្រជុំ ១២៧
**ឯកសារពិគ្រោះ**

# សេចក្ដីផ្ដើម

ប្រទេសជាតិទាំងអស់នៅក្នុងពិភពរូបធាតុនេះ សុទ្ធតែមានគោលចារឹក គឺវប្បធម៌ អរិយធម៌ផ្ទាល់ខ្លួន។ បំណងប្រាថ្នាជាចម្បងរបស់គេ គឺចង់ធ្វើឱ្យវប្បធម៌និងអរិយធម៌ជាតិគេមានសម្ទុះលូតលាស់រីកចម្រើនតាមល្បឿនរបកគំហើញវិទ្យាសាស្ត្រនិងតាមចង្វាក់អភិវឌ្ឍន៍នៃមហាប្រទេស។ គេអាចដឹងនិងស្គាល់ប្រទេសជាតិមួយឿនលឿន ឬឱនថយបាន គឺដោយគេសិក្សាលើវប្បធម៌ អរិយធម៌ជាតិនោះឯងផ្ទាល់តែម្ដង។ ដើម្បីសម្រេចបំណងប្រាថ្នាដ៏ចម្បងនេះ គេបានខិតខំរៀបចំអរិយធម៌ឱ្យមានប្រយោជន៍យ៉ាងសកម្មទៅអនាគត ស្របតាមកាលអាកាសនិងទំនោរនៃសង្គម គឺធ្វើយ៉ាងណាឱ្យអរិយធម៌នោះបម្រើបំណងប្រាថ្នានិងសំណូមពរពិតប្រាកដរបស់គេ គឺសុខៈ។ ក្នុងការស្វែងរកសុខៈនេះ គេបានយកចិត្តទុកដាក់ខ្លាំងលើវិទ្យាសាស្ត្រ គេចាត់ទុកវិទ្យាសាស្ត្រជាគន្លឹះសំខាន់ ជាកម្លាំងចលករក្នុងការរៀបចំសង្គមមនុស្សទៅរកសុខៈ។ ជំនឿលើវិទ្យាសាស្ត្រនេះជាប្រភពនៃការរីកចម្រើនក៏ពិតមែនហើយ តែក៏ត្រូវយកចិត្តទុកដាក់លើវិស័យអក្សរសាស្ត្រ សីលធម៌ផងដែរ ព្រោះការផ្ដល់សុខៈតាមផ្នែកសម្ភារៈតែមួយមុខពុំទាន់គ្រប់គ្រាន់ទេ ត្រូវផ្ដល់សុខៈតាមផ្លូវចិត្តទៀតទើបគ្រប់គ្រាន់។

- វិទ្យាសាស្ត្រ + សីលធម៌ = ការរីកចម្រើន
- វិទ្យាសាស្ត្រ - សីលធម៌ = គ្រោះថ្នាក់

អ្នកប្រាជ្ញ ទស្សនវិទូ ប្រវត្តិវិទូ បញ្ញវន្ត បានខិតខំរិះរកមធ្យោបាយសិក្សាពិចារណា វិភាគនិងបង្កើតអ្វីមួយ គឺក្នុងបំណងស្វែងរកសុខៈជូនមនុស្សជាតិ ប៉ុន្តែបើអ្នកប្រើប្រាស់ខ្វះឧត្ដមគតិ ខ្វះសីលធម៌ ខ្វះមនុស្សធម៌វិញនោះ ប្រាកដជាខិតខំបង្វែរទិសដៅវិទ្យាសាស្ត្រពិតប្រាកដទៅបម្រើមហិច្ឆតាផលប្រយោជន៍ដ៏ខ្មៅកខ្វក់ផ្ទាល់ខ្លួនរបស់គេ។ ចំពោះខ្មែរយើងក៏មានវប្បធម៌ អរិយធម៌ជាគោលចារឹកផ្ទាល់ខ្លួនតាំងពីយូរលង់ណាស់មកហើយដែរ។ ប្រវត្តិសាស្ត្របានបញ្ជាក់ប្រាប់យើងថា ខ្មែរធ្លាប់មានអរិយធម៌ខ្ពង់ខ្ពស់ ល្បីល្បាញរន្ទឺសុះសាយពេញទាំងសាកលលោក ពិសេសគឺអរិយធម៌នាសម័យមហានគរ។ ជាសាក្សីផ្ទាល់ភ្នែក បុព្វបុរសយើងដែលជាយុទ្ធករកសាងអរិយធម៌ខ្មែរឱ្យបានរុងរឿង បានបន្សល់ទុកនូវកេរដំណែលកេតនភណ្ឌនិងបេតិកភណ្ឌដ៏ច្រើនសន្ធឹកសន្ធាប់រាប់មិនអស់ដូចជាប្រាង្គប្រាសាទរាប់រយ សិលាចារឹករាប់ពាន់ផ្ទាំង បារាយណ៍ បណ្ដាញជលមគ្គស្ពានស្ពឺ ក្បូរក្បាច់រចនានិងរូបចម្លាក់... ដែលធ្វើឱ្យពួកបរទេសនិងខ្មែរជំនាន់ក្រោយស្ញប់ស្ញែងកោតសរសើរមិនដាច់ពីមាត់ពីអរិយធម៌ដ៏រុងរឿងនេះ។ ដូចនេះ យើងជាខ្មែរគ្រប់រូបគប្បីមានករណីយកិច្ចខិតខំព្យាយាមសិក្សាពីអរិយធម៌របស់ខ្លួន ដើម្បីឱ្យបានស្គាល់ច្បាស់ពីលក្ខណៈនិងធាតុផ្សេងៗនៃអរិយធម៌ខ្មែរ។ បើយើងបានស្គាល់ច្បាស់ពីអរិយធម៌ជាតិខ្លួនហើយនោះ ប្រាកដជាយើងមានមោទនភាពជាតិ ហើយមើលឃើញអត្តសញ្ញាណជាតិ លើកតម្កើងកិត្យានុភាពជាតិ និងខិតខំរិះរកមធ្យោបាយថែរក្សា ការពារកេរមរតកសម្បត្តិវប្បធម៌ដែលបុព្វបុរសយើងបានបន្សល់ទុកមក ខិតខំច្នៃផ្សាយអរិយធម៌ ព្រមទាំងមានគំនិតរៀបចំអរិយធម៌របស់ខ្លួនឱ្យមានសម្ទុះយ៉ាងលឿនស្របតាមដំណើរវិវត្តនៃពិភពលោក។ ការចេះដឹងតែវប្បធម៌ អរិយធម៌ជាតិខ្លួន ពុំទាន់គ្រប់គ្រាន់ទេ ព្រោះយើងត្រូវតែចេះដឹងនិងស្គាល់អរិយ

ធម៌បរទេសថែមទៀត។ ការស្គាល់អរិយធម៌បរទេសពុំមានន័យថា ធ្វើតាមគេ ចម្លងតាមគេសុទ្ធសាធ ហើយបំបាត់ជាតុលក្ខណៈនិងតម្លៃសុទ្ធសាធនៃអរិយធម៌យើងនោះទេ។ ការយល់ដឹងអរិយធម៌បរទេសនេះ គឺគ្រាន់តែក្នុងគោលបំណងឆ្លុះបញ្ចាំងកែលម្អអរិយធម៌យើង ដោយធ្វើល្បាយជាតុបរទេសនិងជាតុអាយដោយធ្វើយ៉ាងណាឱ្យល្បាយទាំងនោះរក្សានិងទ្រទ្រង់នូវទស្សនៈមនោសាស្ត្រខ្លួន។ ការធ្វើសមានកម្មជាតុបរទេសនេះ គឺធ្វើឱ្យអរិយធម៌យើងកាន់តែដុះដាលថែមទៀត។ ការប៉ះទង្គិចគ្នារវាងអរិយធម៌ជាតិនិងអរិយធម៌បរទេស វាជាការធម្មតា ព្រោះអរិយធម៌បរទេសធំៗដែលរីកចម្រើន ក៏សុទ្ធតែជាផលរួមនៃការប៉ះទង្គិចរវាងអរិយធម៌ជាតិខ្លួននិងអរិយធម៌បរទេស ប៉ុន្តែធ្វើយ៉ាងណាច្នៃជាតុបរទេសទាំងនោះមកបម្រើអរិយធម៌ជាតិខ្លួន។

ឧទាហរណ៍៖

-អរិយធម៌បារាំងរីកលូតលាស់ ដោយសារមានការប៉ះទង្គិចអរិយធម៌បារាំងនិងអរិយធម៌ក្រិករ៉ូម៉ាំង។

- អរិយធម៌ឥណ្ឌា ក៏មានការប៉ះទង្គិចរវាងអរិយធម៌ខ្លួននិងអរិយធម៌អារ្យ៉ន់ដែរ។

- អរិយធម៌ខ្មែរ ក៏មានទំនាក់ទំនងនឹងអរិយធម៌បរទេសដែរ ដូចជាឥណ្ឌា ចិន ជាដើម។

ដូចនេះ ការជះឥទ្ធិពលនិងទំនាក់ទំនងអរិយធម៌មួយទៅនឹងអរិយធម៌មួយទៀត គឺជាលក្ខណៈមិនអាចប្រកែកបានក្នុងការកសាងអរិយធម៌មួយឱ្យជឿនលឿន។

# មេរៀនទី១ សញ្ញាណទូទៅនៃអរិយធម៌

មុននឹងលើយកអរិយធម៌ទាំងឡាយក្នុងលោកមកសិក្សា យើងគប្បីសិក្សាថា តើអ្វីទៅដែលគេនិយមហៅថា «**អរិយធម៌**» ?

អរិយធម៌ជាសញ្ញាណស្មុគស្មាញ ព្រោះថា ធាតុដែលផ្សំឱ្យកើតបានអរិយធម៌នីមួយៗមានច្រើនណាស់ ហើយធាតុទាំងនោះក៏ពុំដូចគ្នាពីអរិយធម៌មួយទៅអរិយធម៌មួយទៀតដែរ។ អរិយធម៌ទាំងឡាយដែលមាននាលោកយើងនេះ សុទ្ធតែមានជីវិតនិងវិវត្តរៀងៗខ្លួនថែមទៀត។ ឯពាក្យដែលគេបង្កើតឡើងក្នុងភាសានីមួយៗ ដើម្បីយកមកប្រើសម្គាល់ «**អរិយធម៌**» ដែលមានន័យផ្លាស់ប្តូរទៅតាមសម័យកាលទៀតផង។

## ១. អត្ថន័យនៃពាក្យអរិយធម៌

អរិយធម៌ (Civilization) ជាអ្វី?

### ១.១. តាមន័យសព្ទជាតិ

-អរិយធម៌ < អរិយ + ធម៌

-អរិយៈ ការប្រសើរ ខ្ពង់ខ្ពស់ ថ្លៃថ្នូរ រុងរឿង ចម្រុងចម្រើន...។

-ធម៌ៈ ជាតុ វិធី ធម្មភាព សភាវៈ ទ្រទ្រង់...។

ដូចនេះ អរិយធម៌ គឺជាធម៌ទាំងឡាយដែលមានសភាពនិងតម្លៃនៃការលូតលាស់ ដុះដាលរីកចម្រើនល្អប្រសើរ ខ្ពង់ខ្ពស់ ថ្លៃថ្នូរក្នុងការរស់នៅរបស់មនុស្សក្នុងសង្គម ដែលប្រកបទៅដោយរបៀបរៀបរយល្អ មានគ្រឿងប្រដាប់ប្រើប្រាស់ ជំនឿ ចំណេះ ចំណង់ចំណូលចិត្តគ្រប់បែបយ៉ាងក្នុងគោលដៅស្វែងរកសុខៈ។[1]

### ១.២. តាមទស្សនៈអ្នកប្រាជ្ញ

តាមវចនានុក្រមខ្មែរ ភាគ២ របស់សម្តេចសង្ឃរាជ ជួន ណាត បានពន្យល់ថា អរិយធម៌ គឺអ្វីដែលនាំឱ្យកើតសុខចម្រើន ឬបែបបទសណ្តាប់ធ្នាប់រៀបរយល្អត្រឹមត្រូវ។

តាមវចនានុក្រម (Larousse) សតវត្សទី២០ បានពន្យល់ថា អរិយធម៌គឺជារបៀបផ្សេងៗនៃការរីកចម្រើនទាំងស្មារតី បញ្ញា ចំណេះដឹង សីលធម៌ ឧស្សាហកម្មនៃសង្គមនីមួយៗ។

លោក ឡាឡង់ (LaLande 1715-1807) ជាតារាវិទូបារាំងយល់ថា អរិយធម៌គឺជាកម្រងមែកជាងច្រើនបែបយ៉ាងក្នុងសង្គមមនុស្សដែលមានលក្ខណៈសាសនា សីលធម៌ សិល្បៈ វិទ្យាសាស្ត្រ តិចនិច អាចមានជីវិតបន្តគ្នាក្នុងកាលអាកាស ហើយជាលក្ខណៈរួមរបស់សង្គមណាមួយ ឬសង្គមចំនួនច្រើនដែលទាក់ទងគ្នា។

[1] អ្នកស្រី ត្រឹង ងា, អរិយធម៌ខ្មែរសម្រាប់ថ្នាក់បញ្ចប់,១៩៧៤, ទំព័រ៨។

លោក មីរ៉ាបូ (Mirabeau 1715-1789) ជាសេដ្ឋកិច្ចវិទូបារាំងពន្យល់ថា អរិយធម៌គឺជាការរីកចម្រើនលូតលាស់នៃជាតិណាមួយដែលផ្ទុយពីភាពព្រៃផ្សៃ។

សរុបមក យើងអាចឱ្យនិយមន័យថា អរិយធម៌គឺជាការរីកចម្រើនលូតលាស់គ្រប់វិស័យ រួមទាំងផ្នែកស្មារតី សម្ភារៈ សិល្បៈ ប្រពៃណី ទំនៀមទម្លាប់ វិទ្យាសាស្ត្រ ទស្សនវិជ្ជា ព្រមទាំងការគ្រប់គ្រងដែលដឹកនាំសង្គមមនុស្សទៅរកភាពថ្លៃថ្នូរុងរឿងដែលផ្ទុយនឹងអំពើព្រៃផ្សៃ។

## ២. មែកធាងអរិយធម៌

### ២.១. និយមន័យនៃពាក្យវប្បធម៌

វប្បធម៌ (Culture) ជាអ្វី?

គេអាចឱ្យនិយមន័យនៃពាក្យវប្បធម៌ប្លែកៗគ្នាដូចខាងក្រោមនេះ៖

- វប្បធម៌ < វប្ប + ធម៌
    - វប្បៈ មានន័យថា សំណាប ពង្រោះ លូតលាស់ រីកចម្រើន ដុះដាល បណ្ដុះបណ្ដាល ផ្សាំ។
    - ធម៌ មានន័យថា ទ្រឹស្ដី ឬធម្មភាព នាំឆ្ពោះទៅរកវឌ្ឍនភាព និងការអនុវត្តយ៉ាងសកម្ម ឬមានន័យថា ធម្មភាព ជាតុ វិធី សភាវៈទ្រទ្រង់។

វប្បធម៌មានន័យច្រើនបែបច្រើនយ៉ាងទៅតាមទស្សននិយមផ្សេងៗគ្នាដូចជា៖

- វប្បធម៌ គឺអ្វីៗដែលទាក់ទងនឹងការសិក្សានិងការអប់រំ។
- វប្បធម៌ គឺការសិក្សាពង្រីកចំណេះវិជ្ជា។
- វប្បធម៌ គឺជាការផ្សាំបណ្ដុះវិជ្ជានិងប្រាជ្ញាស្មារតីឱ្យលូតលាស់ចម្រុងចម្រើនដោយវិទ្យាសាស្ត្រ សិល្បៈ អក្សរសាស្ត្រជាដើម។
- វប្បធម៌ មានន័យថា ធម៌ ឬវិធី ធម្មភាពដែលបណ្ដុះសាបព្រោះធ្វើឱ្យមានឫសគល់ មែកធាង ផ្លែផ្កា ពោលគឺការរីកចម្រើនលូតលាស់ដល់មនុស្ស សង្គមមនុស្ស ទាំងខាងផ្លូវកាយ ទាំងខាងផ្លូវចិត្ត។
- វប្បធម៌ គឺអ្វីៗដែលធ្វើឱ្យមានការរីកចម្រើនលូតលាស់គ្រប់វិស័យ។
- តាមវចនានុក្រមខ្មែរ វប្បធម៌សម្គាល់នូវការផ្សាំបណ្ដុះចំណេះវិជ្ជា ដោយចំណេះវិទ្យាសាស្ត្រ សិល្បៈជាដើម។

ឧទាហរណ៍៖

- បសុវប្បកម្មៈ ការបណ្ដុះបណ្ដាលខាងផ្នែកចិញ្ចឹមសត្វ។
- នេសាទវប្បកម្មៈ ការបណ្ដុះបណ្ដាលខាងផ្នែកនេសាទត្រី។
- រុក្ខវប្បកម្មៈ ការបណ្ដុះបណ្ដាលខាងផ្នែកដាំដុះរុក្ខជាតិ។
- ប្រពលវប្បកម្មៈ ការបណ្ដុះបណ្ដាលធ្វើឱ្យមានទិន្នផលខ្ពស់។

ជាតិពន្ធវិទូស្ត្រីជាតិអាមេរិកម្នាក់ឈ្មោះ**ម៉ាករ៉េតមីដ** (Magret Mead) បានសរសេរថា វប្បធម៌ គឺជាទំនៀមទម្លាប់រួមនិងទូទៅរបស់សង្គមនីមួយៗ ប៉ុន្តែជាទំនៀមទម្លាប់ដែលមានជាតំណនិង ដំណែលជាហូរហែតាមសតវត្ស។ រីឯការថែរក្សាទំនៀមទម្លាប់ជាបន្តបន្ទាប់គ្នានេះធ្វើទៅតាមរយៈ ការអប់រំ។ ឧទាហរណ៍ របៀបធ្វើម្ហូប របៀបចិញ្ចឹមកូនចៅ របៀបដឹកនាំគ្រួសារ និងប្រទេសជាតិ ជាដើម។

សរុបមកឃើញថា ពាក្យវប្បធម៌ទោះបីជាមានទស្សននិយមជាច្រើនបានយល់ខុសៗគ្នា ក៏ ដោយ គឺយើងឃើញនូវចំណុចឯកភាពគ្នាលើការរីកចម្រើនលូតលាស់ចម្រុងចម្រើនក្នុងសង្គម ដោយ សំដៅយកការសិក្សាអប់រំ ឬលទ្ធផលនៃការសិក្សាអប់រំបានដល់ចំណេះវិជ្ជា ការចេះដឹង និងបញ្ញាស្មារតី របស់មនុស្សដើម្បីរចនាច្នៃខ្លួនមនុស្សម្នាក់ៗឱ្យថ្លៃថ្នូរខ្ពង់ខ្ពស់។

## ២.១.១. សញ្ញាណវប្បធម៌

វប្បធម៌បង្កប់នូវតម្លៃជំនឿនិងយល់ឃើញអំពីពិភពមួយដែលស្ថិតនៅពីក្រោយការប្រព្រឹត្ត របស់ មនុស្ស ហើយដែលវាឆ្លុះបញ្ចាំងពីអាកប្បកិរិយារបស់ពួកគេ។ នៅពេលដែលសកម្មភាពទាំងនោះ ត្រូវ បានទទួលយកដោយសង្គមមួយ វាបានក្លាយទៅជាសារមួយដែលធ្វើឱ្យសមាជិកនៃសង្គមនោះបាន យល់អត្ថន័យដោយឆាប់រហ័ស។ វប្បធម៌ គឺពុំមែនជាចំណេះដឹងមួយដែលមនុស្សយើងបានទទួលតាម តំណពូជនោះឡើយ។ យើងទទួលបានវប្បធម៌ផ្សេងៗតាមរយៈភាសា ហើយភាសាគឺជាកាតាលីករ ដែលធ្វើឱ្យមនុស្សទទួលបានវប្បធម៌ឆាប់រហ័ស។ ភារកិច្ចចម្បងមួយរបស់វប្បធម៌ គឺការបង្រួបបង្រួម សង្គមមួយឱ្យប្រកាន់យកនូវអាកប្បកិរិយារួមគ្នាមួយដែលសមាជិកនីមួយៗត្រូវតែទទួលយក។[2]

តាមនិយមន័យខាងលើ វប្បធម៌ផ្សំឡើងពីធាតុជាច្រើនដែលជាចំណេះដឹងទាក់ទងនឹងការរស់ នៅរបស់មនុស្សនិងសង្គមមនុស្ស ហើយដែលគេបានបង្កើតវាឡើងសម្រាប់សម្រួលដល់ការរស់នៅ របស់ពួកគេ។ ទោះជាបុគ្គល ឬសង្គមណាមួយក៏ដោយ ក៏សុទ្ធតែមានវប្បធម៌រៀងៗខ្លួនដែរ ដែលក្នុង នោះ យើងបានចែកវប្បធម៌ជា វប្បធម៌រូបី(វត្ថុ)និងវប្បធម៌អរូបី(មិនមែនវត្ថុ)។

## ២.១.២. ការសិក្សាវប្បធម៌

នរវិទូសិក្សាវប្បធម៌តាមវិធីសាស្ត្ររបស់ក្មេងៗ ដែលទទួលបានចំណេះដឹងតាមរយៈ បទពិសោធដែលខ្លួនសន្សំបានតាំងតែពីកំណើតមក ពោលគឺពួកគេតែងតែទៅសង្កេតនិងជជែក ពិភាក្សាជាមួយបុគ្គលទាំងឡាយ ដែលកំពុងតែអនុវត្តវប្បធម៌ណាមួយនោះ។ ទោះជានរវិទូពុំមាន ពេលវេលាគ្រប់គ្រាន់ក្នុងការរៀនវប្បធម៌នៃសហគមន៍មួយជិតដល់ដូចជាសមាជិកនៃសហគមន៍នោះ ក៏ដោយ ក៏គាត់មានរបៀបច្បាស់លាស់ក្នុងការរៀនដែរ។ វិធីនោះគឺការពិនិត្យមើលនិងពិភាក្សាយ៉ាង ល្អិតល្អន់ជាមួយអ្នកជំនាញការ ឬចាស់ទុំដែលជាសមាជិកនៃសហគមន៍ណាមួយ ដែលស្ថិតក្រោម ការគ្រប់ដណ្តប់នៃវប្បធម៌ដែលកំពុងសិក្សានោះ។ ដូច្នេះ ការសិក្សាវប្បធម៌មួយ នរវិទូតែងចុះទៅរស់ នៅក្នុងសហគមន៍ក្នុងរយៈពេលមួយសមស្របដើម្បីសង្កេតនិងស្រូបយកបទពិសោធពីសមាជិកនៃ

[2] សូមអាន Haviliand, Cultural Anthropology, 2006។

សហគមន៍នោះឱ្យបានច្បាស់លាស់។ ដើម្បីសិក្សាទៅលើវប្បធម៌មួយ មនុស្សត្រូវតែចាប់ផ្តើមសួរនូវសំណួរមួយចំនួនដូចខាងក្រោម៖

-តើប្រជាជាតិនោះ និយាយភាសាអ្វី?

-តើពួកគេស្លៀកពាក់យ៉ាងដូចម្តេច?

-តើពួកគេបរិភោគអាហារអ្វីខ្លះ? ហើយគេបរិភោគយ៉ាងដូចម្តេច?

-តើពួកគេសាងសង់លំនៅដ្ឋានយ៉ាងដូចម្តេច?

-តើពួកអ្នកស្រុកនោះ មានរបរអ្វីសម្រាប់ចិញ្ចឹមជីវិត?

-តើគេគ្រប់គ្រងសង្គម ឬក៏ខ្លួនគេយ៉ាងដូចម្តេច?

-តើពួកគេឱ្យតម្លៃថា អ្វីត្រូវ ឬអ្វីខុសយ៉ាងដូចម្តេច?

**២.១.៣. អត្ថិភាពនៃវប្បធម៌**

មនុស្សបង្កើតវប្បធម៌ដើម្បីដោះស្រាយបញ្ហា ព្រមទាំងបង្កើនសុភមង្គលនិងផាសុកភាពខ្លួននិងសង្គមរបស់ខ្លួន។ វប្បធម៌មួយអាចមានជីវិតនៅក្នុងសង្គមមួយបាន លុះត្រាតែវាអាចបំពេញបាននូវតម្រូវការជាមូលដ្ឋាននៃមនុស្សដែលរស់ក្រោមការគ្របដណ្តប់នៃវប្បធម៌នោះ ពោលគឺធានានូវការប្រព្រឹត្តទៅ សណ្តាប់ធ្នាប់ សេដ្ឋកិច្ច ភាពថ្លៃថ្នូរ ដែលសង្គមត្រូវការ។ ដើម្បីធានានូវសុខុមាលភាពនិងសុវត្ថិភាពនៃសង្គមមួយ វប្បធម៌មួយត្រូវធានាឱ្យបាននូវការរក្សាតុល្យភាពនៃតម្រូវការបុគ្គលនិងតម្រូវការនៃសង្គមទាំងមូល។ ឧទាហរណ៍ បើសង្គមត្រូវការឱ្យមានអាពាហ៍ពិពាហ៍ បុគ្គលក៏ត្រូវតែរៀបអាពាហ៍ពិពាហ៍ដែរ។ ហេតុនេះនៅចុងបញ្ចប់ ដើម្បីមានជីវិតរស់នៅបន្តទៀត វប្បធម៌មួយត្រូវតែ កែប្រែខ្លះដើម្បីសម្របសម្រួលទៅនឹងកាលៈទេសៈថ្មីនិងទស្សនៈថ្មី។ ឧទាហរណ៍មធ្យោបាយធ្វើដំណើរក៏ត្រូវតែកែប្រែឱ្យបានសមស្រមនឹងស្ថានភាពបរិស្ថាន ភូមិសាស្ត្រ សេដ្ឋកិច្ច និងចំណង់ចំណូលចិត្តរបស់មនុស្សដែរ។ វប្បធម៌និងសង្គមមនុស្ស គឺជាធាតុពីរដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងគ្នា។ គ្មានវប្បធម៌ណាមួយអាចកើតមានដោយគ្មានសង្គម ហើយក៏គ្មានសង្គមណាកើតឡើងដោយគ្មានបុគ្គល ហើយបើគ្មានបុគ្គលគឺគ្មានវប្បធម៌។

**២.១.៤. ចរិតនៃវប្បធម៌**

**២.១.៤.១. ការសាយភាយ**

វប្បធម៌ គឺជាកម្រងនៃការផ្តល់ឱ្យគ្នាទៅវិញទៅមកនូវគំនិត តម្លៃ និងអាកប្បកិរិយា គំរូមួយរបស់សហគមន៍មួយ។ វាគឺជាចំណុចរួមមួយដែលសមាជិកម្នាក់អាចទទួលយកមិនបាន គឺមានន័យស្មើនឹងការប្រឆាំងជាមួយនឹងសង្គមទាំងមូល។ ឧទាហរណ៍ កូនមិនបានរៀបការត្រូវសង្គមដាក់ទោស។ ឆ្លងតាមរយៈការចែករំលែកឱ្យគ្នាទៅមកនេះ បុគ្គលម្នាក់អាចស្មានថានឹងត្រូវប្រកាន់អាកប្បកិរិយាបែបណាដែលសង្គមទាំងមូលអាចទទួលយកបាននៅក្នុងកាលៈទេសៈណាមួយ។ មនុស្សមួយក្រុមដែលមានវប្បធម៌ផ្សេងៗគ្នា ប្រសិនបើបានមកនៅលើកោះដាច់ស្រយាលជាមួយគ្នា ពួកគេប្រាកដជាបាន

ចែករំលែកបទពិសោធឱ្យគ្នាទៅវិញទៅមក ហើយបង្កើតបានជាវប្បធម៌មួយមិនខាន។[3] ក្នុងសង្គមនីមួយៗ ត្រូវបានបង្រៀនឱ្យប្រកាន់អាកប្បកិរិយា និងប្រើប្រាស់សម្ភារៈសំខាន់ៗខុសៗគ្នារវាងប្រុសនិងស្រី។ ឧទាហរណ៍ ក្នុងសង្គមខ្មែរបច្ចុប្បន្ន គេគិតថា ប្រុសស្លៀកខោ មនុស្សស្រីស្លៀកសារុង។

### ២.១.៤.២. វប្បធម៌គឺជាអ្វីដែលបានរៀន

វប្បធម៌ គឺជាអ្វីដែលយើងរៀន ជាអ្វីដែលយើងបានទទួលតាមរយៈតំណពូជមនុស្ស រៀនវប្បធម៌ ហើយធំធាត់ក្នុងវប្បធម៌។ ដំណាក់កាលនៃការរៀននេះ គឺត្រូវធ្វើបន្តពីជំនាន់មួយទៅជំនាន់មួយទៀត ពោលគឺជាការត្រាប់តាម។ តាមរយៈការត្រាប់តាមនេះ មនុស្សអាចមានអាកប្បកិរិយាខុសពីសត្វ ឬអាចខុសគ្នាពីវប្បធម៌មួយទៅវប្បធម៌មួយទៀត។ ឧទាហរណ៍ ការបរិភោគនិងការផឹក សត្វអាចផឹកគ្រប់ពេលវេលាដែលវាឃ្លាននិងស្រេកប៉ុណ្ណោះ។ ចំពោះមនុស្សវិញ ការហូបចុកត្រូវតែមានរបៀបទៅតាមសង្គមនីមួយៗ ដូចជានៅក្នុងសង្គមខ្មែរយើងជាទូទៅគេទម្លាប់ឱ្យចាស់ៗបានពិសាមុនក្មេងជាដើម។ ឯការប្រើប្រាស់ពាក្យដែលទាក់ទងនឹងការស៊ីផឹកនេះ នៅក្នុងសង្គមខ្មែរក៏ខុសៗគ្នាតាមវ័យនិងឋានៈដែរ (ស៊ី ឆាន់ សោយ ពិសា) ដែលវប្បធម៌ផ្សេងប្រើពាក្យតែមួយ។ មិនមែនគ្រប់ការរៀនភាសាទាំងអស់សុទ្ធតែជាវប្បធម៌នោះឡើយ ខ្លះគ្រាន់តែជារំញោច (Reflex) ប៉ុណ្ណោះដូចជាសត្វព្រាបនាំសារជាដើម ចំពោះសត្វប្រភេទខ្លះអាចឱ្យមានសញ្ញាថា មានវប្បធម៌ដែរ ព្រោះវាចេះបង្រៀនអំពីវិធីសាស្ត្រនៃការចិញ្ចឹមជីវិតដល់កូនចៅជំនាន់ក្រោយ។ ឧទាហរណ៍ ពួកពានរចេះបង្រៀនកូន។

### ២.១.៤.៣. វប្បធម៌ផ្អែកលើនិមិត្តរូប

សិល្បៈសាសនានិងលុយគឺសុទ្ធតែទាក់ទងនឹងនិមិត្តរូបទាំងអស់។ ភាសាគឺជានិមិត្តរូបដ៏សំខាន់មួយដ៏ជិតតាងឱ្យគ្រប់សកម្មភាពនិងវត្ថុផ្សេងៗ។ បើគ្មានភាសា យើងពិបាកនឹងប្រាប់អ្នកផ្សេងអំពីអ្វីមួយដែលយើងដឹងណាស់។

## ២.២. និយមន័យនៃពាក្យសង្គមធម៌

-សង្គមធម៌ជាអ្វី?

គេអាចឱ្យនិយមន័យសង្គមធម៌ប្លែកដូចខាងក្រោមនេះ៖

សង្គមធម៌ < សង្គម + ធម៌

-ពាក្យ ***សង្គម*** (society) សំដៅយកធម្មជាតិមនុស្សរស់នៅរួមគ្នា មានលំនៅ មានមុខរបររកស៊ី មានរបៀបបែបបទរស់នៅទាក់ទងគ្នាក្នុងស្រុកដែលជារដ្ឋ។

ឯពាក្យ **សង្គមធម៌** សម្គាល់ធម៌ទាំងឡាយណាដែលជាធាតុវិធីធម្មភាពរៀបចំសង្គមមនុស្សឱ្យមានសភាពទម្រង់និងលក្ខណៈចម្រើនលូតលាស់ បានន័យថារៀបចំសង្គមឱ្យរស់នៅបានស្រួលប្រកបដោយគ្រឿងសម្ភារៈគ្រប់គ្រាន់និងមានសភាពល្អប្រសើរថែមទៀត។

រួមសេចក្តីមកវប្បធម៌ សង្គមធម៌ គឺជាមធ្យោបាយ ឬវិធីដើម្បីសម្រេចបាននូវសុខៈក្នុងដំណើរទៅកាន់គោលដៅសុខៈ។

---

[3] សូមអាន Haviliand, Cultural Anthropology, 2006។

**គំនូសបែកធាងសង្ខេបនៃអរិយធម៌**

- អរិយធម៌
  - វប្បធម៌
    - ១. ចំណេះដឹង
      - ជំនឿ
      - សាសនា
      - វិជ្ជា វិទ្យាសាស្ត្រ
    - ២. កំណត់ផ្សាយ
      - ភាសា អក្សរ សញ្ញា
      - អក្សរសាស្ត្រ អក្សរសិល្ប៍
      - សិល្បៈ ព័ត៌មាន (វិទ្យុ ទូរទស្សន៍ កាសែត)
    - ៣. ការអនុវត្ត
      - ទំនៀមទម្លាប់ ប្រពៃណី
      - ការសិក្សាអប់រំ (ប្រដៅទូន្មាន)
      - កីឡា ល្បែងកំសាន្ត ច្បាប់
  - សង្គមធម៌
    - ១. គ្រឿងសង្គម (សម្ភារៈសង្គម)
      - ប្រដាប់រស់នៅ (មានលំនៅ ចំណីអាហារ)
      - ប្រដាប់តិចនិច (ម៉ាស៊ីន សំណង់)
      - មុខរបរ (វិជ្ជាជីវៈ)
    - ២. របបសង្គម (សង្គមវិធី)
      - សេដ្ឋកិច្ច (កសិកម្ម ឧស្សាហកម្ម ...)
      - សង្គមកិច្ច (សន្តិសុខ សុខភាព ការងារ...)
      - នយោបាយក្នុងនិងក្រៅប្រទេស
    - ៣. ទម្រង់សង្គម (សង្គមប្រភេទ)
      - ស្នូលសង្គម (គ្រួសារ)
      - វណ្ណៈសង្គម (វណ្ណៈជាតិកំណើត )
      - អង្គការសង្គម (ស្ថាប័នផ្សេងៗ)

## ២.៣. ទំនាក់ទំនងវប្បធម៌និងសង្គមធម៌

ទំនាក់ទំនងរវាងវប្បធម៌និងសង្គមធម៌ត្រូវបានគេវាយតម្លៃប្លែកៗគ្នា។ អ្នកខ្លះយល់ថា កម្លាំងវប្បធម៌ដូចជាចំណេះដឹង សាសនា អក្សរសិល្ប៍ ការសិក្សា ជាដើម អាចកែប្រែសង្គមមនុស្សឱ្យមានកម្រិតជីវភាពខ្ពង់ខ្ពស់ មានចរិតថ្លៃថ្នូរ មានច្បាប់ទម្លាប់ត្រឹមត្រូវ មានរបៀបរៀបរយ។ ដូចនេះ កម្លាំងអរិយធម៌ស្ថិតលើវប្បធម៌នេះឯង។ អ្នកខ្លះទៀតយល់ថា សង្គមធម៌ជាបុព្វហេតុនៃការជឿនលឿន ព្រោះសង្គមធម៌អាចកែប្រែផ្លាស់ប្ដូរជីវភាពទាំងទស្សនៈ ចិត្តគំនិត ចំណង់ចំណូលចិត្តរបស់មនុស្សគ្រប់ៗរូបផងនិងរបស់សង្គមមនុស្សទាំងមូលផង។ ក្នុងសង្គមបើរបស់របរប្រើប្រាស់របៀបណា របៀបបង្កបង្កើនផលនិងការបែងចែកភោគផលរបៀបណា នោះច្បាប់គ្រប់គ្រងសង្គម ចំណង់ចំណូលចិត្តក៏ផ្លាស់ប្ដូរទៅតាមនោះដែរ។ និយាយរួមទស្សនៈទាំងពីរខាងលើនេះសុទ្ធតែសមហេតុផលដោយឡែករៀងៗខ្លួន គឺ

មានត្រូវខ្លះខុសខ្លះ ដោយហេតុថា ជួនកាលកម្លាំងអរិយធម៌ស្ថិតនៅលើវប្បធម៌ ជួនកាលស្ថិតនៅលើសង្គមធម៌ តែមិនមែនជាច់ខាតស្ថិតនៅលើវប្បធម៌ ឬសង្គមធម៌នោះទេ។ បើនិយាយឱ្យងាយស្តាប់ គឺត្រូវមានទំនាក់ទំនងគ្នារវាងវប្បធម៌និងសង្គមធម៌។ យ៉ាងណាមិញ សង្គមធម៌រីកចម្រើនលូតលាស់ទៅបាន គឺអាស្រ័យនឹងវប្បធម៌។ ឧទាហរណ៍ ឧបករណ៍ប្រើប្រាស់ផ្សេងៗផលិតឡើងដោយសារចំណេះវិជ្ជា គំនិតប្រាជ្ញារបស់មនុស្ស ចំណែកឯវប្បធម៌ក៏ត្រូវពឹងពាក់លើសង្គមធម៌ ព្រោះថាអក្សរសិល្ប៍ វិទ្យាសាស្ត្រ សាសនា រីកចម្រើនទៅបានក៏អាស្រ័យទៅលើគ្រឿងសម្ភារៈនិងគ្រឿងពិសោធន៍ជាដើម។ ក្រៅពីនេះ ធម៌ទាំងពីរអាចកែប្រែនិងផ្លាស់ប្តូរគ្នាបានថែមទៀត។ ឧទាហរណ៍ ពេលជួបប្រទះការលំបាកវេទនា មនុស្សខិតខំស្វែងរកមធ្យោបាយដោះស្រាយដោយពឹងផ្អែកលើជំនឿសាសនា (ទស្សនៈផ្លូវចិត្ត)។ នៅពេលមានជីវភាពធូរធារសម្បូរសប្បាយ មានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់ មនុស្សអាចបំបាត់អបិយជំនឿលើសាសនាបានដែរ។

សរុបមក អរិយធម៌ដែលអាចដុះដាលចម្រើនលូតលាស់ទៅបាន គឺអាស្រ័យទៅលើវប្បធម៌ផង សង្គមធម៌ផង(ទាំងពីរនេះទាក់ទងគ្នានិងអាស្រ័យគ្នាទៅវិញទៅមក)។ សង្គមធម៌ស្វែងរកសុខៈឱ្យមនុស្សតាមផ្លូវសម្ភារៈ។ ដូចនេះ វប្បធម៌និងសង្គមធម៌មានទិសដៅរួមគ្នា គឺបម្រើសេចក្តីសុខរបស់មនុស្ស។

## ៣. អរិយធម៌សំខាន់ៗក្នុងលោក[4]

អរិយធម៌មានចំនួនច្រើន ហើយអរិយធម៌ទាំងនោះច្រើនតែមានទំនាក់ទំនងគ្នាផង ការចែកអរិយអម៌ឱ្យដាច់ពីគ្នាជាការលំបាក។ ប៉ុន្តែដើម្បីសម្រួលដល់ការសិក្សា គេអាចចែកអរិយធម៌សំខាន់ៗក្នុងលោកជាប្រាំគឺៈ

១.អរិយធម៌បស្ចឹម (អឺរ៉ុបខាងលិចនិងអាមេរិក)

២.អរិយធម៌អាស៊ី (អាស៊ីចុងបូព៌ា អាស៊ីអាគ្នេយ៍ ឥណ្ឌា)

៣.អរិយធម៌ឥស្លាម (ប្រទេសដែលកាន់សាសនាឥស្លាម)

៤.អរិយធម៌សង្គមនិយម (ប្រទេសសង្គមនិយមទាំងអស់)

៥.អរិយធម៌អាព្រិកខ្មៅ

## ៤. ឥទ្ធិពលអរិយធម៌បរទេសមកលើសង្គមខ្មែរ

ខ្មែរយើងមានអរិយធម៌របស់ខ្លួនតាំងពីសម័យបុរេប្រវត្តិមកម្ល៉េះ។ ប៉ុន្តែឆ្លងតាមទំនាក់ទំនងជាមួយជនបរទេសក្នុងដំណាក់កាលប្រវត្តិសាស្ត្រជាបន្តបន្ទាប់ អរិយធម៌ដ៏ចំណាស់នេះក៏ត្រូវបានទទួលឥទ្ធិពលពីអរិយធម៌បរទេសជាច្រើនណាស់ដែរ។

តើខ្មែរយើងបានទទួលឥទ្ធិពលវប្បធម៌ អរិយធម៌ បរទេសណាខ្លះ?

[4] ក្រសួងទេសចរណ៍, មគ្គុទ្ទេសក៍ទេសចរណ៍តំបន់ភ្នំពេញនិងសៀមរាបអង្គរ, ២០០៦។

-ឥទ្ធិពលឥណ្ឌា (ស.វទី១) : លុះមកដល់ស.វទី១ ឥទ្ធិពលឥណ្ឌាបានចូលមកស្រុកខ្មែរមុនគេ។ ឥទ្ធិពលនោះមានទស្សនៈរាជាធិបតេយ្យ សាសនា ភាសា អក្សរ អក្សរសិល្ប៍ សិល្បៈ ទំនៀមទម្លាប់ និងច្បាប់ផ្សេងៗ។

-ឥទ្ធិពលចិន (ស.វទី៣) : បន្ទាប់ពីឥទ្ធិពលឥណ្ឌាមក មានឥទ្ធិពលចិនដែលបានជ្រៀតចូលយ៉ាងខ្លាំងនៅស.វទី៣។ ឥទ្ធិពលចិននាពេលនោះមាន ជំនួញ ល្បាយជាតិសាសន៍ និងល្ខោនជាដើម។

-ឥទ្ធិពលចាម-ជ្វា (ស.វទី៥) : មកដល់ស.វទី៥ នៃគ.ស ទើបមានឥទ្ធិពលចាម-ជ្វា ដែលក្នុងនោះមានការរីកចម្រើនផ្នែកស្ថាបត្យកម្ម (សំណង់ប្រាសាទនិងក្បាច់លំអជាដើម)។

-ឥទ្ធិពលថៃ-វៀតណាម (ស.វទី១៣) : ឥទ្ធិពលថៃ-វៀតណាម មកក្នុងសង្គមខ្មែរយើងមានតែពាក្យពេចន៍ (ការខ្ចីពាក្យទៅវិញទៅមកក្នុងឋានៈជាប្រទេសជិតខាង)។

-ឥទ្ធិពលអឺរ៉ុប (ស.វទី១៦) : មានវិទ្យាសាស្ត្របច្ចេកទេស ទម្លាប់ (ចាប់ដៃ ស្លៀកពាក់) លទ្ធិប្រជាធិបតេយ្យ និងកិច្ចការរដ្ឋបាល។[5]

បើតាមសៀវភៅប្រវត្តិសាស្ត្រខ្មែររបស់លោកត្រឹង ងា ភាគ២ បោះ ពុម្ព គ.ស ១៩៧៤ទំ. ២៤ ចែងថា «...ពួកព័រទុយហ្គាល់ គឺជាជនជាតិអឺរ៉ុបដំបូងដែលបានចូលមកទាក់ទងនឹងខ្មែរ នៅខាងចុងរជ្ជកាលរបស់ព្រះបាទចន្ទរាជា»។ ពួកព័រទុយហ្គាល់ មកស្រុកខ្មែរប្រហែល គ.ស ១៥៥៥ ព្រោះពេលនោះ បព្វជិតជាតិព័រទុយហ្គាល់ ខាងគណៈដូមីនីកាំង (Dominicain) មកដល់ក្រុងលង្វែក។

**លក្ខណៈពិសេសនៃអរិយធម៌ខ្មែរ**

ជាការពិតអរិយធម៌ខ្មែរបានទទួលឥទ្ធិពលពីបរទេសច្រើន តែខ្មែរយើងពុំនិយមទទួលយកមកអនុវត្តតាម ឬចម្លងតាមទាំងស្រុងឡើយ។ ខ្មែរយើងតែងយកអរិយធម៌ទាំងនោះមកកែច្នៃផ្សេផ្សំឱ្យមានលក្ខណៈសមស្របតាមចំណង់ចំណូលចិត្តរបស់ជនជាតិខ្លួន ដែលធ្លាប់មានពីមុន ពោលគឺ ខ្មែរបានធ្វើ **ជាតូបនីយកម្ម** ដើម្បីតម្រូវទៅតាមទស្សនៈខ្មែរជានិច្ច។ ចំពោះទស្សនៈបរទេសណាដែល មិនសមស្របតាមទស្សនៈទំនៀមទម្លាប់ប្រពៃណីជាតិខ្មែរទេ ខ្មែរនឹងច្រានចោល ហើយទីបំផុត ទស្សនៈនោះនឹងសាបរលាបខ្លួនឯង។

អាស្រ័យដោយខ្មែរចេះសម្របសម្រួលកែច្នៃអ្វីដែលជាលក្ខណៈបរទេសឱ្យមកលក្ខណៈជាតិបែបនេះ ទើបអរិយធម៌ខ្មែរមានការរីកចម្រើនលូតលាស់កាន់តែប្រសើរឡើងជាលំដាប់។

តាមការរៀបរាប់ខាងលើនេះ យើងអាចសន្និដ្ឋានថា អរិយធម៌ខ្មែរមានលក្ខណៈពិសេសពីរគឺ៖

**ក. លក្ខណៈសំយោគ** : ខ្មែរមិនទទួលយកអរិយធម៌បរទេសទាំងស្រុងឡើយ។ ខ្មែរយកឥទ្ធិពលបរទេសមកកែច្នៃប្រឌិតឱ្យមានលក្ខណៈជាតិ។

**ខ. លក្ខណៈជាតិ** : ឥទ្ធិពលណាដែលមិនសមស្របតាមប្រពៃណី ទំនៀមទម្លាប់ ត្រូវបានខ្មែរបដិសេធទាំងស្រុង (មិនទទួលយកទេ)។

[5] អ្នកស្រី ត្រឹង ងា, អរិយធម៌ខ្មែរសម្រាប់ថ្នាក់បញ្ចប់, ១៩៧៤, ទំព័រ៩។

# មេរៀនទី២ ដំណើរវិវត្តនៃអរិយធម៌ខ្មែរ

## ១. អរិយធម៌ខ្មែរសម័យបុរេប្រវត្តិសាស្ត្រ

### ១.១. កាលប្បវត្តិប្រទេសកម្ពុជា

នៅលើជ្រោយឥណ្ឌូចិនយើងនេះ ជនជាតិខ្មែរដែលស្ថិតនៅក្នុងអម្បូរមន-ខ្មែរជាជនជាតិចាស់ជាងគេ ហើយជនជាតិនេះមានវប្បធម៌-អារ្យធម៌របស់ខ្លួនផ្ទាល់យ៉ាងហោចណាស់ក៏ពីរវាង១លានឆ្នាំ និង ៦៨០.០០០ឆ្នាំ មុនគ.សមកហើយដែរ។ វប្បធម៌នេះមានការវិវត្តពីសម័យមួយទៅសម័យមួយពីភាពសម្បូរបែបដល់ភាពលូតលាស់រុងរឿងលើគ្រប់វិស័យ។

ដោយផ្អែកលើព្រឹត្តិការណ៍ធំៗដែលជាសមិទ្ធផលនៃសង្គម កាលប្បវត្តិប្រទេសកម្ពុជា គេត្រូវបែងចែកជាពីរសម័យកាល គឺសម័យបុរេប្រវត្តិសាស្ត្រនិងសម័យប្រវត្តិសាស្ត្រ។ គេអាចចែកកាល ឬយុគនីមួយៗខាងលើនេះជាច្រើនកង់ថែមទៀត ដូចជាសម័យថ្មបុរមបុរាណ សម័យថ្មក្រួសបំបែក សម័យលោហធាតុ សម័យប្រវត្តិសាស្ត្រយុគបុរាណ យុគកណ្តាល និងយុគទំនើបជាដើម។

ក្នុងសម័យបុរេប្រវត្តិសាស្ត្រដែលបានកើតឡើងចាប់ពីរវាងប្រមាណ១លានឆ្នាំ និង ៦៨០.០០០ឆ្នាំ រហូតដល់ស.វទី១មុនគ.ស មនុស្សខ្មែរពុំទាន់ចេះប្រើតួអក្សរសម្រាប់កត់ត្រានូវរឿងរ៉ាវសាសនា សេដ្ឋកិច្ច និងនយោបាយបន្សល់ទុកដល់មនុស្សជំនាន់ក្រោយនៅឡើយទេ។ គេគ្រាន់តែចងចាំដោយការទន្ទេញចាំមាត់នូវរឿងរ៉ាវប្រវត្តិសាស្ត្រ សង្គមគ្រួសារតែប៉ុណ្ណោះ។ បរិបទវប្បធម៌ខាងលើនេះ គេអាចប្រៀបនឹងសហគមន៍ខ្មែរលើ ដូចជាព្នង ទំពួនជាដើមដែលគ្មានប្រវត្តិសាស្ត្រសរសេរ ដោយមានតែការបញ្ជាក់ពីថ្ងៃខែរបស់ខ្លួន។

ខុសពីសម័យមុន សម័យកាលទី២នៃប្រទេសកម្ពុជាចាប់ផ្តើមឡើងនៅស.វទី១នៃគ.ស គឺជាសម័យប្រវត្តិសាស្ត្រ។ ក្នុងសម័យនេះ ខ្មែរយើងមានអក្សរប្រចាំជាតិរបស់ខ្លួនដោយអ្នកដឹកនាំបានខ្ចីតួអក្សរឥណ្ឌាមកចងក្រងព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររបស់ខ្លួន។ ប៉ុន្តែការប្រើប្រាស់តួរអក្សរនៅពុំទាន់បានផ្សព្វផ្សាយចូលគ្រប់ច្រកល្ហកពេញប្រទេសនៅឡើយទេ។ នាសម័យដើមនោះ វាជាបុព្វសិទ្ធិរបស់អ្នកដឹកនាំកំពូល ឬរបស់អ្នកលក់ដូរក្នុងទីក្រុងប៉ុណ្ណោះ។

ព្រះរាជាណាចក្រកម្ពុជាមានប្រវត្តិសាស្ត្រប្រចាំជាតិរបស់ខ្លួនជាង២០០០ឆ្នាំមកហើយ។ រីឯការប្រើតួអក្សរក៏មានចំណាស់ដូចគ្នាដែរ ទោះបីជានៅគ្រាបឋមនៃប្រវត្តិសាស្ត្រការអប់រំ ការបង្រៀនអក្សរ ឬការផ្សព្វផ្សាយ និងការប្រើប្រាស់តួអក្សរពុំទាន់មានលក្ខណៈទូលំទូលាយក៏ដោយ។

សូមកុំភ្លេចថា អក្សរនេះហើយមិនគ្រាន់តែជាឧបករណ៍សម្រាប់កត់ត្រាព្រឹត្តិការណ៍ក្នុងសង្គមប៉ុណ្ណោះទេ ក៏ប៉ុន្តែជាយានសម្រាប់ផ្សព្វផ្សាយនូវមនោគមវិជ្ជាសាសនា និងជាមធ្យោបាយសម្រាប់ពង្រឹងពង្រីកអំណាចកណ្តាលរបស់ព្រះមហាក្សត្រ ឬអ្នកដឹកនាំសង្គមផងដែរ។

ការរៀបរាប់ខាងលើនេះបានបញ្ជាក់ថា ការអនុវត្តច្បាប់ ការផ្សាយសាសនា ជាពិសេសព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាដែលអាជ្ញាធរបានអនុវត្តនាសម័យនគរភ្នំពីស.វទី១ដល់ទី៧ មិន

បានសំដៅតែមនុស្សនៅតាមទីក្រុងនោះទេ គឺត្រូវធ្វើឡើងនៅគ្រប់ខេត្តតំបន់ដែលគ្រប់គ្រងដោយព្រះរាជាខ្មែរ ហើយការអនុវត្តនេះ ពុំអាចនឹងធ្វើឡើងបានទេ ប្រសិនបើពុំមានអក្សរសម្រាប់ចែងជាច្បាប់បញ្ញត្តិ ឬបទបញ្ជាផ្សេងៗ។

**កាលប្រវត្តិមុនប្រវត្តិសាស្ត្រកម្ពុជា**




## ១.២. ពាក្យថា «ខ្មែរ-កម្ពុជា» និងដើមកំណើតជាតិខ្មែរ

ក្នុងការសិក្សាអរិយធម៌ខ្មែរ បញ្ហាជាតិខ្មែរតែងតែចោទឡើងជានិច្ចកាលដែលធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវខិតខំដោះស្រាយដោយបានបញ្ចេញមតិយោបល់ប្លែកៗគ្នា ហើយពេលខ្លះយោបល់ទាំងនោះមានលក្ខណៈដូចគ្នាទាំងស្រុង។ ជាទូទៅគេច្រើនភ្ជាប់ខ្មែរទៅនឹងជនជាតិណាមួយដែលមានអរិយធម៌ខ្ពង់ខ្ពស់ជាង ដើម្បីរក្សាអត្តិភាពរបស់ខ្មែរ។ អ្នកសិក្សាស្រាវជ្រាវបានខិតខំដោះស្រាយនូវបញ្ហាដ៏សំខាន់នេះ ហើយបានបញ្ចេញជាយោបល់ផ្សេងៗគ្នាមានដូចខាងក្រោមនេះ៖

### ១.២.១. ពាក្យថា ខ្មែរ-កម្ពុជា[6]

ការសិក្សាស្រាវជ្រាវពីខ្មែរ ទោះក្នុងផ្នែកជាតិសាសន៍ក្តី ប្រវត្តិសាស្ត្រក្តី ក្នុងផ្នែកវប្បធម៌ក្តី អរិយធម៌ក្តី គេតែងឃើញមានបញ្ហានេះឡើង ចំពោះពាក្យថា **ខ្មែរ-ខម-កម្ពុជា** នេះឯង។ ចំពោះពាក្យទាំងបីខាងលើនេះ អ្នកសិក្សាស្រាវជ្រាវ បានផ្តល់យោបល់ច្រើនបែបច្រើនយ៉ាងណាស់។ រហូតដល់ពេលនេះ យើងមិនទាន់ហ៊ានសន្និដ្ឋានថា យោបល់ណាត្រឹមត្រូវជាងយោបល់ណាទេ។ ដើម្បីជាការត្រិះរិះសម្រាប់អ្នកសិក្សា យើងសូមលើកទស្សនៈទាំងនេះមកលាតត្រដាងមួយម្តងៗដូចតទៅនេះ៖

[6] ត្រឹង ងា, ប្រវត្តិសាស្ត្រខ្មែរភាគ១&២, ភ្នំពេញ, ១៩៧៣។

**ក. ទស្សនៈលោក កេង វ៉ាន់សាក់**

ក្នុងសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សារាជាណាចក្រ (ឥឡូវព្រឹទ្ធសភា) ស្តីពីការបង្កើតវិទ្យាស្ថានខ្មែរ-មន កាលពីថ្ងៃ ១៦ ខែកុម្ភៈ ឆ្នាំ ១៩៧០ លោក កេង វ៉ាន់សាក់ បានថ្លែងបំភ្លឺអង្គប្រជុំចំពោះពាក្យ **ខ្មែរនិងកម្ពុជា** មានសេចក្តីដូចតទៅៈ

ពាក្យ **ខ្មែរ** ក្លាយពីពាក្យ **ក + មេ** ។ ហេតុបានជាដូច្នេះ ព្រោះខ្មែរយើងជាអ្នកនិយមទុកស្ត្រីជាធំក្នុងគ្រួសារនិងក្នុងសង្គម បានសេចក្តីថា យើងជាអ្នកមេនិយម។ បុព្វបទ **ក** មាននាទីធ្វើឱ្យន័យរបស់ពាក្យណាមួយមានលក្ខណៈកាន់តែខ្លាំងក្លាឡើងៗ ។ ដូចនេះ **ក + មេ** មានន័យថា អ្នកគោរពមេខ្លាំងជាង អ្នកឯទៀត ដែលគោរពល្មមៗ ឬគោរពឪពុកទៅវិញ។

**ក + មេ > កមេ > ក្មេ > ក្មេរ > ខ្មេរ > ខ្មែរ**

ឯពាក្យ **កម្ពុជា** ក្លាយមកពី **ក + ពូជជា** ។ ហេតុបានជាគេហៅខ្មែរយើងថា **ពូជជា** ព្រោះយើងពុំដែលធ្វើខ្ញុំកញ្ជះអ្នកដទៃឡើយ។ ហើយដើម្បីឱ្យឃើញន័យកាន់តែខ្លាំង គេដាក់បុព្វបទ **ក** ពីមុខទៅជា **ក + ពូជជា > កពូជជា** ដែលបាលី-សំស្ក្រឹត និយមសរសេរទៅជា **កម្ពុជា** ដូច្នេះវិញ។

**ខ. ទស្សនៈលោកត្រឹង ងា**

ពាក្យខ្មែរនេះច្បាស់ជាក្លាយមកពីពាក្យ **ខ្មេរ** (សម័យអង្គរ) ដែលបានក្លាយមកពីពាក្យ **ក្មេរ** ទៀត (សម័យមុនអង្គរ)។ ខ្មែរយើងនិយមហៅខ្លួនឯងថា «**ខ្មែរ**» ឯប្រទេសយើងហៅថា ស្រុកខ្មែរ។

ឯពាក្យថា **កម្ពុជា** បានក្លាយមកពីពាក្យ **កម្ពុជៈ** ដែលមានប្រើនៅក្នុងសិលាចារឹក «**ព្រះគោ**» ឬពាក្យ **កម្ពុជ-ទេស** «**ប្រាសាទបន្ទាយឆ្មារ**» ។ សិលាចារឹកចាមក៏មានប្រើពាក្យ កម្ពុជទេសនេះសម្រាប់សម្គាល់ប្រទេសខ្មែរយើងដែរ។ សិលាចារឹកបក្សីចាំក្រុង នាស.វទី១០ បានពន្យល់ថា ស្តេចកម្ពុជាមានដើមកំណើតមកពីឥសី **កម្ពុ** និងនាងអប្សរ **មេរា** ។ បើដូច្នេះ ឃើញថា ពាក្យ **កម្ពុជា** នេះមានជាប់ទាក់ទងនឹងស្តេច ឬរាជវង្សនេះច្រើន។

**គ. ទស្សនៈលោក រស់ សារ៉ែត**

ក្នុងអត្ថបទស្នើសុំធ្វើវិសោធនកម្មផ្ញើទៅជូនសភាជម្មនុញ្ញ ហើយដែលចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៧១ របស់លោក រស់ សារ៉ែត សមាជិកនៃអង្គការជាន់ខ្ពស់នេះ បានសរសេរជាអាទិ៍ថា «បើតាមការសិក្សាស្រាវជ្រាវ ដែលខ្ញុំធ្លាប់បានពិចារណា ចេះចាំមកឃើញថា ប្រទេសខ្មែរដែលកាលពីជំនាន់ដើមហៅថា **ក្រុងខម** នោះជាតួផែនដី ឬឧបទ្វីប**សុវណ្ណភូមិ** ដែលភាសាបារាំងហៅថា La Chersonèse d'or…»។ ការដែលលើយកន័យខាងលើនេះមកពោលគឺគ្រាន់តែចង់បង្ហាញឱ្យឃើញថា **សុវណ្ណភូមិ** គឺ ជានគរ **ខម** ឬហៅថា **ក្រុងខម** ដែលមានន័យថា **មាស** ដូចគ្នា។ ពាក្យថា **ខម** នេះក្លាយមកពីពាក្យថា **កម** ដែលប្រែថា **មាស**។ ឯស្តេចសោយរាជ្យបឋមវង្សនៃ **នគរខម** មានព្រះនាមថា **កមេរុរាជ** ដែលប្រែថា **មាស** ដែរ ហើយដែលត្រូវនឹងភាសាសៀមថា **ព្រះថង** រួចដែលក្លាយយារទៅជា **ព្រះថោង** ដូចដែលយើងធ្លាប់ថារត់មាត់មកហើយ។

ហេតុអ្វីបានជាជនជាតិ **ខម** ប្រែក្លាយទៅជាឈ្មោះ **ខ្មែរ** ទៅវិញ? ត្រង់នេះប្រហែលជាជនជាតិ **ខម** នៅពេលចំណេរចេរកាលតមកក្រោយទៀតចង់រក្សាតម្លៃឥទ្ធានុភាពរបស់ខ្លួនដែលធ្លាប់ល្បីល្បាញខ្លាំងពូកែកាលពីជំនាន់កម្រុរាជ ជាក្សត្របឋមវង្សគ្រប់គ្រងក្រុង **ខម** នោះហើយបានជាប្រែក្លាយឈ្មោះពី **កម** ឬ **ខម** មកជា **កម្រេ** ឬ **ខមេរ** ហើយដែលយារយូរៗមកទៅជា **ក្មេរ** រួចទីបំផុតទៅជា **ខ្មែរ** សព្វថ្ងៃនេះ។

ចុះចំណែកពាក្យថា **កម្ពុជា** វិញយ៉ាងម៉េចដែរ? បើយើងបានពិចារណានូវសម្មតិកម្មពីខាងលើនេះរួចហើយ យើងប្រហែលជាអាចយល់បានដោយងាយអំពីឈ្មោះថា **កម្ពុជា** នេះ។ នៅក្នុងពាក្យថា **កម្ពុជា** យើងឃើញថា មានពាក្យ **កម** ដែលប្រែថា **មាស** ហើយនិងពាក្យ **ពុជា** ដែលប្រែថា **ពូជ** ផ្សំគ្នាទៅជា **កម្ពុជា** គឺ **កម** ឬ **ខម** ឬ **ក្មេរ** ឬ **ខ្មែរ** ដដែលហ្នឹងឯង។

សរុបសេចក្ដីមក យើងអាចសង្ខេបទស្សនៈរបស់លោក រស់ សារ៉េត ដូចខាងក្រោមនេះ៖

**កម > ខម > កមេរ > ខមេរ > ក្មេរ > ខ្មែរ**

**កម + ពុជា > កម្ពុជា**

### ឃ. ទស្សនៈលោក ពៅ ឈិន

លោក ពៅ ឈិន ជាព្រឹទ្ធបុរសនៃក្រុមសាលាសន្សំសុខ សង្កាត់លេខ ៥ ក្រុងភ្នំពេញ បានសរសេរក្នុងសៀវភៅ « អរិយធម៌ខ្មែរ-មន» បោះពុម្ពនៅចុងឆ្នាំ ១៩៧១ ថា ពាក្យ **ខ្មែរ** ក្នុងវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត ព្រះអង្គទ្រង់បានប្រាប់ថា នៅក្នុងអក្សរសិលាចារឹកពីបុរាណឃើញមានសរសេរ **ខ្មេរ** យ៉ាងនេះខ្លះដែរ។ ប៉ុន្តែព្រះអង្គយល់ថា ពាក្យនេះទំនងមកពីមគធភាសាថា **ខេមរៈ** ដែលប្រែថា «មនុស្សមានសេចក្ដីក្សេម » ដោយសម្រេចរូបមកពីអត្ថិតទ្ធិតថា «**ខេមំយស្ស អត្ថិតិ ខេមរោ**» បែបនេះ។

មួយទៀតពាក្យថា **ខេមរៈ** មកពី **ខិ + មះ + រះ** ប្រែថា **ក្សេម** ល្អ ការរក្សានូវប្រយោជន៍ ដែលបានហើយ។

ដូច្នេះ ត្រង់ពាក្យថា **ខ្មែរ** ដែលសម្ដេចព្រះសង្ឃរាជព្រះអង្គទ្រង់យល់ថា ទំនងមកពីមគធភាសា **ខេមរៈ** នោះ បើតាមការពិចារណារបស់ខ្ញុំ ខ្ញុំយល់ថា ពិតជាមកពីពាក្យថា **ខេមរៈ** នោះមែនពីព្រោះកាលខ្ញុំនៅវត្តពីក្មេងនោះ ខ្ញុំធ្លាប់បានមើលឃើញនៅក្នុងសាស្ត្រាស្លឹករឹតដែលចាស់ពីបុរាណកាលបានចារសរសេរអក្សរតម្រួតគ្នារបៀបនេះច្រើនណាស់ (យកជើងព្យញ្ជនៈប្រកប ដូចជា ត្មា= តាម , ថ្មែទ្មាំ=ថែមទាំង, ដ្មើ=ដើម...)។

ដោយអាស្រ័យហេតុដូចមានចង្អុលខាងលើនេះ លោកពៅ ឈិន ជឿថា **ខេមរ > ខ្មេរ > ខ្មែរ** (ស្រៈ អែ កើតមកពីការនិយាយរបស់ខ្មែរក្នុងការអានស្រៈបាលី-សំស្ក្រឹត)។

ចំពោះពាក្យ **ខម** លោក ពៅ ឈិន បានសរសេរថា មួយទៀតពាក្យថា **ខម** នេះ បើថាវាក្លាយមកពីពាក្យដើមថា «**ខម + អ**» ដែលប្រែថា «អត់ អត់ធន់ គួរ» ឬថា «ផែនដី» នោះវិញក៏បានដែរ ដោយហេតុថា ខ្មែរយើងនេះជាអ្នកទទួលអរិយធម៌ព្រះពុទ្ធសាសនា ដែលមានអវិហិង្សាធម៌ (អហិង្សា)

គឺត្រូវមានចិត្តគំនិតអត់ធន់ មិនបៀតបៀនមនុស្សទូទៅជាប្រចាំ។ ចំពោះពាក្យ **កម្ពុជា** លោក ពៅ ឈិន បានសរសេរថា « ព្រះថោងនោះបានផ្លាស់នាមប្រទេសពីនគរគោកធ្លកនោះមកជា ក្រុងកម្ពុជាធិបតី»។ បានជាឱ្យឈ្មោះថា ក្រុងកម្ពុជាធិបតី វិញនោះ ពីព្រោះចង់ប្រើជំនួសពាក្យថា សុវណ្ណភូមិ ប្រែថា កន្លែងកើតមាស ដោយហេតុពាក្យទាំងពីរនេះ មានន័យថា កន្លែងកើតមាសដូចគ្នា។

**ខ. ទស្សនៈលោក ឈឹម ក្រសេម**

លោក ឈឹម ក្រសេម បានសរសេរជាអាទិ៍ថា ខ្មែរយើងដើមឡើយមុនផ្សាយមកនៅក្នុងកម្ពុជរដ្ឋបានអស្រ័យនៅក្នុងកុមេរុរដ្ឋ ដែលជាប្រទេសរបស់ខ្មែរអំពីបុរាណកាលមក។ ឈ្មោះជាតិខ្មែរ ហៅត្រឹមត្រូវតាមសូរស័ព្ទដើមថា **កុមេរុ** ដូច្នេះ។ តែតាមសំឡេងនិយាយជាធម្មតាថា **កុមេរ៍** ទំនងដូច ជាឈ្មោះភ្នំព្រះសុមេរុ គេហៅនៅត្រឹមសុមេរ៍ ដែរ។ លុះយូរមកឈ្មោះនេះបានក្លាយចេញទៅទៀត ប្រាកដនូវក្នុងសិលាចារឹករបស់ខ្មែរថា **ក្មេរ** ហើយតាមសំឡេងផ្សំក្រោយសម័យសិលាចារឹកមក បានប្រែថា **ខ្មែរ** ។

ដូច្នេះ បើតាមលោក ឈឹម ក្រសេម ពាក្យ **ខ្មែរ** បានក្លាយមកពីពាក្យ **ក្មេរ** ដែលជាឈ្មោះសម្គាល់ជនជាតិខ្មែរ និងប្រទេសរបស់ខ្លួនកាលដែលរស់នៅក្នុងប្រទេសឥណ្ឌាម្ល៉េះ។

សរុបមកយើងឃើញថា ទស្សនៈចំពោះ **ខ្មែរ-កម្ពុជា** នៅមានច្រើនណាស់ តែពុំទាន់ចុះ សម្រុងគ្នានៅឡើយ។ ក្នុងនោះឃើញថា អ្នកខ្លះខិតខំពន្យល់តាមឫសគល់ឥណ្ឌា ហើយខ្លះទៀតខិតខំពន្យល់តាមរបៀបខ្មែរសុទ្ធសាធ។

គួរកត់សម្គាល់ថា ពាក្យខ្មែរនេះត្រូវបានជនជាតិបរទេសស្គាល់យូរមកហើយដូចជា៖

- ចិន ហៅថា **គីម៉ារ**
- អារ៉ាប់ ហៅយើងថា **កោម៉ា**
- ចាម ហៅថា **ក្មឹរ -ក្មឹ**
- វៀតណាម ហៅយើងថា **ការមេន** ឬ **ការមៀន**
- សៀមនិងឡាវ ហៅយើងថា **ខម** ។

**១.២.២. ដើមកំណើតជាតិខ្មែរ**

បញ្ហាស្មុគស្មាញបានចោទឡើងនូវរាល់ពេលដែលគេចង់ស្រាវជ្រាវសិក្សាពីវប្បធម៌-អរិយធម៌ខ្មែរ ពិសេសពីបញ្ហាដើមកំណើតជាតិខ្មែរនេះតែម្តង។ ទោះបីមានការលំបាកយ៉ាងណា ក៏គេឃើញអ្នកស្រាវជ្រាវជាច្រើនបានផ្តល់យោបល់ប្រហាក់ប្រហែលគ្នា ពេលខ្លះក៏ផ្ទុយស្រលះតែម្តង ដែលក្នុងនោះគេអាចប្រមូលជាយោបល់ពីរក្រុមគឺ៖

**ក. ក្រុមទី១**:

ទទួលស្គាល់ថា ជាតិខ្មែរ ជាជាតិអន្តោប្រវេសន៍ចេញពីប្រទេសឥណ្ឌាមកដណ្តើមយកទឹកដីរបស់ជនជាតិដើម គឺជនជាតិក្នុងអម្បូរម៉ាឡាយូប៉ូលីនេស៊ីយែន នេះឯង។ ទស្សនៈនេះត្រូវបានបង្កើតឡើងមុនគេដោយលោក Hendrick Kerns ។ បន្ទាប់មកទៀតក៏មានអ្នកស្រាវជ្រាវខ្លះយល់ស្របគ្នា

ដូចជាលោក Adhémard Leclère លោក Paul Benedict និងលោក Pièrre Gourou ជាដើម។ លោក Pièrre Gourou បានបញ្ជាក់ថា ជនជាតិមន-ខ្មែរ ប្រហែលជាត្រូវពួកដ្រាវីដ (Dravidian) ឬ អារ្យ៉ន (Ayen) ដែលត្រូវវាយរុញច្រានចេញពីប្រទេសឥណ្ឌា ហើយសព្វថ្ងៃមាននៅសល់ក្រុមខ្លះដូចជា ពួក **មណ្ឌៈ** បានមកលុកលុយ ភូមា ថៃ កម្ពុជា ជាដើម។

គេអាចបន្ថែមទៅលើមតិស្រាវជ្រាវខាងលើនេះនូវឈ្មោះលោក Etiènne Aymonier ដែលយល់ថាក្រុម **មន-ខ្មែរ-មណ្ឌៈ** មានទីតាំងដើមនៅជើងភ្នំទីបេ ហើយក្រោយមកបានបំបែកជាពីរក្រុម មួយក្រុម (មន-ខ្មែរ) ចូលមករស់នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ឯមួយក្រុមទៀត (មុណ្ឌៈ) ចូលទៅក្នុងប្រទេសឥណ្ឌារហូតដល់សព្វថ្ងៃ។

**ខ. ក្រុមទី២**:

ទទួលស្គាល់ថា ជនជាតិខ្មែរជាជាតិពិសេសមួយស្ថិតនៅក្នុងក្រុមមន-ខ្មែរ ហើយបានមកកកើតឡើងនៅភូមិភាគអាស៊ីអាគ្នេយ៍នេះតាំងពីបុរាណមក។ នេះគឺជាយោបល់របស់លោក Bermard Philippe Groslier (អតីតអភិរក្សអង្គរ) និងលោក Marcel Talabot ។ តាមយោបល់របស់ លោកទាំងពីរនេះយល់ឃើញថា ក្នុងបុរេប្រវត្តិសាស្ត្រ មានមនុស្សជាច្រើនក្រុមបានធ្វើដំណើរពីខាងជើងចុះមកភូមិភាគអាស៊ីអាគ្នេយ៍ ដូចជាពួកអូស្ត្រូឡូអ៊ីត (Austroloides) មេឡាណេស៊ីយាង។ តាមការប៉ាន់ស្មានរបស់លោកទាំងពីរអម្បូរ មន-ខ្មែរ កើតមកពីការផ្សំកាត់រវាងពូជមេឡាណេស៊ីយាង និងពូជឥណ្ឌូណេស៊ីយាង ហើយបានរស់នៅលើទឹកដីលាតសន្ធឹងពីឆ្នេរសមុទ្រចិនរហូតដល់ព្រំប្រទល់ប្រទេសឥណ្ឌា (ឯកសារខ្លះថា បានរស់នៅរាយប៉ាយលើទឹកដីដែលលាតសន្ធឹងពីឥណ្ឌូចិន ជ្រោយម៉ាឡាយូ រហូតដល់ព្រំប្រទល់ប្រទេសឥណ្ឌា)។

គួរកត់សម្គាល់ថា យោបល់ក្រុមទី២នេះ មានលក្ខណៈស្របទៅនឹងទស្សនៈរបស់ខ្មែរ ពីព្រោះបើយើងសំអាងទៅលើរឿងព្រេងខ្មែរ លុះត្រាតែមាននាងនាគនៅស្រុកខ្មែរសិន ទើបព្រះថោង (គេថាមកពីស្រុកឥណ្ឌា) បានជួបប្រកពគ្នា ហើយបានគ្រប់គ្រងនគរគោកធ្លកនេះ។ បានន័យថា លុះត្រាតែមានជនជាតិខ្មែរនៅលើកោះគោកធ្លកនេះ ទើបឥណ្ឌាអាចផ្សាយអរិយធម៌របស់ខ្លួនបានខ្លះចូលក្នុងស្រុកខ្មែរ (នគរគោកធ្លក)។ នេះសឱ្យឃើញថា ជាតិខ្មែរមានប្រកពនៅស្រុកខ្មែរនេះឯង។

សរុបមកខ្មែរជាជនជាតិចំណាស់បានកើតឡើងនៅភូមិភាគអាស៊ីអាគ្នេយ៍នេះ ហើយស្ថិតនៅក្នុងអម្បូរណ៍មនុស្សមួយដោយឡែកពីអម្បូរឥណ្ឌា ហើយដែលនរវិទូ លោកឱ្យឈ្មោះថា «**អូស្ត្រូអាស៊ីយ៉ាទិក** (Austro-Asiatic)»។[7]

*ជាតិមន មាននៅរស់សេសសល់រហូតមកដល់សព្វថ្ងៃ មាននៅប្រទេសភូមាផ្នែកខាងក្រោម និងតាមជួរភ្នំអាណ្ណាមក្នុងប្រទេសវៀតណាម។ ជនជាតិថៃ វៀតណាម និងភូមា ទើបតែចុះមកវាយយកទឹកដីខ្មែរនាស.វទី១៣នៃគ.សតែប៉ុណ្ណោះ។ នៅពេលដែលជនជាតិទាំងនេះត្រូវកងទ័ពម៉ុងហ្គោល (Mongolia) វាយប្រហារដេញខ្វាត់ខ្វាយរត់ពីប្រទេសចិន។

[7] ត្រឹង ងា, ប្រវត្តិសាស្ត្រខ្មែរភាគ១&២, ១៩៧៣,ទំព័រ៧។

## ១.៣. ការរស់នៅតាមរូងភ្នំ

ចាប់ពីរាប់ពាន់ឆ្នាំមុនគ.ស នៅលើទឹកដីខ្មែរគឺមានមនុស្សរស់នៅស្រេចទៅហើយ។ ក្រុមមនុស្សទាំងនោះគឺមានរបៀបរបបរស់នៅរបស់ខ្លួនដូចជា ជម្រក ភូមិដ្ឋាន របរចិញ្ចឹមជីវិត វត្ថុប្រើប្រាស់ ព្រមទាំងជំនឿផ្សេងៗផង។ តាមការស្រាវជ្រាវបែបបុរាណវិទ្យាអំពីបុរេប្រវត្តិគឺរកឃើញ(ធ្វើកំណាយ) ភស្តុតាងជាច្រើនអំពីអារ្យធម៌អ្នកស្រុកដើមនៅទីនេះ។ ក្នុងនោះឃើញមានជម្រកមនុស្សនៅតាមរូងភ្នំ និងទីលំនៅដែលមានរាងមូលនៅតាមទីវាលផ្សេងៗច្រើនកន្លែង។


កំពែងដីរាងមូលនៅតំបន់អង្គរ


ល្អាងស្ពាននៅភ្នំទាក់ទ្រាំងជាស្ថានីយបុរេប្រវត្តិ


ការធ្វើកំណាយនៅល្អាងស្ពាន

### ១.៣.១. របរចិញ្ចឹមជីវិតនិងវត្ថុប្រើប្រាស់

អ្នកបុរាណវិទ្យាធ្វើការស្រាវជ្រាវអំពីអ្នកស្រុកសម័យបុរេប្រវត្តិ ដែលបានរកឃើញវត្ថុប្រើប្រាស់ជាច្រើនដូចជា ផ្លែពូថៅ ខ្មោសធ្វើអំពីថ្ម កាំបិតធ្វើអំពីលោហៈ ថូ ក្អម ឆ្នាំងធ្វើអំពីដីដុតនិងលោហៈ គ្រឿងអលង្ការធ្វើអំពីថ្មនិងលោហៈ ព្រមទាំងរបស់របរប្រើប្រាស់ផ្សេងៗទៀត។







### ១.៣.២. ជំនឿដើម

ជំនឿដើមរបស់ខ្មែរ គេសន្មតហៅថា **ជំនឿជីវចល** (Animism)។ ជីវចល គឺជឿទៅលើភូតផ្សេងៗដែលបង្កឡើងដោយអមនុស្សធ្វើឱ្យវត្ថុ ឬទីកន្លែងនានា មានជីវិត កន្លែងណាក៏មានអមនុស្សនៅបាន។ អមនុស្សទាំងអស់នោះសុទ្ធសឹងតែចេះហោះ ឬធ្វើដំណើរតាមផ្លូវ តាមព្រៃ ឬតាមផ្លូវទឹកផង។ ហើយលាក់ខ្លួនតាមផ្លូវទឹក ក្នុងក្រហែងថ្ម ឬក្នុងបឹងបួរផ្សេងៗ។ អមនុស្សដែលបង្កភូតទាំងនោះចូលចិត្តរស់នៅច្រកជ្រលងជួរភ្នំ ឬមួយក្នុងព្រៃជ្រៅដែលគួរឱ្យខ្លាច។ បើពុំនោះ គឺរស់នៅលើកំពូលភ្នំ ឬផ្ទាំងសិលាធំៗ។ ថ្មមួយដុំយ៉ាងសាមញ្ញ គឺសឹងតែជាទីលំនៅស្ថានរបស់ពួកនោះដែរ។

- រឹងឈើដែលមានមែកសាខា ក៏អាចជាជម្រករបស់ពពួកអមនុស្សទាំងនោះដែរ។
- គេយល់ថា អមនុស្សទាំងអស់នោះ ខ្លះមានសន្ដានចិត្តល្អ ថែមទាំងជួយយកអសារដល់មនុស្សទៀត។ ក៏ប៉ុន្តែអមនុស្សខ្លះអាចបង្កជាការព្យាបាទដល់មនុស្ស សត្វ។
- ថ្វីត្បិតតែក្រោយមក ឥទ្ធិពលឥណ្ឌាបានចាក់ឫសយ៉ាងជ្រៅមាំក្នុងសង្គមខ្មែរ នាសម័យបុរាណក៏ប៉ុន្តែ ប្រព័ន្ធជំនឿ «**ជីវចល**» នៅតែរស់រវើកជាធម្មតារហូតដល់សព្វថ្ងៃ។





វិយោលទងផ្កានៅវត្តវិហារសួគ៌ វត្តព្រះធាតុ នៅខេត្តកំពង់ឆ្នាំង ថ្មស្នងអ្នកតាដែលមានពានាក្រណាត់

***មូលធម៌ខ្មែរ-មន មុនគ.ស**

- ជឿលើព្រលឹង អារក្ស អ្នកតា
- ទុកស្ត្រីជាធំ
- ផ្សាំងសត្វ
- កប់ខ្មោចក្រោមថ្មដុស ឬក្នុងក្រឡ
- ភាសាមានអន្តរបទ...។





ជំនឿទាក់ទងនឹងការកប់ខ្មោច

## ១.៣.៣. ស្ថានីយបុរេប្រវត្តិសាស្ត្រខ្មែរ

**-ស្ថានីយ៍សំរោងសែន** ស្ថិតក្នុងខេត្តកំពង់ឆ្នាំងរកឃើញដោយលោក **រ៉ុក** នៅឆ្នាំ ១៨៧៦។

**-ស្ថានីយ៍អន្លង់ផ្ដៅ** ស្ថិតនៅប្រមាណ ៣០ គ.ម ខាងត្បូងឈៀងខាងកើតស្ថានីយ៍សំរោងសែន រកឃើញដោយលោក **ហង់ រី ម៉ង់ស៊ុយ** ឆ្នាំ១៩០២ វត្ថុតាងដែលគេរកឃើញស្ថិតក្នុងយុគសំរឹទ្ធ។

**-ស្ថានីយ៍ម្លូព្រៃ** ស្ថិតក្នុងខេត្តព្រះវិហារ រកឃើញដោយលោក **ប៉ៃឡង់** ឆ្នាំ ១៩៣៨។

**-ស្ថានីយ៍តំបន់អង្គរ** ក្នុងឆ្នាំ ១៩៥៩ ដោយលោក **ហ្គ្រូលីយេ** បានគូសបញ្ជាក់តាមអត្ថបទរបស់លោក សូលហែម ថានៅតាមគ្រឹះប្រាសាទក្នុងបរិវេណអង្គរនៅខាងមុខនៃជើងប្រាសាទបក្សីចាំក្រុង។ លទ្ធផលរកឃើញគឺស្លាកស្នាមយុគថ្មរំលីង។

**-ស្ថានីយ៍ល្អាងស្ពាន** នៅឆ្នាំ ១៩៦៥ លោក **រ៉ូឡង់ ម៉ូរ៉េ** បានធ្វើកំណាយនៅរូងភ្នំកំបោរក្នុងខេត្តបាត់ដំបង ដែលបញ្ជាក់ថា មនុស្សរស់នៅក្នុងសម័យនោះស្ថិតក្នុងយុគថ្មបំបែក។

**-ស្ថានីយ៍ភ្នំល្អាង** ក្នុងឆ្នាំ ១៩៦៧ រកឃើញដោយលោក **កាប៉ូណែល** ក្នុងខេត្តកំពត។

**-ស្ថានីយ៍ក្បាលរមាស** ក្នុងឆ្នាំ១៩៦៦-៦៩ លោក **កាប៉ូណែល**និងលោក **ដេលីប្រ៊ីយ៉ា** បានធ្វើការរុករកឃើញនៅក្នុងរូងភ្នំខេត្តកំពតដែលជាលំនៅរបស់មនុស្សក្នុងសម័យបុរេប្រវត្តិ។

**-ស្ថានីយ៍អង្គរបុរី** ឆ្នាំ១៩៩៤ លោកបណ្ឌិត **មីរាមស្តាក** និងលោកសាស្ត្រាចារ្យ **ជុច ភឿន**។ របកគំហើញនៅទីនោះ បានបង្ហាញឱ្យឃើញពីអាយុកាលមនុស្សរស់នៅទីនោះប្រមាណជា ៤០០ឆ្នាំមុន គ.ស និងទំនាក់ទំនងពាណិជ្ជកម្មរវាងចិន ឥណ្ឌា និងខ្មែរនៅកំពង់ផែអូកែវ។ ស្ថានីយ៍នេះស្ថិតនៅក្នុងខេត្តតាកែវសព្វថ្ងៃនេះ។


ភាជន៍និងឆ្នាំង (ថ្មរំលីង) អង្គរបុរី


ពូថៅនិងកងដៃ (ថ្មរំលីង) អង្គរបុរី


អង្កាំធ្វើពីកែវនិងដីដុត



ផែនទីបង្ហាញពីស្ថានីយបុរេប្រវត្តិសាស្ត្រខ្លះនៅស្រុកខ្មែរ( សម្រួលមកពីផែនទីរបស់លោក ហេង សុផា

## ២. អរិយធម៌ខ្មែរសម័យប្រវត្តិសាស្ត្រ

### ២.១. អរិយធម៌ខ្មែរសម័យមុនអង្គរ

ដំណើរវិវត្តនៃប្រវត្តិសាស្ត្របានបង្ហាញថា អាណាចក្រភ្នំបានទទួលឥទ្ធិពលអរិយធម៌ឥណ្ឌាយ៉ាងខ្លាំងអស់ពីរលើក គឺមួយលើកនៅដើមគ.ស.ទី១ និងមួយលើកទៀត នៅដើមគ.ស.ទី៥។ តទៅទៀត យើងនឹងសាកល្បងគូសវាសរូបភាពសង្គមខ្មែរនៅសម័យនោះ ដោយពឹងផ្អែកលើឯកសារចិន និងសិលាចារឹក។ គេចែកអរិយធម៌ខ្មែរសម័យមុនអង្គរជា២សម័យគឺ សម័យនគរភ្នំនិងចេនឡា។

#### ២.១.១. អរិយធម៌ខ្មែរសម័យនគរភ្នំ

##### ២.១.១.១. ផ្នែកវប្បធម៌

ឯកសារចិននិយាយថា នៅអាណាចក្រភ្នំមានសៀវភៅនិងកន្លែងទុកបណ្ណសារ តែគួរឲ្យស្តាយព្រោះសៀវភៅទាំងនោះប្រហែលជាត្រូវវិនាសអស់ទៅហើយ ដែលជាហេតុនាំឲ្យយើងមានការលំបាកច្រើនក្នុងការសិក្សាស្រាវជ្រាវពីប្រវត្តិសាស្ត្រខ្មែរក្នុងសម័យនេះ។ សព្វថ្ងៃនេះ យើងមិនដឹងថា អក្សរនិងភាសាដែលដូនតាយើងប្រើក្នុងសៀវភៅទាំងនោះ មានបែបផែនយ៉ាងណាទេ។ បើយើងសំអាងលើសិលាចារឹកទាំង៤ផ្ទាំង ដែលគេបានរកឃើញរហូតសព្វថ្ងៃឃើញថា ភាសាផ្លូវការក្នុងសម័យនោះ គឺភាសាសំស្ក្រឹត។ ត្រង់នេះមិនមែនមានន័យថានៅសម័យនោះ គេមិនប្រើភាសាខ្មែរសោះទេ ឈ្មោះស្រុកក្តី (វ្នំ) ឈ្មោះរាជធានីក្តី(ទ្នាក់ ឬទល្នក់) ជាភស្តុតាងមួយបញ្ជាក់ថា ភាសាខ្មែរក៏គេប្រើទន្ទឹមនឹងភាសាសំស្ក្រឹតដែរ។ យើងសង្ឃឹមថា ក្នុងអនាគតអ្នកស្រាវជ្រាវនឹងរកឃើញសិលាចារឹកជាភាសាខ្មែរបុរាណក្នុងចំណោមសិលាចារឹកប្រើភាសាខ្មែរបុរាណដែលគ្មានចុះកាលកំណត់ ប៉ុន្តែដែលទម្រង់អក្សរអាចឱ្យភ្ជាប់មកសម័យអាណាចក្រភ្នំបាន។

##### ២.១.១.២. ផ្នែកនយោបាយនិងរដ្ឋបាល

អាណាចក្រភ្នំមានការរៀបចំផ្នែកនយោបាយតាមបែបឥណ្ឌា។ អ្នកដឹកនាំរដ្ឋ គឺព្រះរាជាដែលគង់នៅក្នុងប្រាសាទឈើ ដែលមានច្រើនជាន់ ហើយដែលមានរបងព័ទ្ធជុំវិញ។ ព្រះរាជាមានឋានន្តរនាមជា «ក្រុងវ្នំ» ព្រោះយកតាមភ្នំដែលព្រះអង្គយាងឡើងទៅធ្វើសក្ការបូជាព្រះមហេស្វរៈ និងមានតម្កល់លិង្គព្រះគិរិស គឺឈ្មោះព្រះឥសូរ ដែលសណ្ឋិតនៅលើភ្នំនោះ។ ដោយហេតុតែព្រះអង្គមានឋានៈជាតំណាងអាទិទេព ដូច្នេះហើយបានជាអំណាចរបស់ព្រះអង្គមានទំហំទូលំទូលាយណាស់។ រាជសម្បត្តិ ត្រូវបន្តពីបិតាទៅបុត្រ នេះជាហេតុនាំឱ្យមានវិបត្តិរាជវង្សច្រើនលើកច្រើនគ្រាណាស់ដែរ ប៉ុន្តែជួនកាលរាស្ត្រអាចលើកវរជនដែលខ្លួនពេញចិត្តឱ្យឡើងកាន់អំណាចដែរ ដូចជាករណីរបស់ព្រះបាទ **ហ្វាន់ ចេម៉ាន់** និង **កៅណ្ឌិន្យទី២** ជាដើម។

អធិរាជអាណាចក្រភ្នំនិយមធ្វើនយោបាយពង្រីកទឹកដី ព្រះបាទហ្វាន់ ចេម៉ាន់ បានលើកទ័ពជើងទឹកទៅវាយយកបានរដ្ឋជាច្រើនដាក់ជាចំណុះ ក្នុងចំណោមរដ្ឋទាំងនោះមានខ្លះជាខ្មែរ ខ្លះទៀតជាចាម ជាមន ឬមលយូ។ ក្នុងសង្គ្រាមវាទទឹកដីនោះ គេតែងតែចាប់យកឈ្លើយសង្គ្រាម មកធ្វើជាទាសាទាសី។ ដោយអាស្រ័យហេតុនេះហើយបានជាយើងនិយាយថាអាណាចក្រភ្នំជាអធិរាជាណាចក្រ

ហើយព្រះរាជាមានឋានៈជា**មហារាជ ឬជាសាវ៌កៅ** (ស្តេចចក្រវាឡ)។ រដ្ឋដែលស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់អាណាចក្រភ្នំសុទ្ធតែមានស្តេចសោយរាជ្យ ប៉ុន្តែស្តេចទាំងនោះជា**សាមន្តរាជ** របស់អធិរាជអាណាចក្រភ្នំ ហើយត្រូវនាំសួយសាអាករមកថ្វាយព្រះអង្គជារៀងរាល់ឆ្នាំ។ រដ្ឋខ្លះទៀតមានស្តេចសោយរាជ្យដែរ តែស្តេចទាំងនោះជារាជបុត្រ ឬជាព្រះញាតិរបស់អធិរាជភ្នំ។ ព្រះបាទកៅណ្ឌិន្យទី១ បានប្រទានរដ្ឋបែបនេះទៅព្រះរាជបុត្រ ប៉ុន្តែព្រះបាទហ៊ុនប៉ាន់ហួង បានរំលាយរដ្ឋបែបនេះចោលវិញ។ រដ្ឋទី២នេះហៅថា **វិស័យរដ្ឋ** ជាសម្បត្តិផ្ទាល់របស់អធិរាជភ្នំ។ គួរកត់សម្គាល់ថា របនាសម្ព័ន្ធនយោបាយដូចបានពោលរួចមកហើយនេះឃើញថា នាំឱ្យមានគ្រោះថ្នាក់ច្រើនដែរ ព្រោះតែកាលណាអំណាចកណ្តាលធ្លាក់ខ្សោយ ពួកសាមន្តរាជតែងបះបោរឡើងទាមទារយកឯករាជ្យរៀងៗខ្លួន ដូចជាករណីរបស់រដ្ឋចេនឡានៅសតវត្សទី៦។



ក្នុងវិស័យនយោបាយក្រៅប្រទេស អាណាចក្រភ្នំនិយមចងស្ពានមេត្រីជាមួយប្រទេសធំៗដូចជាប្រទេសឥណ្ឌា និងជាពិសេសប្រទេសចិន។ នយោបាយទូតខ្មែរមានសកម្មភាពយ៉ាងមមាញឹក ចាប់តាំងពីរជ្ជកាលរបស់ព្រះបាទ**ហ្វាន់ ឆាន់**។ ទំនាក់ទំនងនេះមានក្នុងវិស័យនយោបាយផងពាណិជ្ជកម្មផង និងវប្បធម៌ផង។

នៅប្របព្រះរាជា គេឃើញមានមន្ត្រីបម្រើរាជការពីរបែប គឺមន្ត្រីឆ្វេងនិងមន្ត្រីស្តាំ។ មន្ត្រីឆ្វេង គឺមន្ត្រីអង្គុយគាល់នៅខាងឆ្វេង រីឯមន្ត្រីស្តាំ គឺមន្ត្រីដែលមានសក្តិធំជាង ហើយអង្គុយនៅខាងស្តាំ។ ក្រៅពីនេះ នៅមានមន្ត្រីផ្សេងទៀត ដែលមានខ្លះទៅឈរត្រួតត្រានៅតាមខេត្ត។ ព្រះអធិរាជតែងប្រទានសវនាការជាញឹកញាប់ដល់ប្រជារាស្ត្រ និងពួកជនបរទេសដែលបានយកតង្វាយផ្សេងៗមកថ្វាយព្រះអង្គមិនដែលខាន។ ក្នុងករណីនេះ ព្រះអធិរាជទ្រង់គង់ប្រថាប់ដោយទម្លាក់ព្រះបាទឆ្វេងដល់ដី ហើយបញ្ឈរព្រះបាទស្តាំ រួចគេក្រាលកម្រាលមួយផ្ទាំងនៅចំពោះព្រះភក្ត្រព្រះអង្គ ដើម្បីយកភាជន៍មាស និងភាជន៍ដុតគ្រឿងក្រអូបមកតម្កល់លើកម្រាលនោះ។ កាលណាយាងចេញទៅក្រៅ ឬយាងចូលមកវិញ ព្រះអង្គតែងប្រថាប់លើដំរី។ ឯពួកស្រីស្នំ និងពួកមន្ត្រីជាបរិវារក៏ជិះដំរីដែរ។ ព្រះអធិរាជទ្រង់សព្វព្រះហឫទ័យនឹងការបរបាញ់ណាស់ ហើយយាងទៅម្តងៗអស់ពេលរាប់ខែ។

នៅអាណាចក្រភ្នំ រាស្ត្របង់ពន្ធជារង្វាន់រាជការជាមាស ប្រាក់ ត្បូង គុជ ឬគ្រឿងក្រអូបផ្សេងៗ។ គេមិននិយមធ្វើគុកដាក់ជនទុច្ចរិតទេ។ បើកាលណាមានកំហុសស្រាលគេពិន័យជនមានទោស តែបើមានកំហុសធ្ងន់វិញ គេយកមនុស្សទោសឱ្យក្រពើ ឬសត្វសាហាវស៊ីតែម្តង។ ក្នុងបីថ្ងៃ បើសត្វអស់នោះមិនព្រមស៊ីទេ គេចាត់ទុកថា គ្មានកំហុសហើយលែងឱ្យរួចខ្លួន។

### ២.១.១.៣. ជីវភាពសង្គម

-**លក្ខណៈមនុស្ស**៖ឯកសារចិនបាននិយាយបញ្ជាក់ថា មនុស្សនៅអាណាចក្រភ្នំមានសម្បុរខ្មៅ សក់រួញអង្គាជី រូបច្រើនមិនសូវបាន។ ព័ត៌មានប៉ុណ្ណោះអាចប្រាប់យើងពីលក្ខណៈនរវិទ្យារបស់ជនជាតិខ្មែរ-មនជាទូទៅ និងជាពិសេសរបស់ជនជាតិខ្មែរយើងនេះឯង។ ដែលចិននិយាយថា មានសម្បុរខ្មៅក្ដី រូបច្រើនមិនសូវបានក្ដី គឺនិយាយដោយប្រៀបធៀបជាមួយនឹងលក្ខណៈរបស់មនុស្សចិន។ ប៉ុន្តែដោយមានកង្វះឯកសារជាភាសាខ្មែរនៅសម័យនោះ ទើបអ្នកសិក្សាស្រាវជ្រាវបានបញ្ចេញទស្សនៈប្លែកៗ ចំពោះម្ចាស់ដើមនៃអាណាចក្រភ្នំនេះ។ អ្នកខ្លះយល់ថា រដ្ឋនេះជារដ្ឋឥណ្ឌា ខ្លះទៀតយល់ថាជារដ្ឋមន ឬខ្មែរ-មនផង ឬមលយូទៅវិញ។ តាមការពិតជាតិទាំងប៉ុន្មានខាងលើនេះ សុទ្ធតែបានរស់នៅក្នុងអាណាចក្រភ្នំជាមួយគ្នាទាំងអស់ ហើយអ្នកខ្លះជាអ្នកកាន់អំណាចគ្រប់គ្រងគេ (ខ្មែរខ្លះ និងឥណ្ឌាខ្លះ) ឯអ្នកឯទៀត ជាអ្នកត្រូវគេគ្រប់គ្រងប៉ុណ្ណោះ (មន មលយូ)។

-**ការរស់នៅ**៖ ឯកសារចិនដដែលបាននិយាយទៀតថា មនុស្សនៅអាណាចក្រភ្នំច្រើនលែងខ្លួន អ្នកក្រស្លៀកសារុងអំបោះដើរជើងទទេ អ្នកមាននិងនាម៉ឺនស្លៀកសារុងចរបាប់ពាក់ស្បែកជើង។ ផ្ទះសង់ខ្ពស់ពីដី ប្រក់ស្លឹកចាក ដែលដុះនៅមាត់សមុទ្រ ហើយមានការតុបតែង។ ផ្ទះទាំងនោះសុទ្ធតែសង់ពីឈើដែលគេកាប់យកមកពីក្នុងព្រៃ មានរបងព័ទ្ធជុំវិញ ហើយផ្តុំគ្នាជាភូមិមានពី៥០ ទៅ ៦០ ផ្ទះដែលមានស្រះមួយសម្រាប់យកទឹកប្រើប្រាស់រួមគ្នា។

-**ទំនៀមទម្លាប់**៖ មនុស្សនៅអាណាចក្រភ្នំគ្មានគំនិតរញ៉ិររញ៉ុំ ត្រង់ណាស់ មិនចេះលួចទេ (ឯកសារខ្លះថាមានចិត្តលោភលន់) មានការប៉ិនប្រសប់ ហើយខិល ព្រោះចូលចិត្តចាប់យកមនុស្សនៅក្រុងជិតខាង ដែលមិនព្រមគោរពរាប់អានខ្លួន មកធ្វើជាខ្ញុំកំដរ។ នៅពេលទំនេរ គេចូលចិត្តលេងល្បែងប្រជល់មាន់និងប្រជល់ជ្រូក។

សង្គមអាណាចក្រភ្នំជាសង្គម «**មេនិយម**» គឺគេទុកស្រីជាធំក្នុងគ្រួសារផងក្នុងសង្គមផង រឿងនាង**លីវយី** លើកទ័ពទៅតទល់នឹង **ហ៊ុន ទៀន** ជាកស្តុតាងមួយយ៉ាងជាក់ស្តែង។ ឯកសារចិនបាននិយាយថា ពិធីបុណ្យការនិងបុណ្យសព មានលំនាំដូចនៅ**លីនយី** ឱ្យស្រីទៅដណ្ដឹងប្រុសនៅឡើយ។ នេះជាធាតុមួយទៀតសម្រាប់បញ្ជាក់អំពីអត្ថិភាពនៃលទ្ធិ «**មេនិយម**» ទៀតដែរ។ ចំពោះរឿងនេះ ពួកចិនបានកត់សម្គាល់ម្យ៉ាងទៀតថា នៅក្នុងគ្រួសារ ពួកស្រីប្រុស គេអាចទាក់ទងគ្នាបានតាមទំនើងចិត្ត។

ក្នុងករណីកាន់ទុក្ខ គេត្រូវតែកោរសក់និងកោរពុកមាត់ ឯពិធីរំលាយសពមាន ៤ យ៉ាង ៖

១- បោះសពចោលទៅក្នុងទឹកទន្លេ

២- បូជាដោយភ្លើង

៣- យកសពទៅកប់

៤- យកសពទៅដាក់ក្នុងព្រៃស្មសានឱ្យសត្វស៊ី។ ក្នុងករណីបូជាដោយភ្លើង គេតែងប្រមូលធាតុដែលនៅសល់យកទៅដាក់ក្នុងកោដ្ឋមួយបិទជិត ហើយយកទៅបោះចោលក្នុងទឹកទន្លេ។ បើជា

ព្រះមហាក្សត្រ កោដ្ឋនោះធ្វើពីមាស បើជានាម៉ឺនសព្វមុខមន្ត្រី គេប្រើកោដ្ឋជាប្រាក់ ហើយបើជារាស្ត្រសាមញ្ញ ប្រើកោដ្ឋដី។

**-វិធីរកយុត្តិធម៌៖** អ្នកស្រុកអាណាចក្រភ្នំ ចូលចិត្តប្រើវិធីអស្ចារ្យដើម្បីរកសេចក្តីពិត។ កាលណាមានបាត់របស់អ្វីមួយ គេក៏យកបាយមួយពំនូតទៅដាក់នៅចំពោះព្រះភក្ត្រទេវតា រួចគេអង្វរសូមឱ្យព្រះអង្គជួយបង្ហាញមុខជនទុច្ចរិត។ ស្អែកឡើង គេយកបាយនោះ ទៅចែកឱ្យពួកខ្ញុំនៅក្នុងផ្ទះបរិភោគ ក្នុងមាត់របស់ចោរនឹងមានឈាមហូរចេញយ៉ាងជាក់ស្តែង ហើយវាមិនអាចទំពារបាយផង ឯមាត់របស់ជនទៀងត្រង់ បាយនោះអាចរអិលទៅក្នុងមាត់យ៉ាងស្រួល។ ម្យ៉ាងទៀត បើកាលណាមានជនជាប់ចោទ គេឱ្យជននោះអត់បាយ ៣ថ្ងៃ រួចគេតម្រូវឱ្យលូកយកវត្ថុផ្សេងៗ ចេញពីទឹកកំពុងពុះ ឬកាន់ពូថៅ ឬច្រវាក់ដុតក្រហមដើរ៧ជំហាន។ បើមានកំហុសមែន ដៃរបស់ជននោះត្រូវរលាករលួយ ផ្ទុយទៅវិញគឺគ្មានហ្មងអ្វីទាំងអស់។

### ២.១.១.៤. សកម្មភាពសេដ្ឋកិច្ច

អាណាចក្រភ្នំដែលមានឈ្មោះថាថ្កុំថ្កើងរុងរឿង ក៏ដោយសារតែយល់នូវសារៈសំខាន់នៃសេដ្ឋកិច្ច។ ឯសកម្មភាពសេដ្ឋកិច្ចចម្បងនៅសម័យនោះ គឺកសិកម្មនិងពាណិជ្ជកម្មនេះឯង។

កសិកម្មមានការចម្រើនលូតលាស់ខ្លាំង។ នេះក៏ដោយសារតែមានជោគជ័យក្នុងនយោបាយទឹក។ យ៉ាងណាមិញ អ្នកស្រុកចេះជីកព្រែកខ្វាត់ខ្វែងដែលមានសល់ដានរហូតដល់សព្វថ្ងៃ នៅត្រង់កម្ពុជាក្រោមភាគខាងលិច។ តាមយោបល់អ្នកជំនាញការ បណ្តាញព្រែកជីកនេះ គេបានកសាងឡើងសម្រាប់បង្ហូរទឹកជំនន់ទន្លេមេគង្គចោលចេញផង សម្រាប់លាងឱ្យស្អាតនូវទឹកភក់ល្បាប់ និងបន្សាបអំបិលដែលជ្រួតជ្រាបទៅក្នុងដីផង សម្រាប់ជាគមនាគមន៍រវាងទីក្រុងទាំងឡាយ និងសម្រាប់ឱ្យសំពៅនិងទូកឆ្លងកាត់ទៅបានពីសមុទ្រចិនទៅឈូងសមុទ្រសៀម ដោយមិនបាច់កុងព័ទ្ធតាមចុងជ្រោយទឹកខ្មៅផង។

ក្រៅពីរបរស្រែដែលចិនថា «គេព្រោះមួយឆ្នាំ រួចគេច្រូតបានបីរដូវ» របរខាងចម្ការទំនងជាមានការលូតលាស់ដែរ គេដាំក្រូច ទទឹម អំពៅ ស្លា។ល។

ពាណិជ្ជកម្មក៏ជាវិស័យមួយមានការចម្រើនលូតលាស់ណាស់ដែរ។ ភស្តុតាង គឺគេបានរកឃើញស្នាមកំពង់ផែសមុទ្រមួយយ៉ាងធំ។ តាមយោបល់អ្នកជំនាញការ គេថាកំពង់ផែនេះ (កំពង់ផែអូរកែវ) ជាកំពង់ផែអន្តរជាតិ ព្រោះកំណាយនៅតំបន់នោះ បានរកឃើញវត្ថុផ្សេងៗដែលមកពីប្រទេសឆ្ងាយៗដូចជាចក្រភពរ៉ូម៉ាំង ពិភពអ៊ីរ៉ង់ ប្រទេសឥណ្ឌា។ ដូច្នេះ ឃើញថា នៅសម័យនោះ អ្នកស្រុកអាណាចក្រភ្នំ មិនគ្រាន់តែធ្វើជំនួញជាមួយប្រទេសជិតខាងប៉ុណ្ណោះទេ គឺបានទាក់ទងខាងផ្លូវជំនួញនេះជាមួយនឹងចិន ឥណ្ឌា រ៉ូម៉ាំង និងពែក្សទៀតផង ហើយការដែលអ្នកជំនួញមានលទ្ធភាពអាចធ្វើដំណើរទៅឆ្ងាយដូច្នេះ ក៏ព្រោះតែគេមានបច្ចេកទេសយ៉ាងខ្ពង់ខ្ពស់ក្នុងការស្ថាបនាសំពៅធំៗសម្រាប់ឆ្លងកាត់សមុទ្របាន។ ឯកសារចិនថា មានសំពៅប្រវែងប្រហែល ៣០ម៉ែត្រ ក្បាល និងកន្សៃមានរាងជាក្បាល និងកន្ទុយសត្វត្រី។ ទំនិញដែលគេលក់ដូរច្រើនតែជាមាស ប្រាក់ សំពត់ព្រៃ គ្រឿងកែវ។ល។






ឯកសារចិនបាននិយាយថា អាណាចក្រភ្នំជាកន្លែងកើតមាស ប្រាក់ ទង់ដែង សំណប៉ាហាំង គ្រឿងក្រអូប ភ្លុកដំរី និងពេជ្រ។ ឯកសារនេះបានបញ្ជាក់ទៀតថា ពេជ្រនេះគេមុជទៅរកនៅបាតសមុទ្រ ហើយមានភាពរឹងណាស់យកដែកដំមិនខូចទេ តែខូចដែកវិញ។ ម្យ៉ាងទៀត អ្នកស្រុកប៉ិនប្រសប់ណាស់ក្នុងរបរធ្វើជាងមាស ឬប្រាក់ ដូចជាធ្វើចិញ្ចៀន ឬកងដៃមាស ធ្វើគ្រឿងចានក្បានប្រាក់។ អ្នកស្រុកប៉ិនណាស់ដែរ ក្នុងរបរសូនរូប ត្បាញសូត្រ ចរបាច់ ស្លកែវ។ល។

## ២.១.២. អរិយធម៌ខ្មែរសម័យចេនឡា

ចំពោះសម័យចេនឡាក៏ដូចជាសម័យអាណាចក្រភ្នំដែរ ព័ត៌មានដែលទាក់ទងនឹងវប្បធម៌ អរិយធម៌ សុទ្ធតែបានមកពីប្រភពចិនស្ទើរតែទាំងអស់។ ចំពោះចេនឡានេះ យើងបានពឹងផ្អែកទៅលើពង្សាវតារ ស៊្វី (Souei) ដែលបានកត់ត្រារឿងរ៉ាវទាក់ទងនឹងរជ្ជកាលព្រះបាទឥសានវរ្ម័នទី១ ហើយដែលលោក ម៉ាតួនលិន បានចម្លងដាក់ទាំងស្រុងក្នុងសៀវភៅ ការសិក្សាពីប្រជារាស្ត្រក្រៅប្រទេសចិនរបស់លោកនៅសតវត្សទី១៣។

### ២.១.២.១. ផ្នែកវប្បធម៌

ក្រៅពីភាសាសំស្ក្រឹតដែលមានប្រើតាំងពីដើមរៀងមក នេះជាលើកដំបូងដែលគេឃើញមានប្រើភាសាខ្មែរបុរាណក្នុងសិលាចារឹក សិលាចារឹកខ្មែរដំបូងដែលមានចុះកាលកំណត់ច្បាស់ គឺសិលាចារឹកអង្គរបុរី ឆ្នាំ៦១១។ ក្នុងផ្នែកអក្សរសិល្ប៍ សិលាចារឹកវាលកន្ទេលបាននិយាយថា គេសូត្រជារៀងរាល់ថ្ងៃនូវរឿងរាមាយណៈ រឿងមហាភារតៈ និងគម្ពីរបុរាណ។






ក្នុងវិស័យសាសនា សិចារឹកបានឱ្យដឹងថា មានការគោរពបូជាចំពោះគណៈផ្សេងៗដែលបានរួមរស់ជាមួយគ្នា៖

-គណៈសិវៈ មានឋានៈជាសាសនាផ្លូវការ ព្រោះព្រះរាជាទាំងអស់តាំងពីព្រះបាទភវវរ្ម័នទី១ និងប្អូនជីដូនមួយរបស់ព្រះអង្គ ចិត្រសេន សុទ្ធតែបានធ្វើការកសាងលិង្គព្រះឥសូរជាច្រើនដូចយើងបានឃើញរួចមកហើយ។ ចំពោះព្រះរាជាខ្លះដូចជាជ័យវរ្ម័នទី១ ជាដើម ទំនងជាមានប្រើមរណនាមរួចទៅហើយ។ យ៉ាងណាមិញសិលាចារឹកឆ្នាំ៧១៣ដែលនិយាយថា«ព្រះរាជាដែលយាងទៅកាន់សិវបុរៈ» ប្រហែលជាចង់ដៅចំពោះព្រះអង្គនេះឯង។ ចំណែកឯព្រះមរណនាម ឥន្ទ្រលោក ដែលមានចារឹកក្នុងសិលាចារឹក៨០៣ ក៏ទំនងជាដៅចំពោះព្រះបាទបុស្គរាក្ស ដែលគេយល់ថា បានយាងទៅសោយរាជ្យនៅសម្ភុបុរៈ នៅពេលដែលរាជបល្ល័ង្កនៅទីនោះនៅទំនេរ ហើយដែលព្រះអង្គប្រើកម្លាំងផង។ ក្រៅពីការគោរពបូជាលិង្គ នៅមានគណៈមួយទៀតដែលគេគោរពព្រះឥសូរដែរ គឺគណៈបាសុបត។

- គណៈវិស្ណុ មិនសូវមានគេនិយមច្រើនទេ។ មានការគោរពចំពោះគណៈបញ្ចរាត្រ។

- ហរិហរៈ គេគោរពព្រះហរិហរៈជាបន្តពីសម័យអាណាចក្រភ្នំមក។ មានរូបបដិមាហរិហរៈយ៉ាងល្អវិចិត្រ ហើយមានរាងសង្ហាថែមទៀត ដូចជាហរិហរៈ ប្រាសាទអណ្តែត (ស្រុកស្ទោង ខេត្តកំពង់ធំ) ជាដើម។ តែក្រោយពីនេះ គេពុំឃើញមានការគោរពហរិហរៈទៀតឡើយ។

- ពុទ្ធសាសនា មិនបាត់បង់ទេ តែទំនងជាត្រូវសាបសូន្យបន្តិចម្តងៗ ជាពិសេសនៅស.វ.ទី៧ បើគេផ្អែកទៅលើសក្ខីភាពរបស់ពុទ្ធសាសនិកចិនឈ្មោះឃីស៊ីង។ គេឃើញមានតែសិលាចារឹកមួយគត់និយាយពីព្រះភិក្ខុពីរអង្គ។ ពុទ្ធសាសនាមហាយាន ចាប់ផ្តើមឃើញមានគេគោរពបូជាខ្លះៗហើយ។

ក្នុងវិស័យស្ថាបត្យកម្ម ប្រាសាទច្រើនតែសង់ពីឥដ្ឋដាច់ៗពីគ្នា ឬផ្តុំគ្នាជាក្រុម។ ផ្តែរនិងក្របក្លោងទ្វារគេធ្វើពីថ្មភក់។







រូបចម្លាក់បដិមានៅមានជាប់លក្ខណៈឥណ្ឌានៅឡើយ តែភាគច្រើនបានបង្ហាញក្បាច់រចនាបែបខ្មែរ ហើយមានរាងសង្ហាផង។ ចម្លាក់តុបតែងមានសភាពល្អប្រណីត ហើយថែមទាំងបានបន្តអានុភាពរបស់ខ្លួន រហូតមកដល់ក្នុងសម័យអង្គរទៀត។







## ២.១.២.២. ផ្នែកនយោបាយនិងរដ្ឋបាល



ចាប់តាំងពីរជ្ជកាលព្រះបាទឥសានវរ្ម័នទៅ រាជធានីតាំងនៅឥសានបុរៈ(ចិនហៅអុីចូណា) ហើយមាន២០០០០គ្រួសារ។ នៅកណ្ដាលក្រុងមានសាលធំមួយ ជាទីដែលព្រះរាជាទ្រង់ប្រទានសវនាការ និងប្រជុំពួកមន្ត្រីសេនាបតី។ ក្រៅពីរាជធានី នៅមានក្រុងចំនួន៣ទៀត ក្រុងនីមួយៗមានច្រើនពាន់គ្រួសារ ហើយត្រួតត្រាដោយអភិបាលម្នាក់។ ក្នុង៣ថ្ងៃម្ដង ព្រះរាជាតែងយាងទៅកាន់សាលប្រជុំ។ មន្ត្រីជាន់ខ្ពស់មាន៥នាក់ ទី១ មានងារហៅតាមចិនថា Kou lo yeou ទី២ Siang kao ping ទី៣ Po hoto ling ទី៤ Cho mo ling និងទី៥ Jan lo leou។ រហូតមកដល់ពេលនេះ គេមិនទាន់រកឃើញថា គោរម្យងារដែលហៅតាមចិននេះ ត្រូវនឹងពាក្យខ្មែរជំនាន់នោះថាយ៉ាងម៉េចនៅឡើយទេ។ ឯពួកមន្ត្រីតូចតាចវិញមានចំនួនច្រើនណាស់។

នៅចំពោះព្រះភក្ត្រព្រះរាជា ពួកមន្ត្រីត្រូវធ្វើគារវកិច្ចដោយឱនក្បាលដល់ដីបីដង។ បើព្រះអង្គទ្រង់មានបន្ទូលហៅ ឬប្រើពួកមន្ត្រីត្រូវលុតជង្គង់ថយទៅអង្គុយដំកង់ជុំវិញព្រះរាជាដើម្បីពិភាក្សាពីកិច្ចការប្រទេសជាតិ។ ចប់កិច្ចហើយ គេត្រូវលុតជង្គង់សំពះជាថ្មីមុននឹងត្រឡប់ទៅវិញ។ មានទាហានរាប់ពាន់នាក់ពាក់អាវក្រោះ កាន់លំពែងឈរយាមគ្រប់ទីកន្លែង តាំងពីជុំវិញរាជបល្ល័ង្ករហូតដល់ទ្វារទាំងឡាយ។

ចំពោះការផ្ទេររាជសម្បត្តិ គឺមានតែបុត្រនៃអគ្គមហេសីទេ ទើបឡើងសោយរាជ្យបាន។ នៅថ្ងៃប្រារព្ធពិធីអភិសេកព្រះរាជាថ្មី គេកាត់ម្រាមដៃ ច្រមុះបុត្រឯទៀត។ រួចយកទៅឃុំទុកនៅកន្លែងទីទៃៗពីគ្នា ដោយមិនឱ្យកាន់តំណែងអ្វីមួយសោះឡើយ។

## ២.១.២.៣. ជីវភាពសង្គម

**-លក្ខណៈមនុស្ស៖** មនុស្សនៅសម័យនោះមានមាឌតូច ហើយសម្បុរខ្មៅ ដូចមនុស្សនៅសម័យអាណាចក្រភ្នំដែរ ប៉ុន្តែស្រីៗភាគច្រើនមានសម្បុរស (នេះប្រហែលជាមកពីនៅក្នុងម្លប់មិនចេញប្រកបការងារខាងក្រៅដូចប្រុសទេដឹង?)។ ទាំងប្រុសទាំងស្រីសុទ្ធតែបួងសក់ ហើយពាក់រយ៉ាថែមទៀត។ លក្ខណៈរូបរាងកាយទាំងនេះ ឃើញថាដូចពួកខ្មែរលើដែលរស់នៅលើខ្ពង់រាបសព្វថ្ងៃច្រើន។

**-ការរស់នៅនិងទំនៀមទម្លាប់៖** ឯកសារចិនបានបញ្ជាក់ទៀតថា ពួកនេះមានគំនិតវាងវៃ ហើយមានមាឌមាំមួនទៀតផង។ គេចាត់ទុកដៃស្ដាំថាបរិសុទ្ធ ឯដៃឆ្វេងថាមិនបរិសុទ្ធ។ រៀងរាល់ព្រឹក គេតែងធ្វើការលុបលាង ចាក់ធ្មេញ រួចអានសៀវភៅ ឬសូត្រធម៌។ មុនពេលទទួលទានអាហារ គេតែងលុបលាងសាជាថ្មី លុះទទួលទានរួចហើយ គេចាក់ធ្មេញហើយគេសូត្រធម៌ជាថ្មីថែមទៀត។ ក្នុងម្ហូបអាហារ គេចូលចិត្តប្រើទឹកដោះគោ ស្ករគ្រាប់ល្អិត បាយ និង millet?

សិលាចារឹកឱ្យដឹងថា គេនិយមរាប់ញាតិដោយយកខ្សែតាមម្ដាយ។ ក្នុងរឿងជ្រើសរើសគូស្រករ គឺពួកប្រុសៗទៅដណ្ដឹងស្រី ត្រង់នេះឃើញថា មានការវិវត្តប្លែកពីសម័យមុនដែលពួកស្រីៗទៅដណ្ដឹងប្រុសៗ។ មុនដំបូង ខាងប្រុសត្រូវលើកជំនួនទៅខាងគ្រួសារស្រីដែលខ្លួនពេញចិត្ត បន្ទាប់មកខាងស្រីត្រូវជ្រើសរើសថ្ងៃមង្គលដើម្បីនាំកូនស្រីទៅផ្ទះខាងប្រុស តាមរយៈមេអណ្ដើកម្នាក់។ គ្រួសារទាំងសងខាងស្ថិតនៅក្នុងផ្ទះអស់រយៈពេល ៨ថ្ងៃ ដោយពុំមានចេញទៅណាមកណា ហើយដោយមានអុជចង្កៀងទាំងយប់ទាំងថ្ងៃ។ លុះពិធីមង្គលការចប់សព្វគ្រប់ហើយ កូនប្រុសទទួលមរតកពីឪពុកម្ដាយបង្កើតរបស់ខ្លួន ហើយបែកផ្ទះទៅនៅដោយឡែក។ ដល់ពេលឪពុកម្ដាយស្លាប់ទៅ ពួកកូនដែលនៅលីវអាចទទួលយកមរតកដែលនៅសេសសល់ទាំងអស់ ប៉ុន្តែប្រសិនបើកូនទាំងនោះមានប្ដីប្រពន្ធ ហើយបានទទួលមរតករួចហើយ នោះទ្រព្យដែលនៅសល់ត្រូវគេបញ្ជូនទៅក្នុងឃ្លាំងជាតិ។

ក្នុងពិធីបុណ្យសព កូនទាំងឡាយរបស់សពត្រូវអត់បាយ ៧ថ្ងៃ ត្រូវកោរសក់ ហើយត្រូវយំស្រែកយ៉ាងខ្លាំង។ ក្រុមគ្រួសារនៃសពដោយរួមនឹងព្រះភិក្ខុ និងភិក្ខុនី បានធ្វើក្បួនដង្ហែដោយមានច្រៀង (?) និងលេងភ្លេងផង។ សពគេបូជាក្នុងប៉ាធាសង់ដោយឈើក្រអូប រួចគេរើសធាតុដាក់ក្នុងកោដ្ឋមាស ឬប្រាក់ ហើយយកទៅទម្លាក់ចោលក្នុងទឹក។ ពួកអ្នកក្រប្រើកោដ្ឋដីមានលាបពណ៌ផ្សេងៗ។ មានខ្លះ គ្រាន់តែយកសពទៅដាក់ចោលក្នុងព្រៃស្មសានឱ្យសត្វស៊ី។

ទម្លាប់របស់អ្នកស្រុកម្យ៉ាងទៀត គឺពេលទៅណាមកណាមានពាក់អាវក្រោះ និងកាន់អាវុធ ហើយបើកាលណាមានរឿងបន្តិចបន្តួច គេក៏ប្រយុទ្ធបង្ហូរឈាមគ្នាភ្លាម។

### ២.១.២.៤. សកម្មភាពសេដ្ឋកិច្ច

ខ្មែរយើងធ្លាប់មានជោគជ័យក្នុងនយោបាយទឹកតាំងពីសម័យអាណាចក្រភ្នំមកម្ល៉េះ។ ចូលមកដល់សម័យចេនឡា នយោបាយទឹកមានសភាពរឹងរឹតតែប្រសើរឡើងថែមទៀត ជាហេតុញ៉ាំងឱ្យមានការកសាងទីក្រុងធំៗនៅក្បែរមាត់ស្ទឹង និងញ៉ាំងឱ្យកសិកម្មមានការរីកចម្រើនលូតលាស់ជាលំដាប់។ ឧទាហរណ៍ ក្រុងឥសានបុរៈត្រូវបានកសាងនៅក្បែរស្ទឹងសែន ឯទឹកស្ទឹងនោះត្រូវបង្ហូរចូលក្នុងស្រះព័ទ្ធជុំវិញក្រុង និងក្នុងអាងទឹកឯទៀតៗក្នុងផ្ទៃក្រុង ធ្វើដូច្នេះ គេអាចមានទឹកប្រើប្រាស់គ្រប់គ្រាន់ ហើយមានលទ្ធភាពពង្រីកដីដាំដំណាំទៀតផង។ បើតាមឯកសារចិនថា គេដាំស្រូវ seigle? Mil? និង gros millet?។ ចំពោះស្រូវ គេជឿថាមានពិតប្រាកដ ហើយតែចំពោះដំណាំឯទៀតៗ គេមិនដឹងថាមានមែន ឬយ៉ាងណាទេ។

## ២.២. អរិយធម៌ខ្មែរសម័យមហានគរ

នៅសម័យអង្គរ ខ្មែរមានឈ្មោះថាជាមហាអំណាចមួយនៅអាស៊ីអាគ្នេយ៍។ យ៉ាងណាមិញ អរិយធម៌ខ្មែរ បានឡើងដល់កម្រិតកំពូលនៅសម័យនោះ ជាពិសេសចាប់ពីស.វ.ទី៩ ដល់ដើមស.វ. ទី១៣។ ភាពរុងរឿងនេះ គេសម្គាល់ដោយផ្ទៃដីធំទូលាយ លាតសន្ធឹងសឹងតែអស់ផ្ទៃដីឥណ្ឌូចិនទាំងមូល ដោយប្រាសាទសិលាមានចំនួនច្រើនរាប់ពាន់ប្រកបដោយក្បាច់រចនាគួរឱ្យកោតស្ញប់ស្ញែង ដោយផ្ទាំងសិលាចារឹកច្រើនសន្ធឹកសន្ធាប់ មានទាំងភាសាសំស្ក្រឹត និងខ្មែរបុរាណ ឬជួនកាលមាន

ភាសាទាំងពីរលាយចម្រុះគ្នាដោយរូបបដិមាគ្រប់ប្រភេទនិងបុរាណវត្ថុផ្សេងៗទៀត។ មានបណ្ដាញ ជលគតិដូចជាបារាយណ៍ ទំនប់ទឹក ផ្លូវថ្នល់ ស្ពាន មន្ទីរពេទ្យ។ល។ ប៉ុន្តែចាប់ពីពាក់កណ្ដាលទី១នៃ ស.វ. ទី១៣ ទៅ ការចុះដុនដាបក៏ចាប់មានបន្តិចម្ដងៗរហូតដល់ត្រូវបោះបង់រាជធានីអង្គរចោលនៅ ស.វ.ទី១៥ ដោយព្រះបាទពញាយ៉ាត។ តទៅនេះ យើងសាកល្បងបង្ហាញរូបភាពនៃសង្គមខ្មែរក្នុង សម័យដ៏រុងរឿងនោះ។

### ២.២.១. ផ្នែកវប្បធម៌

<u>សាសនានិងលទ្ធិផ្សេងៗ</u>

នៅសម័យអង្គរសាសនាមានតួនាទីយ៉ាងសំខាន់បំផុតក្នុងនយោបាយ។ ព្រះរាជាតែងតែផ្លាស់ ប្តូរសាសនាទៅតាមជំនឿនិងចំណូលចិត្តរបស់ខ្លួន។ ព្រះរាជាខ្លះគោរពព្រះឥសូរ ខ្លះគោរពព្រះវិស្ណុ ខ្លះ គោរពព្រះព្រហ្ម និងខ្លះទៀតកាន់សាសនាព្រះពុទ្ធ។

-ពីសតវត្សទី៩ ដល់ទី១១ គណៈសិវៈ(ឥសូរ) មានឧត្តមភាពលើគណៈឯទៀតៗ។ ព្រះរាជា ចាត់ទុកថា ជាសាសនារបស់រដ្ឋ (ធ្វើពិធីទេវរាជ) ហើយមានសិវលិង្គតម្កល់នៅក្នុងប្រាសាទភ្នំ។ ក្នុង រយៈពេលនោះព្រះរាជាបានយកចិត្តទុកដាក់និងជួយឧបត្ថម្ភសាសនាដទៃៗទៀតដែរ ដូច្នេះសាសនា ទាំងអស់រស់ជាមួយគ្នាយ៉ាងសុខដុមរមនា។



ព្រះឥសូរ,
ប្រាសាទបាគង,
ប់មទី៩,
ឆ្នាំ៨៨១



ព្រះនារាយណ៍,
ប្រាសាទបាគង,
ប់មទី៧,
ឆ្នាំ៨៨១



លោកេស្វរៈ

- ជ័យវរ្ម័នទី២ កាន់ព្រហ្មញ្ញសាសនាជឿលើព្រះឥសូរ (មរណនាមបរមេស្វរៈ)
- ជ័យវរ្ម័នទី៣ កាន់ព្រហ្មញ្ញសាសនាជឿលើព្រះវិស្ណុ (មរណនាមវិស្ណុលោក)
- យសោវរ្ម័នទី១ កាន់ព្រះឥសូរ (មរណនាមបរមសិវលោក)
- សូរ្យវរ្ម័នទី១ កាន់ព្រះពុទ្ធសាសនាមហាយាន (មរណនាមនិវ៌ានបទ)
- សូរ្យវរ្ម័នទី២ កាន់ព្រះវិស្ណុ (មរណនាមព្រះវិស្ណុលោក)
- ជ័យវរ្ម័នទី៧ កាន់ព្រះពុទ្ធសាសនាមហាយាន(មរណនាមមហាបរមសៅគត)
- ជ័យវរ្ម័នទី៨ កាន់ព្រះឥសូរវិញ(មរណនាមបរមេស្វរបទ)
- ជ័យវរ្ម័នទី៩ កាន់ព្រះឥសូរ។



ព្រះព្រហ្ម, ព្រះឥសូរ និងព្រះនារាយណ៍, ចម្លាក់នៅប្រាសាទវត្តភូ (ជ័យវរ្ម័នទី៦, ១០៨០-១១០៧)



ព្រះពុទ្ធរូបដែលគេកែឲ្យទៅជាលិង្គ



ចម្លាក់នៅប្រាសាទបាយ័ន្ត



ប្រាសាទនាគព័ន្ធ

## ២.២.២. នយោបាយនិងរដ្ឋបាល

**ក- ព្រះរាជា៖** ដោយការប្រារព្ធធ្វើពិធីទេវរាជ ព្រះរាជាត្រូវមានឋានៈស្មើអាទិទេព។

-ពេលសោយទីវង្គតទៅ ព្រះអង្គនឹងយាងទៅគង់នៅទេវលោក។

-រាជធានីរបស់ព្រះអង្គជាតំណាងនៃចក្រវាឡទាំងមូល ប្រាសាទភ្នំនៅកណ្តាលក្រុងជានិមិត្តរូបភ្នំព្រះសុមេរុ ដែលគេចាត់ទុកថា ជាស្នូលនៃចក្រវាឡ កំពែងនិងគូទឹក ជានិមិត្តរូបជួរភ្នំនិងសមុទ្រដែលព័ទ្ធជុំវិញភ្នំព្រះសុមេរុ។

-ប្រាសាទភ្នំសម្រាប់តម្កល់លិង្គទេវរាជ អាចប្រើបានសម្រាប់តែព្រះរាជាមួយអង្គប៉ុណ្ណោះ លុះព្រះអង្គសោយទីវង្គតទៅ ប្រាសាទនោះនឹងក្លាយជាផ្នូររបស់ព្រះអង្គ។

**ខ- អំណាចព្រះរាជា៖**

-ជាអំណាចរបស់អាទិទេព ព្រះអង្គមានអំណាចលើដីធ្លីទាំងអស់ ការលក់ ការប្តូរ ឬការធ្វើអំណោយដី ត្រូវតែមានសេចក្តីយល់ព្រមពីព្រះអង្គទើបបាន។

-ព្រះអង្គជាអ្នកធ្វើច្បាប់ ជ្រើសរើសមន្ត្រីជាន់ខ្ពស់។

-ព្រះអង្គជាអគ្គបញ្ជាការនៃកងទ័ព ជាអ្នកកាត់សេចក្តី ជាមេសាសនា។

-ព្រះអង្គជាអ្នកការពារប្រទេសមិនឱ្យសត្រូវឈ្លានពានពីខាងក្រៅនិងរ៉ាប់រងឱ្យមានសន្តិភាពនៅខាងក្នុង។

-ព្រះអង្គជាមេទ័ពដឹកនាំទ័ពចេញទៅប្រយុទ្ធជាមួយសត្រូវនៅក្នុងសមរភូមិតែម្តង។

-អត្ថបទសិលាចារឹកជាច្រើនបានកោតសរសើរចំពោះគុណសម្បត្តិយោធារបស់ព្រះរាជាថា សុទ្ធសឹងតែមានតេជៈដ៏ខ្លាំងពូកែ មានជ័យជំនះលើសត្រូវជានិច្ច។

-ការដែលបង្ហាញឱ្យឃើញថា ព្រះរាជាសម័យអង្គរមានអំណាចទូលំទូលាយនោះ ពុំមែនមានន័យថា ព្រះអង្គជាអ្នកកាន់អំណាចផ្តាច់ការទេ ព្រោះព្រះអង្គត្រូវគោរពវិន័យវណ្ណៈក្សត្រ គោរពសិក្ខាបទសាសនា បានសេចក្តីថា ព្រះអង្គត្រូវប្រកបដោយទសពិធរាជធម៌។

-សិលាចារឹកព្រះគោ ស្លោកទី៣ បាននិយាយពីព្រះបាទឥន្ទ្រវរ្ម័នទី១ថា ស្រីឥន្ទ្រវរ្ម័នបានធ្វើឱ្យប្រជារាស្ត្រសម្បូណ៌សប្បាយដោយការប្រតិបត្តិនូវវិន័យទាំង៣ប្រការ។

### គ- ការបន្តរាជសម្បត្តិ

បុត្រច្បងអាចឡើងសោយរាជ្យស្នងព្រះបិតា ប៉ុន្តែបើគ្មានបុត្រទេ ញាតិណាម្នាក់អាចឡើងសោយរាជ្យបាន។ ចំពោះការបន្តរាជសម្បត្តិនេះ មានមតិពីរផ្ទុយគ្នា អ្នកខ្លះយល់ថា មានតែញាតិជាប់ខ្សែខាងស្រីទៅនឹងព្រះរាជា ទើបអាចឡើងស្នងរាជ្យបាន អ្នកខ្លះទៀតយល់ផ្ទុយទៅវិញ ប៉ុន្តែបានបញ្ជាក់ថា ទាល់តែជាប់ខ្សែខាងស្រីជាមួយស្ដេចមុន ឬត្រូវយកក្សត្រី ស្ត្រីណាមួយក្នុងគ្រួសារស្ដេចមុន ទើបអាចទទួលរាជសម្បត្តិបាន។ ក្នុងករណីដែលព្រះរាជាទទួលរាជសម្បត្តិហើយនៅក្មេងពេក នោះកិច្ចការរដ្ឋត្រូវបានព្រះរាជគ្រូជាអ្នកទទួលខុសត្រូវ។

### ឃ- ពួកបរិវារ

-រូបចម្លាក់លើប្រាសាទអង្គរវត្ត បង្ហាញព្រះបាទសូរ្យវរ្ម័នទី២ គង់លើបល្ល័ង្កទទួលគារវកិច្ចពីពួកបរិវារ ដែលមានជាអាទិ៍ពួករាជវង្សានុវង្ស មន្ត្រីជាន់ខ្ពស់ទាំងខាងស៊ីវិល ទាំងខាងទាហាន និងបុគ្គលិកមួយចំនួនច្រើនសន្ធឹកសន្ធាប់ណាស់។

-ព្រះរាជាគង់នៅក្នុងវាំងសង់ពីឈើ។

### ង- រដ្ឋបាល




#### ង.១. រដ្ឋបាលកណ្ដាល

-ការគ្រប់គ្រងរដ្ឋត្រូវស្ថិតនៅក្នុងកណ្ដាប់ដៃរបស់អភិជនមួយក្រុមតូច។ តំណែងធំៗត្រូវបានទៅរាជវង្សានុវង្ស ឯតំណែងជាបុរោហិត អ្នកប្រារព្ធពិធីនៃទេវរាជ ព្រះរាជគ្រូត្រូវបានទៅសមាជិកត្រកូលព្រាហ្មណ៍ខ្លះដែលនិយមការបន្តតំណែងដោយរាប់ញាតិតាមខ្សែស្រី។

-វណ្ណៈក្សត្រិយ៍និងវណ្ណៈព្រាហ្មណ៍ ជាវណ្ណៈខ្ពស់ស្ថិតដាច់ពីវណ្ណៈរាស្ត្រទូទៅ។ វណ្ណៈកំពូលទាំងពីរនេះច្រើនចងសម្ព័ន្ធមេត្រីជាមួយគ្នា។

-ព្រះរាជាទ្រង់ប្រទានសវនាការ២ដង ក្នុង១ថ្ងៃ សម្រាប់ដោះស្រាយកិច្ចការរដ្ឋ។

-ក្នុងពេលសវនាការពួកនាម៉ឺន ឬពួកប្រជារាស្ត្រអង្គុយផ្ទាល់ដី ពេលដែលព្រះអង្គយាងមកដល់ ទាំងមន្ត្រីទាំងប្រជារាស្ត្រត្រូវលើកដៃប្រណម្យ ហើយឱនក្បាលដល់ដី។

-មន្ត្រីជាន់ខ្ពស់ខ្លះជាទីប្រឹក្សា ខ្លះទទួលបន្ទុកធំៗក្នុងវាំង ឬកាន់ទ័ពឈរជើងនៅតាមខេត្ត។

-មន្ត្រីជាន់ទាបត្រូវបានជ្រើសរើសដោយមន្ត្រីជាន់ខ្ពស់។

-គ្រែស្នែង (មាស ប្រាក់) និងចំនួនក្លស់ (ដងមាស ឬប្រាក់) ជាតំណាងសញ្ញាសក្តិ។

### ង.២. រដ្ឋបាលភូមិភាគ

-មានចៅហ្វាយខេត្ត មេស្រុក មេភូមិ មេឃ្លាំង មេត្រួត។ល។

-ស្រីមានមុខងារសំខាន់ណាស់ដែរ ខ្លះធ្វើជាហោរា ខ្លះទៀតជាចៅក្រមក្នុងរាជវាំង។

## ២.២.៣. សេដ្ឋកិច្ចនិងសិល្បៈស្ថាបត្យកម្ម

-នយោបាយទឹកជាមធ្យោបាយមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យកសិកម្មឱ្យបានលូតលាស់ជាអតិបរមា។ រាស្ត្របានរួបរួមគ្នាយ៉ាងស្មោះស្ម័គ្រកសាងបណ្តាញជលគតិ ទំនប់បារាយណ៍ធំៗជាច្រើនដូចជា:

១. ឥន្ទ្រតដាក (សព្វថ្ងៃហៅថា បារាយណ៍លលៃ) : ៣៨០០ម X ៨០០ម

២. យសោធរតដាក (សព្វថ្ងៃហៅថា ថ្នល់បារាយណ៍) : ៧០០០ម X ១៨០០ម

៣. បារាយណ៍ទឹកថ្លា (ពុំស្គាល់ឈ្មោះសម័យបុរាណ) : ៨០០០ម X ២១០០ម

៤. ជ័យតដាក (សព្វថ្ងៃហៅថា វាលរាជដាក) : ៣៧០០ម X ៩០០ម



«ជប់»ជាប្រភពទឹកចេញនៅភ្នំគូលេន



បារាណ៍ធំៗនៅសម័យអង្គរ



ប្រព័ន្ធផ្លូវទឹកសំខាន់ៗនៅសម័យអង្គរ

តាមលោក Henri Stierlin អ្នកឯកទេសជាតិស្វីស បានគន់គូរឃើញថា លើផ្ទៃដី១០០០ម៉ែត្រក្រឡា នៅតំបន់អង្គរ គេអាចផលិតស្រូវបានក្នុងមួយឆ្នាំ ១៥០.០០០ តោន ដែលអាចចិញ្ចឹមប្រជាជនបានដល់ទៅ៨សែននាក់ ហើយនៅសល់៤០%ទៀតសម្រាប់នាំចេញទៅលក់ខាងក្រៅ។ នេះជាលទ្ធភាពមួយដែលអាចឱ្យប្រជារាស្ត្រចូលរួមក្នុងការកសាងប្រាសាទបាន។

-ក្រៅពីបណ្តាញជលគតិ នៅមានបណ្តាញផ្លូវថ្នល់បូករួមជាមួយផ្លូវទឹក (ធម្មជាតិ ឬជីក) ជាមធ្យោបាយសំខាន់បំផុតខាងផ្នែកពាណិជ្ជកម្ម។ ជំនួញតាមផ្លូវនៅមានសកម្មភាពមមាញឹកដដែល។







ប្រព័ន្ធគមនាគមន៍សម័យអង្គរ

-បណ្តាញផ្លូវធំសំខាន់ៗនៅសម័យបុរាណយ៉ាងហោចណាស់មានចំនួន៦ខ្សែដែលចេញពីយសោធរបុរៈទៅទីឆ្ងាយៗឆ្លងកាត់តាមតំបន់នានាជាច្រើនៈ

១. ពីអង្គរទៅទិសខាងលិច (កាត់ប្រាសាទស្តុកកក់ធំ)
២. ពីអង្គរទៅប្រាសាទភិមាយ( ទិសពាយព្យ)
៣. ពីអង្គរទៅទិសខាងជើង
៤. ពីអង្គរទៅបាកាណកាត់បេងមាលា( ទិសខាងកើត)
៥. ពីបេងមាលាទៅវត្តភូកាត់កោះកេរ្តិ៍ (ទិសឦសាន)
៦. ពីអង្គរទៅសម្បូណ៌ព្រៃគុក (ទិសអាគ្នេយ៍)។

**ផ្នែកសិល្បៈស្ថាបត្យកម្ម គេសង្កេតឃើញមានប្រាសាទ២បែបៈ**

-ប្រាសាទភ្នំសង់លើខឿនច្រើនជាន់សម្រាប់លទ្ធិទេវរាជ (ប្រាសាទបាគង បាខែង បក្សីចាំក្រុង អង្គរវត្ត បាយ័ន កោះកេរ៍...) ។



ប្រាសាទកោះកេរ្តិ៍


ប្រាសាទអង្គរវត្ត


ប្រាសាទបាយ័ន

-ប្រាសាទសង់រាបនឹងដីសម្រាប់លទ្ធិបុគ្គលនិយម (ប្រាសាទព្រះគោ លលៃ បន្ទាយឆ្មារ ព្រះខ័ន តាព្រហ្ម...) ។


ប្រាសាទព្រះគោ


ប្រាសាទលលៃ


ប្រាសាទបន្ទាយឆ្មារ

-ពីស្តេចមួយអង្គទៅស្តេចមួយអង្គ ប្រាសាទកាន់តែធំ ហើយកាន់តែច្រើន។

## ២.៣. អរិយធម៌ខ្មែរសម័យកណ្តាល

អរិយធម៌ខ្មែរដែលឡើងដល់កំពូល ត្រូវដួលរលំនិងបាក់ស្រុតតែម្តង ក្រោយពេលដែលព្រះបាទជ័យវរ្ម័នទី៧ចូលទីវង្គតទៅ។ មូលហេតុជាច្រើនដែលធ្វើឱ្យអរិយធម៌អង្គរធ្លាក់ចុះ៖

-មានប្រតិកម្មពួកសិវនិយមប្រឆាំងពុទ្ធសាសនា (ក្នុងរាជ្យជ័យវរ្ម័នទី៨)។

-បដិវត្តត្រសក់ផ្អែមដែលជាជនជាតិសំរែបានធ្វើគត់ព្រះបាទជ័យវរ្ម័នទី៩(១៣២៧-១៣៣៦) ហើយឡើងសោយរាជ្យ។

-មានសង្គ្រាមជាញឹកញាប់ពីពួកសៀមដែលបានប្លន់ទ្រព្យសម្បត្តិ សម្លាប់មនុស្ស កៀរមនុស្ស ពិសេសបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច កសិកម្ម។

-ខ្វះឯកភាពរវាងអ្នកដឹកនាំនឹងប្រជារាស្ត្រ។

-មានវិបត្តិរាជសម្បត្តិជាបន្តបន្ទាប់ក្នុងរាជ្យស្តេចក្រោយៗទៀត។

### ២.៣.១. ផ្នែកវប្បធម៌

#### ក. ភាសា អក្សរ អក្សរសិល្ប៍

-ចាប់តាំងពីសតវត្សទី១៤ រៀងមក គេពុំឃើញមានសិលាចារឹកទៀតទេ។ លុះដល់រជ្ជកាលព្រះបាទចន្ទរាជា ទើបខ្មែរបានកសាងសិលាចារឹកឡើងវិញ សិលាចារឹកទាំងនោះ គេចារទុកនៅប្រាសាទអង្គរវត្ត៣កន្លែង គឺនៅព្រះពាន់ នៅថ្នាក់លើហៅថាបាកាណ និងនៅព្រះរបៀងថ្នាក់ក្រោម។ សិលាចារឹកមាន៤០ផ្ទាំង មានកាលបរិច្ឆេទពីគ.ស. ១៥៦៥-១៧៤៦។ ភាសាដែលប្រើជាភាសាខ្មែរធម្មតាក្នុងសម័យកណ្តាល ហើយមានពាក្យបុរាណលាយឡំខ្លះដែរ។

-សាស្ត្រាស្លឹករឹតនិងក្រាំងនានា ត្រូវវិនាសបាត់បង់។ បើមាននៅសេសសល់ខ្លះតាមវត្តអារាមក៏គ្មានឈ្មោះអ្នកនិពន្ធដែរ។




សិលាចារឹក



សាស្ត្រាស្លឹករឹតធ្វើពីស្លឹកទ្រាំង



ក្រាំង ជាក្រដាសធ្វើពីដើមមទ និងដើមស្វាយ

#### ខ. ពុទ្ធសាសនានិងលទ្ធិផ្សេងៗ

-គេគោរពពុទ្ធសាសនាហីនយាន ប្រើភាសាបាលីដែលបានចាក់ឫសក្នុងសង្គមខ្មែរយ៉ាងជ្រៅគ្រប់ស្រទាប់ចាប់តាំងពីបដិវត្តនាយត្រសក់ផ្អែមមក។

-នៅក្នុងព្រះបរមរាជវាំង គេឃើញនៅមានពួកបាគូ ដែលមានតួនាទីថែរក្សាព្រះខ័នរាជ្យ ព្រះលំពែងជ័យ និងគ្រឿងបញ្ចក្សត្រ និងរៀបចំពិធីផ្សេងៗតែប៉ុណ្ណោះ។

-ក្នុងពេលនោះវត្តអារាមបានកើនឡើងយ៉ាងច្រើន។ ឋានានុក្រមព្រះសង្ឃមានមេគណ (ទទួលខុសត្រូវតាមខេត្តនីមួយៗ) រាជាគណៈទាំង៤ និងសម្តេចព្រះសង្ឃរាជ។ រាជាគណៈមានថ្នាក់ ឯក ទោ ត្រី ចត្វា ដូចមន្ត្រីជាន់ខ្ពស់ខាងអាណាចក្រដែរ។

- សម្រាប់ឯក ជារាជាគណៈរបស់ក្សត្រទ្រង់រាជ្យ
- សម្រាប់ទោ ជារាជាគណៈរបស់ក្សត្រឧភយោរាជ
- សម្រាប់ត្រី ជារាជាគណៈរបស់សម្តេចព្រះមហាឧបរាជ
- សម្រាប់ចត្វា ជារាជាគណៈរបស់សម្តេចព្រះវររាជជននី

-ព្រះពុទ្ធសាសនាសម័យនោះ មានមុខងារសំខាន់ណាស់ខាងសង្គមកិច្ច (អប់រំ ផ្តល់ចំណេះដឹង...) យុវជនតែងនិយមសាងផ្នួស ពេលលាចាកសិក្ខាបទមកវិញ ទើបអ្នកផងចាត់ទុកជាមនុស្សពេញលក្ខណៈ។






### គ. លទ្ធិបុគ្គលនិយម

លទ្ធិបុគ្គលនិយមដែលកើតមាននៅសម័យអង្គរ បានបន្តរហូតមកដល់សម័យនេះផងដែរ។ តាមប្រភពពង្សាវតារបានឱ្យដឹងថា៖

-ព្រះបាទចន្ទរាជាបានសាងព្រះវិហារមួយនៅក្នុងខេត្តលោវ្វៀ រួចទ្រង់ត្រាស់បង្គាប់ឱ្យសាងព្រះពុទ្ធរូបឈើ ស្នងព្រះអង្គមួយអង្គ កម្ពស់ស្មើព្រះអង្គទ្រង់សណ្ឋិតកណ្តាល ហើយសាងព្រះពុទ្ធរូបឈើមួយអង្គទៀត ស្នងព្រះអគ្គមហេសី ភគវតីស្រីទាវធីតា កម្ពស់ស្មើព្រះអង្គសណ្ឋិតម្ខាង ទ្រង់សាងព្រះពុទ្ធរូបឈើមួយព្រះអង្គទៀត ស្នងសម្តេចព្រះទេវីក្សត្រី ជាព្រះរាជបុត្រីកម្ពស់ស្មើព្រះអង្គសណ្ឋិតម្ខាងទៀត។

-ប្រភពដែលបានបញ្ជាក់ថា ព្រះបរមរាជាទី៤ ទ្រង់ត្រាស់បង្គាប់ឱ្យគេសាងរូបសម្តេចចៅហ្វាដុង១ ជំទាវទេវីនារីសោភ័ណជ័យ១ ដែលត្រូវជាមាតាបិតា សម្តេចព្រះអគ្គមហេសីស្រីទេពធីតាពីថ្មល្អិតល្អ ហើយតម្កល់រូបទាំងពីរនោះក្នុងសាលាមួយទុកឱ្យព្រះអគ្គមហេសីគោរពរៀងមក។

### ឃ. សិល្បៈ

-សិល្បៈមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងព្រះពុទ្ធសាសនា។

-គេសាងព្រះវិហារមានត្រីសូល៍កំពូលប្រាំ ចេតិយតូចធំ ស្តូប។

-គេឆ្លាក់រូបគ្រុឌ នាគ គោក្របី ក្បាច់ភ្ញីផ្កា ភ្ញីវល្លិ៍។ល។



## ២.៣.២. នយោបាយ

### ក. ការគ្រប់គ្រងប្រទេស

-ព្រះរាជាមានលក្ខណៈពិសិដ្ឋពុំមានជនណាល្មើសបានឡើយ ហើយដែលគេនិយមហៅថា **ព្រះសម្មតិទេព**(ទេវតាសន្មត) លក្ខណៈពិសិដ្ឋនេះ គឺបានមកពីពិធីរាជាភិសេកឱ្យឡើងសោយរាជ្យសម្បត្តិ។

-ក្សត្រអង្គណាដែលមិនទាន់បានអភិសេក ហើយគ្រាន់តែបានទទួលរាជសម្បត្តិគ្រប់គ្រងអាណាប្រជានុរាស្ត្រជាបណ្តោះអាសន្នសិនហៅថា «**គ្រងរាជសម្បត្តិ**» ដូចព្រះបាទចៅពញាយ៉ាត។

-ប្រសិនបើអភិសេកក្នុងពេលធ្វើសង្គ្រាមហៅថា «**សង្គ្រាមាភិសេក**»។

-ប្រសិនបើអភិសេកក្រោយដែលបានបង្ក្រាបខ្មាំងសត្រូវឱ្យរាបទាបហៅថា «**ប្រាប្តាភិសេក**»។

-ក្សត្រដែលអាចអភិសេកឡើងសោយរាជ្យពេញលក្ខណៈជាព្រះមហាក្សត្របានលុះត្រាតែមានគ្រឿងសម្រាប់រាជ គឺព្រះខាន់រាជ១ ព្រះលំពែងជ័យ១ និងគ្រឿងព្រះបញ្ចក្សត្រ។ ឯកសារខ្លះគេបញ្ចូលព្រះខាន់រាជ ឬព្រះខាន់ជ័យនេះទៅក្នុងគឿងបញ្ចក្សត្រវិញ ដែលគេហៅថា «បញ្ចកកុធភ័ណ្ឌ ឬរាជកកុធភ័ណ្ឌ» គឺ៖

១.ព្រះមកុដ

២.ព្រះវាលវីជនី(ផ្លិតធ្វើពីរោមសត្វពណ៌ស)

៣.ព្រះខាន់

៤.ព្រះស្វេតច្ឆត្រ

៥.ព្រះសុវណ្ណបាទុកា(ស្បែកជើងមាស)



-ដោយសារព្រះរាជពិធីអភិសេកនេះ ព្រះរាជាក៏បានក្លាយទៅជា «**មេសាសនា**» មានសិទ្ធិជ្រើសរើសមន្ត្រីសង្ឃនិងដកសក្តិមន្ត្រីសង្ឃ។

-ព្រះរាជាមានឋានៈជាម្ចាស់ជីវិតលើត្បូង មានសិទ្ធិឱ្យស្លាប់ឱ្យរស់លើសព្វសត្វនៅលើផែនដី បានសេចក្តីថា ព្រះអង្គជាចៅក្រមម្នាក់អាចវិនិច្ឆ័យទោសកំហុសជាយថាហេតុ ប៉ុន្តែត្រូវប្រកបដោយទសពិធរាជធម៌។

-ក្រៅពីអគ្គមហេសីព្រះរាជានៅមានស្រីស្នំស្រីង្គារជាច្រើន ដែលមានងារពីទាបទៅខ្ពស់ដូចជា៖

- អ្នកនាង
- អ្នកម្នាង
- ព្រះម៉ែម្នាង
- ព្រះម្នាង

ពេលសោយទីវង្គតទៅ គេតែងលើកព្រះសពតម្កល់ក្នុងកោដ្ឋ ធ្វើបុណ្យថ្វាយព្រះភ្លើង រួចយកបរមអដ្ឋិធាតុទៅបញ្ចុះក្នុងចេតិយ ដែលច្រើនតែសាងនៅលើភ្នំ ដូចជាភ្នំដូនពេញ (ចេតិយព្រះបរមរាជាទី២ ចៅពញាយ៉ាត) ភ្នំព្រះរាជទ្រព្យ ចេតិយព្រះចន្ទរាជា។ល។

**ខ. ឋានៈក្នុងព្រះរាជវង្សានុវង្សនិងពួកបរិវារ**

-**ឧភយោរាជ** : ក្សត្រដាក់រាជ្យឲ្យអង្គណាមួយសោយរាជ្យតំណាងព្រះអង្គ ទទួលសក្តិជាស្តេចកណ្តាល ជួយរំឭកក្សត្រទ្រង់រាជ្យនិងក្សត្រឧបរាជទាំងពីរអង្គឱ្យស្ថិតនៅក្នុងទសពិធរាជធម៌។

-**ឧបរាជ ឬមហាឧបរាជ** : ជ្រើសរើសក្នុងចំណោមបុត្រច្បង ឬអនុជក្សត្រទ្រង់រាជ្យដែលមានគុណវុឌ្ឍិដ៏ខ្ពង់ខ្ពស់។

-**ចៅហ្វាទឡ្ហៈ**: មានឋានៈស្មើនឹងនាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រីទី១។ បន្ទាប់មកគេឃើញមានមន្ត្រីជាន់ខ្ពស់ ៤រូប ដែលហៅថា **ចតុស្តម្ភ**:

១. ឧកញ៉ាក្រឡាហោម (រដ្ឋមន្ត្រីក្រសួងទ័ពជើងទឹក)

២. ឧកញ៉ារាជវាំង (រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង)

៣. ឧកញ៉ាយមរាជ (រដ្ឋមន្ត្រីក្រសួងយុត្តិធម៌)

៤. ឧកញ៉ាចក្រី (រដ្ឋមន្ត្រីខាងទ័ពជើងគោក)។

-**មហាតលិក** : ជាមន្ត្រីដែលមានមុខងារគាល់បម្រើព្រះរាជា។

-**ហោរា** : មានមុខងារសំខាន់ណាស់ដែរ តាំងពីព្រះរាជារហូតដល់ប្រជារាស្ត្រសុទ្ធតែមានជំនឿលើការទស្សន៍ទាយ។ មុននឹងលើករាជធានីពីទួលបាសានមកភ្នំពេញព្រះបរមរាជាទី២ ចៅពញាយ៉ាតទ្រង់បានបញ្ជាឧកញ៉ាហោរាធិបតីខៀវនិងមន្ត្រីឯទៀតឱ្យមកពិនិត្យមើលកន្លែងតាមក្បួនហោរាសិន។

-**ចៅជិត**: ពួកស្ត្រីជាព្រះរាជបរិវារ មានមុខងារក្រាបបង្គំគាល់បម្រើជិតស្និទ្ធក្នុងព្រះរាជត្រកូល។

-ទៅចម: ពួកស្ត្រីជារាស្ត្រសាមញ្ញ ដែលគេថ្វាយឱ្យធ្វើជាមហេសីស្តេច បានដល់ពួកស្ត្រីស្នំស្រីង្គារនេះឯង។

**គ. ការបន្តរាជសម្បត្តិ**

-ព្រះរាជសម្បត្តិត្រូវបានបន្តពីបិតាក្សត្រទ្រង់រាជ្យទៅបុត្រច្បង បើបុត្រច្បងត្រូវសុគតមុនសោយរាជ្យ គឺបុត្របន្ទាប់មានសិទ្ធិសោយរាជ្យស្នងព្រះបិតា។

-ក្នុងករណីក្សត្រទ្រង់រាជ្យពុំមានបុត្រសោយរាជ្យស្នងទេ សិទ្ធិនេះត្រូវបានទៅព្រះអនុជជាបន្តបន្ទាប់គ្នា។

**ឃ. នយោបាយក្នុងប្រទេស**

-មានវិបត្តិក្នុងរាជវង្ស ជាញឹកញាប់ ជាហេតុបណ្តាលឲ្យមានចម្បាំងគ្នាឯងក្នុងស្រុក។

ឧទាហរណ៍: ចម្បាំងរវាងស្រីរាជា ស្រីសុរិយោទ័យ និងធម្មរាជា អស់រយៈពេល ១០ឆ្នាំ (១៤៧៥-១៤៨៥) និងចម្បាំងស្រីសុគន្ធបទ ស្តេចកន និងចន្ទរាជា (១៥០៩-១៥១២និង១៥១៦-១៥២៥)។

-ចម្បាំងទាំងនេះនាំឱ្យមានការគិតប្រយោជន៍ផ្ទាល់ខ្លួនច្រើនជាងប្រយោជន៍រួម (ដណ្តើមរាជសម្បត្តិគ្នា)។ អ្នកដឹកនាំជាតិមិននិយមការដោះស្រាយដោយសម្របសម្រួលគ្នាទេ បែរជាសុខចិត្តទៅពឹងពាក់ឱ្យបរទេសជិតខាងចូលមកផ្សះផ្សារវិវាទផ្ទៃក្នុងរបស់ខ្មែរទៅវិញ។

**ង. នយោបាយក្រៅប្រទេស**

នៅគ្រានោះខ្មែរមិនទាន់មានកង្វល់នៅព្រំដែនខាងកើតនៅឡើយទេ ព្រោះប្រទេសចម្ប៉ាកំពុងតែជាប់ធ្វើចម្បាំងជាមួយពួកយួន ង្វៀង ការពារទឹកដីរបស់ខ្លួន។

-តែព្រំដែនខាងលិច ព្រះរាជាខ្មែរបានព្យាយាម វាយរំដោះយកទឹកដីដែលត្រូវបាត់បង់ទៅ តាំងពី ស.វ.ទី១៣ មកវិញ។ គឺក្នុងគោលបំណងនេះហើយ ដែលព្រះស្រីរាជា ព្រះចន្ទរាជា ព្រះបរមរាជាទី៤ ព្រះសត្ថាទី១ បានលើកទ័ពទៅវាយលុករហូតដល់រាជធានីស្រីអយុធ្យា ហើយរំដោះយកបានទឹកដីមកវិញច្រើនមែន(ពេលនោះសៀមកំពុងជាប់ដៃច្បាំងជាមួយភូមា)។ ក្រោយមក សៀមបានលើកទ័ពចូលមកវាយខ្មែរញឹកញាប់។ ព្រះសត្ថាទី១ បានងាកទៅរកជំនួយពីពួកព័រទុយហ្គាល់ ហើយក្រោយមកពីពួកអេស្ប៉ាញទៀត។ ព្រះអង្គទ្រង់បានយកចិត្តអ្នកផ្សាយសាសនាអឺរ៉ុបយ៉ាងខ្លាំង ដើម្បីឱ្យពួកនេះជួយធ្វើអន្តរាគមន៍ សុំជំនួយទ័ពមកប្រឆាំងនឹងសៀម តែពុំបានសម្រេច។

**២.៣.៣. រដ្ឋបាល**

តាមពង្សាវតារអាណាចក្រខ្មែរសម័យនោះមានប្រមាណជា ៧០ខេត្តគឺ : ខេត្តលង្វែក អម្រិន្ទបូរក្រគរ គ្រង ពោធិសាត់ បាត់ដំបង ឫស្សីសាញ កាមសីមា មង្គលបុរី រយ៉ង សុរិន្ទ សង្គារ កំពង់សៀមស្ទឹងត្រែង ជើងព្រៃ គោកសេះ អន្លង់រាជ ព្រំទេព ព្រៃក្តី ស្ទោង ជីក្រែង រលួស សៀមរាប កំពង់ស្វាយម្លូព្រៃ ជាំក្សាន្ត ត្នោត ទឹកជោរ សៀមបូក សម្បុកសម្បូណ៌ ក្រចេះ ឆ្លូង ត្បូង បាសាន ទទឹងថ្ងៃ ព្រៃវែងត្បូងឃ្មុំ បាភ្នំ រំដួល ស្វាយទាប រោងដំរី ព្រៃនគរ លង់ហោរ ជើងបាដែង សំរោងទង បាទី លើកដែក

ទ្រាំង បន្ទាយមាស ថ្លង បាសាក់ បារៀ (បារា) ពាម កោះស្លាកែត កំពត កំពង់សោម ទឹកខ្មៅ ណាមមេសរ ព្រះត្រពាំង ក្រមួនស ដូនណៃ។ល។

ក្នុងចំណោមខេត្តទាំងនោះ ខេត្តខ្លះនៅឋានៈជាខេត្ត ខេត្តខ្លះទៅជាស្រុករហូតមកដល់សព្វថ្ងៃនេះ។ ខេត្តនីមួយៗចែកជាស្រុក ភូមិ...។ ប៉ុន្តែខេត្តជាច្រើនត្រូវបានប្រមូលផ្តុំជាតំបន់ធំៗ ដែលគេឱ្យឈ្មោះហៅថា «**ដី**»។

**ក. រដ្ឋបាលកណ្តាល**

ព្រះរាជាជាប្រភពនៃអំណាចពួករាជវង្សនិងមន្ត្រីជាន់ខ្ពស់ ជាអ្នកធ្វើឱ្យម៉ាស៊ីនរដ្ឋបាលកណ្តាលដើរ។ ក្រៅពីមន្ត្រីជាន់ខ្ពស់មានមន្ត្រីថ្នាក់កណ្តាល និងមន្ត្រីជាន់ទាបជាច្រើនទៀតដែលមានឋានន្តរសក្តិដូចតទៅ៖

១. ព្រះ............សក្តិ៦ហ៊ូពាន់
២. ហ្លួង...........សក្តិ៥ហ៊ូពាន់
៣. ឃុននាម៉ឺន...សក្តិ៤ហ៊ូពាន់
៤. ឧកម៉ឺន........សក្តិ៣ហ៊ូពាន់
៥. ចៈម៉ឺន.........សក្តិ២ហ៊ូពាន់
៦. ម៉ឺន.............សក្តិ១ហ៊ូពាន់

ចំណែកខ្ញុំរាជការដែលមិនទាន់បានទទួលយសសក្តិហៅថា «**នាយ**»។

**ខ. រដ្ឋបាលភូមិភាគ**

-ក្នុងចំនួនខេត្តទាំង៧០នោះ គេប្រមូលផ្តុំជាតំបន់(ដី) តំបន់នីមួយៗ មានស្តេចក្រាញ់មួយអង្គឈរត្រួតត្រា។ ស្តេចក្រាញ់មួយអង្គៗ មាននាទីគ្រប់គ្រងតំបន់របស់ខ្លួនផង ហើយមាននាទីគ្រប់គ្រងខេត្តរបស់ខ្លួនផ្ទាល់ផង។ ក្នុងរជ្ជកាលព្រះបាទធម្មរាជាទី១មានការតែងតាំងស្តេចក្រាញ់៥អង្គគឺ៖

| | |
|---|---|
| ១. ពញាតេជោ | ចៅហ្វាយស្រុក ខេត្តកំពង់ស្វាយ១ |
| ២. ពញាសួគ៌ាលោក | ចៅហ្វាយស្រុក ខេត្តពោធិសាត់១ |
| ៣. ពញាស្រីធម្មាតេជោ | ចៅហ្វាយស្រុក ខេត្តបាភ្នំ១ |
| ៤. ពញាពិស្ណុលោក | ចៅហ្វាយស្រុក ខេត្តទ្រាំង១ |
| ៥. ពញាអរជូន | ចៅហ្វាយស្រុក ខេត្តត្បូងឃ្មុំ១។ |

-មន្ត្រីនេះគេនិយមហៅថា **ចៅហ្វាយស្រុក** ឧទាហរណ៍ មន្ត្រីឈរត្រួតខេត្តទ្រាំង គេហៅថា ចៅហ្វាយស្រុកខេត្តទ្រាំង។

-ចៅហ្វាយស្រុក(ប្រធានតំបន់) សុទ្ធតែមានសក្តិ១០ ឬ៩ ហ៊ូពាន់។

## ២.៣.៤. កងទ័ព

មានកងទ័ពជើងគោកនិងជើងទឹក។ កងទ័ពជើងគោកស្ថិតនៅក្រោមអំណាចឧកញ៉ាចក្រី ចែកជា៤ពួក គឺពួកទ័ពដំរី ពួកទ័ពសេះ ពួកទ័ពរថ ពួកទ័ពថ្មើរជើង។

កងទ័ពជើងទឹក ស្ថិតនៅក្រោមបញ្ជាការឧកញ៉ាក្រឡាហោម។ ទ័ពជើងគោកក្ដី ទ័ពជើងទឹកក្ដី គេចែកពីទាបទៅខ្ពស់ដូចខាងក្រោម៖

-ពួក: ជាកងឯកភាពតូចបំផុតនៃកងទ័ព មានមេពួកម្នាក់។

-ក្រុម: មានមេ ឬនាយក្រុមម្នាក់ជាអ្នកគ្រប់គ្រង។

-កងរយ: មានទាហាន១៥០នាក់ (អនុសេនាធំ) មានមេបង្គាប់ម្នាក់ជាអ្នកគ្រប់គ្រង។

-កងពាន់: មានទាហាន១០០០នាក់ មានមេបង្គាប់ម្នាក់ជាអ្នកគ្រប់គ្រង។

-កងទ័ពតូច ឬកងពល: មានទាហាន១០០០០នាក់ មានមេបញ្ជាការកងពលម្នាក់ជាអ្នកគ្រប់គ្រង។

-កងទ័ពធំ ឬកងទ័ពហ្លួង: មានទាហាន១សែននាក់ មានមេបញ្ជាការម្នាក់ជាអ្នកត្រួតត្រា។

**<u>ការរៀបចំទ័ពពេលធ្វើចម្បាំង</u>**

| | | |
|---|---|---|
| | ទ័ពមុខ ២០០០០នាក់ | |
| ទ័ពឆ្វេង | ទ័ពហ្លួង | ទ័ពស្ដាំ |
| ១០០០០នាក់ | ៤០០០០នាក់ | ១០០០០នាក់ |
| | ទ័ពក្រោយ | |
| | ១០០០០នាក់ | |

*ក្រៅពីនេះមានទ័ពបង្កប់ប្រហែល ៥០០០នាក់ទៀត។

## ២.៣.៥. ជីវភាពសង្គម

### ក. ការរស់នៅនិងសេដ្ឋកិច្ច

ជាទូទៅប្រជារាស្ត្របង់ពន្ធជូនរាជការ ប៉ុន្តែក្នុងករណីខ្លះ ព្រះរាជាលើកលែងមិនយកពន្ធបាន។

ឧទាហរណ៍១: ស្ដេចកនពេលច្បាំងឈ្នះព្រះស្រីសុគន្ធបទ ហើយឡើងសោយរាជ្យបានលើកពន្ធឱ្យប្រជារាស្ត្រ១ឆ្នាំ។

ឧទាហរណ៍២: ព្រះធម្មរាជា ទ្រង់បានបញ្ជាឱ្យលើកលែងពន្ធរាជការខ្លួន និងពន្ធព្រះរាជធានីអស់រយៈពេល៣ឆ្នាំ។




កាក់ប្រាក់ខ្លះដែលឃើញមានក្នុងស្រុកខ្មែរសម័យកណ្ដាល និងកាំភ្លើងបុរាណ(វត្តរាំងចាស់ ស្រុកឧដុង្គ)

-ប្រជារាស្ត្រតែងតែកែនឱ្យបំពេញភារកិច្ចធំៗដូចជា លើកផ្លូវ សង់ស្ពាន ជីកព្រែក ជីកអូរ លើកទំនប់។ល។ សម្រាប់បម្រើផលប្រយោជន៍រួមនិងកិច្ចការខ្លះទៀតសម្រាប់បម្រើផលប្រយោជន៍ព្រះរាជា។

-យុវជនក្នុងព្រះរាជាណាចក្រ ត្រូវជាប់កំណែនជាទាហានក្រៅពីកំណែនឯទៀត។

-រាស្ត្រត្រូវប្រមូលទ្រព្យសម្បត្តិ ស្បៀងអាហារផ្គត់ផ្គង់ឱ្យកងទ័ពថែមទៀតពេលមានចម្បាំង។

**ខ. កសិកម្ម**

កសិកម្មទំនងជាសកម្មភាពសំខាន់ជាងគេ ព្រោះអ្នកដឹកនាំជាតិតែងតែយកចិត្តទុកដាក់លើបញ្ហាទឹកណាស់។ ក្នុងការកសាងរាជធានី ស្តេចតែងគិតដល់ដីធ្លីសម្រាប់ឱ្យរាស្ត្រធ្វើស្រែ ចម្ការ ព្រមទាំងជីកព្រែក អូរ សម្រាប់យកទឹកផ្គត់ផ្គង់កសិកម្ម។ ពេលធ្វើចម្បាំងគ្នាឯងក្នុងស្រុក កាលណាដល់រដូវវស្សាតែងស្រុះស្រួលគ្នាដើម្បីរំសាយទ័ព ផ្អាកសង្គ្រាមឱ្យទាហានទៅធ្វើស្រែ។

**គ. ពាណិជ្ជកម្ម**

-ភ្នំពេញជាកំពង់ផែមួយយ៉ាងសំខាន់ដែលមានឈ្មួញបរទេសចេញចូល លក់ដូរតាំងពីរជ្ជកាលព្រះពញាយ៉ាតម្ល៉េះ។

-ចម្បាំងរវាងស្តេចកននិងព្រះចន្ទរាជា គេឃើញមេដឹកនាំទាំងសងខាងសុទ្ធតែបានបញ្ជេញឱ្យដឹកទំនិញយកទៅលក់ឯបរទេស ហើយទិញយកគ្រឿងសាស្ត្រាវុធមកវិញ។

**ឃ. សិប្បកម្មនិងឧស្សាហកម្ម**

ឧស្សាហកម្មសំខាន់ជាងគេ ប្រហែលជាការស្លដែក។ ឧស្សាហកម្មនេះមានទំនុកបម្រុងពីព្រះរាជា។ ផ្នែកសិប្បកម្មក៏មានសកម្មភាពខ្លាំងដែរក្នុងការត្បាញរវៃ។

**ង. ថ្នាក់សង្គម**

ក្នុងសង្គមឥណ្ឌាមានវណ្ណៈ៤គឺព្រាហ្មណៈ ក្សត្រិយៈ វៃស្សៈ និងសូទ្រៈ។ ឯខ្មែរយើងវិញពុំមានចែកជាវណ្ណៈទេ គឺគេចែកជាថ្នាក់ទៅវិញ។ ថ្នាក់ទាំងអស់មាន៥គឺ រាជវង្សានុវង្ស ពួកមន្ត្រី ពួកបុព្វជិត ពួកអ្នកជា និងពួកខ្ញុំ។

## ២.៤. អរិយធម៌ខ្មែរសម័យទំនើប

ចាប់ពីរវាងពាក់កណ្តាលសតវត្សទី១៩មក ស្រុកខ្មែរឈានមកដល់ដំណាក់កាលថ្មីមួយទៀត។ អ្វីៗមួយចំនួនមានការប្រែប្រួលខ្លះ ទាំងការគ្រប់គ្រង ទាំងច្បាប់ទម្លាប់ របៀបរបបរស់នៅ និងសម្ភារៈផ្សេងៗ។ ប៉ុន្តែអ្វីៗនៅសម័យទំនើបនេះជាអរិយធម៌មួយដែលបន្តមរតកពីសម័យកណ្តាល ដែលមានមូលដ្ឋានមកពីសម័យបុរាណហើយបូកផ្សំនឹងរបៀបរបបអឺរ៉ុបខ្លះៗដែរ។ យើងចែកអរិយធម៌ខ្មែរសម័យទំនើបជាពីរដំណាក់កាលគឺ សម័យអាណាព្យាបាលបារាំង (សម័យបារាំង) និងសម័យឯករាជ្យដល់បច្ចុប្បន្ន។

### ២.៤.១. អរិយធម៌ខ្មែរសម័យអាណាព្យាបាលបារាំង

នៅជិតពាក់កណ្ដាលសតវត្សទី១៩ ស្រុកខ្មែរមានវិបត្តិភ័យនឹងស្រុកជិតខាងដែលមានអំណាចលើខ្មែរ ទើបព្រះអង្គឌួង (១៨៤០-១៨៥៩) ទំនាក់ទំនងចងមិត្តជាមួយបារាំង ដើម្បីឱ្យបារាំងជួយការពារអំណាចខ្មែរ កុំឱ្យសៀមនិងយួនដែលចេះតែគ្របសង្កត់មកលើខ្មែរ។

លុះមកដល់រាជ្យព្រះបាទ នរោត្តម បារាំងបែរជាដាក់ស្រុកខ្មែរឱ្យស្ថិតក្រោមការត្រួតត្រារបស់ខ្លួនចាប់ពីថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ តទៅ។ កាលណោះ រាជធានីតាំងនៅឧត្តុង្គនៅឡើយ។

នៅក្នុងរាជ្យព្រះបាទ នរោត្តម (សោយរាជ្យ ឆ្នាំ១៨៥៩-១៩០៤) បានដូររាជធានីពីឧត្តុង្គមកភ្នំពេញឡើងវិញ ពោលគឺវាំងចុងសតវត្សទី១៩ ហើយតាំងនៅរហូតលុះដល់បច្ចុប្បន្ននេះ។

ពីមុនមកច្រើនតែប្រុសៗប៉ុណ្ណោះបានរៀនសូត្រតាមរយៈវត្តអារាម ពោលគឺបួសរៀន។ នៅសម័យបារាំង គេបង្កើតឱ្យមានសាលាទំនើប ដែលមានកម្មវិធីសិក្សាតាមរបៀបបារាំង ហើយរៀនជាភាសាបារាំងថែមទៀត។ ឯសាលាវត្តក៏នៅតែបន្តតាមរបៀបប្រពៃណីដដែល។

សំណេរពីមុនមានតែនៅលើសាស្ត្រាស្លឹករឹតនិងក្រាំង ដែលជាក្បួន ច្បាប់ ធម៌អាថ៌ ព្រះរាជពង្សាវតារ និងរឿងផ្សេងៗជាដើម។ មកដល់ឆ្នាំ១៩០៨ ទើបមានបោះពុម្ពជាសៀវភៅ (បណ្ដាំតាមាស) ជាភាសាខ្មែរលើកដំបូងនៅភ្នំពេញ។ ប៉ុន្តែជំនាន់នោះ ខ្មែរមិនសូវទទួលស្គាល់សៀវភៅបោះពុម្ពទេ គេឱ្យតម្លៃតែសំណេរបែបបុរាណ ដូច្នេះគេនៅតែមានចារសាស្ត្រាស្លឹករឹតនិងក្រាំងជារហូតមក។

រូបរាងអក្សរខ្មែរសម័យទំនើបមានពីរបែប គឺអក្សរមូលនិងអក្សរជ្រៀង។ អក្សរមូលច្រើនប្រើសម្រាប់ចារឬសរសេរអំពីធម៌អាថ៌ យ័ន្ត គាថា ក្បួន ច្បាប់ផ្សេងៗ។ រីឯអក្សរជ្រៀងច្រើនប្រើសម្រាប់ចារឬសរសេរអត្ថបទធម្មតាផង ហើយជួនកាលប្រើសម្រាប់ចារធម៌អាថ៌ ឬក្បួនច្បាប់ដែរ។ អក្សរសាស្ត្របែបទំនើបវិញ គឺមានរឿងផ្សេងៗនិងសារព័ត៌មានជាដើម។ រឿងវែងៗ ហើយមានលាយឡំដោយជំនឿនិងសាសនាផង ពីមុនគេហៅថា «សាស្ត្រាល្បែង ឬរឿងល្បែង» តែរឿងសម័យថ្មីដែលនិយាយអំពីជីវិតពិត ធម្មតាគេហៅថា «ប្រលោមលោក»។ ប្រលោមលោកខ្មែរទី១ ប្រហែលរឿង «សូផាត» តែងដោយលោក រីម គិន ឆ្នាំ១៩៣៨ ឬមួយរឿងទៀត «ទឹកទន្លេសាប» តែងដោយលោក គឹម ហាក់ ឆ្នាំ១៩៣៩។

ចុងសតវត្សទី១៩ និងដើមសតវត្សទី២០ ពិតមែនតែសង្គមខ្មែរ មានឥទ្ធិពលខ្លះពីបារាំងក៏ដោយ ក៏អ្នកស្រុកទូទៅទំនងជានៅមានលក្ខណៈជាខ្មែរបែបសម័យកណ្ដាលច្រើន ពិសេសរបៀបរបបរស់នៅ ស្លៀកពាក់ វត្ថុប្រើប្រាស់ ភាសានិយាយស្ដី ទំនៀមទម្លាប់ផ្សេងៗជាដើម។ លើកលែងតែអ្នកមាន ឬមន្ត្រីនៅតាមក្រុងខ្លះប៉ុណ្ណោះ។

ចាប់ពីវាំងពាក់កណ្ដាលសតវត្សទី២០មក សង្គមខ្មែរឈានដល់របៀបថ្មីមួយទៀត ដែលហៅថា «ទំនើប» ឬ «សម័យ» ទាំងរបៀបរស់នៅ សម្ភារៈប្រើប្រាស់ ការស្លៀកពាក់ របៀបតុបតែងខ្លួន ការគួរសមគ្នា ...ដែលកាលណោះមានអ្នកខ្លះយល់ថា ឆ្គងភ្នែក គួរឱ្យជិនឆ្អន់ ហើយក៏មានអ្នកខ្លះចូលចិត្តបែបបទថ្មីដែរ។ លុះយូរៗទៅទើបស៊ាំភ្នែក លែងសូវមានអ្នករិះគន់ខ្លាំង។

## ២.៤.២. អរិយធម៌ខ្មែរសម័យឯករាជ្យដល់បច្ចុប្បន្ន

នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ បារាំងចូលមកត្រួតស្រុកខ្មែររហូតដល់ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ ទើបខ្មែរទទួលបានឯករាជ្យឡើងវិញក្នុងរាជ្យព្រះបាទ នរោត្តម សីហនុ។ ដូច្នេះ ក្នុងរយៈកាល ៩០ឆ្នាំ ឆ្លងកាត់៤រាជ្យស្តេចដែលខ្មែរស្ថិតក្រោមអាណាព្យាបាលបារាំង។ លុះបានឯករាជ្យជាផ្លូវការ ចាប់ពីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ មក ខ្មែរត្រូវពឹងលើខ្លួនឯងផ្ទាល់ ដើម្បីគ្រប់គ្រងប្រទេស និងត្រូវ ប្រឈមមុខជាមួយអ្វីៗដែលជាមនោគមវិជ្ជារបស់ប្រទេសធំៗក្នុងលោក នាសម័យកាលនោះ។ តែអ្វី ដែលសំខាន់បំផុត គឺការរៀបចំនិងកសាងស្រុកទេសឱ្យមានអ្វីៗដូចប្រទេសនានាទាំងឡាយដែរ។ នៅ ឆ្នាំ១៩៥៥ ព្រះករុណា នរោត្តម សីហនុ ដាក់រាជ្យថ្វាយទៅព្រះបិតា គឺព្រះករុណា នរោត្តម សុរាម្រិត។ ព្រះករុណា សីហនុ យាងចេញធ្វើនយោបាយ និងឡើងជាព្រះប្រមុខរដ្ឋ ហើយព្រះអង្គមានគោល ការណ៍មួយ ហៅថា «សង្គមរាស្ត្រនិយម» គឺខិតខំកសាងប្រទេសឱ្យលូតលាស់ដោយរៀបចំគ្រប់វិស័យ ទាំងអស់តពីមុន។

ការរៀបចំក្រុង គឺពង្រីកហេដ្ឋារចនាសម្ព័ន្ធក្រុងឱ្យទូលំទូលាយជាងអ្វីដែលជំនាន់បារាំងបាន ធ្វើ។ ក្នុងគោលការណ៍របស់រដ្ឋ គឺកសាងអគារសម្រាប់រាជការ និងផ្ទះធំៗ ផ្លូវថ្នល់ ស្ពាន កំពង់ផែ ផ្សារ សួនច្បារ កីឡាដ្ឋាន រោងមហោស្រព សាលារៀន សាកលវិទ្យាល័យ មន្ទីរពេទ្យ។ល។

ប្រព័ន្ធគមនាគមន៍ដែលមានស្រាប់ពីសម័យមុន គេកសាងបន្ថែមផ្លូវថ្នល់ចាក់កៅស៊ូ ស្ពាន ផ្លូវចាក់ក្រួស កំពង់ផែភ្នំពេញ កំពង់ផែកំពង់សោម ព្រលានយន្តហោះ ប្រព័ន្ធផ្លូវរទេះភ្លើង។ល។ រោងចក្រមួយចំនួន បានបង្កើតឡើង ហើយគ្រប់គ្រងដោយរដ្ឋ មានរោងចក្រតម្បាញ រោងចក្រក្រដាស រោងចក្រកែវ រោងចក្រផលិតស្ករ រោងចក្រក្រដាស រោងចក្រកៅស៊ូក្រែប រោងចក្រស៊ីម៉ង់ត៍ រោងចក្រ កៅស៊ូកង់ រោងចក្រតម្លើងគ្រឿងយន្តជាដើម។

សាលារៀនពីមុនច្រើននៅតាមវត្តដែលភ្ជាប់ជាមួយសាសនា និងសាលាខ្លះបង្កើតដោយបារាំង នោះ ឥឡូវរដ្ឋបង្កើតសាលាច្រើននៅតាមគ្រប់ក្រុង ខេត្ត ស្រុក...។ រីឯសាកលវិទ្យាល័យបង្កើតនៅតាម ក្រុងនិងខេត្ត ហើយមានគ្រប់វិស័យ ទាំងកសិកម្ម ឧស្សាហកម្ម សុខាភិបាល បច្ចេកវិទ្យា ច្បាប់ សិល្បៈ សេដ្ឋកិច្ច សង្គមសាស្ត្រ មនុស្សសាស្ត្រ។ល។

# មេរៀនទី៣ ប្រវត្តិនិងឥទ្ធិពលសាសនានៅក្នុងសង្គមខ្មែរ

## ១. ប្រភពជំនឿសាសនា

ដោយប្រើគំនិតប្រាជ្ញាផ្ទាល់ខ្លួននោះ មនុស្សតែងតែគិតថា នឹងមានថាមពលអាថ៌កំបាំងពីខាងក្រៅអាចជួយខ្លួនបាន។ ដូចនេះ គេតែងធ្វើការបន់ស្រន់បួងសួងសូមឱ្យវត្ថុស័ក្តិសិទ្ធិនោះ ជួយខ្លួនឱ្យសម្រេចបំណងប្រាថ្នារបស់ខ្លួន។

ដោយឡែកជនជាតិខ្មែរយើងតាំពីបុរេប្រវត្តិសាស្រ្តមក ក៏តែងតែមានជំនឿបែបនេះដែរ។ ដើម្បីដោះស្រាយបញ្ហាចំពោះមុខ គេគោរពកម្លាំងធម្មជាតិដោយបង្កើតឱ្យមានរូបតំណាងវត្ថុស័ក្តិសិទ្ធិ ដែលគេពុំអាចមើលឃើញ។ **ឧទាហរណ៍:** គេយកដុំថ្មមកតាំងជារូបអ្នកតា ហើយនាំគ្នាគោរពបូជាដូចជាអ្នកតាទឹក អ្នកតាភ្លើង អ្នកតាខ្យល់ អ្នកតាភ្នំ។ ក្រៅពីអ្នកតាតំណាងឱ្យធម្មជាតិ គេបានបង្កើតអ្នកតាតំណាងបុព្វការីជន ជីដូន ជីតា មេបា ដែលបានលាចាកលោកទៅហើយ ហើយព្រលឹងអ្នកទាំងនោះកំពុងនៅថែរក្សា និងផ្តល់សេចក្តីសុខដល់មនុស្សទូទៅដូចជា: អ្នកតាដំបងដែក អ្នកតាក្រហមក អ្នកដូនជំទាវម៉ៅ។ល។ គួរកត់សម្គាល់ថា សាសនា «**អ្នកតានិយម**» បែបនេះមិនសូវមានការលូតលាស់ទេ ព្រោះពុំមានគម្ពីរក្បួនខ្នាតកត់ត្រានូវទស្សនៈ ឬទ្រឹស្តី ដូចសាសនាផ្សេងៗឡើយ។ តែទោះបីមិនមានការលូតលាស់ក្តីក៏សាសនាប្រភេទនេះតែងតែស្ថិតក្នុងគំនិត ក្នុងទំនៀមទម្លាប់ខ្មែររហូតដល់ពេលបច្ចុប្បន្ន។ ម្យ៉ាងទៀត ដោយសារតែសាសនាប្រភេទនេះ គ្មានលក្ខណៈជឿនលឿ គ្មានទ្រឹស្តីសម្រាប់ទ្រទ្រង់ ទើបក្រោយមក ពិសេសនៅដើមគ្រិស្តសករាជ ខ្មែរយើងចាប់ផ្តើមទទួលយកឥទ្ធិពលសាសនាធំៗពីរយ៉ាងងាយ គឺព្រហ្មញ្ញសាសនានិងពុទ្ធសាសនា ហើយខ្មែរយើងជឿនិងគោរពរហូតដល់សព្វថ្ងៃ។

### ១.១. និយមន័យសាសនា

**សាសនា :** គឺជាពាក្យក្លាយមកពីសាសនៈ បានន័យថា ពាក្យបណ្តាំ ពាក្យប្រៀនប្រដៅ ការប្រៀនប្រដៅ ពាក្យបង្គាប់ ពាក្យបង្គាប់បញ្ជា។[8] សាសនាអាចពន្យល់ថា: សាសនាក្លាយមកពីពាក្យសាសនៈ បានន័យថា ពាក្យបណ្តាំ ឬការទូន្មានប្រៀនប្រដៅរបស់គ្រូអាចារ្យណាមួយក្នុងលោក។ អត្ថន័យនៃពាក្យសាសនា ឬលទ្ធិសាសនាពុំមែនស្ថិតនៅលើជំនឿ ឬបញ្ញត្តិ សីលធម៌ និងការគោរពប្រត្តិបត្តិប៉ុណ្ណោះទេ គឺត្រូវមានអង្គពិសេសមួយសម្រាប់ទ្រទ្រង់ថែរក្សាលទ្ធិសាសនាឱ្យមានស្ថិរភាពតាំងនៅជាស្ថាពរវែងឆ្ងាយទៀត។

ដូចនេះ សាសនាមានន័យថា ពាក្យបណ្តាំទូន្មានប្រៀនប្រដៅប្រកាសប្រាប់និងឱ្យដំណឹងរបស់គ្រូអាចារ្យណាមួយក្នុងលោកដើម្បីធ្វើខ្លួនឱ្យក្លាយទៅជាមនុស្សល្អ ធ្វើឱ្យសង្គមមានសន្តិភាពរីកចម្រើនរុងរឿងនាលោកិយ។ ឯមុខងារនៃសាសនាទាំងអស់ ទោះបីមានលក្ខណៈទ្រឹស្តីនិងការប្រតិបត្តិផ្សេងៗ

[8] ជួន ណាត, វចនានុក្រមខ្មែរភាគ១&២, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧, ទំព័រ ១៣៤៣។

ឬក៏ស្របគ្នាក៏ដោយ តែងតែមានគោលការណ៍សម្រាប់បំពេញដល់សេចក្តីត្រូវការរបស់មនុស្សលោក ដូចខាងក្រោមនេះ៖

-សម្រាប់បម្រើសេចក្តីត្រូវការនៃមនុស្សម្នាក់ៗ

-សម្រាប់ធ្វើសម្ព័ន្ធភាពនៃមនុស្សម្នាក់ទៅនឹងអ្នកដទៃ

-សម្រាប់ធ្វើសម្ព័ន្ធភាពនៃជនគ្រប់រូបទៅនឹងទីបំផុតនៃទុក្ខនិងព្រះអាទិទេព ឬវត្ថុស័ក្តិសិទ្ធិ។

## ១.២. សាសនាធំៗលើលោក

**សាសនាមានច្រើនណាស់ក្នុងលោកដូចជា:**[9]

- សាសនាព្រាហ្មណ៍ ឬព្រហ្មញ្ញសាសនា( Bramanisme )មានកំណើតនៅឥណ្ឌា
- សាសនាព្រះពុទ្ធ ឬព្រះពុទ្ធសាសនា( Buddhisme )មានកំណើតនៅប្រទេសឥណ្ឌា
- សាសនាគ្រិស្ត( Christianisme )មានកំណើតនៅប្រទេសស៊ីរី? Palestine?
- សាសនាឥស្លាម( Ismalmisme )មានដើមកំណើតនៅប្រទេសអារ៉ាប់
- សាសនាតៅ(Taoisme) មានកំណើតនៅប្រទេសចិន
- សាសនាសិន្តូ( Shintoisme )មានកំណើតនៅប្រទេសជប៉ុន។ល។

ដោយឡែកលោក ប៉ែន សាអឿន ក្នុងស្នាដៃសាសនាប្រៀបធៀបបានចែកសាសនាជាប្រាំគឺ:

១~ពុទ្ធសាសនា ២~ព្រហ្មញ្ញសាសនា ៣~ គ្រិស្តសាសនា

៤~ឥស្លាមសាសនា ៥~សាសនាសកលនិយមចិន

# ២. ព្រហ្មញ្ញសាសនា ឬសាសនាព្រាហ្មណ៍

## ២.១. ប្រភព

កាលដើមឡើយគេហៅសាសនាព្រាហ្មណ៍ថា «**ព្រហ្មញ្ញសាសនា**» ដែលសម្គាល់ «**សាសនារបស់ព្រះព្រហ្ម**» ឬ**សាសនាតមកអំពីព្រះព្រហ្ម**។ ពួកព្រាហ្មណ៍ដែលប្រកាន់ខ្លួនជាបុត្ររបស់ព្រះព្រហ្មកាន់កាប់ប្រតិបត្តិសាសនានេះ ទើបហៅថា «**សាសនាព្រាហ្មណ៍**» សាសនាព្រាហ្មណ៍ទំនងជាចូលមកប្រទេសខ្មែរយើងក្រោយព្រះពុទ្ធសាសនាតាមរយៈពួកឈ្មួញឥណ្ឌាដែលធ្វើដំណើរតាមសំពៅមកទាក់ទងលក់ដូរជាមួយអ្នកស្រុក ដោយឈ្មួញទាំងនោះច្រើនជាអ្នកចេះដឹងខាងសាសនាព្រាហ្មណ៍ផង ហើយក៏មានឈ្មួញខ្លះបានរៀបការជាមួយនារីខ្មែរផង ម្ល៉ោះហើយឥទ្ធិពលសាសនាព្រាហ្មណ៍ក៏បានជ្រួតជ្រាបយ៉ាងខ្លាំងនៅក្នុងសន្តានចិត្តជនជាតិខ្មែរយើង។

## ២.២. ការវិវត្ត

-សម័យវេទនិយម (១៥០០ឆ្នាំមុនគ.ស ដល់ ៥៥០ឆ្នាំមុនគ.ស)

-សម័យព្រាហ្មណ៍និយម( ៥៥០ឆ្នាំមុនគ.ស ដល់ស.វ.ទី១០នៃគ.ស)

-សម័យហិណ្ឌូនិយម (ស.វទី១០) រហូតមក។

[9] អ្នកស្រី ត្រឹង ងា, អរិយធម៌ខ្មែរសម្រាប់ថ្នាក់បញ្ចប់, ១៩៧៥។

**ទីកន្លែងអាទិទេពមាន:** ឋានសួគ៌ ឋានមនុស្ស ក្នុងខ្លួនមនុស្ស (អាទិទេពមានរូបឋិតនៅជាមួយមនុស្សជួយមនុស្សឱ្យបានឃើញជាក់ស្តែងនឹងផ្នែកគួរគោរព) ដាច់ពីឋានមនុស្ស ឬលើមនុស្ស ឬលើអាកាស (ក្នុងសង្គមមនុស្ស)។

## ២.៣. គម្ពីរវេទ

១-ឫគ្វេទ: សម្រាប់សូត្រសរសើរ អង្វរអាទិទេពផ្សេងៗឱ្យជួយសម្រេចបំណង។

២-យជុរវេទ: ជាអត្ថបទកម្រងកែវ សម្រាប់សូត្រក្នុងពិធីបូជាយញ្ញដើម្បីឱ្យអាទិទេពផ្តល់តេជៈបារមីដល់ខ្លួន។

៣-សាមវេទ: ជាពាក្យសម្រាប់សូត្រកំដរអាទិទេព ពេលដែលព្រះអង្គសោយសុរា និងអាហារ។ ចែកជា២ទៀតគឺ:

- សាមវេទស សម្រាប់សូត្រតែក្នុងស្រុក។
- សាមវេទខ្មៅ សម្រាប់សូត្រក្នុងព្រៃ។

៤-អថវវេទ: ជាគម្ពីរបន្ថែម បង្កើតក្រោយ ដែលសុទ្ធតែក្បួនមន្តអាគម គាថា សម្រាប់ប្រើការផ្សេងៗ។

## ២.៤. គោលទ្រឹស្តីសំខាន់ៗក្នុងព្រហ្មញ្ញសាសនា

- ព្រហ្មន: តាមគម្ពីរឧបនិស័ទ ព្រហ្មនសម្គាល់នូវព្រលឹងសកល ឬហៅថាមេព្រលឹងដែលនៅក្នុងនោះមានព្រលឹងតូចល្អិតៗនៅរួមជាមួយផងគឺអាត្មន។
- អាត្មន: ជាឯកជាតុពិសេសដែលបំបែកចេញពីព្រហ្មនទៅបង្កើតជាភាវៈឯទៀត។ អាត្មនដែលបែកចេញពីព្រហ្មនទៅសណ្ឋិតក្នុងរូបកាយមនុស្ស ឬសត្វ ហើយមិនងាយបានវិលទៅជួបព្រហ្មនវិញទេ ដោយសារកម៌ន។
- កម៌ន: កម៌ន ឬកម្មគឺសម្គាល់អំពើល្អ ឬអាក្រក់ តាមផ្លូវកាយក្តី ផ្លូវវាចាក្តី។

## ២.៥. អាទិទេពត្រីមូ៌តិ

ក្នុងទ្រឹស្តីព្រហ្មញ្ញសាសនាគេជឿថា មានទេពឬទេវីជាច្រើនអង្គហើយគេនិយមហៅថា«ត្រីមូ៌តិ» គឺមាន ព្រះឥសូរ ព្រះវិស្ណុ និងព្រះព្រហ្ម ។

- **ព្រះឥសូរ**

-ព្រះឥសូរមានព្រះនាមច្រើនណាស់។ តែព្រះនាមដែលគេស្គាល់ច្រើនដូចជា: ព្រះសិវៈ ហរៈ មហេសូរ រុទ្រៈ ឧគ្រៈ អឃោរៈ ភៃរវៈ...។ល។

-ជួនកាលគេធ្វើរូបព្រះលិង្គ ត្រីសូល៍ ព្រះបាទា ឬជារូបឥសីមានពុកចង្កាវែង សម្រាប់តំណាងឱ្យព្រះឥសូរ។

-ព្រះនេត្រទីបីនៅលើថ្ងាស មានចំណិតព្រះចន្ទ្រនៅលើផ្នួងសក់

-មានគោនិន្ទជាយានជំនិះ

-ព្រះហស្តអាចធ្លាក់ឱ្យឃើញមានពីរ បួន ប្រាំបី និងដប់

-កេតនភ័ណ្ឌ: កាន់ថូ ស្គរ ផ្គាំ លលាដ៍ក្បាល ត្រីសូល៍ និងខ្សែ

-មហេសីមាន៩អង្គ គឺនាងទុគា ឧមា គោរី កាលី ចន្ទី បវ៌តី កុមារី ទេវី និងនាងមហាទេវី

-បុត្រពីរអង្គ គឺព្រះស្កន្ទនិងព្រះគណេស

-តួនាទី គឺបង្កើតលោកនិងបំផ្លាញលោកចាស់ដើម្បីបង្កើតលោកថ្មីមួយទៀត។

- **ព្រះវិស្ណុ**

-តួនាទី គឺថែរក្សាលោកឱ្យមានរបៀបរៀបរយ

-មានមុខតែមួយ

-មានដៃ២, ៤, ៨

-ពាក់មួករម្យរមូល

-សម្លៀកបំពាក់ពណ៌លឿង

-មានគ្រុឌជាយានជំនិះ

-មានមហេសី២អង្គគឺ នាងលក្ស្មីទេពធីតានិងនាងស្រីទេពធីតា (ព្រះភូមិ)

-មានបុត្រ១អង្គគឺព្រះកាម (Kama)

-កេតនភ័ណ្ឌ: កងចក្រ ដំបងធំ ផ្កាឈូក ខ្យងស័ង្ខ ធ្នូ ដាវ

-មានអវតារ១០គឺ មត្ស្យា (ត្រី) កុរមៈ(អណ្តើក) វរាហៈ (មនុស្សមានក្បាលជាជ្រូកព្រៃ) នរសិង្ហ (មនុស្សក្បាលសិង្ហ) វាមនៈ (ព្រាហ្មណ៍តឿ) បរសុរាម (មនុស្សកាន់ពូថៅ) រាម (រឿងរាមកេរ្តិ៍) ក្រឹស្ណ (មនុស្សខ្មៅ) ព្រះពុទ្ធ (ពួកវិស្ណុនិយមបានបញ្ចូលតួអង្គព្រះពុទ្ធជាអវតារទី៩ដែលមានមុខងារមកកម្ចាត់ការបូជាយញ្ញ រំលាយចោលនូវការប្រកាន់វណ្ណៈក្នុងសង្គម និងដឹកនាំមនុស្សឱ្យទៅរកសន្តិភាព) និងកល្កិន(មនុស្សក្បាលសេះ) ជាអវតាក្នុងពេលអនាគត។

- **ព្រះព្រហ្ម**

-ដំបូងឡើយព្រះព្រហ្មជាអាទិទេពធំណាស់ គឺគេចាត់ទុកថា ជាអ្នកបង្កើតលោក ជាទេពរបស់ទេពនិករ និងជាបិតារាល់គ្រប់សត្វលោក។

-នៅក្នុងកម្ពីរ Satapatha Brahmana និង Manu និទានថា ទេពដែលកើតឡើងដោយឯកឯងបានបង្កើតទឹក រួចទម្លាក់ទឹកកាមចូលទៅក្នុងទឹកនោះរហូតកើតជាស៊ុតមាសមួយ។ ស៊ុតមាសនោះប្រេះបែកកើតជាព្រះព្រហ្មឡើង។

-មុខ៤ ដៃ៤កាន់គម្ពីរវេទ

-ខ្លួនសម្បុរផ្កាឈូក សម្លៀកបំពាក់ពណ៌ស

-កេតនភ័ណ្ឌ : ថូ ផ្គាំ ស្លាបព្រា ថាស

-ដួនកាលឈរ ដួនកាលអង្គុយលើផ្កាឈូក

-ជិះលើសត្វហង្ស
-មានមហេសីមួយអង្គនាមស្វស្វតី
-បុត្រ៣អង្គ(ព្រះទក្ស ព្រះភឫគុ និងព្រះនាងសំធ្យា ឬសន្ធិយា)។


ព្រះសិវៈ


ព្រះវិស្ណុ


ព្រះព្រហ្ម


ត្រីមូ៌តិ

## ២.៦. ភារកិច្ចនិងតួនាទីទេវៈនៅក្នុងទស្សនៈពហុទេវនិយម

**ព្រះឥន្ទ្រ**

- ជាស្តេចនៅស្ថានសួគ៌និងជាទេពនៃភ្លៀង
- តំណាងឱ្យផ្គររន្ទះនិងជាលោកបាលប្រចាំទិសខាងកើត
- មានព្រះហស្ត៤ គង់លើដំរីឲ្យរាវ័ណ កាន់វជ្រៈ(រន្ទះ)
- កេតនភ័ណ្ឌមាន ស័ង្ខ ធ្នូ ព្រួញ ផ្លែសន្ទូច សំណាញ់
- សម័យវេទថយឥទ្ធិពលព្រោះចូលចិត្តសេពសុរា ល្មោភកាម និងចាញ់សង្គ្រាមញឹកញាប់។

**ព្រះអគ្គី**

- តំណាងឱ្យភ្លើងនិងជាសាក្សីនៃអំពើរបស់មនុស្ស
- ជាអ្នកនាំក្តីប្រាថ្នារបស់មនុស្សទៅថ្វាយទេព ពោលគឺជាទូតសម្រាប់ទំនាក់ទំនងរវាងទេព និងមនុស្ស
- ជាលោកបាលប្រចាំនៅទិសអាគ្នេយ៍
- មានយានជំនិះជាសត្វមាស
- កេតនភ័ណ្ឌគឺធ្នូ និងព្រួញ។

**ព្រះយមរាជ**

- ជាទេពបានស្គាល់សេចក្តីស្លាប់ដំបូងគេ
- ជាស្តេចនៃសេចក្តីស្លាប់ និងអ្នកនៅរស់
- មានសេនាពីរនាក់គឺ Chitraguta ជាអ្នកអានឈ្មោះ និង Agra Sandhani ជាអ្នករៀបរាប់ពីជីវិតរបស់បុគ្គលម្នាក់ៗ។
- មានយានជំនិះជាសត្វក្របី

- កេតនភ័ណ្ឌគឺដំបង
- មានឆ្កែ២ក្បាលជាសេនាផ្ទាល់ គឺមួយឈ្មោះSyama និង មួយទៀតឈ្មោះ Sabala ។ ឆ្កែនីមួយៗមានភ្នែក៤។
- បន្ទាប់ពីធ្វើមរណកាលហើយ ព្រលឹងរបស់បុគ្គលគ្រប់រូបត្រូវជួបព្រះយមសិន។ ក្រោយពីអានរបាយការណ៍ចប់ ព្រះយមថ្លឹងថ្លែងពីអំពើល្អនិងអាក្រក់ដែលបុគ្គលបានសាង រួចកាត់សេចក្តីឱ្យមនុស្សថា ត្រូវឱ្យឡើងឋានសួគ៌ ឬធ្លាក់ទៅស្ថាននរក។
- ជាលោកបាលប្រចាំនៅទិសខាងត្បូង។

<u>ព្រះគណេស</u>

- ពាក្យថា Ganesa មកពីពាក្យ Gana + Isa ដែលមានន័យថា ជាម្ចាស់ ឬមេដឹកនាំរបស់ពួក Gana។
- ជាទេពនៃបញ្ញា ចំណេះដឹង និងជាអ្នកកម្ចាត់ឧបសគ្គ ឬអាចដាក់ឧបសគ្គ។
- គម្ពីរ Brahmavaivartapurana ដំណាលថា ព្រះនាង Parvati សុំពរព្រះនារាយណ៍ឱ្យខ្លួនមានបុត្រាម្នាក់។ ព្រះនារាយណ៍ក៏យាងមកច្យុតក្នុងផ្ទៃនាង Parvati ហើយក៏កើតជាព្រះ គណេស។
- ព្រះគណេសមានភ្លុកតែមួយចំហៀងទេ ឯភ្លុកមួយទៀតបាក់ ដោយសារ Parasu-rama ជាអ្នកកាត់នឹងពូថៅ។
- នៅក្នុងគម្ពីរ Varahapurana ដំណាលថា ព្រះគណេសមានរាងសង្ហាណាស់ កើតឡើងដោយសារសំណើចរបស់ព្រះឥសូរ និងការរំភើបរបស់នាង Parvati។ ពេលមួយព្រះឥសូរក៏ស្រាប់តែមានការច្រណែនព្រះគណេស ក៏ដាក់បណ្តាសាព្រះគណេសឱ្យមានក្បាលជាដំរីពោះកំប៉ោ និងចាត់ឱ្យធ្វើជាមេទ័ពរបស់កងទ័ពព្រះឥសូរ។

<u>ព្រះស្កន្ទ</u>

- ស្កន្ទ ឬគេហៅថា **ការត្តិកេយ កុមារ សុព្រហ្មន្យ** ជាទេពនៃសង្គ្រាម ឬជាបញ្ជាការកងទ័ពនៅស្ថានសួគ៌។
- មានយានជំនិះជា**សត្វក្ងោក**
- កេតនភណ្ឌមាន ធ្នូ ដាវ រន្ទះ ពូថៅ និងលំពែង។

<u>ព្រះកាម</u>

- កាម ឬកាមទេពជាទេពតំណាងឱ្យសេចក្តីស្នេហា
- ជាក្មេងប្រុសជំទង់
- មានព្រះហស្តពីរ ឬប្រាំបី
- កេតនភ័ណ្ឌគឺកាន់ធ្នូធ្វើអំពីដើមអំពៅ និងខ្សែធ្នូធ្វើពីឃ្មុំ មានផ្លែព្រួញប្រាំធ្វើពីផ្កា
- មានយានជំនិះជាសត្វសេក (តំណាងឱ្យសេចក្តីស្នេហា និងមនោសញ្ចេតនា)។

**<u>រាហ៊ូ</u>**

- រាហ៊ូចាត់ទុកថា ជាអ្នកប្រឆាំងនឹងទេព
- បានលួចផឹកទឹកអម្រឹតដែលបានមកពីការរួមគ្នារវាងអសុរៈ និងទេវតាក្នុងការកូរសមុទ្រទឹកដោះ។
- ត្រូវព្រះវិស្ណុគប់កងចក្រផ្ដាច់ក ប៉ុន្តែមិនស្លាប់ទេ ដោយសាររាហ៊ូបានលេបទឹកអម្រឹតត្រឹមករួចទៅហើយ ទើបរាហ៊ូពុំស្លាប់ត្រឹមក។
- ចងគំនុំជាមួយព្រះអាទិត្យនិងព្រះចន្ទ « **រាហ៊ូចាប់ចន្ទ** » ឬ « **ចន្ទគ្រាស សូរ្យគ្រាស** » ។

**<u>ព្រះសូរ្យ (ព្រះអាទិត្យ)</u>**

- ជាទេពសំខាន់មួយនៅក្នុងគម្ពីរវេទ
- តំណាងឱ្យពន្លឺ និងកម្ដៅយ៉ាងមហិមា
- ជិះលើរទេះសេះដែលអូសដោយសេះក្បាល៧ អមដោយកាំរស្មី
- អ្នកបររទេះឱ្យព្រះសូរ្យឈ្មោះ Aruna ឬ Vivaswat។

**<u>ព្រះចន្ទ</u>**

- សោម ជាឈ្មោះដើមឈើម្យ៉ាងមាននៅក្នុងសម័យវេទ គឺជារុក្ខជាតិនាំមកនូវភាពសម្បូណ៌សប្បាយ។
- ជាទេពដែលតំណាងឱ្យភាពអណ្ដែតអណ្ដូង
- ទឹកសោមជាភេសជ្ជៈរបស់ទេព
- ក្រោយមកគេបែរជាស្គាល់ « **សោម** » ថាជា «**ព្រះចន្ទ**» ទៅវិញក្នុងគម្ពីរបុរាណ
- ជិះលើរទេះដែលមានកង់បី អូសដោយសេះ១០ ឬសត្វប្រើស។



ព្រះឥន្ទ្រគង់លើដំរីឰរាវ័ណ



ព្រះអគ្គី



ព្រះកាម

## ២.៧. ឥទ្ធិពលព្រហ្មញ្ញសាសនាក្នុងសង្គមខ្មែរ

សាសនាព្រាហ្មណ៍ចូលមកប្រទេសកម្ពុជាតាំងពីសតវត្សទី១មកម្ល៉េះ ហើយឥទ្ធិពលទាំងនេះបានជ្រាបចូលក្នុងសង្គមនិងប្រជាជនខ្មែរស្ទើរគ្រប់ស្រទាប់វណ្ណៈថ្នាក់។ បច្ចុប្បន្នសាសនាព្រាហ្មណ៍បាន

ផុតរលត់ទៅហើយក៏ពិតមែន តែឥទ្ធិពលរបស់វាក៏នៅតែជិតជាមនិងមានជំនឿគោរពដដែល ព្រោះជំនឿនោះបានផ្តល់នូវសេចក្តីសុខដល់ប្រជាជនកម្ពុជា។

**ភស្តុតាងនៃឥទ្ធិពលសាសនាព្រាហ្មណ៍ក្នុងសង្គមខ្មែររួមមានៈ**

-ព្រះរាជាខ្មែរសម័យមុនៗកាន់សាសនាព្រាហ្មណ៍ ប៉ុន្តែបច្ចុប្បន្នព្រះមហាក្សត្រខ្មែរក៏នៅតែមានជំនឿសាសនាព្រាហ្មណ៍នេះដែរ។

-ភាសាសំស្រ្កឹត

-អក្សរសិល្ប៍បែបព្រាហ្មណ៍និយម

-សំណង់ប្រាសាទរាប់ពាន់

-ពិធីនានានៅក្នុងរាជវាំង

-ប្រជារាស្ត្រខ្មែរនៅតែជឿអាទិទេពនិងកម្លាំងក្រៅខ្លួន

-ទំនៀមទម្លាប់សែនព្រេនក្នុងពិធីមង្គលការ សង់ផ្ទះដូចជាពិធីក្រុងពាលី ពិធីរៀបពិស្ណុការ (វិស្ណុការ)មុននឹងសាងសង់។

-ស្រង់ទឹកព្រះ ព្រះសង្ឃ និងមាតាបិតា

-បង្កើតទឹកចិត្តក្លាហាន

-បង្កើតសីលធម៌រស់នៅក្រោមអំណាចព្រះរាជា

-មានជំនឿលើរូបចម្លាក់ជាច្រើនដូចជា ព្រះព្រហ្ម ព្រះវិស្ណុ លិង្គព្រះឥសូរ

-ជំនឿលើមន្តអាគម អូមអាម ខ្សែគាថា កន្សែងយ័ន្ត...។ល។

## ៣. ព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនាមានដើមកំណើត នៅប្រទេសឥណ្ឌាក្នុងសតវត្សទី៦មុនគ.ស ប្រហែលគ្នានឹងកំណើតព្រាហ្មណ៍និយម (សម័យទី២នៃសាសនាព្រាហ្មណ៍)ដែរ។ ក្រោយព្រះពុទ្ធបរិនិព្វានកាលនៅប្រមាណជាង២១៨ឆ្នាំ មានព្រះរាជាមួយព្រះអង្គព្រះនាមព្រះបាទធម្មាសោកមហារាជបានឡើងសោយរាជ្យក្នុងព្រះរាជធានី**បាដលិបុត្រនៃមគធរដ្ឋ**ប្រទេសឥណ្ឌា។ ព្រះរាជាអង្គនេះប្រកបដោយឫទ្ធានុភាព ច្រើនផ្សាយតេជោនុភាពទូទៅពេញប្រទេសឥណ្ឌា។ ទ្រង់បានចូលកាន់ព្រះពុទ្ធសាសនាហើយបានជា**ព្រះសាសនូបត្ថមក៏**ក្នុងការធ្វើ**តតិយសង្គាយនា** ព.ស២៣៤ (សង្គាយនាទី១ឬ**បឋមសង្គាយនា**ធ្វើក្រោយ**ព្រះពុទ្ធបរិនិព្វាន**ប្រមាណ៣ខែ ធ្វើរយៈពេល៧ខែ។ **សង្គាយនាទី២** ធ្វើក្រោយព្រះពុទ្ធបរិនិព្វានកន្លងទៅបាន១០០ឆ្នាំ ធ្វើរយៈពេល៨ខែ។ **សង្គាយនាទី៣** ឬតតិយសង្គាយនាធ្វើក្រោយព្រះពុទ្ធបរិនិព្វានបាន២១៨ឆ្នាំ ធ្វើរយៈពេល៩ខែ។ **សង្គាយនាទី៤** ឬចតុសង្គាយនាធ្វើរយៈពេល១០ខែ ហើយចប់ស្រេចក្នុងពុទ្ធសករាជ២៣៦ និង**សង្គាយនាទី៥** ឬបញ្ចសង្គាយនាធ្វើរយៈពេល១ឆ្នាំ ហើយចប់ស្រេចក្នុងពុទ្ធសករាជ៥២០)។[10] ការផ្សព្វផ្សាយពុទ្ធសាសនាចេញពីប្រទេសឥណ្ឌាទៅកាន់ប្រទេសនានា(ក្រៅប្រទេស)តែងតែធ្វើតាមផ្លូវគោក១និងផ្លូវទឹក១។ ផ្លូវគោកពុទ្ធសាសនាផ្សាយទៅ

[10] សរ សារុន, វប្បធម៌និងអរិយធម៌ខ្មែរភាគ២, បណ្ណាគារពន្លឺវិទ្យា។

តាមពួកពាណិជ្ជក្បួនរទេះដែលធ្វើដំណើរទៅតាមស្រុកតូចធំ និគមជនបទ ឯផ្លូវទឹកពុទ្ធសាសនាផ្សាយទៅតាមពួកពាណិជ្ជសំពៅសមុទ្រដែលធ្វើដំណើរលក់ដូរតាមកោះតូចធំ។ ទំនៀមពុទ្ធសាសនិកទោះជាពាណិជ្ជជើងគោកក្តី ក្នុងពេលធ្វើដំណើរចេញទៅម្តងៗ តែងតែនិមន្តភិក្ខុសង្ឃ ឬកសាងព្រះពុទ្ធរូបយកទៅតាមជាមួយដើម្បីការពារភយន្តរាយតាមផ្លូវផង ដើម្បីធ្វើសក្ការៈបូជាយកចំណែកកុសលតាមផ្លូវផង (ការផ្សាយព្រះពុទ្ធសាសនាធ្វើនៅរដូវចេញវស្សា)។

## ៣.១. ពុទ្ធប្រវត្តិសង្ខេប

| | | | | | |
|---|---|---|---|---|---|
| -ចាប់ | ៖ | រ | អា | ព្រ | |
| -ចេញ | ៖ | ច | ពិ | សុក្រ | ៦២៣ ឆ្នាំ មុនគ.ស |
| -រាជា | ៖ | ឆ្លូវ | ក | អា | ១៦ ព្រះវស្សា |
| -បួស | ៖ | ថោះ | អា | ព្រ | ២៩ ព្រះវស្សា |
| -ត្រាស់ | ៖ | រកា | ពិ | ពុធ | ៣៥ ព្រះវស្សា |
| -និព្វាន | ៖ | ម្សាញ់ | ពិ | អង្គារ | ៨០ ព្រះវស្សា។ |

***សម្គាល់៖**

**ចាប់**: ចាប់បដិសន្ធិ **ចេញ**: ប្រសូត្រ **រាជា**: រាជាភិសេក **បួស**: ចេញសាងផ្នួស

**ត្រាស់**: ត្រាស់ដឹង **និព្វាន**: ទ្រង់ចូលបរិនិព្វាន **រ**: ឆ្នាំរការ **អា**: ខែអាសាឍ

**ព្រ**: ថ្ងៃព្រហស្បតិ៍ **ច**: ឆ្នាំច **ពិ**: ខែពិសាខ **សុក្រ**: ថ្ងៃសុក្រ

**ឆ្លូវ**: ឆ្នាំឆ្លូវ **ក**: ខែកត្តិក **អា**: ថ្ងៃអាទិត្យ **ថោះ**: ឆ្នាំថោះ

**រកា**: ឆ្នាំរកា **ពុធ**: ថ្ងៃពុធ **អង្គារ**: ថ្ងៃអង្គារ

ពុទ្ធសាសនាមានពីរនិកាយគឺ: **ហីនយាននិងមហាយាន៖**

-ហីនយាន: គោរពតាមពុទ្ធវចនៈនិងដើរតាមព្រះអនន្ត

-មហាយាន: គោរពតាមព្រះពោធិសត្វច្រើនអង្គដូចជា ព្រះអវិលោកេស្វរៈ ប្រាជ្ញាបារមីតា វិជ្រាបាណិ ។ មានការនិយមច្រើនពីសង្គមខ្មែរសម័យមុនអង្គរនិងសម័យអង្គរ។

## ៣.២. គម្ពីរព្រះត្រៃបិដក

ព្រះត្រៃបិដកជាគម្ពីរគោលរបស់ព្រះពុទ្ធសាសនា។ គម្ពីរនេះមាន៨ម៉ឺន ៤ពាន់ ធម្មក្ខន្ធ ហើយចែកជាបីផ្នែកគឺ៖

- វិន័យបិដក: ចែងពីបញ្ញត្តិនិងអនុញ្ញាតឱ្យភិក្ខុ សាមណេរ ឧបាសក ឧបាសិកា ប្រតិបត្តិ មាន១៣ភាគ(១-១៣) មាន២១០០០ធម្មក្ខន្ធ ចែកជា៥គម្ពីរធំៗគឺ:

១. អាទិកម្ម (ទោសធ្ងន់) ២. បាចិត្តិយ (ទោសស្រាល)

៣. បហាវគ្គ (វគ្គធំ) ៤. ចុល្លវគ្គ (វគ្គតូច)

៥. បរិវារវគ្គ (បទបន្ទាប់បន្សំ)។

- ព្រះសូត្រ ឬសុត្តន្តបិដក: ចែងពីឱវាទឱ្យដឹងល្អអាក្រក់ (តែមិនបញ្ញត្តអ្វីទេ) មាន៦៤ភាគ (១៤-៧៧) មាន២១០០០ធម្មក្ខន្ធ ចែកចេញជា៥គម្ពីរធំៗគឺ:

១. ទីឃនិកាយ (សូត្រវែង) ២. មជ្ឈិមនិកាយ (សូត្រមធ្យម)
៣. សំយុត្តិកនិកាយ (សូត្រប្រហែលគ្នា) ៤. អង្គុត្តរនិកាយ (សូត្រចែកជាក្រុម)
៥. ខុទ្ទកនិកាយ (សូត្រខ្លី)។

- អភិធម្មបិដក: ពន្យល់ពីចិត្ត ចេតសិក រូប និព្វាន មានចំនួន៣៣ភាគ (៧៨-១១០) មាន ៤២០០០ធម្មក្ខន្ធ ចែកជា៧គម្ពីរធំៗគឺ:

១. ធម្មសង្គណី (ការចាត់របៀបធម៌) ២. វិភង្គ (ការចែករំលែកធម៌)
៣. កថាវត្ថុ (ចំនួនធម៌ដែលមានសេចក្ដីផ្ទុយគ្នា) ៤. បុគ្គលបញ្ញត្ត (បញ្ញត្តជាបុគ្គល)
៥. ធាតុកថា (ការវែកញែកធាតុ) ៦. យមកៈ (ធម៌ជាគូៗ)
៧. បដ្ឋាន (ធម៌ដែលមានទំនាក់ទំនងគ្នា)។

## ៣.៣. គោលទ្រឹស្ដីសំខាន់ៗក្នុងព្រះពុទ្ធសាសនា

**អរិយសច្ចៈ** : សេចក្ដីពិត៤យ៉ាងដែលព្រះពុទ្ធអង្គពិចារណាឃើញ ហៅថា « អរិយសច្ចៈ៤» ឬ « ចតុរារិយសច្ចៈ» គឺៈ

- ទុក្ខអរិយសច្ចៈ : សព្វសត្វទាំងពួងតែងមានទុក្ខ ព្រោះហេតុ៤យ៉ាងធំៗគឺៈ

១. ជាតិទុក្ខ (ទុក្ខព្រោះមានកំណើត)............=កើត
២. ជរាទុក្ខ (ទុក្ខព្រោះចាស់គ្រាំគ្រា).............=ចាស់
៣. ព្យាធិទុក្ខ (ទុក្ខព្រោះជំងឺគ្រប់បែបយ៉ាង)....=ឈឺ
៤. មរណទុក្ខ (ទុក្ខព្រោះសេចក្ដីស្លាប់)...........=ស្លាប់

- សមុទយអរិយសច្ចៈ : ទុក្ខទាំងឡាយកើតឡើងដោយសារមានហេតុ ឬឫសគល់របស់វាគឺ អវិជ្ជានិងតណ្ហា។

- និរោធអរិយសច្ចៈ : ការរួចស្រលះពីទុក្ខ ឬរំលត់ទុក្ខទាំងអម្បាលម៉ានគឺព្រះនិព្វាន។

- មគ្គអរិយសច្ចៈ : ផ្លូវ ឬវិធីដែលនាំឱ្យចាកផុតពីទុក្ខគឺនិព្វាននោះ ត្រូវដើរតាមផ្លូវជាកណ្ដាល ទាំង៨គឺៈ

១. សម្មាទិដ្ឋិ : ការយល់ឃើញត្រឹមត្រូវ
២. សម្មាសង្កប្បៈ : ការត្រិះរិះត្រូវ
៣. សម្មាវាចា : និយាយត្រឹមត្រូវ
៤. សម្មាកម្មន្ត : ការងារត្រឹមត្រូវ
៥. សម្មាអាជីវៈ : ចិញ្ចឹមជីវិតត្រឹមត្រូវ គឺមិនយកទ្រព្យគេ
៦. សម្មាវាយាម : ព្យាយាមត្រឹមត្រូវ គឺខំធ្វើអ្វីៗជាកុសល

៧. សម្មាសតិ : រឭកជារឿយៗក្នុងសេចក្តីត្រឹមត្រូវ

៨. សម្មាសមាធិ : តម្កល់ចិត្តឱ្យត្រឹមត្រូវ គឺអារម្មណ៍នៅនឹង។

ផ្លូវទាំង៨យ៉ាងនេះ រួមសេចក្តីមកនៅត្រឹម៣ប្រការគឺ សីល សម្មាធិ បញ្ញា។

**អដ្ឋង្គិកមគ្គ (មគ្គអរិយសច្ចៈ)**

| **សីល** | **សមាធិ** | **បញ្ញា** |
|---|---|---|
| -សម្មាវាចា | -សម្មាវាយាម | -សម្មាទិដ្ឋិ |
| -សម្មាកម្មន្ត | -សម្មាសតិ | -សម្មាសង្កប្បៈ |
| -សម្មាអាជីវៈ | -សម្មាសមាធិ | |

<u>**កម្ម-ផល**</u> : កម្មផលជាអំពើដែលខ្លួនម្នាក់ៗធ្វើ គឺពុំសាបសូន្យទេ រមែងផ្តល់ជាផលមកវិញទៅតាមកម្មនោះឯង ពោលគឺ បើជាកុសលកម្ម(អំពើល្អ) នឹងទទួលផលល្អ។ បើជាអកុសលកម្ម (អំពើអាក្រក់) នឹងទទួលផលអាក្រក់ ទោះបច្ចុប្បន្ន ឬអនាគតក៏ដោយ។ ដោយសារកម្មនេះហើយធ្វើឱ្យមនុស្សសត្វវិលកើត វិលស្លាប់គឺអន្ទោលក្នុងវាលវដ្តសង្សារ ដូចជាកង់មូលរកដើមរកចុងមិនឃើញដែលជាគំនរទុក្ខប្រៀបបីដូចប្រវ៉ាក់មាន១២កង់។

<u>**ទ្រឹស្តីភ្ជាប់ហេតុនិងផល**</u>

អវិជ្ជា[១]

ជរាព្យាធិមរណៈ[១២] សង្ខារ[២]

ជាតិ[១១] វិញ្ញាណ[៣]

ភព[១០] នាមរូប[៤]

[11]ឧបាទាន[៩] [12]អាយតនៈ[៥]

តណ្ហា[៨] [13]ផស្សៈ[៦]

វេទនា[៧]

<u>**ព្រហ្មវិហារធម៌**</u>: ធម៌ល្អបរិសុទ្ធ ពិសេសថ្លៃថ្លាមាន៤ប្រការគឺ៖

១. មេត្តា : សេចក្តីស្រឡាញ់រាប់អានសព្វសត្វ

២. ករុណា : អាណិតអាសូរចំពោះសត្វទាំងពួង

៣. មុទិតា : ត្រេកអរនឹងសត្វទាំងឡាយដែលបានសុខ

៤. ឧបេក្ខា : ប្រកាន់ចិត្តមិនលម្អៀង ស្មោះស្មើសព្វសត្វ។

[11] ឧបាទាន គឺការប្រតោងចិត្តគំនិត, សេចក្តីប្រកាន់ជាប់ស្អិត, សេចក្តីជំពាក់ចិត្ត ឧ. តណ្ហាជាបច្ច័យនៃឧបាទានៗ ជាបច្ច័យនៃភព។

[12] អាយតនៈ គឺទីប្រជុំនៃអារម្មណ៍ មានភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ, មនោ ទាំង ៦។

[13] ផស្សៈ គឺអារម្មណ៍ដែលមកប៉ះត្រូវអាយតនៈ មានភ្នែកជាដើម, ការប៉ះពាល់ត្រូវ ។

## ៣.៤. ឥទ្ធិពលព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ

ទស្សនៈ ទ្រឹស្តីពុទ្ធសាសនាបានចាក់ឫសយ៉ាងមាំក្នុងផ្នត់គំនិតខ្មែរ ពិសេសលើផ្នែកជំនឿ ទំនៀមទម្លាប់ ប្រពៃណី សិល្បៈ ភាសា អក្សរសិល្ប៍។

-លើជំនឿ: ជឿលើព្រះរតនត្រ័យ វត្តអារាម ធ្វើបុណ្យឱ្យទាន រក្សាសីល (សីល៥ សីល៨ សីល ១០) និងសមាធិកម្មដ្ឋាន ជឿបុណ្យបាប ផលកម្ម ស្ថានសួគ៌ ស្ថាននរក...។

-លើទំនៀមទម្លាប់ ប្រពៃណី: ពិធីផ្សេងៗក្នុងសង្គមខ្មែរ សុទ្ធតែបានភ្ជាប់ទៅនឹងពុទ្ធសាសនា។ ប្រពៃណីខ្លះភ្ជាប់សុទ្ធសាធទៅនឹងពុទ្ធសាសនា (ពិសាខបូជា មាឃបូជា ចូលវស្សា ចេញវស្សា បុណ្យកឋិន...)។ ប្រពៃណីខ្លះទៀតមានលាយចម្រុះ ព្រាហ្មណ៍សាសនាផង ពុទ្ធសាសនាផង និងជំនឿផ្សេងៗផង (អាពាហ៍ពិពាហ៍ បូជាសព ចូលឆ្នាំខ្មែរ...)។

-លើសិល្បៈ : សិល្បៈស្ថាបត្យកម្ម(ព្រះវិហារ ប្រាសាទ ចេតិយ ហោត្រៃ...) គំនូរ (នៅតាមព្រះវិហារ ហោត្រៃ...) បដិមា (រូបពុទ្ធបដិមា)។

-ភាសា: ក្នុងភាសាខ្មែរមានកម្ចីពាក្យបាឡីជាច្រើន។

-អក្សរសិល្ប៍: មានរឿងទាក់ទងនឹងពុទ្ធនិយម (ទសជាតក បញ្ញាសជាតក កាកី ...)។

# មេរៀនទី៤ ប្រវត្តិសិល្បៈខ្មែរ

សិល្បៈកើតឡើងតំណាលគ្នានឹងកំណើតជីវិតមនុស្សដែរ ពោលគឺមនុស្សបង្កើតឡើងតាមរយៈតម្រូវការរបស់មនុស្សនិងដើម្បីមនុស្ស។ ជាទូទៅសិល្បៈកើតឡើងដោយ ៖

- ត្រាប់តាមធម្មជាតិ ឬតាមសត្វ
- គំនិតច្នៃប្រឌិត
- សំយោគអនុកម្ម + នវកម្ម

ពាក្យសិល្បៈ(សំស្ក្រឹត) ឬសិប្បៈ (បាលី)សំដៅយកការងារសម្រិតសម្រាំងដោយដៃមនុស្ស ប្រកបដោយភាពច្នៃប្រឌិតខ្ពស់និងទេពកោសល្យដ៏ប៉ិនប្រសប់បំផុត ពោលគឺធ្វើឱ្យមនុស្សចាប់ចិត្ត ចាប់អារម្មណ៍ ចង់មើល ចង់ឃើញ ចង់ស្គាល់។ សិល្បៈមានច្រើនប្រភេទណាស់ដូចជាសិល្បៈរបាំ ចម្រៀងភ្លេង ល្ខោន ចម្លាក់ សំណង់ និងសិប្បកម្មសូន្យរូបជាដើម។ ប្រទេសកម្ពុជាជាប្រទេសមួយបានឆ្លងកាត់នូវសម័យប្រវត្តិសិល្បៈដ៏យូរលង់។ មានន័យថា ប្រទេសយើងសម្បូរទៅដោយសិល្បៈ ពោលគឺសិល្បៈមានលក្ខណៈសម្បូរបែប(សិល្បៈនៃការរស់នៅ សិល្បៈនៃការនិយាយ សិល្បៈនៃការគ្រប់គ្រង... ។ល។ តែទោះជាយ៉ាងណាក៏ដោយ ក៏គេបង្រួម ឬធ្វើបំណែងចែកសិល្បៈតែ៧ប៉ុណ្ណោះ។

**និយមន័យនៃពាក្យសិល្បៈ**

**ក. ទស្សនៈផ្សេងៗ**

-លោក **អារី ស្តូត** (៣៨៥-៣២២) ទស្សនវិទូក្រិក: សិល្បៈ គឺជាការត្រាប់តាមធម្មជាតិ។

-លោក **ដេម៉ូ គ្រីត** (៤៨០-៣៧០) ទស្សនវិទូក្រិក: សិល្បៈ ចាប់កំណើតយកតាមតម្រាប់ធម្មជាតិ មនុស្សចេះច្រៀងដោយសារមនុស្សចេះធ្វើត្រាប់តាមសំឡេងបក្សាបក្សី។ មនុស្សចេះរាំដោយសារគេធ្វើត្រាប់តាមចលនាសត្វ ឬមនុស្សគ្នាឯងដែលរស់នៅប្រចាំថ្ងៃ។

-លោក **ហ្សៀ យៀបាក់** (១៨០២-១៨៧២) ទស្សនវិទូអាល្លឺម៉ង់: លោកបានរកឃើញទំនាក់ទំនងប្រឈមគ្នារវាង **អាទិទេព មនុស្ស សាសនា សិល្បៈ**។ គាត់បានអះអាងថា៖

**មនុស្ស សាសនា សិល្បៈ អាទិទេព**

...ទង្វើក្នុងចំណោមទង្វើជាច្រើនរបស់មនុស្សពីបុរាណកាលមកបានលេចចេញពីសង្គមនូវសកម្មភាពមួយទៀតហៅថា «**សិល្បៈ**» ពាក្យថា សិល្បៈមិនកំណត់ន័យត្រឹមតែសកម្មភាពរបស់មនុស្សប៉ុណ្ណោះទេ តែកំណត់ពីលទ្ធផលរបស់សកម្មភាពនោះដែរ គេឱ្យឈ្មោះថា «**វណ្ណកម្មសិល្បៈ**»...។

-ព្រឹទ្ធាចារ្យ **ឆេង ផុន** : សិល្បៈ គឺជាការបកប្រែរបស់ធម្មជាតិពិតៗ រស់រវើកនៅជុំវិញខ្លួនប្រកបដោយចិត្តរំភើបនិងមនុស្សធម៌ជាទីបំផុត។[14]

---

[14] សេង គឹមលី, ប្រវត្តិសិល្បៈខ្មែរ, ២០០២។

ខ. ទស្សនៈ សម្ដេចសង្ឃរាជ ជួន ណាត

សិល្បៈ : មកពីពាក្យ សំ.; បា.(ន.) (គិល្ប; សិប្ប) សិប្បៈមានន័យថា ជំនាង ការជាងផ្សេងៗ ហត្ថកម្មគ្រប់បែបយ៉ាង។ ចំណេះដែលត្រូវសិក្សាមាន ជាងឈើ ការជាងឈើ ឆ្លាក់រូប រៀបឥដ្ឋ បូកបាយអរ រហូតដល់បង្ហាត់សេះ បង្ហាត់ដំរី។ ចំណេះភ្លេង ចម្រៀង របាំ ។ល។ ឬការតាក់តែង ការរចនាវិចិត្រផ្សេងៗ។

ការលើកយកទស្សនៈខ្លះៗរបស់ព្រឹទ្ធាចារ្យនិងអ្នកប្រាជ្ញខាងលើនេះ គឺដើម្បីពង្រីកចំណេះដឹងអំពីពាក្យសិល្បៈ ដោយភ្ជាប់នឹងចំណេះដឹងថ្មីរបស់យើងជាមួយគំនិតទាំងឡាយខាងលើនេះ គឺជាទស្សនវិស័យនៃសិល្បៈ។

## ១. សិល្បៈស្ថាបត្យកម្មខ្មែរ

### ១.១. និយមន័យ

-ស្ថាបត្យកម្ម (Architecture): សិល្បៈក្នុងការសាងសង់ប្រកបដោយការតុបតែងតាមក្បួនខ្នាត។

-រចនាបថ : ទីនេះសំដៅលើសិល្បៈក្នុងការសាងសង់ ឬតាក់តែងលម្អតាមគំនិតរបស់ថ្នាក់ដឹកនាំ(ព្រះមហាក្សត្រ) ក្នុងការស្ថាបនាប្រាង្គប្រាសាទបុរាណ។

### ១.២. ស្ថាបត្យកម្មខ្មែរ

លក្ខណៈទូទៅដែលទាក់ទងនឹងប្រាសាទខ្មែរបុរាណមានដូចជា៖

**ក. ប្រាសាទ:** ប្រាសាទខ្មែរគឺចាត់ទុកដូចជាវិមាន ឬលំនៅអាទិទេព។ ប្រាសាទគឺប្រៀបបាននឹងលោកសន្និវាសមួយ ដែលតួប្រាសាទប្រៀបនឹងភ្នំព្រះសុមេរុ (លំនៅព្រះអាទិទេព)។ ដើម្បីអាចឱ្យឈ្មោះជាប្រាសាទបានលុះត្រាតែប្រកបដោយលក្ខណៈ២យ៉ាងគឺ ខណ្ឌសីមានិងផ្លូវ។

-ខណ្ឌសីមា: សម្រាប់ខណ្ឌភាពពិសិដ្ឋឱ្យដាច់ចេញពីភាពជាបុថុជ្ជន គឺខណ្ឌពិភពអាទិទេពនិងពិភពមនុស្សឱ្យដាច់ចេញពីគ្នា។

-ផ្លូវ: ក្នុងរង្វង់ខណ្ឌសីមាត្រូវមានផ្លូវនាំតម្រង់ឆ្ពោះទៅកាន់តួប៉ម ដែលស្ថិតនៅចំកណ្ដាលចំណោមសំណង់ឯទៀតដែលរាយរង។ តួប៉មកណ្ដាលនេះ គឺជាឋានដ៏ប្រសើរលើសលប់អស់ទីឋានទាំងឡាយទៅលើភាពបរិសុទ្ធ។

**ខ. អំពីថែវ:** ថែវដែលនៅជុំវិញប្រាសាទបង្កើតបានជាកសិណជាប់ៗគ្នា ដែលគេនិយមរាប់ពី កណ្ដាលប្រាសាទចេញទៅក្រៅ (ថែវទី១ ថែវទី២...)។ នៅតាមថែវគឺមានដំបូលកោង។

**គ. របងប្រាសាទ ឬកំពែង:** សុទ្ធតែធ្វើឡើងពីវត្ថុធាតុរឹង(ថ្មបាយក្រៀម ឥដ្ឋ ថ្មភក់...)។

**ឃ. ក្លោងទ្វារ:** ភាគច្រើនស្មើរទាំងអស់នៃប្រាសាទ ក្លោងទ្វារតែងតែមានការតុបតែងលម្អធំទូលាយ នោះគឺក្លោងទ្វារត្រូវចូលស្ថិតនៅទិសខាងកើត។

**ង. ទ្វារបញ្ឆោត**: ជាទ្វារគ្រាន់តែធ្វើឱ្យមានជាហេតុ តែបិទជិត។

**ច. អគារផ្សេងៗ (ជុំវិញតួប៉ម)**: ចំពោះប្រាសាទខ្លះមានបន្ទប់ធំមួយលយចេញអំពីតួប៉មទៅខាងកើត (ហើយគេច្រើនហៅថា មណ្ឌបប្រាសាទដែរ)។

**ឆ. ប្លង់ប្រាសាទ**: គឺមានច្រើនបែបនៅមុនអង្គរ។

**ជ. បណ្ណាល័យ**: បណ្ណាល័យ ឬហោត្រៃទី១ដែលគេបានស្គាល់គឺនៅប្រាសាទព្រះគោ ហើយដែលមានបន្តបន្ទាប់សម្រាប់ប្រាសាទក្រោយៗទៀត។

**ឈ. តួប៉មប្រាសាទ**: តួប៉មប្រាសាទនៅសម័យមុនអង្គរ ថ្នាក់ៗ ប្រាសាទពុំសូវឃ្លាតចេញពីគ្នាទេ។ តែនៅសម័យអង្គរ តាមថ្នាក់ៗមានសសរផ្អោបច្រើន ហើយវាឃ្លាតពីគ្នាឆ្ងាយៗ។

**ញ. វត្ថុធាតុសម្រាប់សាងសង់ប្រាសាទ**: មានឈើ ឥដ្ឋ និងថ្មៗល។

**ដ. ផ្តែរ**: គឺជាថ្មមួយផ្ទាំងរាងចតុកោណកែងសម្រាប់លម្អទ្វារចូលទៅក្នុងប្រាសាទ។

**ឋ. សសរពេជ្រ ឬសសរស្តម្ភ**: នៅសម័យមុនអង្គរសសរពេជ្រច្រើនតែមានរាងមូល លុះមកដល់សម័យអង្គរសសរពេជ្រច្រើនតែមានរាងជ្រុង។

**ឌ. ហោជាង**: មានការវិវត្តជាច្រើនពីសម័យកាលមួយទៅសម័យកាលមួយ។

## ១.៣. ការវិវត្តនៃសំណង់ស្ថាបត្យកម្មខ្មែរ

ប្រវត្តិសាស្ត្របានបង្ហាញឱ្យឃើញថា សិល្បៈខាងសំណង់របស់ខ្មែរយើងមានកំណើតតាំងពីសម័យនគរភ្នំ ហើយស្នាដៃសិល្បៈនេះទាំងសម្ភារៈសំណង់ ទាំងការវិវត្តនៃសំណង់រីកចម្រើនជាហូរហែរហូតមកដល់សម័យបាយ័នចុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧។

គេនិយមចែកសិល្បៈជារចនាបថដោយយកឈ្មោះប្រាសាទសំខាន់ៗមកដាក់ឈ្មោះរចនាបថទាំងនោះ។ សិល្បៈស្ថាបត្យកម្មខ្មែរចែកចេញជា២សម័យកាលគឺស្ថាបត្យកម្មមុនសម័យអង្គរនិងស្ថាបត្យកម្មសម័យអង្គរ។

### ១.៣.១. ស្ថាបត្យកម្មសម័យមុនអង្គរ

អ្នកសិក្សានិយមហៅសិល្បៈសម័យហ្វូណននិងសម័យចេនឡាជាសិល្បៈបុរេអង្គរ (សិល្បៈសម័យមុនអង្គរ) សិល្បៈបុរេអង្គរមាន៤ រចនាបថ (Style)គឺ :

១. រចនាបថ ភ្នំដា (ស.វទី១ ដល់ ស.វទី៦នៃគ.ស): គេបានយកប្រាសាទភ្នំដាជាគោល។ ភ្នំនេះស្ថិតនៅអង្គរបុរីសព្វថ្ងៃ។ សិល្បៈនេះបានបញ្ជាក់ពីទំនាក់ទំនងរវាងប្រទេសខ្មែរបុរាណ និងឥណ្ឌានៅសម័យនគរភ្នំ។

២. រចនាបថ សម្បូណ៌ (ពាក់កណ្តាលទី១ នៃស.វទី៧): រចនាបថសម្បូណ៌ស្ថិតនៅក្នុងរជ្ជកាលព្រះបាទ ឥសានវរ្ម័នទី១ (៦១៦-៦៣៥នៃគ.ស)ដោយមានរាជធានីឈ្មោះថា ឥសានបុរៈ គឺសម្បូណ៌ព្រៃគុក។ ប្រាសាទក្នុងរចនាបថនេះមាន៖

-ប្រាសាទសម្បូណ៌ព្រៃគុកស្ទើរតែទាំងអស់

-ប្រាសាទភ្នំធំ

-ប្រាសាទដំបងដែក។ល។

៣. រចនាបថ ព្រៃក្មេង (ពាក់កណ្តាលទី២ នៃស.វទី៧): រចនាបថព្រៃក្មេងស្ថិតក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១(គ.ស ៦៥៥-៦៨១) ដែលមានរាជធានីនៅអង្គរបុរី។ ប្រាសាទដែលគេបញ្ចូលក្នុងរចនាបថនេះគឺ៖

-ប្រាសាទព្រៃក្មេង (នៅស្រុកពួក ខេត្តសៀមរាប)

-ប្រាសាទស្វាយព្រាហ្មណ៍(ផ្នែកបុរាណ)

-ប្រាសាទភ្នំបាសិត (ទ្វារខាងកើត)

-ប្រាសាទព្រៃប្រាសាទ (បារាយណ៍ខាងកើត)

-ប្រាសាទអណ្តែត (ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ)។

៤. រចនាបថ កំពង់ព្រះ (ស.វទី៨): រចនាបថនេះស្ថិតក្នុងសម័យដែលចេនឡាបែកបាក់គ្នាជា២។ ប្រាសាទដែលគេបញ្ចូលក្នុងរចនាបថនេះមាន៖

-ប្រាសាទកំពង់ព្រះ (ខេត្តកំពង់ឆ្នាំង)

-ប្រាសាទអកយំ (ផ្នែកបុរាណ) នៅខេត្តសៀមរាប

-ប្រាសាទត្រពាំងផុង (ផ្នែកបុរាណ) នៅខេត្តសៀមរាប

-ប្រាសាទភ្នំបាសិត (ទ្វារខាងលិច)

-ប្រាសាទភូមិប្រាសាទ (កំពង់ធំ)។

### ១.៣.២. ស្ថាបត្យកម្មសម័យអង្គរ

នៅសម័យកាលនេះ គេចែករចនាបថសិល្បៈសំណង់ជា៩រចនាបថ ដែលមានឈ្មោះដូចខាងក្រោមនេះ៖

១. រចនាបថ គូលែន (៨០២ ដល់ ៨៥០នៃគ.ស ពាក់កណ្តាលទី១ នៃស.វទី៩): ស្ថិតក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី២ (គ.ស ៨០២-៨៥០)ដែលមានរាជធានីច្រើនកន្លែង។ ខ្នងភ្នំគូលេនមាន៥៣ប្រាសាទ។ ប្រាសាទដែលគេរាប់បញ្ចូលក្នុងរចនាបថនេះគឺ៖

-ប្រាសាទព្រៃប្រាសាទ

-ប្រាង្គC1 នៅសម្បូណ៌ព្រៃគុក

-ប្រាសាទនៅភ្នំគូលេន (ប្រាសាទដំរីក្រាប ខ្ទីងស្លាប់ រូបអារក្ស ថ្មដា គគីរ ក្រហម...)។

២. រចនាបថ ព្រះគោ (៨៥០ ដល់ ៨៧៧នៃគ.ស មួយភាគ៤ ចុងក្រោយ នៃស.វទី៩): ស្ថិតក្នុងរជ្ជកាលព្រះបាទឥសានវរ្ម័នទី១ (គ.ស ៨៧៧-៨៨៩)និង យសោវរ្ម័នទី១ (គ.ស ៨៨៩-៩០០) ដែលមានរាជធានីនៅហរិហរាល័យ។ ប្រាសាទដែលគេរាប់បញ្ចូលក្នុងរចនាបថនេះមាន៖

-ប្រាសាទព្រះគោ (គ.ស ៨៧៩) }
-ប្រាសាទបាគង (គ.ស ៨៨១) } កសាងដោយព្រះបាទឥន្ទ្រវរ្ម័នទី១

-ប្រាសាទលលៃ (គ.ស ៨៩៣) កសាងដោយព្រះបាទយសោវរ្ម័នទី១។

៣. រចនាបថ បាខែង (៨៨៩ ដល់ ៩១២នៃគ.ស ចុងស.វទី៩ និងដើមស.វទី១០): ស្ថិតក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី១ (គ.ស ៨៨៩-៩០០) ដែលមានរាជធានីនៅយសោធរបុរៈ (ភ្នំបាខែង)។ ប្រាសាទដែលគេរាប់បញ្ចូលក្នុងរចនាបថនេះមានៈ

-ប្រាសាទភ្នំបាខែង

-ប្រាសាទភ្នំក្រោម

-ប្រាសាទភ្នំបូក

៤. រចនាបថ កោះកេរ (៩២១ ដល់ ៩៤១ នៃគ.ស មួយភាគ៤ នៃស.វទី១០): ស្ថិតក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៤ (គ.ស ៩២៨-៩៤១) ដែលទ្រង់តាំងរាជធានីថ្មីនៅកោះកេរ។ ប្រាសាទដែលគេរាប់បញ្ចូលក្នុងរចនាបថនេះគឺប្រាសាទកោះកេរទាំងអស់និងប្រាសាទនាងខ្មៅ (ខេត្តតាកែវ)។

៥. រចនាបថ បន្ទាយស្រី (៩៤៤ ដល់ ៩៦៨ នៃគ.ស ពាក់កណ្តាលទី២ នៃស.វទី១០): ស្ថិតក្នុងរជ្ជកាលព្រះបាទរាជិន្ទ្រវរ្ម័ន (គ.ស ៩៤៤-៩៦៨) ដែលមានរាជធានីនៅអង្គរ។ ប្រាសាទដែលគេរាប់បញ្ចូលក្នុងរចនាបថនេះគឺៈ

-ប្រាសាទមេបុណ្យខាងកើត

-ប្រាសាទប្រែរូប

-ប្រាសាទបន្ទាយស្រី

-ប្រាសាទស្រឡៅ

៦. រចនាបថ ឃ្លាំង (៩៦៥ ដល់ ១០៥០ នៃគ.ស ចុងស.វទី១០ និងពាក់កណ្តាលទី១ នៃស.វទី១១): ស្ថិតក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៥ (គ.ស ៩៦៨-១០០១) និងព្រះបាទសូរ្យវរ្ម័នទី១ (គ.ស ១០០២-១០៥០) ដែលមានរាជធានីនៅអង្គរ។ គេរាប់បញ្ចូលក្នុងរចនាបថនេះនូវៈ

-ប្រាសាទតាកែវ

-ប្រាសាទឃ្លាំងខាងជើង

-ប្រាសាទភិមានអាកាស

-ប្រាសាទឃ្លាំងខាងត្បូង

-ប្រាសាទភ្នំជីសូរ

-ប្រាសាទចៅស្រីវិបុល

៧. រចនាបថ បាពួន (ពាក់កណ្តាលទី២ នៃស.វទី១១): ស្ថិតក្នុងរជ្ជកាលព្រះបាទឧទយាទិត្យវរ្ម័នទី២ (គ.ស ១០៥០-១០៦៦) និង ព្រះបាទហ៌សវរ្ម័នទី៣ (គ.ស ១០៦៦-១០៨០) ដែលមានរាជធានីនៅអង្គរដែរ។ ប្រាសាទដែលគេរាប់បញ្ចូលក្នុងរចនាបថនេះមាន៖

-ប្រាសាទបាពួន

-ប្រាសាទមេបុណ្យខាងលិច

-ប្រាសាទវត្តខ្នារ

៨. រចនាបថ អង្គរវត្ត (គ.ស ១១១២ ដល់ ១១៥២ ពាក់កណ្តាលទី១ នៃស.វទី១២) : ស្ថិតនៅក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២ (គ.ស ១១១៣-១១៤៥) ដែលមានរាជធានីនៅអង្គរ។ ប្រាសាទដែលគេរាប់បញ្ចូលក្នុងរចនាបថនេះមាន៖

-ប្រាសាទបេងមាលា

-ប្រាសាទព្រះបាលិលេយ្យ

-ប្រាសាទភិម៉ាយ

-ប្រាសាទព្រះពិធូរ

-ប្រាសាទចៅសាយទេវតា

-ប្រាសាទធម្មនន្ទ

-ប្រាសាទបន្ទាយសំរែ

-ប្រាសាទអង្គរវត្ត

-ប្រាសាទអធ្វា

-ប្រាសាទព្រះខាន់ (កំពង់ស្វាយ)។

៩. រចនាបថ បាយ័ន (គ.ស ១១៨១ ដល់ ១២២០ ពាក់កណ្តាលទី២ នៃស.វទី១២ និងដើមស.វទី១៣): ស្ថិតក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ (គ.ស ១១៨១-១២១៨) ដែលមានរាជធានីនៅអង្គរ។ ប្រាសាទដែលគេរាប់បញ្ចូលក្នុងរចនាបថនេះមាន៖

-ប្រាសាទតាព្រហ្ម

-ប្រាសាទបន្ទាយក្តី

-ប្រាសាទព្រះខាន់

-ប្រាសាទនាគព័ន្ធ

-ប្រាសាទបន្ទាយឆ្មារ

-កំពែងនិងក្លោងទ្វារទាំង៥នៃអង្គរធំ

-ប្រាសាទបាយ័ន

-ប្រាសាទតាព្រហ្ម ( ទន្លេបាទី ខេត្តតាកែវ )

-ប្រាសាទវត្តនគរ (កំពង់ចាម)។

### ១.៤. រចនាសម្ព័ន្ធនិងសិល្បៈសំណង់ប្រាសាទ

**ក. រចនាសម្ព័ន្ធ** : សំណង់ប្រាសាទទាំងឡាយជាទូទៅសុទ្ធសឹងប្រកបដោយរចនាសម្ព័ន្ធដូចខាងក្រោម ៖

-**ជញ្ជាំង**: ធ្វើពីថ្មភក់ ឬថ្មបាយក្រៀម។ គេយកដុំថ្មដែលបានដុះរំលីង ហើយទៅតម្រៀបគរលើគ្នាដូចយើងតម្រៀបឥដ្ឋ សព្វថ្ងៃនេះដែរ។

-**ក្បាច់វូត**: នៅលើដំបូលប្រាសាទជួនកាលគេយកដុំថ្មតម្រៀបគ្នាដើម្បីធ្វើវូត (voúte)។

-**ទ្វារបង្អួច** : គេធ្វើក្របទ្វារប្រាសាទអំពីថ្មភក់។ បង្អួចជួនកាលមានរាងការេ ជួនមានរាងចតុកោណកែង។ គេច្រើនធ្វើទ្វារបង្អួចបិទជិតដោយថ្មភក់ ជួនកាលគេធ្វើចម្រឹងអំពីថ្មភក់។ នៅតាមជញ្ជាំងប្រាសាទខ្លះ ស្ថាបត្យករបានឆ្លាក់ធ្វើទ្វារនិងបង្អួចបញ្ឆោត។

-**ផ្តែរ** : ច្រើនមានទំហំធំនិងធ្ងន់ដែលទ្រដោយសសរពេជ្រពីរ។ ធម្មតាគេធ្វើផ្តែរពីរជាន់។

**ខ. ប្រភេទនៃប្រាសាទ** : សំណង់ប្រាសាទមានច្រើនប្រភេទគឺ៖

-ប្រាសាទដែលមានប្រាង្គតែមួយ ហើយសង់ដាច់តែឯង។

ឧទាហរណ៍ ៖ ប្រាសាទបាយ័ន ប្រាសាទភ្នំបាសិត ប្រាសាទភូមិប្រាសាទ...។

-ប្រាសាទដែលមានប្រាង្គច្រើន នៅលើខឿនតែមួយជាន់។

ឧទាហរណ៍ ៖ ប្រាសាទព្រះគោ ប្រាសាទលលៃ......។

-ប្រាសាទដែលសង់លើដីរាបស្មើគ្មានខឿន គឺសង់ផ្ទាល់លើដីរាបស្មើ។

ឧទាហរណ៍ ៖ ភូមិប្រាសាទ ប្រាសាទព្រះខាន់...។

-ប្រាសាទភ្នំ សង់ខ្ពស់ដូចភ្នំមានទំហំធំមានខឿនច្រើនជាន់។ ប្រាសាទភ្នំមានពីរយ៉ាង ៖

- ប្រាសាទភ្នំសង់លើភ្នំធម្មជាតិ (ប្រាសាទភ្នំបាខែង ប្រាសាទភ្នំព្រះវិហារ...)។
- ប្រាសាទភ្នំដែលសង់នៅលើដី (ប្រាសាទបាគង ប្រាសាទបក្សីចាំក្រុង...)។

**គ. មុខងារប្រាសាទ**

-ឧទ្ទិសថ្វាយអាទិទេព ឬទេវៈផ្សេងៗក្នុងសាសនាព្រាហ្មណ៍

-ឧទ្ទិសថ្វាយព្រះពោធិសត្វក្នុងពុទ្ធសាសនាមហាយាន

- ឧទ្ទិសថ្វាយទេវរាជ(តម្កល់លិង្គព្រះឥសូរ តំណាងឱ្យព្រះរាជា)

- ឧទ្ទិសថ្វាយបុព្វបុរស មានមាតា បិតា និងវីរជនដែលបានពលីកម្មដើម្បីជាតិ។

### ១.៥. តម្លៃនៃស្ថាបត្យកម្មខ្មែរ

ការអធិប្បាយកន្លងមកបង្ហាញឱ្យយើងឃើញថា ស្ថាបត្យកម្មខ្មែរមានការវិវត្តឥតឈប់ឈរពីសម័យមួយទៅមួយ ហើយកាន់តែលូតលាស់ជាលំដាប់ផង។ ត្រង់នេះបង្ហាញឱ្យឃើញថា ស្ថាបត្យករខ្មែរមានទេពកោសល្យខ្ពង់ខ្ពស់ណាស់។ ក្រៅពីទេពកោសល្យខាងការផ្សេផ្សំធ្វើសំយោគសិល្បៈបរទេស និងសិល្បៈខ្មែរបង្កើតឱ្យបានសិល្បៈថ្មីមួយទៀតមានទម្រង់ជាសិល្បៈខ្មែរ ស្ថាបត្យករខ្មែរនៅមានទេពកោសល្យពិសេសម្យ៉ាងទៀត គឺការបង្កើតសិល្បៈខ្មែរស្របតាមទស្សនៈខ្មែរថែមទៀត។ ឧទាហរណ៍ៈ នៅសម័យភ្នំដាខ្មែរបានលុងភ្នំធ្វើប្រាសាទតាមបែបឥណ្ឌាដែរ តែដល់ក្រោយមកទៀតស្ថាបត្យករខ្មែរបានច្នៃប្រឌិតជំនឿគោរពទីខ្ពស់ដោយការកសាងប្រាសាទភ្នំ។ ទស្សនៈគោរពទីខ្ពស់នេះ ខ្មែរមានរួចមកហើយតាំងពីបុរេប្រវត្តិម្ល៉េះ លុះឥណ្ឌាចូលមកទស្សនៈទាំងពីរក៏ស្របគ្នាតែម្តង។ ឯបង្កាន់ដៃរូបនាគ អមសងខាងផ្លូវទៅកាន់ប្រាសាទនីមួយៗ និងគូទឹកព័ទ្ធជុំវិញប្រាសាទជានិមិត្តរូបនៃការកូរសមុទ្រទឹកដោះក្នុងទស្សនៈ ឥណ្ឌាសម័យដើមក៏បានក្លាយមកជានិមិត្តរូបនៃនយោបាយទឹករបស់ខ្មែរនាសម័យអង្គរ។ ចំណុចនេះបញ្ជាក់ឱ្យឃើញថា សិល្បៈស្ថាបត្យកម្មខ្មែរ មិនគ្រាន់តែជានិមិត្តរូបផ្នែកសាសនាប៉ុណ្ណោះទេ គឺវាបម្រើផលប្រយោជន៍មនុស្សផងដែរ។ អាស្រ័យដោយបំណិនប្រសប់គួរឱ្យកោតស្ញប់ស្ញែងនៃបុព្វបុរសយើងបែបនេះហើយបានជាសិល្បៈស្ថាបត្យកម្មខ្មែរ មានតម្លៃខ្ពង់ខ្ពស់និងទទួលការកោតសរសើរពីមតិជាតិនិងអន្តរជាតិ។

## ២. សិល្បៈចម្លាក់ខ្មែរ

### ២.១. មុខងារនៃចម្លាក់

នៅក្នុងសិល្បៈខ្មែរបុរាណរូបចម្លាក់មានមុខងារសំខាន់ពីរយ៉ាងគឺៈ

-ចម្លាក់សម្រាប់គោរពបូជាៈ ដូចជាបដិមាព្រះពុទ្ធ ព្រះពោធិសត្វ ព្រះសិវៈ និងព្រះវិស្ណុជាដើម។

-ចម្លាក់សម្រាប់លម្អៈ ដូចជាចម្លាក់ក្បាច់ក្បូរផ្សេងៗ ចម្លាក់ភ្ញីផ្កាជាដើម។

### ២.២. ប្រភេទចម្លាក់

ចម្លាក់បុរាណខ្មែរមានបីយ៉ាងគឺចម្លាក់លិប ចម្លាក់លៀនឬចម្លាក់ជ្រៅ និងចម្លាក់លោត(ក្លាយជារូបបដិមា)។

**ក. ចម្លាក់លិប**ៈ គឺក្បាច់ដែលគេឆ្លាក់នៅលើផ្ទាំងថ្មលូតចូលទៅក្នុងផ្ទៃថ្មមើលទៅមិនសូវឃើញខ្ពស់ ឬផុសចេញពីផ្ទាំងថ្មខ្លាំងពេកទេ។ ឧទាហរណ៍ៈ ក្បាច់លិបជារឿងនៅតាមថែវជាន់ទីមួយនៃប្រាសាទអង្គរវត្ត(គេច្រើនឆ្លាក់នៅជញ្ជាំងប្រាសាទ)។

**ខ. ចម្លាក់លៀន**ៈ គឺក្បាច់ដែលឆ្លាក់លៀនខ្ពស់ចេញពីផ្ទៃថ្ម ព្រោះគេដាប់សាច់ថ្មឱ្យជ្រៅមើលទៅរូបចម្លាក់ដូចជាផុសចេញពីផ្ទៃថ្ម។ គេច្រើនឆ្លាក់នៅលើផ្តែរ លើសសរពេជ្រ លើជញ្ជាំងប្រាសាទ។

**គ. ចម្លាក់លោត:** គេឆ្លាក់រូបសត្វ ឬមនុស្សពុំមែននៅលើជញ្ជាំងទេ ពោលគឺដាច់ពីជញ្ជាំងតែផ្អែកជាប់ជញ្ជាំងដោយទម្រ(ព្រោះខ្លាចដួលរលំ)។ ក្រោយមកទៀតគេឆ្លាក់រូបបដិមាដាច់តែឯងពុំបាច់មានទម្រដូចមុនទៀតឡើយ។

## ២.៣. ប្រធានចម្លាក់

រូបចម្លាក់បុរាណមានច្រើនបែបយ៉ាងណាស់តែពេលនេះ យើងលើកយករូបចម្លាក់ (បដិមានិងសត្វ) ដែលទាក់ទងនឹងសាសនា ដែលមាននៅក្នុងប្រាសាទបុរាណខ្មែរយើង។

**ក. ពុទ្ធរូប:** ព្រះពុទ្ធរូបគេបានប្រទះឃើញតាំងពីសម័យនគរភ្នំមកម្ល៉េះ។ ក្នុងសិល្បៈខ្មែរព្រះពុទ្ធរូបគ្មានគ្រឿងអលង្ការទេ ហើយមានព្រះកាយវិការប្លែកៗគ្នា៦ យ៉ាងដូចតទៅ ៖

-ឈានមុទ្រៈ(សមាធិមុទ្រ)៖ព្រះអង្គទ្រង់ភ្នែនបាតព្រះហស្តទាំងពីរលាមកលើដាក់លើភ្លៅមានន័យថា ព្រះអង្គទ្រង់កំពុងសមាធិ។

-ភូមិស្បសមុទ្រៈ ៖ព្រះហស្តឆ្វេងដាក់លើភ្លៅចុងព្រះហស្តស្តាំចុចដីមានន័យថា ព្រះអង្គយកព្រះធរណីជាសាក្សី។

-អភយមុទ្រៈ ៖ ព្រះហស្តលាដាក់នៅខាងមុខ ចង្អុលព្រះហស្តលើកទៅលើមានន័យថាកុំខ្លាច។

-ធម្មចក្រមុទ្រៈ ៖ ព្រះហស្តទាំងពីរមានទម្រង់ជាបង្វិលកងចក្រមានន័យថា ព្រះអង្គសម្ដែងធម៌។

-វរមុទ្រៈ ៖ព្រះហស្តលាដាក់ទៅខាងមុខចង្អុលព្រះហស្តដាក់ទៅក្រោមមានន័យថា សម្បុរធម៌ ឬទាន។

-វិតក្កមុទ្រៈ ៖ចង្អុលដៃខ្មោចមកប៉ះនឹងមេដៃជាសញ្ញានៃទឡ្ហីកម្មថា ការដែលធ្វើរួចហើយ ធ្វើថែមទៀតឱ្យរឹតតែមាំមួនឡើង(បង្ហាញការត្រិះរិះពិចារណា)។ ក្រៅពីរូបដែលមានកាយវិការទាំងនេះគេបានសង្កេតឃើញមាន ព្រះពុទ្ធរូបគង់ភ្នែនមានរូបស្គាំងស្គមឃើញតែឆ្អឹង(ព្រះពុទ្ធធ្វើទុក្ករកិរិយា) និងព្រះពុទ្ធរូបផ្ទុំផ្អៀងទៅខាងស្ដាំ (ព្រះពុទ្ធចូលបរិនិព្វាន)។

នៅមានលក្ខណៈផ្សេងៗទៀតដើម្បីសម្គាល់ព្រះពុទ្ធរូបដូចជា:

- គ្រងចីវរ ទុកស្មាខាងស្ដាំទទេ
- មានសញ្ញាមួយនៅចន្លោះភ្នែក
- មានពក ឬ បន្តុកនៅក្រោយព្រះកេស
- មានសក់ច្រើនរួញ ហើយក្ដួចត្របាញ់ជុំៗ
- មានមុខមូលរាងពងក្រពើ
- មានត្រចៀកធំៗ ហើយវែងធ្លាក់ទៅក្រោម
- មានទឹកមុខញញឹម។ល។

❋ប្រក់នាគ ៖ទ្រង់គង់ដូចសមាធិមុទ្រៈមាននាគពែនខ្លួនធ្វើជាបល្ល័ង្គបើកពពារបាំងពីលើ។ ព្រះពុទ្ធរូបប្រក់នាគជាពុទ្ធរូបបែបខ្មែរសុទ្ធសាធ ព្រោះមាននៅក្នុងរចនាបថខ្មែរមុនរចនាបថឯទៀត។

-ព្រះចេតិយ/ព្រះស្តូប

- ព្រះស្តូបរាងមូល(ដូចបាត្រផ្កាប់ ឬជាចេតិយតូចរាបដែលមានរាងស្រដៀងនឹងសណ្ឋានអកកំបោរ ឬសណ្ឋានចេតិយខ្សាច់។
- ព្រះចេតិយរាងដូចអកកំបោរមានក្បាច់រចនាជាទីសម្រាប់តម្កល់ធាតុ ឬព្រះសិរីរីកធាតុអរហន្តធាតុ។ ព្រះចេតិយមានច្រើនបែបៈ

-ធាតុចេតិយ : សម្រាប់ដាក់ធាតុ។

-បរិភោគចេតិយ : សម្រាប់ដាក់គ្រឿងប្រើប្រាស់ មានបាត្រ ចីវរបស់ព្រះពុទ្ធ។

-ធម្មចេតិយ : សម្រាប់តម្កល់ក្បួនខ្នាតគម្ពីរដីកា ដូចជាធម្មមន្ទីរ ហោត្រ័យជាដើម។

-ឧទ្ទេសិកចេតិយ : ទីដែលសម្រាប់ឧទ្ទិសថ្វាយព្រះពុទ្ធ ឬបុព្វបុរសផ្សេងៗ។

**ខ. ពោធិសត្វ(ព្រះពុទ្ធសាសនាមហាយាន)**

-**លោកេស្វរៈ** : ជាពោធិសត្វជួយសង្គ្រោះនិងឱ្យសុខដល់សត្វលោក។ គេឆ្លាក់រូបពោធិសត្វលោកេស្វរៈ គង់លើផ្កាឈូកមានព្រះហស្តច្រើនទ្រង់កេតនភណ្ឌផ្សេងៗ មានគម្ពីរ ខ្សែផ្កាំ ដប ឬថូផ្កាឈូកជាដើម។ មានគ្រឿងអលង្ការជាច្រើនមានផ្នួងសក់ធំៗ ហើយនៅលើផ្នួងសក់មានព្រះពុទ្ធរូបមួយឈ្មោះ**អមិតាភៈ**។

-**មញ្ជុស្រី** : ជាពោធិសត្វគុលាការ។ គេធ្វើរូបមនុស្សកាន់សៀវភៅមួយនិងព្រះខាន់មួយគង់លើសត្វតោ។

-**សមន្តភទ្រៈ** : ជាពោធិសត្វគ្រប់គ្រងខ្ទាន់(អ្នកកាន់)សាសនា គេធ្វើរូបមនុស្សគង់លើសត្វដំរី។

-**មៃត្រេយ** : ជាពោធិសត្វដែលនឹងបានត្រាស់ជាព្រះពុទ្ធបន្ទាប់ពីព្រះពុទ្ធសមណគោតម។

-**ក្សិតិគត៌** : ជាពោធិសត្វស្រង់មនុស្សពីនរក។

-**វជ្របាណិ** : ជាពោធិសត្វការពារសាសនា។ គេធ្វើរូបមនុស្សកាន់រន្ទះ។

-**ប្រាជ្ញាបារមីតា** : ជាពោធិសត្វស្រី ជានិមិត្តរូបនៃប្រាជ្ញា។

**គ. សិវលិង្គ**: នាសម័យអង្គរគេឃើញមានចម្លាក់រូបលិង្គព្រះឥសូរដែលគេឆ្លាក់អំពីថ្មពណ៌ប្រផេះ ហើយដែលមានរាងរៅដូចខាងក្រោមៈ

-ផ្នែកលើមានរាងមូលវែងដូចសសរ

-ផ្នែកកណ្តាលមានរាង៦ជ្រុង ឬ៨ជ្រុងជាទម្រ

-ផ្នែកក្រោមមានរាង៤ជ្រុងស្មើជាទម្រដែរ

* នៅលើរូបលិង្គខ្លះគេឆ្លាក់មុខមនុស្ស លិង្គបែបនេះគេហៅថា មុខលិង្គ។ គេនិយមតម្កល់លិង្គព្រះឥសូរលើយោនីនាងឧមា (ជាទម្រ)។

**ឃ. ព្រះនារាយណ៍ ឬព្រះវិស្ណុ** : គេឆ្លាក់រូបមនុស្សដែលច្រើនតែមានដៃ៤ មានកេតនភណ្ឌផ្សេងៗដូចជាថាស ខ្យងស័ង្ខ មោង ដុំមូល (ផែនទី) ឬផ្កាឈូក មុដមូលវែង។ នៅជញ្ជាំងប្រាសាទអង្គរវត្តគេប្រទះឃើញព្រះនារាយណ៍ជិះគ្រុឌ ឬព្រះនារាយណ៍ផ្ទុំលើពស់ឈ្មោះ «សេសៈ» នៅកណ្តាលសមុទ្រមានដើមឈូកដុះចេញពីផ្ចិត ហើយនៅលើផ្កាឈូកមានរូបព្រះព្រហ្ម។

**ង. ព្រះហរិហរៈ** : គេឃើញបដិមាព្រះហរិហរៈនៅប្រទេសខ្មែរតាំងពីស.វទី៦នៃគ.សម្ល៉េះ (ឯប្រទេសឥណ្ឌាវិញគេបានរកឃើញកំណើត ព្រះហរិហរៈនាស.វទី១០នៃគ.ស)។ គេបានសាងរូបបដិមាហរិហរៈសម្រាប់អាទិទេពឥសូរ(ចំហៀងខាងស្តាំ) និងអាទិទេពវិស្ណុ (ចំហៀងខាងឆ្វេង) ហើយបដិមានេះរាងរៅសមសួនល្អណាស់។

**ច. សត្វ :** សំណង់ប្រាសាទបុរាណ ទីសក្ការបូជា និងគ្រឹះស្ថានធំៗ មានព្រះវិហារ ព្រះបរមរាជវាំង សារមន្ទីរជាដើមតែងមានលម្អដោយសត្វ និងក្បាច់លម្អមួយចំនួន។ ឯសត្វដែលគេដាក់លម្អតាមទីប្រាសាទបុរាណ ឬកន្លែងដទៃទៀតនោះមានអត្ថន័យដូចខាងក្រោមៈ

**-មករ** : ក្នុងចម្លាក់ខ្មែរមុនសម័យអង្គរនៅតាមប្រាសាទនានា គេនិយមឆ្លាក់រូបសត្វមករនេះនៅតាមផ្តែរទ្វារជារូបពាំផ្កា លុះមកដល់សម័យអង្គរសត្វមករត្រូវបាន គេឆ្លាក់ជាក្បាលព្រួលនាគពាំផ្កាតាមថែវ ឬរចនាសម្ព័ន្ធនានារបស់ប្រាសាទអង្គរវត្ត នៅតាមផ្តែរខ្លះគេឆ្លាក់រូបព្រះភិរុណជិះមករ។ មករជាសត្វតំណាងឱ្យទឹក។

⁕ **បញ្ជាក់** ៖ មករជាឈ្មោះត្រីសមុទ្រមួយប្រភេទមានខ្លួនធំ ក្បាលខ្លីក្រមុប ធ្មេញ និងចង្កូមស្វាញគួរស្ញើម។ តែបើយើងសង្កេត រូបភាពសត្វមករដែលមាននៅតាមផ្តែរឃើញថា មករមានខ្លួនខ្លីកំប៉ាង កន្ទុយក្រពើ មាត់ធំវែង ខាងលើជារាងប្រមោយដូចប្រមោយដំរី។

**-នាគ** : ប្រភេទសត្វល្មូនម៉្យាងដែលមានក្បាលចំនួនសេស (ពី១ដល់៩តាមនិយមឆ្លាក់របស់ជាង)។ តាមទស្សនៈខ្មែរយើង នាគជានិមិត្តរូបដែលកើតចេញមកអំពីសត្វពស់វេកពពារ ដែលចាស់បុរាណបានប្រើសមាធិត្រិះរិះប្រឌិតជារូបនាគឡើង។ នាគដែលមានចំនួនសេស(១.៣.៥.៧.៩) គឺតំណាងឱ្យជីវិតរស់នៅ។ ឯនាគដែលមានចំនួនគូ (២.៤.៦.៨) គឺជាតំណាងឱ្យសេចក្តីស្លាប់។ ដោយសត្វនាគជារូបដែលក្លាយមកពីពស់ ហើយសត្វពស់ជាសត្វចាស់សក(គេមិនដែលឃើញសត្វពស់ងាប់ដោយខ្លួនឯងទេក្រៅពីការសម្លាប់ពីអ្នកដទៃ) ម៉្យាងទៀតជាជំនិះរបស់ព្រះវិស្ណុ (**នាគអនន្ត**

Ananta ឬ**សេសៈ**Sèsa)ជាឈ្មោះតែមួយ ជាពស់ដែលគ្មានទីបំផុត Sèsa អ្វីដែលនៅសេសសល់ក្រោយពេលបំផ្លាញ។ តាមន័យខាងលើនេះនាគជានិមិត្តរូបតំណាងភាពអមតៈ។ នៅក្នុងប្រព័ន្ធពហុទេវៈ នាគជាជំនិះរបស់ឆ្មាំទិសបស្ចិម(ព្រះភិរុណជិះនាគ)។ ក្រៅពីទៅប្រចាំទិសបស្ចិមព្រះភិរុណជាទេវៈនៃទឹកភ្លៀង)នាគជាសត្វតំណាងឱ្យទឹក(ទឹកភ្លៀង)ផងដែរ។ នៅសម័យបុរាណគ្រប់ប្រាសាទគេតែងធ្វើរូបនាគ ឬសត្វមករជាចម្លាក់ជានិច្ច ដើម្បីជាតំណាងឱ្យនយោបាយទឹក ឬប្រព័ន្ធធារាសាស្ត្រក្នុងវិស័យកសិកម្ម។ ពេលដែលព្រះពុទ្ធ បានត្រាស់ភ្លាមៗ មានភ្លៀងមួយមេយ៉ាងធំមកអបអរព្រះអង្គ ទើបនាគមច្ចុលិនចេញពីស្រះមច្ចុលិនមកបើកពពារឆ្វាយរង្វេលការពារព្រះអង្គកុំឱ្យត្រូវទឹកភ្លៀង។ តាមរយៈនេះ នាគត្រូវបានគេចាត់ទុកជាឆ្មាំមរតក។ ក្រៅពីចម្លាក់លម្អតាមប្រាសាទនានានៅតាមវត្តអារាម ឬតាមរបស់ប្រើប្រាស់ផ្សេងៗដូចជា រទេះគោ នង្គ័ល (សម្រាប់ច្រត់ព្រះនង្គ័ល) នៅក្បាលរទេះគេឆ្លាក់ជារូបក្បាលនាគ។ សរុបមកតួនាទីរបស់នាគមាន៖

- ជាសត្វតំណាងឱ្យភាពអមតៈ
- ជាសត្វតំណាងឱ្យទឹក
- ជាសត្វតំណាងឱ្យឆ្មាំមរតក

-**តោ** : សត្វតោមានឫកពារមាំមួនខ្លាំងក្លា និងភាពអង់អាចបានឈរយ៉ាងសង្ហាតាមផ្លូវចូល ឬភ្លោងទ្វារប្រាសាទ។ ទីកន្លែងណាដែលមានសត្វតោនៅ មិនដែលមានអ្នកណាមួយចូលទៅក្បែរនោះឡើយ ហេតុនេះនៅតាមប្រាសាទបុរាណដែលជាទីសក្ការៈ ឬមានរបស់មានតម្លៃ គេតែងដាក់សត្វតោឱ្យនៅយាមជាទ្វារបាល។ ម៉្យាងទៀតតោជាជំនិះរបស់ព្រះពោធិសត្វមញ្ជុស្រី ដែលពោធិសត្វតំណាងឱ្យភាពយុត្តិធម៌ និងតុលាការ។ តាមន័យខាងលើនេះតោមានតួនាទីជា៖

- តំណាងឱ្យភាពអង់អាចក្លាហាន អំណាចយុត្តិធម៌
- ជាឆ្មាំមរតក
- តំណាងឱ្យដី

❋តោក៏ជាឆ្មាំមរតកដូចនាគដែរ តែនាគជាសត្វតំណាងឱ្យទឹក ឯតោវិញជាសត្វតំណាងឱ្យដី។

-**គ្រុឌ** : គ្រុឌជាប្រភេទបក្សីម៉្យាង ហើយជាជំនិះរបស់ព្រះវិស្ណុ។ នៅក្នុងទេវកថា ព្រាហ្មណ៍សាសនា គ្រុឌជាសត្រូវស៊ីសាច់ហុតឈាមជាមួយសត្វនាគ។ ដោយសារកម្លាំងដ៏ខ្លាំងក្លារបស់គ្រុឌត្រូវបានគេយកមកធ្វើជាទម្រដំបូលព្រះវិហារ ឬសំណង់ស្ថាបត្យកម្មនានាជាលម្អ។

❋គ្រុឌជាសត្វតំណាងឱ្យអាកាស។

ក្រៅពីប្រភេទចម្លាក់ខាងលើ បុព្វបុរសខ្មែរយើងបានកែច្នៃរចនានូវក្បាច់ចម្លាក់ដែលរចនាចេញពីសត្វ ធម្មជាតិ រុក្ខជាតិ (ដើម ស្លឹក ផ្កា ផ្លែ)មកលម្អនៅតាមប្រាសាទនិងវត្ថុប្រើប្រាស់ផ្សេងៗ។ កន្លងមកគេចែកក្បាច់ខ្មែរជា៤ប្រភេទធំៗគឺក្បាច់អង្គរ ក្បាច់ភ្ញីទេស ក្បាច់ភ្ញីវល្លិ៍ និងក្បាច់ភ្ញីភ្លើង។ នៅមានក្បាច់រាយរងជាច្រើនទៀតដែលគេយកមកប្រើលាយជាមួយនឹងក្បាច់ធំៗនេះដែរ ដូចជាក្បាច់ធ្មេញត្រី ធ្មេញក្របី ពងត្រី...។[15]

## ក្បាច់ចម្លាក់ខ្មែរ (ទម្រង់ក្បាច់មូលដ្ឋាន)

១. ទម្រង់ត្របកឈូកចំពីមុខ



២. ទម្រង់ត្របកឈូកចំហៀង ឬកន្ទុយហង្ស



៣. ទម្រង់ក្បាច់ភ្ញីទេស



៤. ទម្រង់ក្បាច់ភ្ញីភ្លើង



៥. ទម្រង់ទ្រនុងនាគ



៦. ទម្រង់សំបកទំពាំង



៧. ទម្រង់ពងត្រី



៨. ទម្រង់ហៀន



៩.ទម្រង់វង់ហៀន ឬគូថខ្យង



១០. ទម្រង់ក្បាច់ធ្មេញត្រី



[15] វ៉ៃយំ, ក្បាច់ខ្មែរ, ២០០៥។

១១. ទម្រង់ក្បាច់ធ្មេញក្របី



១២. ទម្រង់ក្បាច់កេសរ



១៣. ទម្រង់ក្បាច់កញ្ចាំង



១៤. ទម្រង់ច័ក្កច័ន



១៥. ទម្រង់ផ្កាច័ន ឬដកច័ន



១៦. ទម្រង់មុនីពន់



## រូបភាពខ្លះៗនៃក្បាច់ខ្មែរ



























## ៣. សិល្បៈគំនូរ

គំនូរជាសិល្បៈទី៣ក្នុងចំណោមសិល្បៈចម្បងទាំង៧។ គំនូរជាសិល្បៈរូបភាពមួយដែលពុំមានចលនាដូចរបាំ ឬមានសូរសំឡេងដូចតន្ត្រីទេ។ ប៉ុន្តែសិល្បៈរូបភាពបានបង្កប់នូវអត្ថសញ្ញាណនិងអត្ថន័យយ៉ាងជ្រាលជ្រៅទៅតាមកម្រិតយល់ដឹងរបស់អ្នកវិភាគ។ សិល្បៈគំនូរមានដូចជាគំនូរវាសគំនូរបៀក គំនូរផាត់ពណ៌...។ល។

នៅក្នុងប្រវត្តិសិល្បៈខ្មែរបុរាណ គំនូរជាផ្នែកមួយដែលយើងមិនសូវដឹង មិនសូវយល់ច្បាស់ដោយសារភស្តុតាងដែលអាចយកមកពិនិត្យសិក្សាបាន កម្រមានទុករហូតមកដល់បច្ចុប្បន្ន។ បើយើងគិតពីកម្រិតដ៏ល្អនៃរូបចម្លាក់ថ្មដែលមានពាសពេញប្រាសាទបុរាណ យើងអាចស្មានថា គំនូរនៅក្នុងសម័យបុរាណក៏អាចមានការលូតលាស់យ៉ាងខ្លាំងដែរ ឧទាហរណ៍នៅក្នុងប្រាសាទនាងខ្មៅ សតវត្សទី១០ បើយើងពិនិត្យមើលច្បាស់ឃើញមានស្លាកស្នាមគំនូរ។ ផ្ទុយពីចម្លាក់ថ្ម គំនូរច្រើនគូរនៅលើផ្ទាំងឈើ លើបាយអរ ឬស្លឹករឹត (តិចតួចណាស់) ឬក្រាំង ដែលពិបាកការពារនឹងខ្យល់ ទឹក និងភ្លើងបាន។ សព្វថ្ងៃគំនូរដែលមាននៅសេសសល់គឺមានតែនៅវត្តអារាម ដូចជានៅលើជញ្ជាំងព្រះវិហារនៃវត្តកំពង់ត្រឡាច ឬក្នុងវត្តរាជបូណ៌ និងព្រះវិហារព្រះកែវមរកតជាដើម។ ជាទូទៅគំនូរទាំងនោះពុំមានអាយុច្រើនជាង៣០០ឆ្នាំទេ។ គំនូរបែបនេះ ជាទូទៅក្នុងសង្គមខ្មែរគេហៅថា «គំនូរបុរាណ» ។ ក្រៅពីគំនូរបែបបុរាណនេះ មានគំនូរមួយបែបទៀតដែលគេនិយមហៅ «គំនូរសម័យ ឬគំនូរទំនើប»។ ការកំណត់ហៅ «គំនូរទំនើប» នេះគឺជាទស្សនៈមួយដែលទើបតែកើតឡើងនៅកណ្តាលសតវត្សទី២០ ពោលគឺលេចចេញពីស្ថាប័នបណ្តុះបណ្តាលផ្នែកសិល្បៈដែលបង្កើតឡើងនៅចុងទសវត្សទី២០ បារាំងហៅថា Ecole des arts Cambodgiens (សាលារចនា)។[16]



១. គំនូរនារីផល (គំនូរសខ្មៅ ប្រទេសបារាំង សារមន្ទីរខេត្តអាឡាំងសុង ចុងស.វទី១៩. MT.
២-៣.គំនូរនារីផលពណ៌ដកស្រង់ពីច្បាប់ត្រៃភូមិខ្មែរតម្កល់នៅបណ្ណាល័យជាតិបាងកកបោះពុម្ពដោយអ្នកនិពន្ធនៅឆ្នាំ ១៩៩៦ នៅភ្នំពេញ MT.



គំនូររាហ៊ូនៅតាមសសរព្រះវិហារ( www. khmerenaissance.info )

[16] វ៉ែយ៉ំ, ខ្មែរប្រឈមនឹងវប្បធម៌, ២០០១, ទំព័រ ២៣៩។

## ៤. សិល្បៈតន្ត្រី

### ៤.១. តន្ត្រីខ្មែរ[17]

#### ក. តន្ត្រីអារក្ស

ជាតន្ត្រីមួយប្រភេទដែលគេប្រគុំឡើងថ្វាយអ្នកតា ឬព្រលឹងធម្មជាតិដើម្បីសុំសេចក្តីសុខសប្បាយ ឬក៏គេលេងភ្លេងនេះដើម្បីបញ្ចូលខ្មោចដែលមានឫទ្ធិអំណាចមកសាកសួរ និងអង្វរករឱ្យជួយស្រោចស្រង់អ្នកជំងឺព្រមទាំងលេងដើម្បីអញ្ជើញអ្នកទាំងនោះមកលេងសប្បាយ និងលៀងភោជនាហារដែលគេហៅថា «**ឡើងរោង ឬលៀងអារក្ស**»។ ឧបករណ៍ភ្លេងក្នុងតន្ត្រីនេះមានដូចជាទ្រខ្មែរ ចាប៉ីដងវែង(ខ្សែមួយ) ប៉ីបបុស ប៉ីពក ស្គរមួយគូ សាដៀវមួយ ឈិងមួយ។

#### ខ. តន្ត្រីអាពាហ៍ពិពាហ៍

ជាតន្ត្រីមួយប្រភេទដែលបែកចេញពីវង់តន្ត្រីអារក្ស ប្រគុំកំដរពិធីមង្គលការទៅតាមកម្មវិធីជាបន្តបន្ទាប់។ ចំណែកឧបករណ៍ភ្លេងដូចគ្នានឹងឧបករណ៍នៅក្នុងវង់តន្ត្រីអារក្សដែរ។

#### គ. តន្ត្រីពិណពាទ្យ

ជាតន្ត្រីមួយប្រភេទដែលគេប្រគុំឡើងដើម្បីកំដររបាំក្បាច់បុរាណ ថ្វាយព្រះអាទិទេព ឬបារមីព្រះដែលមានមហិទ្ធិឫទ្ធិ កំដរបុណ្យសព បុណ្យ៧ថ្ងៃ បុណ្យ១០០ថ្ងៃ ឬបុណ្យខួប១ឆ្នាំ និងបុណ្យខួបជាបន្តបន្ទាប់។ លើសពីនេះវង់តន្ត្រីពិណពាទ្យមានតួនាទីចាំបាច់បម្រើក្នុងព្រះរាជពិធី និងពិធីបុណ្យសាសនា មានបុណ្យកឋិនទាន បុណ្យបញ្ចុះសីមា បុណ្យអភិសេកព្រះពុទ្ធរូបជាដើម។ ទន្ទឹមនឹងនេះតន្ត្រីពិណពាទ្យមាននាទីលេងកំដរសិល្បៈល្ខោនខោល ស្បែកតូច និងស្បែកធំ។ តន្ត្រីពិណពាទ្យវង់ធំមានឧបករណ៍ច្រើនមុខដូចជារនាតឯក១ រនាតដែក១ រនាតថុង១ រនាតថោង១ ស្រឡៃតូច១ ស្រឡៃធំ១ គងវង់ធំ១ គងវង់តូច១ សម្ភោរ១ ស្គរធំ១គូ ឈិង។ ឯវង់តូចមានរនាតឯក១ គងវង់ធំ១ ស្រឡៃ១ សម្ភោរ១ ស្គរធំ១គូ។

#### ឃ. តន្ត្រីមហោរី

ជាតន្ត្រីមួយប្រភេទដែលគេប្រគុំឡើងដើម្បីបន្ធូរបន្ថយបរិយាកាសឱ្យសប្បាយរីករាយ កំដរក្នុងពិធីសាសនា ពិធីបុណ្យតាមបែបប្រពៃណី និងពិធីជប់លៀងពិសាភោជនាហារជាដើម។ សូមបញ្ជាក់ថាតន្ត្រីមហោរីដើមឡើយជាកម្មសិទ្ធិរបស់ព្រះរាជវាំង ពោលគឺសម្រាប់ស្តេច នាម៉ឺន មន្ត្រី ឬអ្នកដែលមានឋានៈខ្ពង់ខ្ពស់ តែក្រោយមក ជាពិសេសក្រោយសម័យអង្គរ វង់ភ្លេងនេះក៏ក្លាយទៅជាវង់ភ្លេងសាមញ្ញសម្រាប់ប្រជារាស្ត្រទូទាំងប្រទេស។ តន្ត្រីមហោរីច្រើនតែលាតត្រដាងអំពីជីវិតខ្មែរពិតៗ ដូចជាចម្រៀងរៀបរាប់ពីសម្រស់ធម្មជាតិ ចម្រៀងក្នុងការងារ ចម្រៀងស្នេហាថ្នាក់ថ្នមរវាងគូសង្សារ ឬការបបោសអង្អែលរបស់ម្តាយចំពោះកូនរហូតដល់ទុក្ខសោកព្រាត់ប្រាស។ វង់ភ្លេងមហោរីមានឧបករណ៍ភ្លេងដូចជារនាតឯក១ រនាតធុង១ ខ្លុយ១ តាខេ ឬក្រពើ១ ទ្រអ៊ូ១ ទ្រសោតូច១ ស្គរថូនរមនា ឈិង។ បើជាវង់ធំគេបន្ថែមឧបករណ៍ខ្លះទៀតដូចជា ទ្រសោធំ១ ទ្រឆេ-អ៊ូ១ ទ្រឆេ-សោ១។

[17] កែវ ណារុំ, តន្ត្រីនិងជីវិតខ្មែរ, ១៩៩៥។

### ង. តន្ត្រីយីកេ

ជាតន្ត្រីមួយប្រភេទដែលគេប្រគំឡើងដើម្បីកំដរល្ខោនយីកេ។ តន្ត្រីយីកេមានភាពទន់ភ្លន់ដូចតន្ត្រីមហោរីដែរ តែបង្អួសល្វតល្វន់ ហាក់អណ្តែតលើផ្ទៃទឹក ជួនរេចុះរេឡើងតាមកម្លាំងខ្យល់ដ៏ស្រទន់ និងត្រជាក់។

### ច. តន្ត្រីបាសាក់

ជាតន្ត្រីមួយប្រភេទដែលគេប្រគំឡើងដើម្បីកំដរល្ខោនបាសាក់។ សាច់ភ្លេងបាសាក់ផ្ទុយពីសាច់ភ្លេងយីកេ ព្រោះមានភាពឆាប់រហ័ស និងគឹកកងដោយសន្ទឹកស្គរ។ ឧបករណ៍ភ្លេងក្នុងវង់តន្ត្រីបាសាក់មានទ្រអ៊ូចំហៀង១ ទ្រឆេ១ ឃឹមតូច១ ឃឹមធំ១ ឈិង ប៉ោឡោគា (ឆាប ប៉ាន់ ឃ្មោះគង) ស្គរឡុក១ ស្គរធំ១ ខ្លុយ១។

### ឆ. តន្ត្រីចាប៉ី

ជាចម្រៀងមួយប្រភេទដែលគេច្រៀងរំឭកអំពីក្បួនសាស្ត្រានៃពាក្យប្រៀនប្រដៅរបស់ដូនតាពីសីលធម៌ក្នុងការរស់នៅ ពីសុភាសិត ឬរៀបរាប់ពីរឿងព្រេងនិទានផ្សេងៗ។ ចម្រៀងចាប៉ីមាននាទីជួយអប់រំមនុស្សឱ្យមានការរីកចម្រើន និងសីលធម៌នៅក្នុងការរស់នៅ។ ចម្រៀងចាប៉ី គេអាចច្រៀងតែម្នាក់ឯង ឬច្រៀងពីរនាក់ដោយឆ្លើយឆ្លងគ្នា។ ចម្រៀងចាប៉ី គេសម្តែងកំដរពិធីបុណ្យសាសនា ពិធីសម្ពោធសាលារៀន ស្ពានថ្នល់ នៅក្នុងវត្ត ឬកណ្តាលវាល។

### ជ. តន្ត្រីអាយ៉ៃ

ជាចម្រៀងមួយប្រភេទដែលគេច្រៀងបកស្រាយអំពីបញ្ហាសង្គម រឿងព្រេង សុភាសិត...ដោយលើកបញ្ហាចោទឆ្លើយដេញដោលគ្នាម្តងម្នាក់ រវាងស្រីនិងប្រុសដែលជាគូវិវាទ គឺជាការដេញប្រាជ្ញាជំរុញទៅរកការយល់ដឹង។ គេច្រៀងចម្រៀងអាយ៉ៃសម្រាប់កំដរពិធីបុណ្យសាសនា ឬសម្ពោធសមិទ្ធផលផ្សេងៗដូចចម្រៀងចាប៉ីដែរ។

### ឈ. តន្ត្រីប្រឹន

ជាតន្ត្រីមួយប្រភេទដែលគេប្រគំឡើងដើម្បីសុំពរពីវត្ថុសក្តិសិទ្ធិ ពិសេសក្នុងពិធីសុំទឹកភ្លៀង។ គេក៏អាចលេងតន្ត្រីនេះ ក្នុងពេលកំពុងបំពេញការងារដើម្បីបន្ធូរបរិយាកាសតានតឹង។ ជួនកាលគេលេងនៅពេលយប់ ក្រោយពេលសម្រាកពីការងារ។ ប្រធានបទដែលគេលើកយកមកច្រៀង គឺធម៌ក្នុងសាសនា សុភាសិត ក្បួនច្បាប់ផ្សេងៗ ការអប់រំក្នុងគ្រួសារ។ ឧបករណ៍តន្ត្រីក្នុងតន្ត្រីប្រឹនមានដូចជាប៉ីទ្រ ឈិង ក្រាប ស្គរ ចង្រ្កង់ដំបែរ។

### ញ. តន្ត្រីឆៃយ៉ាំ

ជាតន្ត្រីមួយប្រភេទដែលគេប្រគំឡើងដើម្បីកំដរក្នុងពិធីបុណ្យដែលមានភាពសប្បាយរីករាយដូចជាពិធីបុណ្យផ្កា កឋិន បំបួសនាគជាដើម។ តន្ត្រីឆៃយ៉ាំ គឺជាអ្នកនាំមុខក្នុងការដង្ហែក្បួនដូចជាដង្ហែនាគចេញពីផ្ទះទៅកាន់វត្ត ឬការហែអង្គកឋិនទានប្រទក្សិណជុំវិញព្រះវិហារជាដើម។ ក្រៅពីនេះគេក៏អាចយកតន្ត្រីឆៃយ៉ាំទៅហែក្នុងក្បួនផ្សេងៗដទៃទៀតដែរ ដូចជាការហែក្បួនទិវាមហោស្រពសិល្បៈ

ឬនាំមុខថ្នាក់ដឹកនាំពីទីមួយទៅកាន់ទីមួយទៀត។ ចំណែកឯឧបករណ៍ភ្លេងក្នុងវង់តន្ត្រីនេះវិញមានស្គរវែង ៥, ៧, ៩ ទៅតាមលទ្ធភាពដែលគេហៅថា ស្គរឆៃយ៉ាំ ក្រាប១ ឬ១គូ ឆាប១ ឬ១គូ គងម៉ង់ ជាអ្នកឱ្យចង្វាក់ ឬមេចង្វាក់។ ទំនុកច្រៀងជាពាក្យកំប្លុកកំប្លែងមានន័យលើកសរសើរថ្នាក់ដឹកនាំ ឬអ្នកផ្ដើមបុណ្យ។ ភាគច្រើនមានន័យដៀមដាមរបស់ពួកបុរសៗឱ្យនារី។ ពាក្យនោះជាពាក្យខិល មិនផ្ដេសផ្ដាសទេ គឺតែងនាំឱ្យអ្នកស្ដាប់សើចសប្បាយក្អាកក្អាយ។

**ឯ. តន្ត្រីស្គរឈ្នះ**

ជាតន្ត្រីមួយប្រភេទដែលគេលេងដើម្បីកំដរពិធីដង្ហែសព កីឡាប្រដាល់សេរី ដង្ហែព្រះពុទ្ធរូប ដង្ហែទៀនព្រះវស្សា ដង្ហែជាតុអ្នកមានគុណទៅបញ្ចុះ។ ប៉ុន្តែឈ្មោះស្គរឈ្នះ(ខ្លងខែក) តែងជាស់អារម្មណ៍ប្រជារាស្ត្រឱ្យមើលឃើញតែក្ដីមរណៈតែមួយមុខប៉ុណ្ណោះ។ ឧបករណ៍ភ្លេងនៃតន្ត្រីស្គរឈ្នះមានស្គរយោន១ ស្គរយោន២ ស្រឡៃតូច១។

**ប. តន្ត្រីត្រៃលក្ខណ៍**

ជាវង់តន្ត្រីដែលគេប្រគំឡើងសម្រាប់កំដរពិធីបុណ្យសព។ ខ្មែរនិយមហៅតាមពាក្យសាមញ្ញថា កន្ទ្រាំមីង កន្ទាំមីង ទាំមីង ធម្មមីង ឬម៉ងគ្រំ។ ឯបងប្អូនខ្មែរនៅកម្ពុជាក្រោមហៅថា ភ្លេងគងស្គរ ភ្លេងបណ្ដើរស្គរ។ ឧបករណ៍ភ្លេងក្នុងវង់តន្ត្រីនេះ គឺគងវង់ចំណិតខែដែលមានផ្លែ៨ឬ៩(តំណាងតំណក់ទឹកភ្លៀង) ស្គរធំ១ គងដោះធំ២ និងស្រឡៃ១ ដែលមានចម្រៀងយ៉ាងកំសត់។ វង់តន្ត្រីត្រៃលក្ខណ៍សម្រាប់លេងកំដរតែក្នុងពិធីបុណ្យមានសពតម្កល់និងក្នុងពេលលើកសពទេ។ វង់តន្ត្រីទាំងមូលជានិមិត្តរូបនៃការវិលកើត វិលស្លាប់ក្នុងវដ្តសង្សារ ដូចទឹកសមុទ្រ និងទឹកទន្លេ ស្ទឹង ត្រូវកម្ដៅហួតជាពពកអណ្ដែតឡើងលើអាកាសវេហាស៍ រួចត្រូវខ្យល់ត្រជាក់បក់បោកឱ្យបែកធ្លាយ ជាតំណក់ទឹកភ្លៀងស្រក់ចុះមកលើផែនដីជ្រាបចូលក្នុងបឹង ស្ទឹង ទន្លេ សមុទ្រវិញ។ ក្នុងពេលប្រគំដើម្បីជានិមិត្តរូបនៃ«ការបែកកាយ រំលាយខន្ធ» នោះ តាមទំនៀមទម្លាប់ តន្ត្រីករត្រូវអង្គុយចេញពីគ្នា ឬអង្គុយទល់ខ្នងគ្នា។

## ៤.២. តន្ត្រីខ្មែរលើ[18]

**ក. វង់គងស្គាន់ ឬសំរីទ្ធ** (ជនជាតិ ទំពួន គ្រឹង ព្នង ព្រៅ ចារ៉ាយ) មានចំនួនគងតិច ឬច្រើនទៅតាមពិធីៈ គង១៣ គង១២ គង៨ គង៦ គង២(ផ្សំផ្គុំកូនចៅ)។





របាំគងប្រើឃ្មោះ និង ផឹងមណ្ឌលគិរី, ក្បាលសម្ព័ន្ធមន-ខ្មែរ ចមា វៀតណាមកណ្ដាល ឯកសារបារាំង មុន ១៩៥០ គងទៅផ្ទះអ្នកស្រុកខេត្តតាកែវ

CHANBOKEO.COM

[18] សូមអាន ពេជ្រ ទុំក្រវិល, តន្ត្រី របាំ និងល្ខោនខ្មែរ, ២០១០។

ខ. វង់តន្ត្រី ហ្គុង ប. ឬគងឫស្សី

 

គ. ឌីងប៊ុក ឬប៊ុងប៊ុ (ស្គរបំពង់ឫស្សីទះ)

 

ឃ. ហ្គុងណាក (រនាតបំពង់ឫស្សី)



រូបលេខ ៦: បុរសខ្មែរលើ-គ្រឹង លេងឧបករណ៍
តន្ត្រី **គងណាក** .២០០១ ។

**ង. ម៉ិម** : គឺជាឧបករណ៍ភ្លេងរបស់អម្បូរខ្មែរ-មន ដែលបានចាប់បដិសន្ធិឡើងនាសម័យបុរេប្រវត្តិសាស្ត្រ ហើយត្រូវបានបន្តប្រើរហូតដល់សម័យបច្ចុប្បន្ន នៅក្នុងសហគមន៍ខ្មែរដើម ជាពិសេសក្រុមកុលសម្ព័ន្ធគ្រឹងនិងទំពួននៅខេត្តរតនគិរីជាដើម ។





រូបលេខ១៣: រូបចម្លាក់នាងទេពអប្សរា និងកំដរដោយឧបករណ៍តន្ត្រីមិម
នៅប្រាសាទបាយ័ន ជ្រុងខាងកើតឆៀងខាងត្បូង ថែវខាងក្រៅ( សតវត្សរ៍ទី១៣) ។
( ប្រភព : កែវ ណារុំ. ២០០៥. ទំព័ ១១៧) ។



ច. ហ្គងរ៉ង (គងរ៉ង) និងន្លូម (ខ្លុយ)



ឆ. ហេតហូត



## ៤.៣. តន្ត្រីសម័យ[19]

តន្ត្រីសម័យនេះបានហូរចូលមកប្រទេសកម្ពុជាពីបស្ចឹមប្រទេស ពិសេសក្នុងរជ្ជកាលព្រះបាទនរោត្តម (១៨៥៩-១៩០៤) ពោលគឺក្នុងពេលដែលមានវត្តមានអាណាព្យាបាលបារាំង។ នៅក្នុងអំឡុងឆ្នាំ១៩៤០ មានភ្លេងត្រែដែលខ្មែរនិយមហៅថា «**ភ្លេងម៉ានីល**» ហើយវង់ភ្លេងនេះបង្កើតបានជាតន្ត្រីសម័យសម្រាប់កែកម្សាន្តដែលខ្មែរនិយមហៅថា «**ភ្លេងអ័រកេស**»។ ចាប់ពីពេលនោះមក ខ្មែរយើងចាប់ផ្តើមមានអ្នកនិពន្ធបទភ្លេងនិងទំនុកច្រៀងខាងផ្នែកតន្ត្រីសម័យយ៉ាងល្បីល្បាញមាន ដូចជាព្រះបាទសម្តេច នរោត្តម សីហនុ ដែលទ្រង់ជាកវីនិពន្ធដ៏ឆ្នើម។ ក្នុងពេលនោះដែរក៏មានអ្នកចម្រៀងដ៏ល្បីៗដូចជា អ្នកស្រី ម៉ៅ សារ៉េត អ្នកស្រី កែវ មន្ថា អ្នកស្រី ហួយ មាស អ្នកស្រី ប៉ែន រ៉ន លោក សុស ម៉ាត់ លោក មាស សាម៉ន លោក អ៊ិន យ៉េង លោក ស៊ិន ស៊ីសាមុត អ្នកស្រី រស់ សិរីសុទ្ធា។ល។

## ៥. សិល្បៈរបាំ[20]

របាំក៏ដូចជាល្ខោន តន្ត្រី ចម្រៀង កំណាព្យ ចម្លាក់ និងទម្រង់សិល្បៈដទៃទៀតទាំងអស់ដែរ គឺសុទ្ធតែជាតម្រូវការរបស់ជីវិតខ្មែរទាំងអស់។ ដោយហេតុហ្នឹងហើយ ទើបខ្មែរកើតទម្លាប់ប្រើពាក្យថា

[19] សូមអាន ពេជ្រ ទុំក្រវិល, តន្ត្រី របាំ និងល្ខោនខ្មែរ, ២០១០។

[20] ដដែល។

«**ជីវិតគឺសិល្បៈ ហើយសិល្បៈគឺជាជីវិត**» នេះឯង។ តាំងពីថ្ងៃកើតដល់ថ្ងៃស្លាប់ ជីវិតខ្មែរត្រូវការសិល្បៈជាចាំបាច់។ ម្ដាយបំពេរកូនតាំងពីនៅជាទារក...រហូតដល់ពេលស្លាប់សំឡេងស្មូត្រព្រះធម៌មកជំនួសវិញ។

-ពេលរស់ធ្លាក់តាំងពីក្បាលដណ្ដើរ ស៊ុមតែ ក្បាក់តែ វែក ត្រឡោក ហិបស្លា អកកំបោរ...ដល់ពេលស្លាប់ ធ្លាក់ក្ដារមឈូស បិទក្រដាស់ពណ៌ មេរុលម្កចាក់ចេក។

ប្រជាជនខ្មែរត្រូវការរបាំដើម្បីរាំថ្វាយអារក្ខ អ្នកតា សុំសេចក្ដីសុខ រាំបួងសួងសុំទឹកភ្លៀងសម្រាប់ធ្វើស្រែចម្ការ រាំបន់ស្រន់សុំឱ្យវត្ថុសក្ដិសិទ្ធិជួយបំបាត់ឧបទ្រព្យចង្រៃ រាំដើម្បីសុំសុខសប្បាយក្នុងពេលប្ដូរភូមិករស់នៅក្នុងភូមិថ្មី រហូតដល់រាំដើម្បីកែកម្សាន្ត ឬបំបាត់ការនឿយហត់ក្រោយពេលធ្វើពលកម្មនានាក្នុងជីវិតថែមទៀត។ ជាទូទៅនៅប្រទេសកម្ពុជា យើងសង្កេតឃើញមានរបាំជាច្រើនដែលមានលក្ខណៈខុសៗគ្នាទាំងប្រភពកំណើត ទាំងរូបភាព ពណ៌សម្បុរ ទាំងតួនាទីក្នុងសង្គមផងដូចជាៈ

-របាំខ្លះមានប្រភពចេញមកពីសាសនាព្រាហ្មណ៍ រួចធ្វើដំណើរឆ្លងកាត់ដំណាក់កាលជាច្រើនមកដល់សម័យពុទ្ធសាសនាមហាយាន រួមទាំងថេរវាទ ជាប្រភេទសិល្បៈទេវៈដែលគេប៉ាន់ស្មានថា ជាស្នាដៃច្នៃប្រឌិតរបស់អ្នកប្រាជ្ញរាជបណ្ឌិត រួចក្រោយមកជិតជាប់ក្នុងពិធីនានានៃព្រះបរមរាជវាំង។

-របាំខ្លះទៀត មានប្រភពចេញមកពីជំនឿអារក្ខ អ្នកតា(ជំនឿខ្មែរដើម) ហើយជារបាំដែលត្រូវថែបន្តគ្នាពីមួយជំនាន់ទៅមួយជំនាន់ដែលគេរាប់ថាជាមរតក «**បន្តត្រកូល**» របស់ជនជាតិខ្មែរ និងរបស់ជនជាតិភាគតិចដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាតាមតំបន់ខុសៗគ្នា និងមានទម្លាប់ ខុសៗគ្នាខ្លះផង ដែលអ្នកស្រាវជ្រាវច្រើនយល់ថា គឺជាស្នាដៃច្នៃប្រឌិតដែលចេញមកពីប្រភពមហាជន ប្រជាជន អ្នកស្រែចម្ការ។

-និងមានរបាំមួយប្រភេទទៀត ជារបាំដែលមានប្រជាប្រិយធំធេងនៅក្នុងប្រទេសកម្ពុជាទាំងមូល ដែលប្រជាជនខ្មែរទាំងក្មេងទាំងចាស់ ទាំងប្រុសទាំងស្រី ចេះរាំរបាំនេះទាំងអស់គ្នា នោះគឺជារបាំសម្រាប់កែកម្សាន្ត លំហែកាយ និងធ្វើឱ្យសប្បាយចិត្តបំបាត់ការនឿយហត់ពីពលកម្មនានា។

គេចែករបាំខ្មែរជាបីប្រភេទគឺ របាំប្រជាប្រិយ របាំប្រពៃណី និងរបាំព្រះរាជទ្រព្យ ឬរបាំក្បាច់បុរាណខ្មែរ។

## ៥.១. របាំប្រជាប្រិយ

របាំប្រជាប្រិយខ្មែរជាប្រភេទរបាំដែលងាយចាំ ងាយចេះ ហើយងាយក្នុងការរៀបចំសម្ដែងទៀតផង។ ប្រជាជនខ្មែរតាំងពីព្រះរាជា នាម៉ឺនសព្វមុខមន្ត្រី រហូតដល់ប្រជារាស្ត្រ ទាំងក្មេងទាំងចាស់ ប្រុសស្រីចេះរាំរបាំនេះគ្រប់ៗគ្នា។ របាំប្រជាប្រិយខ្មែរមានដូចជា របាំរាំវង់ រាំក្បាច់ សារ៉ាវ៉ាន់ ប្រើន កន្ទ្រឹមឡាំលាវ។ល។

<u>**អត្ថន័យ**</u>:

សិល្បៈរបាំប្រជាប្រិយខ្មែរដែលរាំជារង្វង់មូល ហើយប្រើកាយវិការនិងក្បាច់ដៃ «**ជីប**» ពីក្រោមហើយលើកឡើង «**លា**» នោះវិញ មានន័យថា ជាការបង្កើតសាមគ្គីភាពរវាងគ្នានឹងគ្នាផង ការបង្ហាញពី

សុភមង្គលក្នុងជីវិតខ្មែរផង និងជានិមិត្តរូបនៃវង្វង់ជីវិត ដែលត្រូវតែមានពលកម្មដាំដុះផលដំណាំសាចុះសាឡើងបន្តជានិរន្តរ៍មិនចេះចប់ដើម្បីទ្រទ្រង់ជីវិត និងការចាំបាច់នៃការបន្តពូជពង្សវង្សត្រកូល (បន្តវេន) នៃធម្មជាតិនិងមនុស្ស ពិសេសគឺពូជពង្សវង្សត្រកូលខ្មែរនេះតែម្តង។

## ៥.២. របាំប្រពៃណី

ពាក្យប្រពៃណី ឬប្រវេណី ឬបវេណីមានន័យថា ទំនៀមពូជពង្ស តំណវង្សត្រកូល ដូចជាការខិតខំថែរក្សាបវេណីនៃត្រកូលរបស់ខ្លួន ឬការនិយមធ្វើបុណ្យទានតាមប្រពៃណីជាដើម។ ឯរបាំប្រពៃណីវិញ គឺសម្គាល់របាំទាំងឡាយដែលស្ថិតជាប់នឹងពិធីប្រពៃណី ឬពិធីតំណត្រកូលដ៏យូរលង់មកហើយរបស់ជនជាតិខ្មែរ ឬក៏ជនជាតិដទៃទៀតទាំងអស់ ដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាក្នុងតំបន់ខុសៗគ្នា ទាំងមានការនិយមដូចគ្នាក្តី ឬការនិយមខុសគ្នាក្តី នៅតំបន់ភ្នំ ខ្ពង់រាប តំបន់វាលទំនាប ទន្លេមេគង្គ និងតំបន់មាត់សមុទ្រ។ ដូចជា របាំកាប់ក្របីផឹកស្រារបស់បងប្អូនជនជាតិខ្មែរ-ព្នង ខ្មែរ-គ្រឹង ខ្មែរ-ទំពួន ដែលជឿលើជំនឿអារក្ខ អ្នកតា។ របាំនេះនៅភូមិភាគឦសាន បានស្ថិតនៅជាប់ជាមួយនឹងពិធីប្រពៃណីកាប់ក្របីសែនអ្នកតាក្នុងពេលដែលអ្នកភូមិជួបគ្រោះអាសន្ន និងដើម្បីបំបាត់ឧបទ្រពចង្រៃ សុំសេចក្តីសុខសប្បាយឱ្យកើតមានដល់ស្រុកភូមិ ហើយពេលខ្លះគេរាំសុំទឹកភ្លៀងផងដែរ។

របាំប្រពៃណីមានដូចជា របាំត្រុដិ របាំក្ងោកប៉ៃលិន របាំបេះក្រវាញ របាំកន្តែរ៉ែ របាំគោះអង្រែ របាំគោះត្រឡោក របាំគែន របាំកាប់ក្របីផឹកស្រា។ល។



របាំត្រុដិ (ពេជ្រ ទុំក្រវិល, របាំខ្មែរ ២០០១)



ទស្សនាវដ្តីស្រាវជ្រាវវប្បធម៌ខេត្តពោធិសាត់ ឆ្នាំទី១- ១៩៩៩

**<u>អត្ថន័យ</u>:**

របាំប្រពៃណីសម្តែងឡើងសម្រាប់អង្វរលន់តួ ផ្គាប់ផ្គុន បំពេរអារម្មណ៍ដល់វត្ថុសក្តិសិទ្ធិ ម្ចាស់ទឹក ម្ចាស់ដី ម្ចាស់ព្រៃភ្នំ អារុកអារក្ខ អ្នកតា អកូតផ្សេងៗ ដែលប្រជាជនយល់ថា ជាអ្នកខ្លាំងពូកែសក្តិសិទ្ធិ អាចជួយគេបានពេលគេជួបវិបត្តិផ្សេងៗ ពិសេសគឺសុំសេចក្តីសុខសេចក្តីចម្រើនក្នុងការរស់នៅ។

## ៥.៣. របាំព្រះរាជទ្រព្យ ឬរបាំក្បាច់បុរាណ

ខ្មែរយើងមានពាក្យពីរម៉ាត់សម្រាប់សម្គាល់ទម្រង់សិល្បៈទស្សនីយភាពក្បាច់បុរាណនេះគឺ ១-របាំ ឬល្ខោនក្បាច់បុរាណខ្មែរ និង២-របាំ ឬល្ខោនព្រះរាជទ្រព្យ។ ឯពាក្យថា របាំនិងល្ខោនក្នុងទីនេះក៏សម្រាប់គូសបញ្ជាក់ពីភាពខុសគ្នាខ្លះៗនៃទម្រង់សិល្បៈនេះក្នុងឱកាសសម្តែងម្តងៗផងដែរ។

ឧទាហរណ៍ជាក់ស្ដែង កាលណាទម្រង់ក្បាច់បុរាណនេះសម្ដែងជាទ្រង់ទ្រាយរបាំដាច់ៗតែឯង ដូចជារបាំជូនពរ របាំអប្សរា របាំទេពមនោរម្យជាដើមនោះ គេច្រើននិយមប្រើពាក្យថា របាំក្បាច់បុរាណខ្មែរ ឬរបាំព្រះរាជទ្រព្យ។ ប៉ុន្តែបើទម្រង់ដដែលនេះ សម្ដែងជាសាច់រឿងផ្សេងៗដូចជារឿងរាមកេរ្តិ៍ រឿងព្រះជិនវង្ស ឬរឿងព្រះថោងនាងនាគជាដើម គេច្រើននិយមហៅថា ល្ខោនព្រះរាជទ្រព្យ ឬល្ខោនក្បាច់បុរាណខ្មែរទៅវិញ។

**ប្រភព:**

តាមរយៈការសិក្សាស្រាវជ្រាវដោយផ្អែកទៅលើការគាស់កកាយរកវត្ថុបុរាណ ការសិក្សាពីរូបចម្លាក់តាមប្រាសាទបុរាណនានា ការសិក្សាសិលាចារឹក និងការសិក្សាអំពីទំនៀមទម្លាប់ ប្រពៃណីផ្សេងៗនាំឱ្យគេអាចសន្និដ្ឋានថា ទម្រង់សិល្បៈក្បាច់បុរាណនេះ ប្រហែលជាយោនយកកំណើតនៅលើទឹកដីប្រទេសកម្ពុជាតាំងពីសម័យនគរភ្នំ (ស.វទី១ ដល់ទី៦ នៃគ.ស.) មកម្ល៉េះ ដោយទទួលឥទ្ធិពលពីឥណ្ឌា ជារបាំក្នុងព្រាហ្មណ៍សាសនា សម្រាប់រាំថ្វាយអាទិទេព។ នេះបើផ្អែកលើចម្លាក់រូបស្រីរបាំនិងរូបហនុមានដែលគេបានរកឃើញនៅវត្តទួលគំនូរ នៅស្រុកអង្គរបុរី ខេត្តតាកែវ។ តាមកាយវិការនៃរូបចម្លាក់នេះឃើញថា មានលក្ខណៈជាឥណ្ឌាច្រើនជាងខ្មែរ។

**ការវិវត្តនៃរបាំក្បាច់បុរាណ:**

ក្រោយពីបានចូលមកក្នុងប្រទេសខ្មែររួចហើយ របាំនេះតែងតែមានការវិវត្តដោយសម្របទៅតាមផ្នត់គំនិតប្រជាជនខ្មែរ។ នៅសម័យអង្គររបាំនេះត្រូវបានពេញនិយមនៅតាមទេវស្ថានព្រាហ្មណ៍សាសនា ដែលជានិច្ចកាល គេតែងបានឃើញសិលាចារឹករៀបរាប់អំពីតង្វាយនៃស្រីរបាំនិងក្រុមតន្ត្រី។ ម្យ៉ាងវិញទៀតនៅតាមជញ្ជាំងប្រាសាទ គេឃើញមានចម្លាក់អប្សរាក្នុងកាយវិការពត់ពែនអែនអនយ៉ាងសមសួន ដែលអាចបញ្ជាក់បានថា ពួកគេកំពុងតែរាំថ្វាយព្រះរាជាទត ឬរាំក្នុងពិធីសាសនា។ ក្រោយសម័យអង្គរ ដោយសារការផ្លាស់ប្តូរសាសនាពីព្រហ្មញ្ញសាសនាទៅព្រះពុទ្ធសាសនា បានធ្វើឱ្យរបាំនេះបាត់បង់ប្រជាប្រិយភាព គឺសល់តែចម្លាក់នៅលើប្រាង្គប្រាសាទបុរាណប៉ុណ្ណោះ។ រហូតមកដល់ឆ្នាំ ១៩៦០ ព្រះមហាក្សត្រិយានី កុសុមៈនារីរតន៍សិរីវឌ្ឍនា ព្រះមាតាសម្ដេច នរោត្តម សីហនុ ព្រះអង្គបានធ្វើការសិក្សាស្រាវជ្រាវអំពីកាយវិការនៃចម្លាក់អប្សរានៅតាមជញ្ជាំងប្រាសាទបុរាណខ្មែរយ៉ាងល្អិតល្អន់ រួចបានធ្វើការផ្សំផ្គុំរួមបញ្ចូលគ្នាបង្កើតបានជារបាំក្បាច់បុរាណឡើង។

របាំក្បាច់បុរាណខ្មែរ ឬរបាំព្រះរាជទ្រព្យមានដូចជា របាំអប្សរា របាំថ្វាយព្រះពរ របាំសុវណ្ណមច្ឆា របាំមណីមេខឡា។ល។



ព្រះវិស្ណុកំពុងរាំរបាំ





គំនូរសម្ដែងរបាំនិងការហាត់រាំរបាំ( www. google.com.kh )

## ៦. សិល្បៈអក្សរសិល្ប៍

### ៦.១. ប្រភពនិងកម្មវត្ថុអក្សរសិល្ប៍

ទស្សនៈទូទៅពីបញ្ហាប្រភពនិងកម្មវត្ថុអក្សរសិល្ប៍ មានក្រុមអ្នកសិក្សាជាច្រើនបានលើកយកមកពិភាក្សាដោយប្រកាន់ទស្សនៈគោលជំហរខុសៗគ្នា យើងសង្កេតឃើញមានទស្សនៈពីរសំខាន់គឺទស្សនៈមនោនិយមនិងរូបជាតុនិយម។ នៅក្នុងស្នាដៃអក្សរសិល្ប៍ពួកអ្នកសិល្បវិទ្យាមនោនិយមបានស្រាវជ្រាវពីកម្មវត្ថុ និងប្រភពអក្សរសិល្ប៍ដោយកាត់ផ្តាច់ពីជីវភាពសង្គម ហើយយល់ថា សិល្បៈគឺដើម្បីសិល្បៈតែប៉ុណ្ណោះ។ ចំណែកពួករូបជាតុនិយមបានភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងអក្សរសិល្ប៍ និងជីវភាពសង្គម។

### ក. ប្រភពអក្សរសិល្ប៍

តាមទ្រឹស្តីវិវត្តនៃមនុស្សជាតិបានឱ្យដឹងថា អក្សរសិល្ប៍បានកើតឡើងតាំងពីយូរយារណាស់មកហើយ មនុស្សចេះច្រៀងរាំ ចេះប្រើសិល្បៈដើម្បីកែច្នៃឧបករណ៍ប្រើប្រាស់ពីមួយថ្ងៃទៅមួយថ្ងៃកម្លាំងផលិតកម្មមានការរីកចម្រើននាំឱ្យការបែងចែកពលកម្ម ក៏ចាប់បដិសន្ធិរវាងកម្លាំងកាយនិងបញ្ញា ហើយជីវភាពស្មារតីរបស់មនុស្សកាន់តែរីកចម្រើនឡើង ហើយបញ្ហាស្មុគស្មាញកាន់តែសម្បូរបែបនៅក្នុងសង្គមជាហេតុធ្វើឱ្យការស្រាវជ្រាវរកប្រភពអក្សរសិល្ប៍មានការលំបាកយ៉ាងខ្លាំង។ ទោះជាយ៉ាងណាក៏ដោយគេសង្កេតឃើញមានទស្សនៈប្លែកគ្នាចំនួនបួនដែលលើកឡើងពីប្រភពរបស់អក្សរសិល្ប៍សិល្បៈដូចជា:

- ប្រភពទី១: ទស្សនៈសាសនា ឬមន្តអាគម
- ប្រភពទី២: សភាវគតិកំសាន្ត
- ប្រភពទី៣: សភាវៈអនុកម្ម (ការត្រាប់តាម)
- ប្រភពទី៤: ពលកម្មជាប្រភពពិតនៃអក្សរសិល្ប៍សិល្បៈ

បើយើងសង្កេតទៅលើប្រភពទាំង៤ខាងលើ៖

-មនុស្សចេះរណាបធម្មជាតិនិងត្រាប់តាមធម្មជាតិដើម្បីសប្បាយ តើគេត្រូវការសប្បាយនៅពេលណា? គឺនៅពេលគេធ្វើពលកម្មនឿយហត់។

-តើគេត្រូវការជំនឿសាសនានៅពេលណា? គឺនៅពេលពលកម្មជួបឧបសគ្គ។

ដូច្នេះប្រភពអក្សរសិល្ប៍សិល្បៈ គឺពលកម្ម(តាមទស្សនៈជឿនលឿនបានអះអាងថា មនុស្សវិវត្តពីសត្វស្វាអង់ត្រូប៉ូម័រ)។ ពលកម្មនាំឱ្យមនុស្សខុសពីសត្វនិងបានសាងនូវគុណសម្បត្តិប្រកបដោយសមត្ថភាព អាចបង្កើតនូវវត្ថុអស្ចារ្យផ្សេងៗ ដែលគ្មានសត្វណាប្រៀបធៀបបាន។

ឧ. ប្រាសាទអង្គរវត្ត សំណង់ធំៗ ស្នាដៃវិទ្យាសាស្ត្រ....។

## ខ. និយមន័យអក្សរសិល្ប៍

ពាក្យថា«**សិល្ប៍**» បានពញ្ញាក់អារម្មណ៍របស់យើងឱ្យរំភើបតាមបែបជំនឿ ព្រោះគេយល់ច្រឡំថាសិល្ប៍នេះគឺមន្តអាគមដែលអាចជួយឱ្យខ្លួនគេក្លាយជាមនុស្សអស្ចារ្យ មានលទ្ធភាពបំបាំងខ្លួនជាពិសេសគឺអាចជួយបង្កើតជាវត្ថុផ្សេងៗបានតាមចិត្តចង់។ ដូច្នេះពាក្យ«**អក្សរសិល្ប៍**» នេះមនុស្សដែលទើបបានឮ ឃើញភ្លាម គឺប្រាកដជាច្រឡំថា អត្ថបទគាថាបាលី មន្តអាគម អូមអាមដែលសម្រាប់សូត្រផ្លុំដើម្បីប្រើក្នុងការបំពេញបំណងផ្សេងៗរបស់គេដូចជាធ្វើឱ្យគេស្រលាញ់ ធ្វើជាស្នេហ៍នេះជាដើម ...។ល។ តែក្រោយពីបានសិក្សាអ្នកដែលមានជំនឿងងប់ងល់ទៅក្នុងបញ្ហាខាងលើគឺប្រាកដជាខកចិត្តយ៉ាងខ្លាំង ព្រោះអត្ថន័យពិតប្រាកដរបស់អក្សរសិល្ប៍ផ្ទុយស្រឡះពីការគិតទុក។ ស័ព្ទ «**អក្សរសិល្ប៍**» មកពី: អក្សរ + សិល្ប៍

-អក្សរ : សំណេរស្នាមគំនូសដែលចារនៅលើផ្ទាំងថ្ម ស្បែកសត្វ ឬក្រាំង គម្ពីរ សាស្ត្រាស្លឹករឹតដើម្បីកត់ត្រាពាក្យសំដី។

-សិល្ប៍ : សំដៅលើលក្ខណៈច្នៃប្រឌិត ធ្វើឱ្យលេចចេញនូវសោភ័ណភាពមានភាពរស់រវើកគួរជាទីចាប់ចិត្តដិតអារម្មណ៍ មានសមត្ថភាពលួងលោម អន្ទងព្រលឹង បង្កើតនូវចិត្តរំភើប។

ដូចច្នេះអក្សរសិល្ប៍ ជាអត្ថបទទាំងឡាយណាដែលប្រើដោយអក្សរប្រកបដោយសិល្បវិធីក្នុងការធ្វើឱ្យអ្នកអាន អ្នកស្តាប់ រំភើប សប្បាយរីករាយក្នុងអារម្មណ៍។

**-អក្សរសិល្ប៍:** គឺជាផលិតកម្មទាំងអស់របស់អ្នកនិពន្ធ។ អក្សរសិល្ប៍មានឥទ្ធិពលទៅលើគេបានដោយសារតែលក្ខណៈជាតិ គោលគំនិត ទស្សនៈ របៀបរស់នៅ(សង្គមបរិយាកាស)ឬដោយសារតែការអធ្យាស្រ័យផ្ទាល់របស់អ្នកនិពន្ធ។ គឺដោយហេតុនេះហើយ ដែលនាំឱ្យអក្សរសិល្ប៍មានច្រើនបែបច្រើនយ៉ាងស្របទៅតាមសង្គមមនុស្សដែលមានច្រើនបែបយ៉ាងនោះដែរ។ អក្សរសិល្ប៍ ចាប់កំណើតឡើងនៅពេលណាដែលមនុស្សចេះយកគំនិតរបស់ខ្លួនមកផ្សុំផ្គុំគ្នា ហើយសំដែងចេញមកខាងក្រៅតាមពាក្យសំដី ឬតាមការសរសេរ។ អក្សរសិល្ប៍មានព្រំដែនទូលំទូលាយណាស់ ប្រសិនបើមនុស្សជាតិកាន់តែជឿនលឿនលូតលាស់។ អក្សរសិល្ប៍ជនជាតិនីមួយៗ តែងតែសម្គាល់យ៉ាងជាក់លាក់នូវគំនិតតម្លៃនៃវប្បធម៌និងអរិយធម៌ដែលដើរទៅដល់ ហើយបញ្ចាំងចេញមកវិញនូវលក្ខណៈទ្រង់ទ្រាយគ្រប់បែបយ៉ាងរបស់វប្បធម៌និងអរិយធម៌នេះឯង។

**-លោកសាស្ត្រាចារ្យ កេង វ៉ាន់សាក់** : អក្សរសិល្ប៍ គឺជាវិទ្យាសាស្ត្រដែលចោទនិងដោះស្រាយបញ្ហាមនុស្សដោយសិល្បវិធីទៅតាមសង្គមនីមួយៗ។ មានន័យថា នៅពេលដែលវិទ្យាសាស្ត្ររីកចម្រើនឡើង អ្នកអក្សរសិល្ប៍ក៏ផ្តើមអនុវត្តវិទ្យាវិធីក្នុងនិម្មិតកម្មស្នាដៃរបស់ខ្លួនតាមរយៈការសង្កេតពិនិត្យទៅ

លើតថភាពជាក់ស្តែង ទៅលើបាតុភូតធម្មជាតិ បាតុភូតសង្គម ព្រមទាំងលើកយកបញ្ហាមនុស្សពិតៗ មកចោទនិងដោះស្រាយតាមសិល្បវិធី ទៅតាមសង្គមនីមួយៗ។

**គ. កម្មវត្ថុអក្សរសិល្ប៍**

អក្សរសិល្ប៍ឆ្លុះបញ្ចាំងតថភាពសង្គមក្នុងលក្ខណៈសកលនិងស្មុគស្មាញ។ វាបានឆ្លុះបញ្ចាំងពីវាសនារបស់មនុស្ស ចរិតលក្ខណៈរបស់មនុស្ស និងបញ្ហាទំនាក់ទំនងក្នុងជីវភាពរស់នៅ។ ក្រៅពីមនុស្ស អក្សរសិល្ប៍បានរៀបរាប់អំពីធម្មជាតិផ្សេងៗដើម្បីបំផុសទឹកចិត្តស្នេហាជាតិ ទឹកដី និងប្រជាជន ព្រោះការរៀបរាប់ធម្មជាតិខ្លះ ត្រូវបានបង្កប់ដោយគោលគំនិតសំខាន់ៗរបស់អ្នកនិពន្ធ គឺនិយាយដល់ស្ថានភាពរបស់មនុស្ស និងចរិតលក្ខណៈរបស់មនុស្សយ៉ាងពិតប្រាកដ។

**ឧ.** តាមរយៈរឿងវរនិងស្រមោច រឿងចចកនិងកូនចៀម មេអំបៅនិងដង្កូវ សុទ្ធតែមានខ្លឹមសារទាក់ទងនឹងជីវភាពរស់នៅរបស់មនុស្ស។

លោក Gorky បានសរសេរថា «**អក្សរសិល្ប៍ ជាការសិក្សាអំពីមនុស្ស**»។ តើមានសភាពខុសគ្នាយ៉ាងណាខ្លះរវាងមនុស្ស ក្នុងក្របខណ្ឌជាកម្មវត្ថុក្នុងអក្សរសិល្ប៍ និងមនុស្សក្នុងក្របខណ្ឌជាកម្មវត្ថុរបស់វិទ្យាសាស្ត្រ?

មនុស្សក្នុងក្របខណ្ឌកម្មវត្ថុរបស់អក្សរសិល្ប៍ គឺគេមិនត្រូវមើលឃើញមនុស្សក្រោមរូបភាពជីវវិទ្យានោះទេ តែត្រូវមើលឃើញក្នុងឋានៈជាមនុស្សប្រកបដោយទិដ្ឋភាពគ្រប់យ៉ាង។ អ្នកនិពន្ធសិល្បករ រៀបរាប់ពីជីវិតរបស់មនុស្សក្នុងសភាពស្មុគស្មាញ។ កម្មវត្ថុអក្សរសិល្ប៍មិនមែនស្ថិតស្ថេរពុំផ្លាស់ប្តូរនោះទេ ប៉ុន្តែត្រូវប្រែប្រួលជានិច្ចស្របតាមបម្រែបម្រួលនៃតថភាពសង្គម។ ពោលគឺ សង្គមយ៉ាងណា អក្សរសិល្ប៍យ៉ាងនោះ ព្រោះអក្សរសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងសង្គម។

## ៦.២. មុខងារអក្សរសិល្ប៍[21]

កាលពីមុនអ្នកទ្រឹស្តីខ្មែរយើងបានកំណត់នូវមុខងារអក្សរសិល្ប៍រហូតដល់៦យ៉ាងដូចជាមុខងារពុទ្ធិ អប់រំ សិល្បវិជ្ជា កំសាន្ត តថៈ និងទំនាក់ទំនងរវាងអ្នកនិពន្ធនិងអ្នកអាន ។ ប៉ុន្តែរហូតមកដល់ពេលនេះ អ្នកស្រាវជ្រាវមួយចំនួនបានសង្កត់ធ្ងន់តែទៅលើមុខងារសំខាន់ៗបី គឺ មុខងារពុទ្ធិ មុខងារអប់រំ និងមុខងារសិល្បវិជ្ជា។

**ក. មុខងារពុទ្ធិ**

តាំងពីយូរយារណាស់មកហើយពន្លកពុទ្ធិកើតមានជាប់ក្នុងមុខងារអក្សរសិល្ប៍។ នាសតវត្សទី២០ អក្សរសិល្ប៍មានទំនាក់ទំនងច្រើនជាមួយបញ្ហាមនុស្ស បញ្ហាសង្គម បញ្ហាជីវភាព ដូចជារឿង

---

[21] ពន់ ឆាយ, ទ្រឹស្តីនិងអក្សរសិល្ប៍, ២០០៨។

ទុំទាវ ច្បាប់ផ្សេងៗ បណ្ដាំក្រមង៉ុយ ប្រលោមលោកទំនើប។ល។ អក្សរសិល្ប៍ ជាកម្រងឯកសារស្ដីពីជីវិត ព្រោះនៅពេលអានសៀវភៅរឿងទាំងឡាយ គេរមែងយល់ដឹងច្រើនតាំងពីភាពពិស្ដារនៃទេសភាពធម្មជាតិ ទំនៀមទម្លាប់ ប្រពៃណី សកម្មភាពជនជាតិ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និងព្រឹត្តិការណ៍សង្គម។ ក្រៅពីអក្សរសិល្ប៍មានសិល្បៈខ្លះពុំបានផ្ដល់ប្រយោជន៍ឱ្យឃើញភ្លាមៗទេ តែវាក៏បានបំពេញតួនាទីយល់ដឹងតថភាពដែរ។

**ខ. មុខងារអប់រំ**

ទន្ទឹមនឹងមុខងារពុទ្ធិ អក្សរសិល្ប៍នៅមានមុខងារអប់រំមួយទៀតដែលបំពេញតួនាទីយ៉ាងសំខាន់។ អប់រំមានន័យថា ជាការរៀនសូត្រលើកកម្ពស់ស្មារតី កម្រិតវប្បធម៌។ **ឧ.** នៅពេលបានអានរឿងច្រើន យើងរមែងមានសមត្ថភាពប្រើប្រាស់ពាក្យពេចន៍បានត្រឹមត្រូវ ជឿនលឿន មិនឆ្គង ហើយការប្រើប្រាស់ភាសា ប្រជាជនកាន់តែត្រូវបានលើកកម្ពស់សម្បូរបែបនិងជាក់លាក់។ អក្សរសិល្ប៍សិល្បៈរបស់ជាតិមួយនាំយើងឆ្ពោះទៅកាន់អរិយធម៌មួយ។

**គ. មុខងារសិល្បវិជ្ជា**

សិល្បវិជ្ជា ជាមុខងារវិជ្ជាមួយដែលផ្ដល់នូវសោភ័ណរស ទារុណរស ហាសរស វិសិដ្ឋរស...។ សោភ័ណជាវត្ថុមួយដែលមានសមត្ថភាពអាចភ្ញោច ឬកន្ទ្រាក់អារម្មណ៍របស់យើងឱ្យមានសញ្ចេតនារំភើប។ មធ្យោបាយសម្រេចជោគជ័យនៃពុទ្ធិ និងអប់រំមានតែសិល្បវិជ្ជានេះទេ។ យើងមិនអាចទាត់ចោលសិល្បៈបានទេ ហើយគួរកុំបញ្ចូលនូវមនោគមវិជ្ជាច្រើនពេក ព្រោះវានាំឱ្យបាត់បង់តម្លៃសិល្បៈ។ **ឧ.**រឿងស៊ីមអ្នកបរឡាន គ្រូបង្រៀនស្រុកស្រែមានតែសាច់ការគ្មានលក្ខណៈសិល្បវិជ្ជានាំឱ្យគេមិនចូលចិត្តអាន វាត្រូវទទួលបរាជ័យ ព្រោះអ្នកនិពន្ធគ្មានសិល្បវិធី។ ស្នាដៃមួយអាចមានតម្លៃទៅបានត្រូវមានការអប់រំ ផ្ដល់ពុទ្ធិ និងសិល្បវិជ្ជា បើខ្វះផ្នែកមួយណានាំឱ្យរឿងមិនល្អ។

## ៦.៣. លក្ខណៈអក្សរសិល្ប៍

**ក. លក្ខណៈមនុស្ស:** អក្សរសិល្ប៍មានលក្ខណៈមនុស្ស គឺអត្ថបទអក្សរសិល្ប៍ណាដែលលើកយកបញ្ហាមនុស្សមកចោទនិងដោះស្រាយ ហើយបង្កើតបានជាបញ្ហាមនុស្ស។ ឧ. រឿងរាមកេរ្តិ៍ រឿងក្រពើនិងអ្នកបរទេះ...។

**ខ. លក្ខណៈវណ្ណៈ:** អក្សរសិល្ប៍ជារូបភាពនៃមនសិការសង្គម។ អក្សរសិល្ប៍ត្រូវឆ្លុះបញ្ចាំងនូវមូលដ្ឋានមួយជាក់ស្ដែង ពោលគឺសង្គមមនុស្ស។ បើសង្គមមនុស្សមានវណ្ណៈ នោះអក្សរសិល្ប៍ក៏មានវណ្ណៈដែរ ហេតុដូចនេះហើយបានជាគេនិយាយថា សង្គមបែបណា អក្សរសិល្ប៍បែបនោះ។

**គ. លក្ខណៈសង្គម:** អក្សរសិល្ប៍ដែលមានលក្ខណៈសង្គមបាន លុះត្រាតែអក្សរសិល្ប៍នោះបាននិយាយអំពីទំនាក់ទំនងរវាងមនុស្សនិងមនុស្ស ក្រុមមនុស្សនិងក្រុមមនុស្ស សង្គមមនុស្សនិងសង្គមមនុស្ស។ ឧ. តួអង្គទុំទាវ ដែលងើបឡើងប្រឆាំងនឹងប្រពៃណី(ក្នុងការរៀបចំទុកដាក់កូនចៅ) គឺតំណាងយុវជន យុវនារីខ្មែរមួយក្រុមនាសម័យលង្វែកដែលទាមទារសិទ្ធិសេរីភាពក្នុងការរើសគូស្រករ។

**ឃ. លក្ខណៈប្រវត្តិ:** ជាប្រភេទស្នាដៃអក្សរសិល្ប៍ដែលសរសេរទាក់ទងនឹងសម័យកាលណាមួយ ឬព្រឹត្តិការណ៍ណាមួយនៃចរន្តប្រវត្តិសាស្ត្រ។ ឧ. រឿងភូមិតិរច្ឆាន រឿងគូលីកំណែន...។

**ង. លក្ខណៈជាតិ:** ជាស្នាដៃដែលមានតម្លៃសំខាន់ មានឧត្តមគតិវិសេសវិសាល ទ្រទ្រង់វប្បធម៌ សង្គមធម៌របស់ជាតិទាំងមូល។ ឧ. រឿងទុំទាវបានបង្ហាញពីប្រពៃណីចូលម្លប់ រៀបការ សាសនា ភាសា ភូមិសាស្ត្រ...នៃប្រទេសកម្ពុជានាសម័យលង្វែក។

**ច. លក្ខណៈអន្តរជាតិ:** ជាស្នាដៃទាំងឡាយណាដែលមានលក្ខណៈជាតិរួចជាស្រេច ហើយត្រូវប្រទេសដទៃទៀតទទួលស្គាល់ថា ជាអត្ថបទល្អ អាចយកទៅសិក្សាបាន បកប្រែជាទូទៅបាន ព្រោះជារឿងមានតម្លៃសកល ទាក់ទងនឹងវិទ្យាសាស្ត្រ បច្ចេកទេស សីលធម៌ ដែលជាបំណងរបស់មនុស្សជាតិទូទៅ។ ឧ. រឿង១០០១យប់ រឿងរាមាយណៈ ...។

## ៧. សិល្បៈភាពយន្ត ឬកុន

### ៧.១. ប្រវត្តិភាពយន្ត ឬកុនខ្មែរ

នៅក្នុងចំណោម «**ល្បែង**» ខ្មែរ មានបែបល្ខោនមួយប្រភេទ គឺល្ខោនស្បែក ឬណាំង ឬអាយ៉ងដែលជាបែបនិទានរឿងដោយប្រើស្រមោលបញ្ចាំងរូបភាពធ្លាក់លើស្បែកគោ ឬស្បែកក្របី ទៅលើផ្ទៃក្រណាត់។ នេះជាបែបសម្តែងដែលខ្មែរខ្លះ សព្វថ្ងៃហៅថា «**កុនខ្មែរ**»។

ភាពយន្ត ឬកុន ដែលជាសិល្បៈទី៧ គឺជាទស្សនីយភាពទំនើបដែលកើតនៅចុងសតវត្សទី១៩ ក្នុងប្រវត្តិសាស្ត្រពិភពលោក ភាពយន្តបានចូលមកស្រុកខ្មែរតាមរយៈអាណាព្យាបាលបារាំង។ យើងមានភស្តុតាងខ្លះៗ ដូចជារូបថត ឬឯកសាររដ្ឋបាលបារាំងដែលឱ្យយើងដឹងថា នៅដើមសតវត្សទី២០ មានកុននៅក្នុងស្រុកខ្មែរហើយ។ ឧទាហរណ៍ នៅក្នុងឆ្នាំ១៩០៩ មានការសម្ពោធរោងកុនមួយនៅក្នុងក្រុងភ្នំពេញដែលមានឈ្មោះ Brignon។ រោងកុននោះស្ថិតនៅម្តុំមាត់ទន្លេ។ តែជាទូទៅរហូតដល់ពាក់កណ្តាលសតវត្សទី២០ ការទស្សនាភាពយន្តនៅតែជាឱកាសដ៏ពិសេសមួយ។ រឿងដែលយកមកបញ្ចាំងនៅតាមរោងកុននោះ ជាទូទៅជារឿងដែលផលិតនៅបរទេសដូចជាប្រទេសបារាំង អាមេរិកាំងជាដើម។

-នៅពាក់កណ្តាលទសវត្សទី៥០ មានកុនឥណ្ឌានិងកុនសៀមចូលមកស្រុកខ្មែរ។

-ចាប់ពីទសវត្សទី៥០ មានការផលិតកុនខ្មែរនៅក្នុងស្រុកខ្មែរដោយខ្មែរខ្លួនឯង។

-អ្នកថតកុនមុនគេគឺព្រះករុណា នរោត្តម សីហនុ ដែលព្រះអង្គបានចាប់ផ្តើមថតកុនខ្លីៗដោយប្រើហ្វីល១៦មីលីម៉ែត្រ តាំងពីទសវត្សទី៤០ម្ល៉េះ។

-លោក រឿម សុផុន និងលោក អៀវ បណ្ណាការ បានទៅរៀនបច្ចេកទេសថតកុននៅប្រទេសបារាំង ហើយនៅដើមទសវត្សទី៥០ បានត្រឡប់មកស្រុកខ្មែរវិញដោយបម្រើការក្នុងរាជវាំង។

-លោក អៀវ បណ្ណាការ បានថតកុនមួយមានចំណងជើងថា «ឈាមខ្មែរ» ស្តីពីការដែលជប៉ុនមកកាន់កាប់ស្រុកខ្មែរ ក្នុងអំឡុងសង្គ្រាមលោកលើកទី២។

-លោក សោម សំអាល់ បានថតកុនមួយរឿងដែរ មានចំណងជើងថា «ផ្ការីក ផ្ការោយ» នៅក្នុងឆ្នាំ១៩៦០។

-ទសវត្សទី៦០ និងដើមទសវត្សទី៧០ ជាសម័យកាលដែលទស្សនីយភាពកុនមានប្រជាប្រិយយ៉ាងខ្លាំង ពោលគឺពេលនោះរោងកុនកើតឡើងយ៉ាងច្រើន រីឯរឿងក៏ត្រូវបានថតយ៉ាងច្រើនដែរ ដោយសារមានមនុស្សទៅមើលច្រើន។ ម្ល៉េះហើយអាជីវកម្មភាពយន្តដំណើរការល្អ រកលុយបាន។

-ពេលនោះមានកុនដូចជា «លាហើយដួងតារា» រឿង «ពស់កេងកង» ថតដោយ លោក ទា លីមឃួន (ផលិតកម្មតារាវត្តភាពយន្ត) រឿង «សព្វសិទ្ធិ» រឿង «អនអើយស្រីអន» ថតដោយ លោក លី ប៊ុនយឹម (ផលិតកម្មរន្ទះពេជ្រភាពយន្ត)។

-នៅដើមទសវត្សទី៧០ មានសង្គ្រាមរាលដាលពេញផ្ទៃប្រទេស។ ប្រទេសជាតិបានជួបអសន្តិសុខ ជាហេតុធ្វើឱ្យការថតកុនមានការលំបាក ពោលគឺគេមិនសូវហ៊ានទៅថតនៅក្រៅទេ។

-មកដល់ឆ្នាំ១៩៧៣-៧៤ ស្ថានភាពក្នុងប្រទេសកាន់តែតានតឹងឡើងដោយខ្មែរក្រហមវាយលុកមកកាន់តែកៀក ដល់មានការបិទរោងកុន។ ពេលនោះមនុស្សលែងហ៊ានចេញពីផ្ទះហើយ។[22]







ការសម្ពោធរោងកុនព្រះសីហនុ នៅខេត្តកំពង់ចាម ឆ្នាំ១៩៥៣ ការបង្ហាត់បង្រៀនរៀបនិងជួសជុលម៉ាស៊ីនបញ្ចាំងកុន និងការបង្រៀនគ្រូខ្មែរថតកុន

[22] រៃយំ, ខ្មែរប្រឈមនឹងវប្បធម៌, ២០០១, ទំព័រ ១៤១-១៦១។

### ៧.២. ប្រភេទភាពយន្ត

- ភាពយន្តគំនូរជីវចល
- ភាពយន្តឯកសារ
- ភាពយន្តរឿង

### ៧.៣. ធាតុភាពយន្ត

- នាដកថា
- ចលនារូបភាព
- សំឡេង

### ៧.៤. រចនាសម្ព័ន្ធភាពយន្ត

- ចាងហ្វាងផលិតកម្ម
- អ្នកដឹកនាំរឿង
- អ្នកនិពន្ធ
- តួអង្គ
- អ្នកតុបតែង
- វិស្វករសំឡេង
- អ្នកកត់ត្រាឆាក
- អ្នកថតរូបលើឆាក
- អ្នកធ្វើទំនាក់ទំនងសាធារណៈ។

សរុបមក ខ្សែភាពយន្ត គឺជាសិល្បៈមួយ ជាទស្សនីយភាពមួយ និងជាព័ត៌មានមួយ ដែលមហាជននានាត្រូវការទស្សនា មិនគ្រាន់តែដើម្បីកម្សាន្ត លំហែដួងចិត្ត ធ្វើឱ្យអារម្មណ៍ធូរស្បើយ ត្រេកត្រអាល ខ្សឹបខ្សួល ឬរីករាយ ទៅតាមឈុតនីមួយៗក្នុងផ្ទៃរឿង ក្រោយដែលខ្លួនបានធ្វើការយ៉ាងហត់នឿយ ក្រោមកម្តៅព្រះអាទិត្យប៉ុណ្ណោះទេ។ ខ្សែភាពយន្តមួយចំនួន ក៏អាចនឹងចាត់ទុកថា ជាព័ត៌មានមួយយ៉ាងសំខាន់ដល់អ្នកទស្សនា។ ឧទាហរណ៍ ខ្សែភាពយន្តឯកសារខ្លះ ដែលស្តីពីទស្សនកិច្ច ស្តីពីសង្គ្រាម ឬនៅក្នុងស្រុកនេះ នៅក្នុងប្រទេសនោះ ទិដ្ឋភាពប្រាសាទអង្គរវត្ត ឬទិដ្ឋភាពឯទៀតៗ។ល។ ដែលគេបានប្រឌិតឡើង សមទៅតាមព្រឹត្តិការណ៍ពិតប្រាកដ ឬថតយកទិដ្ឋភាពជាក់ស្តែងជាដើម។

# មេរៀនទី៥ ទំនៀមទម្លាប់ប្រពៃណីខ្មែរ «ពិធីឆ្លងវ័យ»

ជាទូទៅចាប់ពីពេលដែលមនុស្សមានកំណើតឃើញពន្លឺព្រះអាទិត្យរហូតទៅដល់ស្លាប់ទៅវិញ វ័យរបស់មនុស្សម្នាក់ៗ រំកិលខិតទៅមុខទៀងទាត់ជាប្រក្រតីតាមធម្មជាតិ។ ប៉ុន្តែសង្គមពុំគិតថាដូច្នោះឡើយ គឺធ្វើការកំណត់ថា ពីពេលនេះ ថ្ងៃនេះតទៅមនុស្សចូលដល់វ័យនេះ ឬវ័យនោះ។ ដូច្នេះការកំណត់ហាក់ពុំត្រូវនឹងដំណើរជីវិតតាមធម្មជាតិពិតប្រាកដទេ។ ឧទាហរណ៍ មនុស្សស្រីនិងមនុស្សប្រុសដែលឡើងខ្លួនពេញលេញ ហើយបើរួមរស់ជាមួយគ្នាឃើញថា គ្មានអ្វីខុសនឹងធម្មជាតិឡើយ ហើយអាចមានកូនទៀត។ ប៉ុន្តែសង្គមមិនយល់ព្រមថាដូច្នោះទេ ព្រោះអ្នកទាំងពីរមិនបានឆ្លងកាត់ពិធីមង្គលការឱ្យសង្គមដឹងឮ ប្រសិនបើមានផ្ទៃពោះសង្គមនិយាយថា «**ផើមព្រៃ**»។ ពាក្យថា «**ព្រៃ**» នេះងាយយល់ណាស់ ព្រោះបញ្ជាក់ថា នៅក្រៅសង្គម ក្រៅច្បាប់ ត្បិតវិស័យនៃសង្គមមនុស្សពុំមែនព្រៃទេគឺ «**ស្រុក**»។ សង្ខេបមកក្នុងពាក្យថា «**ពិធីឆ្លងវ័យ**» យើងត្រូវយល់ថា ជាវ័យឆ្លងពីដំណាក់កាលមួយទៅដំណាក់កាលមួយតាមរយៈ «**ពិធី**»។ ពិធីឆ្លងវ័យជាកិច្ចដែលសង្គមទាមទារ ឬតម្រូវទៅលើបុគ្គល ហើយសម្រាប់បុគ្គលដដែលនោះផង។ សង្គមទាមទាររបៀបនេះដើម្បីជាប្រយោជន៍បុគ្គលសុទ្ធសាធ ហើយក៏ជាប្រយោជន៍ដល់សង្គមខ្លួនឯងដែរ។ បើបុគ្គលពុំគោរពច្បាប់សង្គមឃើញថា សង្គមនោះមានការរង្គោះរង្គើ។ មនុស្សម្នាក់ៗដែលស្លាប់ទៅហើយមិនអាចមកទាមទារឱ្យសង្គមធ្វើបុណ្យឱ្យខ្លួនឡើយ ប៉ុន្តែសង្គមត្រូវតែធ្វើជាដាច់ខាត ត្បិតបើពុំដូច្នោះ គេយល់ថា សពនោះនឹងធ្វើទុក្ខបុកម្នេញដល់ក្រុមគ្រួសារនិងអ្នកភូមិខ្លួនឯងជាពុំលែង។

អាស្រ័យហេតុនេះឃើញថា ពិធីឆ្លងវ័យនៅប្រទេសកម្ពុជាមានដល់ទៅ៨។ ដំណាក់ទី១គឺពិធីទាក់ទងនឹងកំណើតមនុស្ស។ ដំណាក់ទី២ គឺការប្រុងប្រៀបខ្លួនទៅក្នុងវ័យដែលហៅថា ពេញវ័យ។ លុះវ័យពេញមកដល់ហើយ ក៏មានពិធី២ទៀតយ៉ាងសំខាន់។ ប្រុសមានពិធីសម្រាប់ប្រុស ឯស្រីមានពិធីផ្សេងរបស់ខ្លួន។ មកដល់ដំណាក់កាលនេះរាប់ថាមានពិធី៤ហើយ។ ពិធីទី៥គឺមង្គលការ។ ចំណែកឯពិធីទី៦ទាក់ទងតែនឹងស្រីប៉ុណ្ណោះ គឺការឆ្លងទន្លេពិសេសឆ្លងទន្លេលើកដំបូង ត្បិតដំណាក់នោះគឺស្រីឆ្លងពីភាពជាភរិយាមកភាពជាមាតា។ ពិធីទី៧គឺចម្រើនអាយុ។ ដំណាក់កាលចុងក្រោយនៃជីវិតជាពិធីទី៨គឺពិធីដែលទាក់ទងនឹងសព។

## ១. ពិធីទាក់ទងនឹងកំណើត «បង្កក់ឆ្មប»[23]

ពិធីកាត់សក់បង្កក់សម្រាប់ទារកនេះជាប់គ្នានឹងកិច្ចពីរទៀត មួយសម្រាប់ម្ដាយដែលនៅលើភ្លើង មួយទៀតសម្រាប់ឆ្មបដែលជួយបង្កើតទារកនោះមក។ គេច្រើននិយាយថា «**កាត់សក់ បង្កក់ឆ្មប**» បើពោលឱ្យអស់គេបន្ថែមថា «**ទម្លាក់ជើងក្រាន**» ទៀតផង។ នេះបង្ហាញថា សាមីខ្លួននៃពិធីមានពីរនាក់ កាត់សក់និងដាក់ឈ្មោះឱ្យទារក បង្កក់ឆ្មបជាកិច្ចធ្វើជូនឆ្មប ចំណែកឯទម្លាក់ជើងក្រានគឺសម្រាប់ម្ដាយ

[23] អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, ស៊ុន ចាន់ដឹប, ដំណើរជីវិតមនុស្សខ្មែរមើលតាមពិធីឆ្លងវ័យ, ហនុមានទេសចរណ៍, ២០០៧។

ដែលនៅអាំងភ្លើងដើងក្រាននោះ។ យ៉ាងឆាប់បំផុតពិធីនោះធ្វើឡើង៣ថ្ងៃក្រោយពីទារកកើតមក ប៉ុន្តែបើមួយអាទិត្យក្រោយមកទើបធ្វើ ក៏ធ្លាប់ឃើញញឹកញាប់ដែរ។

សក់កំណើតទារកគេហៅថា «**សក់ព្រៃ**» គឺត្រូវផ្ដាច់ចេញពីក្មេងនោះដើម្បីឱ្យវាមកនៅក្នុងវិស័យឬពិភពមនុស្សពេញលេញ លែងជំពាក់ជំពិននឹងវិស័យព្រៃដែលជាពិភពខ្មោច។ ជាពិសេសគេខំធ្វើយ៉ាងម៉េចឱ្យដាច់ចេញពី «**ម្ដាយដើម**» ពោលគឺម្ដាយរបស់វានៅក្នុងជាតិមុនៗ។

បង្កក់ធ្មបមានន័យថា លាងសម្អាតជម្រះធ្មបនោះឱ្យផុតពីមន្ទិលដែលជាប់ប្រឡាក់ប្រឡូសដោយសារគាត់បានប៉ះពាល់នឹងឈាមជំរពោះពុងនៃស្ត្រីជាម្ដាយពេលឆ្លងទន្លេនោះ។

រីឯទម្លាក់ដើងក្រាន គឺគេពន្លត់ភ្លើងដើងក្រានដែលម្ដាយអាំងដើម្បីបញ្ចប់ត្រណមផ្សេងៗដែលកាន់ក្នុងរយៈពេលកាន់ភ្លើង។ ទោះជាពន្លត់ភ្លើងនោះ ហើយដុតឡើងវិញក្ដីដោយសារនឹកថារងារ ក៏ត្រណមទាំងនោះផ្ដាច់ទៅហើយដែរ ភ្លើងនោះគ្រាន់តែជាភ្លើងកម្ដៅធម្មតាប៉ុណ្ណោះ។

### ១.១. រណ្ដាប់

- គេនិយមហៅកញ្ជើស្រូវនោះថា «**ស្រូវកញ្ជើ**» ដូច្នេះតែម្ដង ឬជួនកាលហៅថា«**ស្រូវពន្លៃ**»។
- ប្រដាប់ប្រដាកាត់សក់មានកន្ត្រៃ ក្រាស កាំបិតកោរ កញ្ចក់ និងកន្ទោងសម្រាប់ដាក់សក់ជាដើម (ជួនកាលគេញាត់កន្ទោងនោះទៅក្នុងផ្លែជំនីកតែម្ដង)។
- ប្រដាប់ប្រដាបំពេញលក្ខណៈជាមនុស្សមានពន្លាក អន្លូង ម្សៅលាបមុខ ខ្មៅដៃសម្រាប់គូរចិញ្ចើមជាដើម។
- បើនៅទីណាដែលគេនិយមបង្វិលពពិលក្នុងកិច្ចពិធីនេះ គឺត្រូវមានពពិលនិងទៀនថែមទៀត។
- ជមសម្រាប់ធ្មប។ បើមានអាចារ្យផងតែងមានជមសម្រាប់អាចារ្យនោះទៀត។

### ១.២. អ្នកធ្វើកិច្ច

បើកិច្ចសមល្មមម្ចាស់បុណ្យរ៉ាប់ទទួលភ្ញៀវដូចជានំបញ្ចុកជាដើម ជួនកាលទៀតសន្តានព្រៀងលាននោះអាចនៅស៊ីផឹករហូតដល់ពេលយប់ មានភ្លេងភ្លាត់ទៀត។ មានន័យថា អ្នកដែលមកចូលរួមមានចំនួនច្រើន។ បើនិយាយតែពីនាក់ដែលត្រូវធ្វើកិច្ចនោះយ៉ាងហោចណាស់ត្រូវមានធ្មបពុំនោះទេជួនកាលឃើញមានមនុស្សប្រុសដែលជាគ្រូ ឬជាអាចារ្យវត្តផង។

### ១.៣. កិច្ចពិធី

នៅតំបន់អង្គរគេនិយមធ្វើពិធីនេះនៅខែចន្ទគតិណាដែលពេញលេញ (ឬហៅថាខែចំណេញ) ពោលគឺខែណាដែលមាន៣០ថ្ងៃ មានន័យថាពិធីនេះអាចធ្វើដាច់ផ្សេងពីការទម្លាក់ដើងក្រានដែរ ព្រោះទាល់តែរើសពេលឱ្យបានត្រឹមត្រូវ។ ជួនកាលពិធីនេះធ្វើចូលគ្នា ក្មេងខ្លះជាទារកពិតៗ ឯក្មេងខ្លះធំទៅហើយ។ ប្រការនេះទៀតក៏បង្ហាញកាន់តែច្បាស់ថា ជួនកាលមិនថា៣ថ្ងៃឬ៧ថ្ងៃ ក្រោយពេលឆ្លងទន្លេនោះទេដែលគេធ្វើពិធីឆ្លងវ័យទារក។ កិច្ចទាំងឡាយតែងតែចាប់ផ្ដើមនឹងការសែនដូនតា ដូច្នេះតែងតែ

មានម្ហូបអាហារ បង្អែមចង្អាបជាធម្មតា។ រីឯស្រាវិញពុំសូវខានឡើយ ហាក់ដូចជាជូនតានោះត្រូវការខ្លាំងណាស់។

តាមពិតកិច្ចសែនជូនតាតែងចែកជា២ផ្នែក គឺដំបូងឡើងគេតែងបំបែកសំណែនខ្លះទៅដល់ខ្មោចផ្សេងៗ ដែលតែងតែមកជាមួយគេ ដោយសារអត់ឃ្លានអាហារ។ នៅតំបន់អង្គរខ្មោចដែលគេមិនបានអន្ទងតែនៅតែមកនេះហៅថា «**មារការ**» គឺគេរំលែកអាហារឱ្យដើម្បីជៀសវាងការយាយីតែប៉ុណ្ណោះ។ បន្ទាប់ទើបគេសែនជូនតាពិតប្រាកដ។ បើមានអាចារ្យគឺអាចារ្យជាអ្នកប្រកាស បើគ្មានអាចារ្យទេ គឺធ្មបជាអ្នកប្រកាសប្រាប់ជូនតាឱ្យជ្រួតជ្រាបអំពីពិធី ហើយនិងសូមពរជ័យពីជូនតានោះទៅដល់សមាជិកថ្មីនៃគ្រួសារ។ នៅស្រុកបាធាយ លុះសែនជូនតាចប់ភ្លាមហើយ គេមានសែនប្រាប់ចាស់ស្រុកទៀត ពោលគឺប្រាប់អ្នកតាប្រចាំសហគមន៍របស់គេ។ ប្រការនេះគួរឱ្យចាប់អារម្មណ៍ណាស់ព្រោះថា ទារកជាសាមីនៃពិធីនោះ ពុំត្រឹមតែគេទទួលស្គាល់ថា ជាសមាជិកមួយថ្មីនៃគ្រួសារប៉ុណ្ណោះឡើយ គឺជាសមាជិកថ្មីនៃសហគមន៍ទៀតផង។ ក្នុងពេលប្រកូកប្រកាសនោះគេតែងច្រូចស្រាទៅជាមួយ។ អ្នកដែលនិយមបង្វិលពពិលក្នុងពិធីនេះ គឺនៅពេលនេះហើយដែលគេបង្វិលលើកទី១ ហើយនៅមានបង្វិលម្តងទៀតជាលើកទី២ ដែលធ្លាប់ឃើញនៅខេត្តកំពង់ចាមគឺគេបង្វិលជុំវិញម្តាយនិងកូន។ កិច្ចបង្វិលពពិលនោះសំដៅថា ឱ្យព្រលឹងទាំងអស់នៅនឹងរូបកុំឱ្យបែកខ្ញែកទៅណា។ ដូច្នេះហើយយ៉ាងណាក៏ដោយក្នុងកិច្ចបង្វិលពពិលលើកទី២ គេបង្វិលឱ្យបាន១៩ជុំ ត្បិត១៩ជាចំនួនពេញលេញនៃព្រលឹង។ ពេលនោះអាចារ្យមានសូត្រជយន្តោផង។ តែកិច្ចសំខាន់បំផុតដែលធ្វើខានមិនបាន គឺការកាត់សក់ ពោលគឺកាត់សក់ព្រៃដូចបាននិយាយនៅខាងលើ ទោះជាទារកនោះឥតទាន់មានសក់សោះ ក៏ឧបកិច្ចធ្វើជាកាត់ដែរ។ យើងបាននិយាយមកហើយថា នេះជាការផ្តាច់ក្មេងចេញពីវិស័យព្រៃឱ្យមកនៅក្នុងវិស័យស្រុក។ អ្នកខ្លះធ្វើកិច្ច «**បើកភ្នែក**» ឱ្យក្មេងនោះទៀត ដោយប្របាច់ទឹកដោះពីម្តាយមកលាបលើត្របកភ្នែកឱ្យក្មេង។ ភ្នែកក្មេងបើកមើលឃើញគឺឃើញឯកឯងក៏ពិតមែនតែហាក់នៅមិនទានគ្រប់ឥតខ្ចោះ ទើបបន្ថែមកិច្ចបំបើកនេះឱ្យកាន់តែភ្លឺក្នុងសង្គមដែលមានវប្បធម៌។ កិច្ចមួយទៀតដែលឃើញធ្វើពុំដែលខាន គឺការចងដៃឱ្យក្មេងនោះ ជួនកាលគេហៅព្រលឹងឱ្យយ៉ាងខ្លីជាមួយគ្នាផង។ បន្ទាប់ពីទារក ក៏ចងដៃឱ្យម្តាយ ទើបឱ្យម្តាយនិងឪពុកនោះចងដៃឱ្យធ្មបម្តងវិញ។ ទោះជាគេបានធ្វើនៅទម្លាក់ជើងក្រានហើយក៏ដោយ ក៏នៅពេលនេះគេអាច «**បង្កក់**» ជូនគាត់ម្តងទៀតដែរ។ ការជម្រះមន្ទិលនេះជួនកាលមិនឃើញមានកិច្ចអ្វីច្បាស់ឡើយ តែជួនកាលទៀតលាងដៃធ្មបដោយទឹកត្រាំផ្លែសម្បួរ។ ជួនកាលផុតពីនោះភ្លាមទៅ ធ្មបក៏យកទារកមកបីក្នុងដៃខ្លួន ហើយហុចទៅស្រីៗដែលមករួមពិធីនោះតៗគ្នាពីដៃមួយទៅដៃមួយ ទើបទីបំផុតប្រគល់ទៅម្តាយវិញ។ នេះពុំពិបាកយល់ទេ គឺគេរាប់ក្មេងនោះ

ថា គឺជាសមាជិកនៃសង្គមនោះហើយ។ ទីបញ្ចប់នៃពិធី ទាំងឪពុកទាំងម្ដាយតែងតែទៅសំពះផ្នូប សូមខមាទោសដោយសារគាត់បាន «**កាន់ពោះ កាន់ពុង**» ស្រីជាម្ដាយ ពុំគិតពីមន្ទិលផ្សេងៗ ហេតុតែត្រូវបង្កើតកូននោះ។ ស្រូវកញ្ជើក៏គេជូនទៅគាត់ជាឱឡារិកដែរ ត្បិតជាកំណាល់សម្រាប់គាត់។

**អត្ថន័យ**

សរុបសេចក្ដីមក ចំណុចសំខាន់ក្នុងពិធីនេះ គឺជាការបញ្ចូលទារកមកក្នុងសង្គម ដោយធ្វើការកែច្នៃទារកឱ្យត្រូវទៅតាមចំណង់ចំណូលចិត្តនៃសង្គម ព្រមទាំងដាក់ឈ្មោះប្រគល់នាមរូបដល់ទារកនេះផង ។

## ២. ពិធីនៅពេលរៀបពេញវ័យ «កោរជុក ឬកោរសក់»

-ពិធីនេះជាការរៀបចំឱ្យសាមីខ្លួនត្រៀមនឹងចូលក្នុងភាពពេញវ័យ។

-ជាគោលការណ៍ ឬជាទ្រឹស្ដីត្រូវធ្វើចាប់ពីអាយុ១១ទៅ១៣ឆ្នាំ តែបើក្មេងប្រុសជួនកាលអាចមានអាយុរហូតដល់១៥ឆ្នាំ។

-ក្មេងប្រុសក្មេងស្រីអាចធ្វើលាយឡំចូលគ្នាបាន។

-អ្នកស្រុកភាគច្រើនរៀបចំធ្វើកិច្ចនៅក្នុងខែមាឃ ផល្គុន និងពិសាខ មានរយៈពេល៣ថ្ងៃ។

-មានលក្ខណៈព្រហ្មញ្ញសាសនា ព្រោះកន្លែងកោរហៅថា «**រានកោរ ឬរានម៉ា**»។

-សព្វថ្ងៃ យើងអាចប្រទះឃើញពិធីនេះដោយកម្រ គឺមាននៅតំបន់អង្គរនិងនៅភាគខាងជើង ឬប៉ែកពាយព្យនៃប្រទេស។

### ២.១. រណ្ដាប់

-បាយស្រីដើម[24]: មានកម្ពស់ស្មើនឹងសាមីខ្លួននៃពិធី ប៉ុន្តែអាចមានលើស ឬខ្វះបន្តិចបន្តួច។ បាយស្រី(បាយសី) អាចមាន៧ថ្នាក់ ឬ១៩ថ្នាក់ ដែលជាវត្ថុសួងឱ្យសាមីខ្លួន។

-បាយព្រលឹង: សាមីខ្លួនម្នាក់ៗត្រូវមានបាយព្រលឹងមួយ។

-ស្រូវកញ្ជើមួយសម្រាប់ក្មេងម្នាក់អង្គុយធ្វើធ្មេញ។

-គ្រឿងអង្ករាប: មានអង្ករ រង្វាល់(តក់ នាឡិ ត្រល់ សំពៅ) កញ្ចប់ថ្នាំ៨មុខ និងកំណាត់ស្បូវភ្លាំង។

-ពពិល: មានបីដើម។

-ប្រដាប់ប្រដាហៅព្រលឹង: មានកូនឈ្នាង វែក កញ្ចើ និងបាយព្រលឹង។

-ប្រដាប់ប្រដាកោរសក់: មានកាំបិតកោរច្រើនយ៉ាង កន្ត្រៃ កន្ទោង ស័ង្ខសម្រាប់ស្រោចទឹក។

---

[24] ពាក្យ«បាយស្រី» ត្រឹមត្រូវដូច្នេះ សព្វថ្ងៃឮគេប្រើតែនៅប៉ែកខាងជើង ដូចជាអ្នកស្រុកលើក្នុងខេត្តសៀមរាប អ្នកស្រុកនៅខេត្តឧត្តរមានជ័យ និងព្រះវិហារ ព្រមទាំងខ្មែរទាំងអស់ដែលរស់នៅប្រទេសថៃបច្ចុប្បន្ន ដូចជាខេត្តសុរិន្ទ្រ បុរីរម្យ ជាដើម។ រីឯខ្មែរកណ្ដាលឬនៅខាងត្បូង និយាយក្លាយមកជា «បាយសី» ជាទូទៅហើយ។

-ព្រះខ័ន ឬដំបងពេជ្រ: ធ្វើពីស្លឹកកំពូលត្នោត ហើយចារគាថានៅលើនោះផង។ បើធ្វើចូលគ្នា ក្មេងម្នាក់ត្រូវមានព្រះខ័នផ្ទាល់ខ្លួនម្នាក់មួយៗ។

-គ្រឿងតុបតែងខ្លួន: មានសម្លៀកបំពាក់ សម្ភារៈតុបតែងសក់។

-ជម ឬពិស្ដារផ្សេងៗ: សម្រាប់អ្នកមានតួនាទីសំខាន់នៅក្នុងកិច្ចអ្វីមួយច្បាស់ដូចជាតាអាចារ្យ ជាងធ្វើពានកោរ អ្នកភ្លេង ខ្មែ ជាដើម។



ពានកោរ ឬពានម៉ា (ប្រភព: www.khmerenaissance.info)

## ២.២. អ្នកធ្វើកិច្ច

-តាអាចារ្យអាចមានម្នាក់ ឬ២នាក់ និងចាស់ទុំ។

-ខ្មែ ពោលគឺស្រីម្នាក់ ឬច្រើនជាងនោះដែលទទួលខុសត្រូវលើការតុបតែងខ្លួនក្មេង។

-ក្រុមស្រីអ្នកដើរទៅហៅព្រលឹងនៅក្រៅផ្ទះ ប្រសិនបើមានកិច្ចជញ្ជាត់ព្រលឹង។

-ព្រះសង្ឃ ជាទូទៅតែងឃើញមាន៥ ឬ៧អង្គ។

## ២.៣. កិច្ចពិធី

**-ថ្ងៃទី១**: គេរៀបចំធ្វើនំនែកច្រើនមុខ(នំក្រូច នំខ្ចី នំកន្ត្រាំ នំកង នំខ្លួត...)។ នំជាលជានំសំខាន់ជាងគេ។ មេជាង កូនជាង អ្នកស្រុក ចាប់ផ្ដើមរៀបចំធ្វើពានកោរ ចាក់ចេក និងរៀបចំពិស្ដារ។

**-ថ្ងៃទី២**: គេបន្តធ្វើនំបន្តទៀតមាននំអន្សម អន្សមផ្អោប និងនំបញ្ចុក។ គេរៀបចំផ្តុំបាយស្រីដើម។ នៅពេលរសៀល ធ្វើពលីការចំពោះដីដែលគេហៅថា «**ប្រុងពលី**» ដែលធ្វើនៅផ្ទាល់ដីខាងត្បូងជាប់នឹងពានកោរ។ «**ពលី**» នោះគឺពលីនាងគង្ហីងជានិមិត្តរូបនៃដី ដោយកប់ពៃដែលមានរូបស្នងធ្វើអំពីម្សៅអង្ករទៅក្នុងដីជម្រៅប្រមាណជាងមួយចំអាម។ អ្នកដែលគេឧទ្ទិសទៅនោះហៅថា «**ក្រុងពាលី**»។ នៅក្បាលព្រលប់គេនិមន្តព្រះសង្ឃសូត្រមន្ត (៥ ឬ៧អង្គ) លុះយប់បន្តិចទៅ ប្រមាណម៉ោង៨ គេរៀបចំពិធីសែនដូនតា បង្វិលពពិលអង្គរាប ជញ្ជាត់ព្រលឹង។

**-ថ្ងៃទី៣**: ព្រះអាទិត្យពុំទាន់រះនៅឡើយគេត្រូវរួសរាន់ «**រង់ពេលា**»។ គេដាស់ក្មេងឱ្យ «**រាវអង្កររាប**» ដោយចាប់យកវត្ថុណាមួយនៅក្នុងអង្ករនោះ បន្ទាប់មកអាចារ្យទាយប្រមើមើលពីអនាគតនៃក្មេងម្នាក់ៗតាមរបស់ដែលរាវបាន។ គេតុបតែងខ្លួនក្មេងនោះសាជាថ្មី ជាពិសេសក្ងួចសម្ផិតសម្អាងដុក។ ក្នុងពេលជាមួយគ្នានោះអាចារ្យម្នាក់ស្លថ្នាំសម្រាប់ធ្វើធ្មេញ។ អាចារ្យនាំក្មេងទាំងនោះហែដើរឆ្លងស្ពានសំដៅទៅស្ពានកោរ ប្រទក្សិណ៣ជុំ ហើយក៏បង្គាប់ឱ្យក្មេងអង្គុយនៅទីនោះ ទើបនិមន្តព្រះសង្ឃឱ្យគង់ក្នុងពានកោរផ្ដាច់សក់កំប៉ោយក្មេង រួចស្រោចទឹក។ ពេលត្រឡប់ពីពានវិញ ស្រាយបាយស្រីដើមដាក់ផ្តេកលើករំលងលើក្បាលក្មេងនោះ៣ដង បន្ទាប់មកក៏យកទៅចោលនៅក្បែរទីនោះ។ កិច្ចបញ្ចប់ឆ្លងវ័យនេះ

គឺគេឱ្យក្មេងហូបផ្លែចេកដែលនៅក្នុងបាយព្រលឹងម្នាក់ៗរៀងៗខ្លួន។ វេលាប្រមាណម៉ោង១០ព្រឹក គេរាប់បាត្រប្រគេនព្រះសង្ឃជាកិច្ចបញ្ចប់ពិធីទាំងមូល។

## ៣. ពិធីនៅពេលពេញវ័យ «ចូលម្លប់»

### ៣.១. សង្ខេបទូទៅ

-ជាពិធីដែលគេជួបដោយកម្រក្នុងសម័យបច្ចុប្បន្ន តែពីបុរាណពេញនិយម។

-ធ្វើនៅពេលដែលកូនស្រីពេញក្រមុំ ពោលគឺពេលមានរដូវជាលើកដំបូង។

-ពិធីនេះហាក់ដូចជាឧបកិច្ចថា ស្រីនោះបានរៀបការរួចទៅហើយ ត្បិតយើងសង្កេតឃើញមានការសំពះផ្ទឹមដូចការដែរ។

-ក្នុងពិធីនីមួយៗឃើញថា ចំណាយថវិកាមិនតិចជាងមង្គលការប៉ុន្មានឡើយ។

-មិនអាចធ្វើចូលរួមគ្នាបានទេ។

-ពិធីចូលម្លប់សព្វថ្ងៃ មាននៅស្រុកស្រែអំបិល(កោះកុង) ស្រុកបាជាយ(កំពង់ចាម)និងស្រុកសូត្រនិគម (សៀមរាប)។

-នៅបាជាយមានរយៈពេលពី២ខែ ទៅ៣ខែ ឯនៅកោះកុងវិញមានតែ១អាទិត្យប៉ុណ្ណោះ។

### ៣.២. រណ្តាប់

-ស្រូវកញ្ចើ ឬស្រូវពន្លៃ

-កូនចេកនិងកូនអំពៅ

-ត្បាល់...។

### ៣.៣. កិច្ចពិធី

-ជ្រើសរើសពេលវេលាយ៉ាងត្រឹមត្រូវ តាមខែឆ្នាំនៃសាមីពិធី។

-ពុំមានលក្ខណៈអធិកអធមខ្លាំងទេ តែគ្រាន់តែធ្វើឱ្យបានសមរម្យ ព្រោះមានចាស់ទុំនិងអាចារ្យចូលរួមដែរ។

-មានរៀបចំជាគ្រឿងសំណែនផ្សេងៗដល់ដូនតា ហើយអ្នកចូលរួមបាននិយាយសុំឱ្យដូនតាបានដឹងឮថា កូនស្រីបានចូលម្លប់ហើយ។

-ក្នុងពិធីនេះស្រាមានតួនាទីសំខាន់ណាស់សម្រាប់ទំនាក់ទំនងជាមួយខ្មោច។

-និមន្តព្រះសង្ឃសូត្រមន្តដូចក្នុងកិច្ចអ្វីទូទៅជាធម្មតា។

-អាចារ្យបំបួសកូនស្រី បំបួសកូនចេកនិងកូនអំពៅហើយឱ្យកូនស្រីស្រោចទឹកថៃទាំឱ្យបានល្អ។

-មានត្រណមផ្សេងៗដែលត្រូវអនុវត្ត។

-អាហារប្រចាំថ្ងៃរបស់កូនម្លប់គឺត្រូវហូបបួស ហើយហាមទទួលទានផុតពីថ្ងៃត្រង់ទៅ។

-កូនម្លប់ត្រូវដាំស្លដោយខ្លួនឯង។

-នៅពេលចេញពីម្លប់ ទើបមានពិធីគគ្រឹកគគ្រេង ដូចជាមានសង់បុស្បុក សែនក្រុងពាលី និមន្តព្រះសង្ឃមកសូត្រមន្ត ត្លុកកំប្លែង បង្វិលពពិល ធ្វើធ្មេញ កាត់សក់ កូនស្រីស្លៀកពាក់តុបតែងកាយ

ស្អាត មានពិធីបើកវាំងនន...។ ការឆ្លងវ័យនៅដំណាក់កាលនេះ គឺបញ្ចប់ដោយកិច្ចកប់សក់ ពោលគឺយកសក់ទៅកប់ក្នុងស្រែដែលបម្រុងនឹងចែកឱ្យកូនទៅថ្ងៃអនាគត ដោយមានត្លុក និងពួកភ្លេងដង្ហែហែហមផង។

## ៤. ពិធីនៅពេលពេញវ័យ «បំបួសនាគ»

ពិធីបួសអាចគិតថា ចែកជាពីរដំណាក់កាលក៏បាន។ ក្នុងរយៈពេលដំបូងគេរៀបចំឱ្យកំលោះទាំងនោះនៅក្នុងភាពមួយដែលគ្រហស្ថមិនចំគ្រហស្ថ បព្វជិតមិនចំជាបព្វជិត ប្រុសមិនចំជាប្រុស ស្រីមិនចំជាស្រី អាចនិយាយថា មនុស្សមិនចំជាមនុស្សផងក៏សឹងបាន ត្បិតគេហៅអ្នកទាំងនោះថា «**នាគ**»។ មកពីដូច្នេះហើយបានជាគេហៅពិធីបួសនេះថា «**បួសនាគ**»។

### ៤.១. លក្ខណៈទូទៅ

-ជាទំនៀមទម្លាប់ដ៏មានសារៈសំខាន់មុនពេលខ្មែរមានសាលារដ្ឋបរិបូរ

-នៅតែពេញនិយមក្នុងស្រុកខ្មែរ ពិសេសតំបន់ជនបទ

-ការបួសមានច្រើនដូចជាបួសមុខភ្លើង បួសរៀន បួសដើម្បីសន្សំកុសលទៅអនាគតជាតិ។

-ដើម្បីអប់រំសិក្សាឱ្យទៅជាមនុស្សមានសមត្ថភាព

-ហាក់ផ្តាច់មួយរយៈចេញពីមនុស្សភេទផ្ទុយ។

### ៤.២. ភាពជានាគ

-ការតុបតែងមុនបួស (ជូនសម្អិតសម្អាងរួមគ្នា នៅជាមួយគ្នា)

-អ្នកបួសហៅថា «**នាគ**» (ខ្ពង់ខ្ពស់)

-ដង្ហែនាគ (ជិះសេះ កង់ ជិះគោ ឬជិះកឪពុក និងអ្នកទូលត្រៃ)

-ក្បួនដង្ហែផ្តើមពីតិចទៅច្រើន

-ការហៅព្រលឹងនាគ (សូត្រតាមក្រាំង)

-មានធ្វើពិធីជញ្ជាត់ព្រលឹង នៅពេលទៀបភ្លឺ

-ពិធីបង្វិលពពិល ធ្វើផ្ទេញនៅពេលព្រឹកព្រលឹម

-ពេលនោះអ្នកបួសពុំដឹងថាជាភេទអ្វីមួយឱ្យច្បាស់ទេ។

### ៤.៣. ភាពជាបព្វជិត

-ការបំបួសធ្វើឡើងនៅក្នុងព្រះវិហារនាពេលរសៀល

-នាគត្រូវចេះធម៌បួសដើម្បីសូត្រឆ្លើយឆ្លងជាមួយឧបជ្ឈាយ៍

-ឧបជ្ឈាយ៍យកអង្សកែមកទាក់ក រួចសូត្រធម៌ឱ្យនាគប្តូរសម្លៀកបំពាក់សង្ឃដូចជា ស្បង់ ចីវរ សំពត់ងូត សង្ឃាដី អង្សក វត្តពន្ធទ្រូង...។

### ៤.៤. ការលាចាកសិក្ខាបទ

-មានព្រះសង្ឃជាអ្នកផ្សឹក

-សឹកក្បាលដំបូក

-អ្នកសឹកពីបួសហៅថា «**អន្ទិត**»

-ពុំមានរៀបចំពិធីអ្វីឱ្យធំដុំទេ។



ក្បួនដង្ហែនាគ និងការរៀបចំកិច្ចពិធីនៅក្នុងព្រះវិហារ

## ៥. ពិធីអាពាហ៍ពិពាហ៍ ឬមង្គលការ

នៅក្នុងសង្គមខ្មែរយើង ការទទួលគ្នាជាប្ដីប្រពន្ធ ចាំបាច់ត្រូវតែឆ្លងកាត់តាមសេចក្ដីសម្រេចរបស់លោកមេបា។ ក្រមុំកំលោះណាប្រព្រឹត្តខុសនឹងសីលធម៌នេះ (សាហាយស្មន់គ្នា) ទោះជាចាស់ទុំយកទៅរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីក៏ដោយ ក៏សង្គមនៅតែដាក់ទោសក្រមុំកំលោះនោះមិនឱ្យចូលរួមធ្វើមេបា អាចារ្យ ជ្មាយ មហា ឬចូលរួមក្នុងការបង្វិលពពិលទេ។ កំហុសនេះវាបន្តដល់កូនចៅតទៅទៀត ទោះជាកូនចៅនោះមិនបានប្រព្រឹត្តខុសដូចម៉ែឪក៏ដោយ។ ដូចនេះអាពាហ៍ពិពាហ៍មានសារៈសំខាន់ណាស់ក្នុងជីវភាពនារី គ្រួសារ និងសង្គម។

ពាក្យអាពាហ៍ពិពាហ៍ < អាវាហៈ + វិវាហៈ

-អាវាហៈ = នាំកូនស្រីមកផ្ទះកូនប្រុស

-វិវាហៈ = នាំកូនប្រុសមកផ្ទះខាងកូនស្រី

} ការនាំមកនិងត្រឡប់ទៅវិញនៃកូនប្រុសកូនស្រី

ដូចនេះគេរៀបចំពិធី២លើក។ ប៉ុន្តែជាទូទៅ យើងសង្កេតឃើញគេនាំកូនប្រុសមករៀបការនៅផ្ទះកូនស្រី ហើយនាំកូនស្រីទៅរោងខាងប្រុសវិញដែលគេហៅថា «**សង្កត់រោង**»។

### ៥.១. ប្រភពអាពាហ៍ពិពាហ៍

-ខ្លះថាយកតាមពិធីអភិសេកព្រះថោងនិងនាងនាគ

-ខ្លះថាយកតាមពិធីមង្គលការព្រះរាមនិងនាងសីតា

-ខ្លះថាយកតាមពិធីអភិសេកចៅក្រឹស្នានិងជាលី

-តាមលោក ម៉ម ប៊ុណ្ណា (នៅក្នុងសៀវភៅ Les tites de mariage traditional Khmer) ថាមនុស្សចេះធ្វើពិធីអាពាហ៍ពិពាហ៍តាំងពីមនុស្សចេះអៀនខ្មាស ចេះស្រឡាញ់កិត្តិយស។

### ៥.២. មុនពេលរៀបអាពាហ៍ពិពាហ៍

កាលបើឪពុកម្ដាយខាងកូនប្រុសពេញចិត្តកូនក្រមុំហើយ គេរកមធ្យោបាយដូចជាៈ

**ក. ចូលថែចូវ**ៈ ឪពុកម្ដាយខាងកូនប្រុសរកស្រីដែលមានឥទ្ធិពលនៅក្នុងភូមិ (មិនអភ័ព្វគូ មានចរិយាសម្បត្តិល្អ អ្នកភូមិគោរព មានទ្រព្យសម្បត្តិ) ទៅផ្ទះឪពុកម្ដាយកូនស្រី និយាយប្រាប់គ្រួសារកូន

ស្រីថា អ្នកនេះនៅឯនោះចង់ភ្ជាប់សាច់ឈាមជាមួយគ្រួសារលោក តើលោកថាម៉េច? (ទៅច្រើនដង) រហូតលទ្ធផលវិជ្ជមាន ឬអវិជ្ជមាន។ បើវិជ្ជមានអ្នកចែចូវត្រូវជម្រាបសួរថ្ងៃខែឆ្នាំកូនស្រីដើម្បីឱ្យឪពុកម្ដាយខាងកូនប្រុសយកទៅរកហោរាគន់គូពិធីផ្សំពង្សនិងផ្សំជាតុ។ បើល្អហើយត្រូវរៀបពិធីចូលស្ដីដណ្ដឹងទៅទៀត។

**ខ. ពិធីស្ដីដណ្ដឹង**

-ឪពុកម្ដាយខាងកូនប្រុសរកហោរាមើលពេលាជ័យ ថ្ងៃខែឆ្នាំល្អ ដើម្បីចូលស្ដីដណ្ដឹង។

-ឪពុកម្ដាយខាងកូនប្រុសរកឆ្មាយ(នារីមានលក្ខណៈល្អប្រសើរ) ចេះនិយាយប្រពៃណីការច្បាស់លាស់ រកប្រដាប់ប្រដាស្លាម្លូ នំចំណីជាទ្រនាប់ដៃចូលទៅនិយាយការជាមួយនឹងញាតិមិត្តសាច់សារលោហិតទៅចូលរួម។

-ឪពុកម្ដាយខាងកូនស្រី ត្រូវរកចាស់ព្រឹទ្ធាចារ្យដែលចេះប្រពៃណីមកធ្វើជាមេបា តំណាងឱ្យខាងស្រី (បង្គោលការ) សម្រាប់សម្រេចកិច្ចការដែលឆ្មាយស្នើសួរ។

-រៀបចំម្ហូបអាហារ ផ្ទះសំបែង អញ្ជើញញាតិមិត្ត។

លុះដល់ថ្ងៃខែកំណត់ ឪពុកម្ដាយកូនប្រុសនាំឆ្មាយ មហាអ្នកមុខអ្នកការ (អ្នកផ្លូវចៅមហា ទៅផ្ទះកូនស្រីដើម្បីស្ដីដណ្ដឹងចំពោះមុខលោកមេបាតាមប្រពៃណី)។

ពីបុរាណកាលពិធីស្ដីដណ្ដឹងមាន៣លើកៈ

- មេបាគ្រាន់តែអនុញ្ញាតឱ្យផ្លូវដើរជណ្ដើរឡើង
- មេបាអនុញ្ញាតឱ្យមានទំនាក់ទំនងពឹងពាក់សំណាក់អាស្រ័យបាន
- មេបាអនុញ្ញាតឱ្យកូនប្រុសទៅជាមួយដើម្បីពិនិត្យមើលរូបសម្បត្តិនិងចរិយាសម្បត្តិកូនប្រុស។

**គ. ពិធីស៊ីស្លាម្លូ**: ពិធីស៊ីស្លាត្រូវធ្វើ២ដង

-ស៊ីស្លាតូច មានរណ្ដាប់ប្រហែល ១/៣ នៃពិធីរៀបអាពាពិពាហ៍។

-ស៊ីស្លាធំ មានរណ្ដាប់ប្រហែល ១/២ នៃពិធីអាពាហ៍ពិពាហ៍។

<u>**កំណត់សម្គាល់**</u>: លំនាំពិធីត្រូវមានឆ្មាយ មហា មេបាដូចក្នុងពិធីស្ដីដណ្ដឹងដែរ។ ពេលស្ដីដណ្ដឹង គេកំណត់ភស្តុភារបណ្ណាការ ថ្ងៃខែឆ្នាំរៀបអាពាហ៍ពិពាហ៍ បើយល់ស្របគ្នាហើយត្រូវប្រុងប្រៀប:

| <u>**ខាងប្រុស**</u> | <u>**ខាងស្រី**</u> |
|---|---|
| -រកអាចារ្យពេលា | -រកលោកមេបា |
| -រកឆ្មាយនិងមហា | -រកអាចារ្យខ្មែនិងយាយខ្មែ |
| -រកភ្លេងប្រពៃណី | -ជម្រាបបងប្អូនញាតិមិត្ត |

| | |
|---|---|
| -ជម្រាបមាមីងបងប្អូនញាតិមិត្ត | -រកអង្ករនិងគ្រឿងធ្វើធ្មេញ (បើមានធ្វើពិធី) |
| -រកភស្តុភារបណ្ណាការ (ជំនួយ) | -រកស្បៀងអាហារសម្រាប់ទទួលភ្ញៀវ |
| -រកស្បៀងអាហារសម្រាប់ទទួលភ្ញៀវ | -រកអ្នកផ្ទង និងរៀបចំផ្ទះសំបែង |

## ៥.៣. ពេលរៀបអាពាហ៍ពិពាហ៍

ពីបុរាណគេកំណត់ពិធីរៀបអាពាហ៍ពិពាហ៍ចំនួន៣ថ្ងៃ ៣យប់ទើបចប់។[25]

**<u>ថ្ងៃទី១</u>**

-ពេលព្រឹកព្រហាម: ជ្មាយ ឬមហា ចូលទៅសុំអនុញ្ញាតពីលោកមេបា:

- សុំផ្លូវដើរដណ្ដើរឡើងនិងផ្ទះអង្គុយនិយាយ
- សុំដីសង់រោងផ្កាស្លា រោងការ និងរោងដាំបាយ
- សុំវាលលែងក្របី សុំព្រៃកាប់ឈើសាងសង់ពីព្រះភូមិករ រកអុស សុំត្រពាំងដងទឹក...។

បើលោកមេបាអនុញ្ញាតហើយ ទើបមហាសុំដកខ្លួនមកជម្រាបលោកអាចារ្យ។ បន្ទាប់មកលោកអាចារ្យមើលទីកន្លែងសង់រោងទាំង៣ ហើយត្រូវរៀបចំអុជធូបទៀនសុំម្ចាស់ទឹកដី សុំកន្លែងសង់រោងពីព្រះភូមិករធរណីរក្សាដី។

-ពេលល្ងាច: មហាព្រមទាំងអ្នកមុខអ្នកការ ចូលទៅសុំអនុញ្ញាតពីលោកមេបា រៀបចំធ្វើពិធីចូលរោងការ គោះគង ទូងភេរី និងលេងភ្លេងប្រពៃណី។

បើលោកមេបាអនុញ្ញាត លោកមហាចុះមកជម្រាបលោកអាចារ្យ លោកអាចារ្យក៏រៀបចំក្រាលកន្ទេលខ្មើយ ក្រាលសំពត់ស ឱ្យរៀបផ្លែឈើ បាយសម្ល អុជធូបទៀន រួចបញ្ជាឱ្យអ្នកភ្លេងលេងបទ «**ហោមរោង**»។

-ពេលយប់: លោកមហា ចូលទៅសុំអនុញ្ញាតគោលការណ៍ (កម្មវិធី) រៀបអាពាហ៍ពិពាហ៍ត្រូវអនុវត្តនៅពេលខាងមុខ។

**<u>ថ្ងៃទី២</u>**

អាចារ្យច្រើនរៀបចំតាមកម្មវិធីដែលលោកមេបាអនុញ្ញាតៈ

**ក. ពិធីសែនក្រុងពាលី**

លោកមហាចូលទៅសុំអនុញ្ញាតពីលោកមេបា ធ្វើពិធីសែនក្រុងពាលីព្រមទាំងអញ្ជើញត្រកូលរៀមច្បងចូលរួមផង។

[25] ញាណ គឿន និង ម៉ម ឆៃ, លំអានទំនៀមខ្មែរបុរាណ(ទម្លាប់អាចារ្យ), ២០០៤។

-លោកអាចារ្យរៀបចំជ្រើសរើសកន្លែងរៀបចំសែនក្រុងពាលី (ក្រាលកន្ទេលផ្ទាល់នឹងដីខាងត្បូងផ្ទះកូនស្រី ខាងត្បូងល្វែងចន្ទ្របែរមុខទៅត្បូង បើគ្មានកន្លែងខាងត្បូង ត្រូវរៀបចំទៅទិសខាងកើតបែរមុខទៅទិសខាងត្បូងដែរ។ រណ្តាប់រៀបចំមាន បាយសី ស្លាធម៌ ភ្ញីផ្កា អុជទៀនធូប ម្ហូបអាហារ មាន់ស្ងោរមួយគូ ពែពារូត ឬពៃ៥រូតមួយ...។ ពិធីនេះធ្វើដើម្បីសុំក្រុងពាលីឱ្យកូនប្រុសសុំរស់នៅលើទឹកដីថ្មីនេះ និងផ្តល់សេចក្តីចម្រើនឱ្យកូនប្រុស។

**ខ. ពិធីស្តីដណ្តឹង**: ធ្វើដូចមុនដែរ គ្រាន់តែសង្ខេបខ្លីជាងមុន។

**គ. ពិធីហែកំណត់**

ពីបុរាណពិធីហែកំណត់ គេមិនហែកូនកំលោះទៅជាមួយដូចសព្វថ្ងៃទេ គឺគេហែតែភស្តុភារបណ្ណាការទៅតែប៉ុណ្ណោះ។ ហែទៅដល់មាត់ជណ្តើរមានបុរសពីរនាក់ឃាត់សួរដំណើរទំនងសព្វគ្រប់ទើបអនុញ្ញាតឱ្យឡើងលើផ្ទះ។ ពេលរៀបចំជំនូនសព្វគ្រប់ហើយ ទើបឱ្យអាជ្ញាកណ្តាលពីរនាក់ពិនិត្យភស្តុភារបណ្ណាការសាជាថ្មីម្តងទៀត។ បើគ្រប់ហើយទើបធ្វើពិធីជូនពេលា និងពិធីស៊ីស្លា។ លុះចប់ពិធីទាំងពីរនេះហើយ លោកមេបាបានបង្គាប់ឱ្យរករបាំមួយគូរាំសង្កត់ស្លាដក់ ស្លាកន្សែងរហូតដល់ថ្ងៃត្រង់ទើបលោកមេបាបញ្ជាលោកមហាឱ្យរៀបចំពិធីបញ្ចូលក្រយា។

**ឃ. ពិធីកាត់ផ្កាស្លា**

សុំបញ្ជាក់ថា ពីបុរាណគេមិនកាត់ផ្កាស្លា ឬផ្កាដូងយកមកទុកមុនដូចសព្វថ្ងៃនេះទេ គេហែកូនប្រុសទៅដល់ដើមដូង ឬដើមស្លាតែម្តង ដោយមានជើងពានទ្រផ្កាស្លា រកអំបោះពណ៌សសម្រាប់ចងដើមដូង ឬដើមស្លា។

**ង. ពិធីកាត់សក់**

ពីបុរាណគេរៀបចំកាត់សក់កូនប្រុសនៅក្នុងរោងការ បែរមុខទៅទិសខាងកើតចំរានទេវតាដែលគេសង់នៅខាងកើតរោងការ។ កូនស្រីរៀបចំកាត់សក់នៅលើផ្ទះ អង្គុយនៅល្វែងចន្ទ្របែរមុខទៅទិសខាងកើតដូចគ្នា មានអាចារ្យខ្មែរជាអ្នករៀបចំ។ ពិធីនេះកាត់ពេលជាមួយគ្នា តាមការបញ្ជាពីអាចារ្យពេលា។

<u>**កំណត់សម្គាល់**</u>: សព្វថ្ងៃរៀបកាត់សក់ជាមួយគ្នា តែកូនស្រីដាច់ខាតត្រូវអង្គុយនៅខាងស្តាំកូនប្រុស។ កាត់សក់រួចកូនប្រុសទៅមុជទឹកសម្អាតកាយនៅទន្លេ ឬស្ទឹង ដោយជិះដំរី ឬសេះ ឬក្របី។

**ច. ពិធីសូត្រមន្ត**

ពិធីបុរាណ គេនិមន្តព្រះសង្ឃសូត្រមន្តដោយឡែកពីគ្នា គឺសូត្រមន្តខាងលើនិងសូត្រមន្តខាងក្រោម។ គេនិមន្តព្រះសង្ឃយ៉ាងតិច៤អង្គមកសូត្រមន្តខាងលើមុន ទើបចុះទៅសូត្រខាងក្រោម។

**ឆ. ពិធីសែនគួចដៃ**

ជាពិធីគោរពវិញ្ញាណក្ខ័ន្ធជីដូនជីតា និងសុំឱ្យវិញ្ញាណក្ខ័ន្ធជីដូនជីតាទទួលស្គាល់ថា ខ្លួនបានរៀបចំអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមប្រពៃណី។

**ជ. ពិធីធ្វើធ្មេញ**

គេធ្វើឱ្យតែនារីទេ ដើម្បីបំពេញលក្ខណ៍ឱ្យនារីទៅជានារីគ្រប់លក្ខណ៍ មានចរិយាល្អស្គាល់ខុសស្គាល់ត្រូវ...។

<u>***សម្គាល់***</u>: កន្លែងខ្លះគេនិយមធ្វើឱ្យបុរសដែរ បើបុរសនោះមិនបានបួស។ ប៉ុន្តែបើបានបួសហើយមិនបាច់ធ្វើធ្មេញក៏បានដែរ។ ពិធីធ្វើធ្មេញមានលំនាំដូចខាងក្រោមនេះ៖

-ពិធីក្រាលអង្គរាប
  - ពិធីរាំខ្វែងអង្គរាប
  - ពិធីរាំខ្វែងពែង

-ពិធីអង្គុយលើអង្គរាប

-ពិធីគាស់ខ្វែរ

-ពិធីរកល័ក្តជុំកន្លង់

-ពិធីកាប់ឈើធ្វើត្បាល់អង្រែ

-ពិធីបុកល័ក្ត

-ពិធីជីកស្រះ ឬអណ្តូង

-ពិធីកាត់ស្លឹក

-ពិធីធ្វើធ្មេញ

-ពិធីប្រគប់ធ្មេញ

-ពិធីឱ្យបាយព្រលឹង

-ពិធីបរសេះ

-ពិធីកាត់ខាន់ស្លា
  - ប្រាក់ខាន់ស្លា (ពីដើមគិតតាមសក្តិ)
  - ប្រាក់ស្នាប់ទឹកដោះ
  - ផ្កាស្លា៣ (ផ្កាស្លាច្បង កណ្តាល និងពៅ)

-ពិធីកប់ល័ក្ត

**ឈ. ពិធីយកពេលា**

ពិធីយកពេលានេះ ពីបុរាណគេគោរពណាស់ ព្រោះជាពិធីមួយដែលធ្វើឱ្យគូស្វាមីភរិយាបានសុខចម្រើន សិរីសួស្តីបន្ទាប់ពីរៀបការរួច ដូចនេះបានជានៅពេលរៀបការ គេបានមើលពេលានេះរួចស្រេចទៅហើយ។ ពេលានេះពីបុរាណគេនិយមថាមាន៤គឺ៖

-ពេលាសត្វ: ចាប់ពីពេលរំលងអធ្រាត្រដល់ម៉ោង៤កន្លះ។

-ពេលាសព្វអក្សរ: ពេលមើលអញ្ចាញដៃឃើញ។

-ពេលាព្រះចន្ទ្រពេញវង់: ពេលថ្ងៃរះពេញវង់។

-ពេលាជាន់ឆាយា: ពេលថ្ងៃត្រង់។ តែជាន់ឆាយានេះអាចារ្យខ្លាចណាស់មិនហ៊ានធ្វើទេ ទាល់តែអ្នកចេះកម្មដ្ឋានទើបហ៊ាន ព្រោះខ្លាចអន្តរាយ តែបើបែរធ្វើបាន គឺល្អបំផុត។

**ថ្ងៃទី៣**

**ក. ពិធីសំពះផ្ទឹម**: ពេលបានពេលាហើយ លោកអាចារ្យឡើងទៅសុំអនុញ្ញាតពីលោកមេបា ធ្វើពិធីជាបន្តបន្ទាប់ដូចខាងក្រោម៖

- ពិធីហែកូនប្រុសទៅផ្ទឹម
- ពិធីសុំកូនស្រីចេញលាងជើង
- ពិធីសំពះផ្កាស្លា
- ពិធីសុំកូនស្រីមកផ្ទឹម
- ពិធីសែនជីដូនជីតា
- ពិធីចាប់ដៃផ្សំផ្គុំ
- ពិធីរាំបើកបាយសី
- ពិធីចងដៃកូនប្រុសស្រី
- ពិធីបង្វិលពពិល
- ពិធីតោងស្បៃចូលបន្ទប់កូនស្រី

**ខ. ពិធីរាំលុបជើងពីរ**: ពេលកូនប្រុសកូនស្រីចូលបន្ទប់ លោកមេបាបង្គាប់ឱ្យពួកភ្លេងលេងបទលុបជើងពីរបំបាត់ចង្រៃ។

**គ. ពិធីរាំសាកន្ទេល**: ពួកភ្លេងពីរនាក់រាំប្រទក្សិណកន្លែងសំពះផ្ទឹម ច្រៀងសសើរគុណសម្បត្តិកន្ទេលដែលខ្លួនលី និងពពាយនាយលក់កន្ទេល។

**ឃ. ពិធីផ្សំដំណេក**: ម៉ោង៨-៩យប់ពិធីផ្សំដំណេកកន្លែងកូនស្រីដេក។ គេរើសយកនារីពីរនាក់ដែលមានខាន់ស្លាមិនអភ័ព្វគូ មានអាយុច្រើន និងត្រូវជាញាតិខាងស្រី ជាអ្នកចេះដឹងពិធីផ្សំដំណេកច្បាស់លាស់។ គេរៀបចំបាយសីមួយគូ ម្ហូបមួយថាស បង្អែមមួយថាស និងដូងខ្ចីមួយសែនដូនតា។

## ៦.ពិធីឆ្លងទៅភាពជាម្ដាយ «ឆ្លងទន្លេ»

ធម្មតាប្ដីប្រពន្ធតែងមានកូន។ បើយោងតាមពរដែលគេឱ្យក្នុងមង្គលការនោះ ឃើញថា គេចង់ឱ្យអ្នកទាំងពីរមានកូនច្រើនផង។ តែអ្នកដែលត្រូវឆ្លងកិច្ចអ្វីមួយនោះគឺស្រីមិនមែនប្រុសទេ ត្បិតស្រីជាអ្នកពពោះ ហើយឆ្លងទន្លេ។ ម្យ៉ាងទៀត គេចាត់ទុកការដែលមានកូនដំបូងថា សំខាន់ខ្លាំងណាស់ ដូច្នេះគេប្រយ័ត្នប្រយែងគ្រប់បែបយ៉ាង។ ពិតហើយថា គ្រោះថ្នាក់នឹងកើតមានឡើង ប៉ុន្តែរឿងកូនដំបូងនេះសំខាន់ត្រង់ថា លើសពីប្រពន្ធទៅទៀត គឺអំណឹះតទៅស្រីនោះក្លាយជាម្ដាយ ពេលមានកូនក្រោយៗមកទៀតសារៈសំខាន់នោះថយចុះ។ អ្នកដែលរាប់អានមន្តអាគមអាចយកទឹកដោះស្រីដែលមានកូនដំបូងមកប្រើធ្វើអ្វីមួយ មិនខុសពីរដូវទីមួយរបស់ក្មេងស្រីដែលអ្នកនោះយកមកប្រើដែរ ព្រោះឈាមដំបូងទាក់ទងនឹងការឆ្លងពីភាពជំទង់មកពេញវ័យក្រមុំ។ ការឆ្លងទន្លេគឺជាទីបញ្ចប់នៃការពពោះ ដូច្នេះដំណាក់កាលទាំងពីរនោះត្រូវយកមកពិនិត្យជាមួយគ្នា។

### ៦.១. ពពោះ

នៅទីនេះគួរយើងយកពាក្យខ្មែរដែលពាក់ព័ន្ធមកពិនិត្យបន្តិច។ ស្រីដែលមានកូននៅក្នុងពោះមិនទាន់កើត គេអាចនិយាយបានច្រើនបែបយ៉ាងដូចជា «ផើម ពោះធំ មានទម្ងន់ មានពោះ (ជួនកាលបន្ថែមថា មានពោះមានពុង) មានផ្ទៃពោះ ពពោះជាដើម»។ ពាក្យដែលប្រើជាធម្មតានេះ ហាក់ដូចជាគេនិយាយគេចមិនឱ្យមានពាក្យថា «**កូន**» ពុំដូចកូនដែលកើតរួចហើយមកទេ។ បើចាត់ទុកការវាស់វែងសម្ដីនោះថា ជាត្រណមក៏សឹងថាបាន។ រីឯត្រណមដែលចេញឈ្មោះចំដូច្នេះមានច្រើន មិនងាយនឹងរាប់ឱ្យអស់ឡើយ តែបើយកបែបផែនមកគិតអាចរៀបរាប់សង្ខេបដូចតទៅនេះ៖

**-ទាក់ទងនឹងកាយវិការ:** មិនឱ្យឈោងចាប់វត្ថុអ្វីមួយដែលនៅខ្ពស់ ជិះរទេះរលាក់ ងូតទឹកពេលយប់ អង្គុយចោងហោង អង្គុយមាត់ទ្វារ ឬមាត់ជណ្ដើរ...។

**-ទាក់ទងនឹងការងាររាល់ថ្ងៃ:** មិនឱ្យដេរអ្វីជិតមុខ ឧទាហរណ៍ច្រកក្នុងខ្នើយហើយដេរបានតែមិនឱ្យភ្ជិតមុខបញ្ចប់ឡើយ ទុកឱ្យអ្នកដទៃធ្វើវិញ...។

**-ទាក់ទងនឹងម្ហូបអាហារ:** តមហឹរ ខ្យង ម្ហូបដែលមានត្រយូងចេក...។

**-ទាក់ទងនឹងអាក្បកិរិយាជាស្រី ឬជាប្រពន្ធ:** ពេលទទួលទានអាហារគេមិនឱ្យដើរ ឬទទួលទានបង្អួសយូរពេលពេក ដើរកន្លងប្ដី ពេលយកត្រីអាំងចេញពីតម្បុតមិនត្រូវហែកតម្បុតនោះទេ...។

**-ទាក់ទងនឹងស្រុកភូមិទាំងមូល:** មិនឱ្យទៅសួរសុខទុកអ្នកដែលឆ្លងទន្លេពិបាក រួមក្នុងបុណ្យសព...។

**-ត្រណមពិសេស:** ដើរកាត់មុខទុកប្រណាំង...។

អ្វីដែលទើបនឹងសង្ខេបមកនេះ គឺសុទ្ធសឹងជាការហាមប្រាម។ ការហាមខ្លះងាយយល់ទេ ដូចជាមិនឱ្យឈោងចាប់អ្វីខ្ពស់ ឬជិះរទេះរលាក់ ហូបហឹរ...។ ត្រណមខ្លះទៀតទាក់ទងទៅនឹងជំនឿ។ ឯគ្រោះថ្នាក់ដែលគេជឿថា អាចកើតឡើង គឺមានពីរចំណុចធំៗ។ មួយគឺការរលូតកូន ឯមួយទៀតគឺកូនមិនចេញ ឬកើតដោយលំបាក។

ត្រណមដែលត្រូវតែធ្វើនោះ គឺកាលណាមានចន្ទ្រគ្រាស ឬសូរ្យគ្រាស អ្នកមានផ្ទៃពោះត្រូវចេញក្រៅមករួមជាមួយគេឯងក្នុងការបណ្តេញរាហ៊ូដែលកំពុងលេបព្រះចន្ទ្រ ឬព្រះអាទិត្យនោះ មានការស្រែកថា «**ជួយលោកៗ**» ព្រមទាំងយករំពាត់ ឬដំបងវាយដើមឈើជាដើម។ នេះមានន័យថា ទារកនោះបានចេញមកក្រៅ ហើយរួមកិច្ចបណ្តេញជាមួយគេដែរ ព្រោះបើពុំដូច្នោះ គេថា «**គ្រាសកន្លង**»។ ក្រៅពីនោះ ការដែលគួរធ្វើមានដូចជា ទទួលទានថ្នាំឫសឈើពេលជិតគ្រប់ខែ បើមានពាក់ខ្សែគាថានៅចង្កេះ ត្រូវដោះចេញជាដើម។

## ៦.២. ឆ្លងទន្លេ

ពាក្យថា «**ឆ្លងទន្លេ**» ស្តាប់ទៅពីរោះខ្លាំងណាស់។ អ្នកខ្លះយល់ថា គេប្រៀបព្រឹត្តិការណ៍នេះទៅនឹងការឆ្លងកាត់ផ្ទៃទឹកធំ អាចពើបប្រទះគ្រោះថ្នាក់ ត្បិតកាលមិនទាន់ខ្ចីពាក្យ «**សមុទ្រ**» ពីភាសាសំស្ក្រឹតមក ខ្មែរហៅសមុទ្រថា «**ទន្លេ**» សូម្បីសព្វថ្ងៃក៏ផ្ទៃទឹកអ្វីមួយដែលធំល្វឹងល្វើយ ឬតូចជាងនោះផងក៏នៅហៅថា «**ទន្លេ**» ដែរ ឧទាហរណ៍«**ទន្លេសាប**» «**ទន្លេបាទី**» ជាដើម។ ទារកដែលចេញមកពីផ្ទៃម្តាយប្រដូចបានទៅនឹងឆ្លងមហាសាគរមួយដល់ត្រើយដែរ។ យ៉ាងណាក៏ដោយន័យថា ឆ្លងទឹកនេះទោះជានិយាយពីម្តាយ ឬនិយាយពីកូនក៏នៅតែមាន ត្បិតមានពាក្យថា «**បែកទឹកភ្លោះ**»។ ក្រៅពីពាក្យដ៏ពីរោះនេះ យើងនិយាយថា «**កើតកូន**» «**សម្រាលកូន**» នេះពុំគិតពីខ្មែរដែលនៅតំបន់ឰសានប្រទេសសៀមផង ដែលនិយាយថា «**លេចកូន**»។ មកដល់តំណាក់កាលនេះ ឃើញថា គេលែងនិយាយពង្វាងពុំប្រើពាក្យ«**កូន**» ដូចកាលពពោះទៀតហើយ។

ពិនិត្យមើលត្រឹមតែទំនៀមទម្លាប់ជាតិពន្ធុនានាដែលរស់នៅប្រទេសកម្ពុជា ក៏ឃើញហើយថា ការឆ្លងទន្លេនៅក្នុងផ្ទះជាការកម្រ ត្បិតគេតែងតែធ្វើជម្រក ឬកូនខ្ទមមួយតូចនៅជីជាប់ពីផ្ទះធំ[26]។ សេចក្តីពន្យល់របស់អ្នកស្រុកតែងតែថា ដើម្បីងាយស្រួលក្នុងការបោសលាងឈាមជំរជាដើម។ តាមពិតទំនៀមនេះទាក់ទងទៅនឹងគំនិតមនុស្សជាតិទាំងមូលដែលយល់ថា អ្នកឆ្លងទន្លេមាន «**មន្ទិល**» ខ្លាំងជាប់នឹងខ្លួន។ ក្រោមខ្ទមនេះគេដុតភ្លើងដើម្បីអ្នកសរសៃខ្ចីនោះអាំង ប្រហែល៣ថ្ងៃក្រោយមកក្រោយពីទម្លាក់ជើងក្រាន ទើបស្រីនោះឡើងទៅនៅលើផ្ទះធំបាន។ ទំនៀមនេះគេនៅតែប្រតិបត្តិ ជាពិសេសតាមភូមិដែលដាច់ស្រយាលពីទីក្រុង ព្រោះគេផ្តាច់អ្នកនោះចេញពីសង្គមមួយរយៈ រាប់បញ្ចូលតាំងពីសង្គមគ្រួសារផង។ វត្ថុសម្រាប់កំណត់រយៈពេលនេះ គឺភ្លើងដែលស្រីនោះអាំង។ ភ្លើងនោះគេពុំឱ្យរលត់ឡើយ គឺត្រូវឆេះជាប់ជានិច្ចក្នុងរយៈពេលអាំង។ រីឯទីកំណត់កន្លែងហៅថា «**ក្រឡាភ្លើង**» ពោលគឺកូនផ្ទះនៅជាប់ដែលពោលអម្បាញ់មិញ ឬបន្ទប់ក្នុងផ្ទះដែលគេបានព័ទ្ធសីមា ហើយសម្រាប់

[26] លើកលែងតែជនជាតិព្នងនៅមណ្ឌលគិរី ឃើញខ្លះសម្រាលកូននៅផ្ទះធំ ខ្លះទៀតក៏សង់កូនខ្ទមជិតផ្ទះធំសម្រាលកូនដែរ។

ការឆ្លងទន្លេ។ ដរាបណាពុំទាន់ទម្លាក់ជើងក្រាន ផ្ទះ ឬបន្ទប់នោះជា «**កន្លែងពិសេស**» ត្បិត «**ពេល**» ដែលកំណត់ដោយភ្លើងនោះ ជាពេលពិសេសដូចគ្នា។ ដូច្នោះហើយអ្វីៗដែលធ្វើឡើងក្នុងរយៈពេលនិងក្នុងបន្ទប់នេះក៏ពិសេសដែរ ពោលគឺធ្វើអ្វីៗក្នុងត្រណម។ ឯទីតាំងនៃជើងក្រានវិញ អាចនៅក្នុងបន្ទប់ក៏បាន ឬនៅក្រោមផ្ទះក៏បាន។ បើនៅក្នុងបន្ទប់ ជួនកាលគេប្រើជើងក្រានដែលមានលក់ស្រាប់ៗ តែវត្ថុនោះត្រូវតែថ្មី ហើយដាក់នៅក្រោមគ្រែ។ ជួនកាលទៀតគេបូកដីហៅថា «**ផ្នោះ**» ដុតភ្លើងនៅក្បែរគ្រែ ឬដំណេក។ បើភ្លើងនៅក្រោមផ្ទះ គេអាចដុតអុសធំៗផ្ទាល់លើដីតែម្តង។

ពេលនៅលើភ្លើងនេះ ត្រណមក៏មានច្រើនបែបយ៉ាងទៀត។ ពុំត្រឹមតែស្រីឆ្លងទន្លេទេ អ្នកក្រៅដែលចូលក្នុងក្រឡាភ្លើងក៏ត្រូវតមមាត់កដែរ។ ឧទាហរណ៍ បើឃើញថាភ្លើងក្តៅពេក ពុំអាចនិយាយថា «**ក្តៅណាស់**» ឬដូច្នេះ ដូច្នោះឡើយ ត្រូវតែជួយធ្វើម្តេចបន្ធូរបន្ថយកម្តៅនោះដោយពុំចេញស្តីអ្វីទាំងអស់។ បរិបទ ឬទេសកាលនេះពិសេសខ្លាំងណាស់ ត្បិតអ្នកដែលអាចប៉ុនប៉ងយាយីឱ្យទុកទោសដល់អ្នកឆ្លងទន្លេជាអមនុស្សពីរ ចំណែកឯអ្នកដែលជួយឱ្យកិច្ចនោះប្រព្រឹត្តទៅដោយគ្មានឧបសគ្គអ្វីក៏មានពីរនាក់ដែរ។

<u>**ភារកិច្ចឆ្មប**</u>: ឆ្មបតែងតែជាមនុស្សស្រី ច្រើនតែមានវ័យចំណាស់បន្តិច ហើយដែលជាអ្នកស្រុកធម្មតា។ វិជ្ជាឆ្មបនោះចេះតៗគ្នាដោយរៀនពីគេពីឯងផង ដោយដកស្រង់បទពិសោធខ្លួនឯងផង ត្បិតឆ្មបតែងតែមានជំនួយការពីមនុស្សស្រីក្មេង ឬចាស់ផ្សេងទៀត ជាញាតិ ឬអ្នកជិតខាងអ្នកឆ្លងទន្លេនោះ។ ក្រៅពីបច្ចេកទេសបង្កើតកូនជាធម្មតានោះ ឆ្មបត្រូវគោរពតាមក្បួនច្បាប់ចាស់ៗខ្លះទាក់ទងទៅនឹងជំនឿ ឧទាហរណ៍ បើគេមកហៅបន្ទាន់ថា មាននរណាម្នាក់ឈឺពោះហើយ ឆ្មបត្រូវស្រូតរូតទៅ ពុំនៅជំអក់ ទោះជាកំពុងរវល់អ្វីក្តី បើពុំដូច្នោះ គេជឿថាពោះនឹងឈឺយូរ កូនក្រចេញ។ ដោយសារមាននាទីប្រាកដដូច្នោះហើយបានជាគេត្រូវរៀបទ្រនឹបអ្វីបន្តិចបន្តួចជូនឆ្មប។

<u>**គ្រូ**</u>: ជួនកាលក្នុងកាលព័ទ្ធសីមាកំណត់ក្រឡាភ្លើងឆ្លងទន្លេ គេទៅរកគ្រូ ឬអាចារ្យណាម្នាក់ឱ្យធ្វើកិច្ចនេះ។ បើការឆ្លងនោះមានដំណើរទៅធម្មតា ឥតឧបសគ្គ គ្រូនោះគ្មានតួនាទីអ្វីទៀតឡើយ។ ប្រសិនបើមាន គ្រូនោះសូត្រមន្តអាគមគាថាផ្សេងៗដើម្បីបណ្តេញព្រាយជាដើម។ បើម្តាយនៅលើភ្លើងចង់ចូលរួមក្នុងពិធីកាត់សក់បង្កក់ឆ្មប គឺត្រូវឱ្យគ្រូ ឬអាចារ្យដដែលនោះដោះសីមាដែលខ្លួនបានព័ទ្ធកាលពីមុននោះចេញវិញ ទើបអាចចេញពីក្រឡាភ្លើងនោះបាន។ការប្រុងប្រយ័ត្នគ្រប់បែបយ៉ាង ការពពោះ និងការសម្រាលកូនដែលអាចប្រឈមនឹងគ្រោះថ្នាក់ ទម្រាំបានកូនចេញពីផ្ទៃមកនេះសមនឹងពាក្យថា «**ឆ្លងទន្លេ**» ដូច្នោះមែន។ ប្រការនេះកាន់តែសំខាន់ណាស់ទៅទៀត បើសិនជាកូនដំបូង ត្បិតក្រៅពីការលំបាកលំបិនទាំងឡាយ ស្រីដែលកន្លងមកគ្រាន់តែជាភរិយានោះ ឆ្លងមកដល់ភាពជាមាតាហើយ។

## ៧. ពិធីចម្រើនអាយុ ឬចម្រើនព្រះជន្ម

ធម្មតាវ័យដែលឆ្លង គឺឆ្លងទៅមុខ ពីក្មេងទៅចាស់។ កិច្ចនេះពុំដូច្នោះឡើយ គឺចាស់ហើយ ឆ្លងឱ្យមកនៅក្មេងវិញ ពោលគឺគេឧបកិច្ចថា សាមីពិធីដែលច្រើនតែជាមនុស្សចាស់នោះស្លាប់ហើយកើត

សាជាថ្មីវិញក្នុងបំណងឱ្យអ្នកនោះរស់បានយូរតទៅទៀត «**អាយុវែង**»។ ពាក្យថា «**ចម្រើនអាយុ**» ជាពាក្យហៅទូទៅ។ ភាគច្រើនតែងឮគេហៅថា «**បុណ្យបច្ច័យបួន**» ជាពិសេសនៅទីក្រុងភ្នំពេញនិងតំបន់ជុំវិញនោះ។ នៅទីដទៃខ្លះទៀត ពុំថាក្រុងឬជនបទឡើយ ជួនកាលគេនិយមធ្វើកិច្ចនោះវែងឆ្ងាយ ហៅថា «**ចំរ៉ុនសុគីវីស្ត្រ**» ឬហៅម្យ៉ាងទៀតថា «**ឆាកមហាបង្សុកូល**»។

### ៧.១. សាមីពិធី

ជាទូទៅ សាមីនៃពិធីច្រើនតែជាមនុស្សដែលមានវ័យចំណាស់ ហើយដែលកូនចៅផ្ទាល់ព្រមទាំងញាតិមិត្តជិតឆ្ងាយប្រារព្ធពិធីនោះជូន។ ទោះបីជាក្នុងចិត្តពុំប្រាកដថាធ្វើទៅច្បាស់ជាបានអាយុច្រើនមែន ក៏អ្នកទាំងនោះធ្វើជូនគាត់ជាកិច្ចដឹងគុណដែរ។ រីឯសាមីពិធីដែលជាមនុស្សចាស់នោះ យ៉ាងហោចណាស់ក៏មានចិត្តសោមនស្សរីករាយដោយឃើញថាកូនចៅជិតឆ្ងាយបង្ហាញការគោរពដឹងគុណមកខ្លួន។ បើតាមជនបទខ្លះដែលអ្នកស្រុករស់នៅតាមប្រពៃណីពីបុរាណនៅឡើយនោះ យើងធ្លាប់ប្រទះឃើញថា គេប្រារព្ធពិធីនេះ ជូនដល់នរណាម្នាក់ដែលគេគោរពជាទូទៅដោយយល់ថា អ្នកនោះជាចាស់ទុំធ្លាប់ជួយគេឯងច្រើនបែបច្រើនប្រការ។

### ៧.២. អត្ថន័យ

ពិធីបុណ្យចម្រើនអាយុ ឬចម្រើនព្រះជន្ម គឺជាការសន្មតថា មនុស្សចាស់ម្នាក់នេះ បានស្លាប់ទៅហើយព្រោះអស់អាយុ ឯរូបថ្មី ដែលយើងឃើញនេះ គឺជារូបថ្មី ដែលទើបតែកើតមក ដូច្នេះ គាត់អាចរស់នៅបានយូរទៀត។

## ៨. ពិធីបុណ្យសព

ក្នុងគ្រួសារជាតិសាសន៍ដទៃក៏ដូចគ្រួសារខ្មែរដែរ កាលបើមានមនុស្សស្លាប់ គេតែងតែរៀបចំធ្វើពិធីបុណ្យជូនដំណើរសពតាមទំនៀមទម្លាប់របស់ខ្លួន។ ការរៀបចំនេះមានការប្រែប្រួល និងប្លែកគ្នាខ្លះៗទៅតាមតំបន់។ ខ្មែរចាត់ទុកពិធីបុណ្យសពនោះ ជាករណីពិសេសមួយដែលគ្រួសារនីមួយៗត្រូវតែបំពេញ ទោះធំក្តី តូចក្តី ទៅតាមលទ្ធភាពធនធានរបស់ខ្លួន។ បើរំលងប្រពៃណីនេះ ត្រូវទទួលការរិះគន់យ៉ាងខ្លាំងពីសង្គម។ បើមិនធ្វើបុណ្យជូនដំណើរសពទេនោះ គឺជាកំហុសធ្ងន់មិនអាចអត់ឱនបានព្រោះទុកឱ្យជីដូនជីតា ឪពុកម្តាយ បងប្អូន កូនចៅ ស្លាប់ដូចសត្វធាតុ។

បើមានមនុស្សស្លាប់ដោយតាយហោង តាមទម្លាប់ គេមិនយកសពនោះទៅបូជាទេ គឺគេយកទៅកប់សិន ចាំបានពេលល្អទើបគេគាស់ឆ្អឹងមកធ្វើបុណ្យវិញ តែបច្ចុប្បន្ននេះ គេយកខ្មោចប្រភេទនេះមករៀបចំបូជាដូចខ្មោចស្លាប់ធម្មតាដែរ។

### ៨.១. មុនពេលស្លាប់

ចាប់ពីពេលដែលខ្មែរទទួលឥទ្ធិពលពុទ្ធសាសនាហិនយានមក ការរៀបចំពិធីមានទំនៀមដូចខាងក្រោម៖

**ក. ពេលឈឺធ្ងន់** : កាលបើមានលោកអ្នកដ៏មានគុណ មានមាតាបិតាជាដើម កំពុងឈឺធ្ងន់ ដោយរោគាពាធអស់សង្ឃឹមនឹងព្យាបាល គេនាំគ្នារៀបចំធ្វើពិធីបុណ្យជូនគាត់ជាបន្តបន្ទាប់។ ពេលព្រឹកនិមន្តព្រះសង្ឃជារបង្សុកូលវេរបច្ច័យប្រគេនទេយ្យទានព្រះសង្ឃ (គេយកវត្ថុទាំងនោះទៅបង្ហាញអ្នកជំងឺដើម្បីឱ្យគាត់ត្រេកអរនឹងកុសលនេះ) ហើយប្រកាសបុញ្ញកម្មជូនលោកអ្នកដ៏មានគុណ។ នៅពេលល្ងាចគេនិមន្តព្រះសង្ឃសូត្រមន្ត ឬអញ្ជើញចាស់ព្រឹទ្ធាចារ្យសូត្រធម៌ជូនគាត់។ គេរកអាចារ្យម្នាក់នៅប្រចាំរហូតដល់ផុតដង្ហើម។ គេឱ្យអ្នកជំងឺទន្ទេញធម៌ «**ពុទ្ធោអរហំ**» កុំឱ្យខ្វល់ កុំឱ្យជំពាក់លើប្រពន្ធកូន ទ្រព្យសម្បត្តិ (ចំណងបីប្រការ)។

ពីបុរាណពេលអ្នកជំងឺមានកម្លាំងតិច គេធ្វើជណ្តើរកាំបីយកទៅដាក់ក្បែរបុគ្គលឈឺធ្ងន់ ហើយមានចងអំបោះសក្ជាប់ពីជណ្តើរកាំបីឡើងទៅលើ។ ការធ្វើបែបនេះដើម្បីឱ្យអ្នកជំងឺពិចារណាផ្តាច់ពិភពទាំងបីទៅភពថ្មីមួយទៀត ឬក៏ឱ្យអ្នកជំងឺធ្វើចិត្តឱ្យរួចផុតពីលោភៈ ទោសៈ មោហៈ។

**ខ. ពេលអ្នកជំងឺជិតផុត** (កម្លាំងតិច): លោកអាចារ្យហៅកូនប្រពន្ធ ឬក្រុមគ្រួសារឱ្យអុជទៀនកល្ប៤ជាតំណាងស្មើព្រះពុទ្ធ៤អង្គ ដែលបានត្រាស់ក្នុងភទ្ទកប្បនេះ (ព្រះកកុសន្ធៈ ព្រះកោនាគមនៈ ព្រះកស្សបៈ ព្រះគោតម)។ រួចហើយមនុស្សទាំងអស់នៅទីនោះ នាំគ្នានមស្សការព្រះរតនត្រ័យដោយប្រើសំឡេងធូរស្រាលៗ។

-អាចារ្យលញ់ទៀនកល្ប ទៀនគោល ធ្វើស្លាត្រួយ ទង់ព្រលឹង និងសុពណ៌បត្រ[27]៦សន្លឹក។

-ពេលជិតដាច់ខ្យល់ ឬពេលស្លាប់គេដុតទៀនកល្ប។

-គេដាក់ទង់ព្រលឹងនៅក្បាលគ្រែអ្នកជំងឺ ព្រោះគេមានជំនឿថា ពេលមនុស្សស្លាប់ទៅទង់ព្រលឹងនឹងទ្រព្រលឹងរហូតដល់ពេលចាប់ភពថ្មី។

-នៅជុំវិញអ្នកជំងឺមានចងសំពត់ស ឬព្រះបត់។

## ៨.២. ក្រោយពេលស្លាប់

-អាចារ្យចូលទៅបិទភ្នែក និងបិទមាត់។

-អុជទៀនកល្បដាក់ក្បាលគ្រែ ទៀនគោល៥ដើម អុជក្បែរក្បាល ស្មា និងជើង។ ទៀនកល្បនៅក្បាលគ្រែត្រូវជំនួសដោយចង្កៀងប្រេងកាតវិញ។

-រៀបទៀនត្បូង ស្រូវពន្លៃមួយល្អី ប្រាក់១បាត សំពត់ស៥ហត្ថ ចេកទុំមួយស្និត ដាក់ចុងជើង។

-ខាងក្រោមកន្លែងតម្កល់ គេដាក់ជុំថ្ម១ជុំ ទឹកមួយក្អម។

-ដោតទង់ក្រពើនៅមុខផ្ទះសពដើម្បីជាសញ្ញាថា មានមនុស្សស្លាប់ថ្មីៗ។

-យកប្រាក់កាក់ទៅដាក់ក្នុងមាត់ «**បង់មាត់**» ជានិមិត្តរូបថា ពេលស្លាប់មនុស្សគ្មានយកអ្វីទៅបានទេ សូម្បីតែមួយកាក់ក៏យកមិនបានផង។

-លើកខ្មោចចំអាសទឹក[28]ដោយលាបទឹកអប់ សិតសក់ «**ទៅមុខ៣ដង ទៅក្រោយ៣ដង**» ជានិមិត្តរូបនៃការវិលកើតស្លាប់របស់មនុស្សនៃភពទាំងបី។

[27] សុពណ៌បត្រជាបន្ទះធ្វើដោយមាស ឬប្រាក់ ឬទង្ហា ឬស្លឹករឹត ឬក្រដាសក៏បាន។

-ពាក់អាវឡេវខ្នង: ពេលចំអាសទឹករួចហើយ គេយកអាវមកបំពាក់ឱ្យសព។ ការបំពាក់អាវនេះគឺគេដាក់ឡេវទៅក្រោយ ព្រោះគេចង់បញ្ជាក់ថា ខ្មោចខុសពីមនុស្សរស់។

-អាចារ្យយោគីបង្គាប់ឱ្យយកសុពណ៌បត្រទាំង៦សន្លឹក មកបិទត្រង់មាត់ ភ្នែក ត្រចៀក ច្រមុះ ខ្លួន និងផ្ចិត គ្រប់ទ្វារខ្មោចទាំង៦ដែលជាផ្លូវអកុសល កុំឱ្យបុគ្គលនោះទៅកើតនៅកន្លែងអកុសល។

-បំពាក់ចិញ្ចៀនខ្មោច: លោកអាចារ្យយកចិញ្ចៀនដែលមានមុខជិត មកចងនឹងដៃខ្មោច មិនឱ្យស្រាយចេញចូលបាន ព្រោះតំណាងឱ្យវាលវដ្តសង្សារមិនអាចកាត់ចេញបាន។

-អាចារ្យយោគីបានឱ្យយកកាំបិតស្លា មកដាក់នឹងដៃខ្មោចសម្រាប់ឱ្យកាត់ចិញ្ចៀន គឺកាត់វដ្តសង្សារ ឬតណ្ហាដែលធ្លាប់រួតរឹតសត្វលោក ឆ្លងទៅរកព្រះនិព្វានមិនកើត។

-យកស្លាត្រួយមានស្លា ម្លូ ធូបមកដាក់ភ្ជាប់នឹងបាតដៃទាំងពីរនៃសព ដាក់ប្រណមលើដើមទ្រូងសម្រាប់យកទៅថ្វាយព្រះចូឡាមណីចេតិយនៅឋានត្រៃត្រិង្សដែលបញ្ចុះព្រះកេសា និងស្នៀតព្រះកេសរបស់ព្រះសម្មាសម្ពុទ្ធ។

-យកសំពត់ស៤ហត្ថស្លៀកឱ្យខ្មោចដាក់ថ្នក់មកខាងមុខ ៤ហត្ថទៀតស្លៀតដាក់ថ្នក់ទៅក្រោយវិញ ចង់បង្ហាញថា អវិជ្ជាបិទមុខ បិទក្រោយ និងតណ្ហាចាក់ស្រេះគ្នា។

-សំពត់៤ហត្ថទៀតពានាពាក់លើស្មាខាងស្តាំ។

-ចងខ្សែបាសត្រង់ក កដៃ និងកជើងមានន័យថា មនុស្សតែងតែជាប់ជំពាក់ចំណងលោកិយ៣ប្រការគឺ ប្រពន្ធ ឬប្តី កូន និងទ្រព្យសម្បត្តិ។

-យកកំណាត់សំពត់ប្រវែង១ចំអាម ៤ជ្រុងគ្របមុខខ្មោច រួចលើកដាក់លើស្នប (សំពត់រុំខ្មោចប្រវែង១២ហត្ថ តំណាងឱ្យបដិច្ចសមុប្បាទធម៌[29])។ រួចគេចងខ្សែបាសម្តងទៀត ទើបលើកដាក់ក្តារមឈូស។ គេនិមន្តព្រះសង្ឃបង្សុកូល។ រយៈពេលតម្កល់សពអាស្រ័យទៅលើធនធានរបស់គ្រួសារ។

## ៨.៣. ពិធីដង្ហែនិងរំលាយសព

-ពិធីរំកិលសពចេញពីទីតម្កល់

- និមន្តព្រះសង្ឃបង្សុកូល
- បង្វិលពពិល៣ជុំ ជុំវិញមឈូស
- យកទឹកក្នុងក្អមស្រោចរំងាប់ដុំថ្ម រួចទម្លាក់ចោលទៅដីទាំងដុំថ្ម ទាំងក្អមទឹកជានិមិត្តរូបនៃការបែកធ្លាយរូបរាងកាយ។

-ពិធីដង្ហែ

- ព្រះសង្ឃអភិធម្ម
- ព្រះសង្ឃមាតិកា

[28] ការចំអាសទឹកឱ្យខ្មោច តាមជំនឿពួកព្រាហ្មណ៍ថាជាការលាងបាបនៅពេលស្លាប់។ តាមព្រះពុទ្ធសាសនាថា ជាការជម្រះក្លិនមិនល្អ ឬជាការដឹងគុណចំពោះសព។

[29] បដិច្ចសមុប្បាទ គឺជាធម៌ភាពដែលភ្ជាប់ហេតុទៅនឹងផល។

- អាចារ្យយោគីកាន់ទង់ព្រលឹង
- ភ្លេងខ្មោចលេងកំដរ (បើសិនមាន)
- អ្នកប្រាយលាជ «ក្មេងស្រីស្លៀកពាក់ស បាចលាជទៅឆ្វេងទៅស្តាំ ដោយទន្ទេញធម៌បណ្តើរនិងមើលទៅមុខជានិច្ច»។ គ្រាប់លាជតំណាងធ្មឹងដែលនៅរាយប៉ាយលើដី។
- អ្នកបួសមុខភ្លើង ក្មេងប្រុសកោរសក់ពាក់ស មានខ្សែស្បូវភ្លាំងរុំជុំវិញក្បាលតភ្ជាប់រហូតដល់មឈូស មានន័យថាខ្សែជីវិតមនុស្សបន្តគ្នាដូចច្រវាក់។ ការបួសមុខភ្លើងជាការតបស្នងសងគុណដល់អ្នកស្លាប់។
- អ្នកភ្លុក «អ្នកដុតខ្មោច» ៤នាក់សែងមឈូសយកជើងទៅមុខ។ សព្វថ្ងៃគេដាក់ក្នុងរថយន្ត។
- អ្នកទទួលទៀនត្បូង «ធម្មតាជាអ្នកជិតស្និទ្ធនឹងសព»។
- គ្រួសារ ញាតិមិត្តរបស់សពដង្ហែតាមក្រោយ។

-ទៅដល់ឈាបនដ្ឋាន

- ដង្ហែប្រទក្សិណបីជុំ «ឈាបនដ្ឋាន» ពីឆ្វេងទៅស្តាំ រួចដាក់មឈូសលើជើងថ្ករ យកក្បាលទៅទិសខាងលិច។
- បើកគម្របមឈូស អាចារ្យបើស្នប បើកកន្សែងគ្របមុខ កូនចៅយកកន្សែងនេះឡើងដើម្បីបានសិរីសួស្តី។
- កាត់ចំណងខ្សែបាស រួចនិមន្តព្រះសង្ឃបង្សុកូល។
- ញាតិមិត្តយកផ្កា ទៀន ធូបទៅដាក់លើសព សុំខមាទោសជាចុងក្រោយ។
- អាចារ្យយោគីនិងអ្នកភ្លុក៤នាក់ យកចន្លុះ១ដើមម្នាក់ ដើរព័ទ្ធជុំវិញមឈូស៣ជុំ។ រួចអាចារ្យដុតភ្លើងបូជាសព។

-ពេលភ្លើងកំពុងឆេះ

- បំបួសអ្នកបួសមុខភ្លើង ហើយសឹកវិញនៅពេលបូជាសពរួច។
- ទេសនាមុខភ្លើង។

-ពេលសពឆេះអស់

- អ្នកភ្លុកយកសំពត់គ្របមឈូស ចោលរំលងភ្លើង៣ដង ដើម្បីរំងាប់ចង្រៃឧបទ្រព។
- យោគីយកទឹកមន្ត «ទឹកសំបួរមាស» មួយផ្តិល អ្នកភ្លុកកាន់ក្អមទឹកមួយដើរប្រទក្សិណ៣ជុំដូចមុន ហើយពន្លត់ភ្លើង។

- បាចគ្រាប់ស្រូវ ល្ង...លើគំនរធ្យូងដើម្បីប្រារព្ធពិធីប្រែរូប «នេះជាសំណាបនៃជីវិតថ្មី»។ ពិធីប្រែរូបប្រព្រឹត្តទៅ៣ដង។
- គ្រួសារសពរើសជាតុមកលាងនឹងទឹកម្ហូរ ទឹកសំបួរមាស ឬទឹកដូងខ្ចី។ ពេលរើសបើអ្នកណារើសបានកាក់ ឬធ្មេញ ចាត់ទុកជាអ្នកមានសំណាងត្រូវថែរក្សាឱ្យបានល្អ។
- វេលាយប់និមន្តព្រះសង្ឃសូត្រមន្ត ទេសនា។

**<u>ពិធីបុណ្យរំឭកវិញ្ញាណក្ខ័ន្ធ</u>**

-គម្រប់៧ថ្ងៃ និង១០០ថ្ងៃ គេប្រារព្ធពិធីនេះរំឭកវិញ្ញាណក្ខ័ន្ធដល់សព

-គម្រប់មួយខួប(១ឆ្នាំ) គេធ្វើបុណ្យឧទ្ទិសកុសលឱ្យទៅទៀតដូចមុន ពិធីនេះអាចធ្វើរៀងរាល់ឆ្នាំទៅតាមលទ្ធភាពគ្រួសារ។

**<u>ការកាន់ទុក្ខ</u>**

-ចំពោះគ្រួសារផ្ទាល់: កោរសក់ ស្លៀកស ពាក់ស ឬស្លៀកខ្មៅ ពាក់ស

-ចំពោះគ្រួសារឆ្ងាយ: អាចត្រឹមស្លៀកពាក់ស ឬខ្មៅ មិនបាច់កោរសក់

-រយៈពេលកាន់ទុក្ខជាធម្មតា មានរយៈពេល១០០ថ្ងៃ អ្នកខ្លះអាចដល់១ឆ្នាំ តែបច្ចុប្បន្នត្រឹម៧ថ្ងៃប៉ុណ្ណោះ។

# មេរៀនទី៦     ពិធីបុណ្យធំៗ ក្នុងប្រពៃណីខ្មែរ

ប្រទេសកម្ពុជាគឺជាប្រទេសមួយ ដែលមានអរិយធម៌ចំណាស់ជាងគេនៅអាស៊ីអាគ្នេយ៍យើងនេះ។ បើតាមប្រវត្តិសាស្ត្រកម្ពុជា ដែលមានតាំងពីបុរាណកាលបានចែងថា៖ «ប្រទេសកម្ពុជាគឺមានអរិយធម៌ វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីរបស់ខ្លួនតាំងពីយូរយារណាស់មកហើយ ដែលជាកេរដំណែលបន្សល់ពីបុព្វបុរសនិងដូនតាជំនាន់ដើមរបស់ខ្លួន។ ខ្មែរយើងមានពិធីបុណ្យជាច្រើនដូចជា៖

## ១. ពិធីបុណ្យចូលឆ្នាំខ្មែរ

មនុស្សជាតិសាសន៍ទាំងអស់តែងប្រារព្ធធ្វើពិធីបុណ្យចូលឆ្នាំថ្មីគ្រប់ៗគ្នា គ្រាន់តែការកំណត់ពេលវេលា និងលំនាំពិធីប្លែកៗពីគ្នាស្របទៅតាមជំនឿ ទំនៀមទម្លាប់ និងប្រពៃណីរបស់ជនជាតិនីមួយៗតែប៉ុណ្ណោះ។

ជនជាតិខ្មែរបានរៀបចំពិធីបុណ្យចូលឆ្នាំថ្មីនេះរៀងរហូតមក តាំងពីបុរាណកាល តែការកំណត់ពេលវេលាប្លែកពីគ្នា។

### ១.១. ប្រវត្តិបុណ្យចូលឆ្នាំ

ប្រទេសខ្មែរពីដើម គឺពីត្រឹមសម័យក្រុងអង្គរជំឡើងទៅ គេច្រើនប្រើតាមចន្ទគតិ ចូលឆ្នាំនៅខែមិគសិរ។ ដូចនេះបានជាគេរាប់ខែមិគសិរជាខែទី១ លុះក្រោយមកទើបគេត្រឡប់ប្រើតាមសុរិយគតិវិញ ហើយគេកំណត់ចូលឆ្នាំនៅខែចេត្រវិញ។ កំណត់យកព្រះចូលកាន់មេសរាសីដែលជាសាមញ្ញសង្ក្រាន្ត គឺព្រះអាទិត្យដើរត្រង់ពីលើក្បាល ជាសង្ក្រាន្តវិញ គេមិនយកតាមអាយន្តសង្ក្រាន្ត (ចន្ទគតិៈ ពេលដែលព្រះអាទិត្យដើរបញ្ឆៀង មិនចំពីលើក្បាល)។ ឯថ្ងៃចូលឆ្នាំមិនបានទៀងទាត់ទេ ជួនកាលត្រូវថ្ងៃទី១៣ មេសាច្រើនជាង។ សព្វថ្ងៃគេប្រើចន្ទគតិអមគ្នានឹងសុរិយគតិដែរ ព្រោះចន្ទគតិមានទំនាក់ទំនងនឹងពុទ្ធប្បញ្ញត្តិជាច្រើន។ ចំណែកការគិតតាមចន្ទគតិនេះ មិនបានទៀងជាថ្ងៃណាជាមួយគ្នាទេ ជួនកាលចូលឆ្នាំក្នុងវេលាខ្នើត ជួនកាលក្នុងវេលារនោច ប៉ុន្តែមិនឱ្យមុនថ្ងៃ៤កើត ខែចេត្រ និងមិនហួសថ្ងៃ៤កើត ខែពិសាខទេ។ ពិធីបុណ្យចូលឆ្នាំនេះប្រារព្ធក្នុងរយៈពេល៣ថ្ងៃ។

-ថ្ងៃទី ១ គេហៅថា ថ្ងៃមហាសង្ក្រាន្ត ឬថ្ងៃចូលឆ្នាំកំណត់ពីដំណាច់ឆ្នាំចាស់ចូលឆ្នាំថ្មី

-ថ្ងៃទី ២ គេហៅថា ថ្ងៃវ័នបត ឬវារកណ្តាល (ថ្ងៃខ្វាក់)

-ថ្ងៃទី ៣ គេហៅថា ថ្ងៃឡើងស័ក ឬវារឡើងសក្តិ (ថ្ងៃផ្លាស់ស័កថ្មី)។

តាមទំនៀមថា ថ្ងៃសង្ក្រាន្តនិងថ្ងៃវ័នបត ជាថ្ងៃមិនល្អទាំងអស់ ឯថ្ងៃឡើងស័កជាស្តេចថ្ងៃ ជាថ្ងៃល្អបំផុត។

### ១.២. ពិធីសង្ក្រាន្តចូលឆ្នាំ

សង្ក្រាន្ត ឬសង្ក្រាន្តិ (សំស្ក្រឹត) មានន័យថា ដំណើរឃ្លាតចាកទី ការឈាន ចូលមកដល់ គឺជាដំណើរដែលព្រះអាទិត្យចរចូលដល់ទីជួបមួយជុំរាសីចក្រ បានសេចក្តីថា ជាដំណើរដែលដើម និងចុងនៃរាសីចក្រ ជួបគ្នាពេលគ្រប់មួយឆ្នាំ (ដំណើរដាច់ឆ្នាំចាស់ ចូលឆ្នាំថ្មី)។

ឯការចាប់បដិសន្ធិនៃរាសី (ផ្កាយ) ទាំងប្រាំពីរប្រចាំសប្តាហ៍ មានទំនាក់ទំនងនឹងជំនឿលើរឿងព្រេងបុរាណមួយឈ្មោះថា «**សង្ក្រាន្តសូត្រ**» ដែលដំណាលពីកបិលមហាព្រហ្មបានមកចោទជាប្រស្នា ៣ខ ចំពោះធម្មបាលកុមារ។ ប្រស្នាទាំង៣ខនោះគឺ៖

១. តើវេលាព្រឹក សិរីស្ថិតនៅត្រង់ណា?

២. តើវេលាថ្ងៃត្រង់ សិរីស្ថិតនៅត្រង់ណា?

៣. តើវេលាល្ងាច សិរីស្ថិតនៅត្រង់ណា?

**បុត្រីទាំង៧របស់កបិលមហាព្រហ្ម(ឈ្មោះទេពធីតាមហាសង្ក្រាន្តនិងគ្រឿងអាភរណៈ)៖**

**១. ថ្ងៃអាទិត្យ** *ទុង្សាទេវី* សៀតផ្កាទទឹម គ្រឿងប្រដាប់បទុមរាគ ភក្សាហារផ្លែឧទុម្ពរ អាវុធស្តាំកងចក្រ ឆ្វេងស័ង្ខ ពាហនៈគ្រុឌ។

**២. ថ្ងៃចន្ទ** *គោរាគទេវី* សៀតផ្កាអង្គាបុស្ស គ្រឿងប្រដាប់មុក្តា ភក្សាហារប្រេង អាវុធស្តាំព្រះខ័ន អាវុធឆ្វេងឈើច្រត់ ពាហនៈខ្លា។

**៣. ថ្ងៃអង្គារ** *រាក្សសាទេវី* សៀតផ្កាឈូក គ្រឿងប្រដាប់មោរ៉ា ភក្សាហារលោហិត អាវុធស្តាំត្រីសូល៍ អាវុធឆ្វេងធ្នូ ពាហនៈអស្សតរ។

**៤. ថ្ងៃពុធ** *មណ្ឌាទេវី* សៀតផ្កាចំប៉ា គ្រឿងប្រដាប់ពិទូរ្យ ភក្សាហារទឹកដោះសប្បិ អាវុធស្តាំម្ជុល អាវុធឆ្វេងឈើច្រត់ ពាហនៈលា។

**៥. ថ្ងៃព្រហស្បតិ៍** *កិរិណីទេវី* សៀតផ្កាមណ្ឌា គ្រឿងប្រដាប់មរកត ភក្សាហារសណ្តែក ល្ង អាវុធស្តាំកង្វេរ អាវុធឆ្វេងកាំភ្លើង ពាហនៈដំរី ។

**៦. ថ្ងៃសុក្រ** *កិមិរាទេវី* សៀតផ្កាចង្កុលណី គ្រឿងប្រដាប់បុស្សរាគ័ម ភក្សាហារចេកណាំវ៉ា អាវុធស្តាំព្រះខ័ន ឆ្វេងពិណ ពាហនៈក្របី។

**៧. ថ្ងៃសៅរ៍** *មហោទរាទេវី* សៀតផ្កាត្រកៀត គ្រឿងប្រដាប់នីលរតន៍ ភក្សាហារសាច់ទ្រាយ អាវុធស្តាំកងចក្រ ឆ្វេងត្រីសូល៍ ពាហនៈក្ងោក។

មុនពេលទេវតាចុះ គេនាំគ្នាជញ្ជូនខ្សាច់សាងវាលុកចេតិយនៅក្នុងវត្តត្រង់កន្លែងណាមួយ តាមការរៀបចំរបស់អាចារ្យវត្ត។ គេនិយមហៅពិធីសាងវាលុកចេតិយនេះថា «**ពិធីពូនភ្នំខ្សាច់**»។ អ្នកមិនបានចូលរួមក្នុងពិធីពូនភ្នំខ្សាច់នៅពេលនោះ នៅពេលបន្ទាប់មកអាចយកដីខ្សាច់ទៅដាក់បន្ថែមក៏បាន។ គេទាំងអស់គ្នាមានជំនឿថា ការពូនភ្នំខ្សាច់នេះបានអានិសង្សច្រើនណាស់ ព្រោះអាចឱ្យគេរួចចាកកម្មពៀរវេរា។ គ្រួសារខ្លះគេពូនភ្នំខ្សាច់ជាបែបឯកជន ដាក់ដីខ្សាច់ក្នុងថាស ដាក់កន្លែងសមរម្យ។

**១.៣. សកម្មភាពពេលបុណ្យចូលឆ្នាំ**

-**ថ្ងៃទី ១**: វេលាព្រឹក ឧបាសក ឧបាសិកានាំគ្នាវេរភត្តាហារប្រគេនព្រះសង្ឃ រួចទើបនាំគ្នាដើរហែជាក្បួនប្រទក្សិណភ្នំ៣ជុំ។ រួចទើបអាចារ្យប្រកាសសុំសេចក្តីសុខចម្រើនដល់ទាយក ទាយិកាគ្រប់ៗគ្នា រួចគេនាំគ្នាចូលទៅអុចធូបទៀន ដោយត្រងក្រដាសពណ៌ស នៅជើងភ្នំខ្សាច់ ព្រមទាំងប្រោះព្រំម្សៅ ទឹកអប់ ឯពេលល្ងាច គេនិមន្តព្រះសង្ឃសូត្រមន្តនិងទេសនា។

នៅតំបន់ខ្លះគេមិនយកខ្សាច់ទៅពូនភ្នំទេ គឺគេយកស្រូវអង្ករមកពូន រៀបសាងភ្នំខ្សាច់ និងយកនំចំណីទៅសែនទេវតា។




-**ថ្ងៃទី២**: វេលាព្រឹកវេរភត្តាហារប្រគេនព្រះសង្ឃ។ ក្នុងថ្ងៃទី២ នេះ កូន ឬចៅជូនសម្លៀកបំពាក់ លុយកាក់ដល់អ្នកមានគុណ។ ឯនៅពេលរសៀលគេនាំគ្នាពូនភ្នំខ្សាច់ថែមទៀត ហើយសូត្រធម៌អធិដ្ឋានភ្នំខ្សាច់ ដែលគេសន្មតទុកដូចជាព្រះចូឡាមុណីចេតិយ បន្ទាប់មកនិមន្តព្រះសង្ឃបង្សុកូលចេតិយ បញ្ជូនមគ្គផលទៅអ្នកដែលបានស្លាប់ទៅ។ នៅពេលល្ងាច គេនិមន្តព្រះសង្ឃចំម្រើនព្រះបរិត្តនិងទេសនា។

-**ថ្ងៃទី ៣**: គេនិមន្តព្រះសង្ឃឆ្លងភ្នំខ្សាច់។ ពេលល្ងាច និមន្តព្រះសង្ឃស្រង់ទឹកព្រះ ដើម្បីសុំឱ្យមានសិរីសួស្តី និងមានទឹកភ្លៀងសម្រាប់ធ្វើស្រែចម្ការពេញមួយឆ្នាំ។ នៅពេលល្ងាច គេនិមន្តព្រះសង្ឃចម្រើនព្រះបរិត្តនិងទេសនាជាកិច្ចបង្ហើយបុណ្យ។

ក្នុងរយៈពេលបុណ្យចូលឆ្នាំថ្មីនោះ អ្នកស្រុកនាំគ្នាលេងល្បែងប្រជាប្រិយផ្សេងៗ ដូចជា ចោលឈូង ទាញព្រ័ត្រ បោះអង្គុញ់ ចាប់កូនខ្លែង...។ល។ របាំប្រជាប្រិយជាច្រើនក៏ត្រូវបានផុសឡើងដែរនៅពេលចូលឆ្នាំ ដូចជា រាំវង់ រាំក្បាច់ សារ៉ាវ៉ាន់ ឡាំលាវ...។ល។ ប្រជាជននាំគ្នាតែងខ្លួនយ៉ាងស្រស់សោភា ខ្លះនាំគ្នាធ្វើដំណើរពីវត្តមួយទៅវត្តមួយទៀត ខ្លះនាំគ្នាលេងនៅក្នុងវត្ត ធ្វើឱ្យទិដ្ឋភាពវត្តប្រៀបដូចជាទីប្រជុំជនមួយយ៉ាងកុះករ។ បច្ចុប្បន្ននេះ នៅតាមតំបន់ខ្លះ គេប្រារព្ធពិធីបុណ្យចូលឆ្នាំច្រើនជាង ៣ ថ្ងៃទៅទៀត ដោយមានមនុស្សជាច្រើនគេចង់លេងសប្បាយបន្តទៀត។ នៅថ្ងៃស្រង់ទឹកព្រះនោះ ពុទ្ធបរិស័ទចំណុះជើងវត្តនាំគ្នាប្រជុំគ្នាក្នុងធ្លាវត្ត រួចគេប្រគំវង់ភ្លេងឆៃយ៉ាំថ្វាយទេវតាឆ្នាំថ្មី និងដង្ហែព្រះពុទ្ធរូបជុំវិញព្រះវិហារ៣ជុំ រួចទើបឡើងទៅលើព្រះវិហារ។ ប្រជាជននាំគ្នាស្រែកហ៊ោទ្រហឹងអឺងកង ដើម្បីបំផុសទិដ្ឋភាពឱ្យកាន់តែសប្បាយ រួមជាមួយកាយវិការក្រមិចក្រមើមនៃអ្នករាំក្នុងវង់ភ្លេងឆៃយ៉ាំ ធ្វើឱ្យយើងភ្លេចអស់នូវភាពនឿយហត់ និងភាពលំបាកក្នុងឆ្នាំចាស់ ហើយឃើញតែភាពសប្បាយនិងសិរីសួស្តីក្នុងឆ្នាំថ្មី។

## ២. ពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក សំពះព្រះខែ
### ២.១. ប្រវត្តពិធីបុណ្យប្រណាំងទូក

ប្រវត្តិសាស្ត្របានបញ្ជាក់ថានៅ « ថ្ងៃទី ១៤-១៥ កើតខែអស្សុជ និង ១ រោជខែកត្តិក» ពិធីអុំទូក អកអំបុក បណ្តែតប្រទីប ជាបុណ្យប្រពៃណីជាតិដ៏ធំមួយ មានដើមកំណើតតាំងពីបុរាណកាលមក ហើយដែលគេបានចែងទុកក្នុងឯកសារជាតិនិងអន្តរជាតិ ឬតាមសិលាចារឹកនៃប្រាសាទជាដើម។ ពិធីនេះរីកចម្រើនយ៉ាងខ្លាំងនៅសង្គមខ្មែរនាសម័យអង្គរក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ សតវត្សទី១២ និងសម័យលង្វែកនាពុទ្ធសករាជ ២០៧១ គ្រិស្តសករាជ ១៥២៨ ក្នុងរាជព្រះបាទអង្គច័ន្ទទី១ ទ្រង់តាំងពញាតាត ងារជាស្និទ្ធភូបាល ជាស្តេចក្រាញ់នៅកម្ពុជាក្រោមស្រុកបាសាក់។

ក. នៅសម័យអង្គរសតវស្សទី១២ ក្រុងកម្ពុជាមានសេចក្តីសុខសប្បាយក្សេមក្សាន្ត រុងរឿងណាស់ ដោយព្រះបាទជ័យវរ្ម័នទី៧ សម្តេចចេញធ្វើសង្គ្រាមជើងទឹកបង្ក្រាបជាតិបរទេសចាម ដោយកងទ័ពទូក រំដោះក្រុងកម្ពុជាឱ្យរួចផុតពីកណ្តាប់ដៃខ្មាំងសត្រូវ ។ គ្រិស្តសករាជ ១១៧៧-១១៨១ រឿងចម្បាំងទាំងអស់ត្រូវបានបុព្វបុរសខ្មែរឆ្លាក់ទុកនៅលើជញ្ជាំងប្រាសាទបាយ័ននិងប្រាសាទបន្ទាយឆ្មារ ដែលមានរូបព្រះឆាយាល័ក្ខណ៍នៃព្រះបាទ ជ័យវរ្ម័នទី៧និងទ្រង់ឈរលើនាវាចម្បាំង ទ្រង់កាន់ធ្នូ ដំបងដែលមានកងទ័ពយ៉ាងច្រើនមហិមា។

ខ. តាមឯកសារប្រណាំងទូករបស់ក្រុមជំនុំទំនៀមទម្លាប់ និពន្ធដោយ ថាប់ ប៉ែន បានសរសេរថា សម័យលង្វែក ព.ស ២០៧១ គ.ស ១៥២៨ ព្រះបាទអង្គច័ន្ទទី ១ ទ្រង់តាំងពញាតាត ងារជាសិទ្ធភូបាល ជាស្តេចនៅកម្ពុជាក្រោមស្រុកបាសាក់ឱ្យរៀបចំកងទ័ពជើងទឹកចែកចេញជាបីក្រុម។

ក្រុមទី១ : គឺកងទ័ពស្រួចហាត់ចម្បាំងដោយទូកង

ក្រុមទី២ : គឺជាកងទ័ពជំនួយហាត់ចម្បាំងដោយទូកចែវពីរជួរ

ក្រុមទី៣ : គឺជាទ័ពបាសាក់ ជាទូកធំមានដំបូល១ មានចែវ មានក្តោងដូចជាទូក«**ប៉ុកចាយ**» តែរាងស្តួចវែងសម្រាប់ផ្ទុកស្បៀងកងទ័ព។

គ. តាមឯកសារមហាបុរសខ្មែរ ព.ស ២៤០៤ គ.ស ១៨៦០ បានចែងថា ព្រះបាទ នរោត្តមត្រាស់បង្គាប់មន្ត្រីរាជការរៀបចំពិធីបុណ្យទ្វារទេសមាស ។ ស្តេចគង់ព្រះរាជដំណាក់ផែទតទូក ទូកមួងទូកចែវ ដែលអុំប្រណាំងថ្វាយ ផ្តាច់ព្រ័ត្រក្នុងពេលចេញវស្សា និងជង្វាយដល់ព្រះចន្ទ្រ និងបណ្តែតប្រទីបថ្វាយដល់ព្រះចង្កូមកែវ។

<u>**ពិធីបុណ្យអុំទូក**</u> : ដើម្បីជាទីសក្ការៈដឹងគុណដល់បុព្វបុរសខ្មែរយើង ដែលរក្សាបាននូវបុរាណភាពទឹកដី បង្ក្រាបបានរាល់សង្គ្រាមឈ្លានពាននៃបច្ចាមិត្រ ដែលមានបំណងដណ្តើមយកនូវសម្បត្តិជាតិ ត្រូវបុព្វបុរសយើងកម្ទេចឱ្យវិនាសមហន្តរាយ ហើយការប្រឆាំងតបនឹងសត្រូវទាំងនោះ ដូនតាយើងមានកងទ័ពជាច្រើនផ្នែកពិសេសគឺកងទ័ពជើងទឹកនេះឯង។ ដូច្នេះពិធីអុំទូកជាពិធីមួយរំឭកឡើងវិញនូវអនុស្សាវរីយ៍នៃការរៀបចំក្បួនសមយុទ្ធកងទ័ពជើងទឹករបស់ខ្មែរបុរាណ ដែលពីដើមគេតែងតែប្រារព្ធធ្វើឡើងនៅថ្ងៃទី ១៤-១៥ កើត និង១រោចខែអស្សុជរៀងរាល់ឆ្នាំ។ ម្យ៉ាងទៀតដោយមានការដឹង

គុណដល់ទឹកដីដែលយើងគ្រប់គ្នាបានរស់នៅប្រកបដោយសេចក្តីសុខសាន្តនេះ ដើម្បីជាដង្វាយដល់ព្រះគង្គានិងព្រះធរណី។





## ២.២. ប្រភពពិធីបណ្តែតប្រទីប

ពិធីបណ្តែតប្រទីប ជាបុណ្យប្រពៃណីជាតិដែលប្រព្រឹត្តទៅនៅវេលាយប់ថ្ងៃទី ១៤-១៥ កើត និង ១ រោច ខែកត្តិក ភ្ជាប់នឹងពិធីបុណ្យអុំទូក ដែលប្រព្រឹត្តទៅនៅពេលថ្ងៃ គឺមានកំណើតដំណាលគ្នានឹងពិធីអុំទូក ហើយរីកចម្រើននៅក្នុងសង្គមខ្មែរ តាំងពីសម័យអង្គរដែរ។ ពិធីបណ្តែតប្រទីប មានប្រវត្តិយ៉ាងជិតស្និទ្ធនឹងព្រះពុទ្ធសាសនា ហើយក៏មានជាប់ឥទ្ធិពលព្រាហ្មណ៍សាសនាក្នុងការប្រតិបត្តិពិធីអគ្គិហោត្រ[30] ឬហោមពិធី ដែលគេអុជទៀនធូបប្រទីបផ្កាលា ដើម្បីបូជាដល់អាទិទេព។ តាមគម្ពីរទាសវង្សភាសាបាលីមានចែងថា ព្រះចង្កូមកែវទាំងបួននៃព្រះសម្មាសម្ពុទ្ធ ប្រតិស្ថាននៅទីទាំងបួនគឺៈ

-ទី១ នៅត្រៃត្រឹងសួគ៌

-ទី២ នៅពិភពនាគ

-ទី៣ នៅស្រុកគន្ធារ

-ទី៤ នៅទន្តបុរៈ(កលិង្គរដ្ឋ)

**អត្ថន័យនិងខ្លឹមសារនៃពិធីបណ្តែតប្រទីប**

+ ពិធីបណ្តែតប្រទីប ជាពិធីបុណ្យទាក់ទងទៅនឹងសាសនា ជាបុណ្យប្រពៃណីរបស់ខ្មែរ បញ្ជាក់នូវទឹកចិត្តសញ្ចេតនាស្នេហា និងគោរពដឹងគុណដល់ព្រះសម្មាសម្ពុទ្ធ គឺព្រះចង្កូមកែវដែលប្រតិស្ថាននៅពិភពនាគ ព្រមទាំងស្នាមព្រះបាទរបស់ព្រះអង្គដែលប្រតិស្ថាននៅស្ទឹងនម្មទា និងកន្លែងដទៃទៀត។

+ ដឹងគុណដល់ព្រះគង្គានិងព្រះធរណី ដែលបានផ្តល់នូវជីវភាពរស់នៅរបស់ប្រជាជាតិកម្ពុជាយ៉ាងរុងរឿងប្រកបដោយសុខុមាលភាព។

+ ដើម្បីសម្តែងមនោសញ្ចេតនា ដឹងគុណចំពោះទន្លេមេគង្គនិងទន្លេសាប ដែលផ្តល់ជីជាតិយ៉ាងសំខាន់សម្រាប់ជីវិត។

## ២.៣. ប្រវត្តិពិធីអកអំបុក សំពះព្រះខែ

បុណ្យប្រពៃណីអកអំបុក សំពះព្រះខែ មានប្រវត្តិជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងប្រវត្តិរបស់ព្រះពុទ្ធជាម្ចាស់នៃយើង។ ពិធីនេះប្រហែលជារីកចម្រើនដំណាលគ្នានឹងបុណ្យអុំទូក បណ្តែតប្រទីប

[30] ហោត្រ គឺវត្ថុដ៏ឧត្តមសម្រាប់បូជាភ្លើង, ទឹកដោះថ្លាសម្រាប់ថ្វាយព្រះអគ្គិ, ការបូជាយញ្ញ។

ដែរ។ តាមគម្ពីរបរមត្ថទីបនី អដ្ឋកថាចរិយាបិដកភាសាបាលីបានចែងថា ក្នុងដើមកទ្ធកប្បនេះព្រះបរមពោធិសត្វនៃយើងទ្រង់យោនយកកំណើតជាទន្សាយពោធិសត្វ។ វេលាខែពេញបូណ៌មី ទន្សាយពោធិសត្វបានអធិដ្ឋានឧបោសថសីល ហើយឧទ្ទិសមំសៈជាទានបរមត្ថបារមីដើម្បីពេញសម្មាសម្ពោធិញាណឱ្យបានត្រាស់ជាព្រះពុទ្ធ។ ព្រះឥន្ទទ្រង់ជ្រាបពីហេតុការណ៍នោះ ទ្រង់ក៏ក្រឡាខ្លួនជាព្រាហ្មណ៍ចាស់ម្នាក់មកសុំមំសៈ របស់ទន្សាយព្រះពោធិសត្វធ្វើជាអាហារ។ ទន្សាយព្រះពោធិសត្វបានឱ្យព្រាហ្មណ៍នោះបង្កាត់ភ្លើងឆេះយ៉ាងសន្ធោសន្ធៅ។ ទន្សាយព្រះពោធិសត្វក៏រលាស់ខ្លួនឡើងបីដង ដើម្បីឱ្យសត្វល្អិតដែលជាប់នឹងរោមជ្រុះចេញ រួចក៏លោតចូលក្នុងភ្លើងភ្លាម ភ្លើងនោះប្រែជាពុំឆេះសន្ធោសន្ធៅដូចមុនឡើយ ឃើញដូច្នោះ ព្រះឥន្ទ្រព្រាហ្មណ៍ក៏ស្ទុះទៅពយកទន្សាយពោធិសត្វឡើងទៅដល់មណ្ឌល ព្រះចន្ទ្រ ហើយទ្រង់ក៏យកម្នាងសិលាគូររូបទន្សាយពោធិសត្វ ហើយឥន្ទ្រព្រាហ្មណ៍អធិដ្ឋានថាសូមឱ្យរូបទន្សាយពោធិសត្វដែលយើងខ្ញុំគូរនេះនៅជាប់រហូតដល់ទីបំផុតកប្ប។ ដោយអនុភាពទានបរមត្ថបារមីនៃព្រះពោធិសត្វផង និងសេចក្តីអធិដ្ឋានរបស់ឥន្ទ្រព្រាហ្មណ៍ផង រូបទន្សាយក៏ឃើញប្រាកដក្នុងមណ្ឌលជាដរាបរហូតដល់សព្វថ្ងៃ។ ពិធីបុណ្យនេះរីកចម្រើននៅក្នុងសង្គមខ្មែរ ពីព្រោះឥទ្ធិពលនៃព្រះពុទ្ធសាសនា បានចាក់ឫសយ៉ាងជ្រៅទៅក្នុងព្រលឹងរបស់ប្រជាជាតិទាំងមូល ដែលតែងតែគោរពបូជាដល់ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ពិសេសគឺព្រះពោធិសត្វដែលយោនយកកំណើតជាទន្សាយបានផ្ដិតរូបព្រះឆាយាល័ក្ខណ៍របស់ព្រះអង្គនឹងលោកខែ ដើម្បីបានបំភ្លឺសត្វលោកតរៀងទៅ។

**អត្ថន័យនិងខ្លឹមសារនៃពិធីអកអំបុក សំពះព្រះខែ :**

\+ សក្ការៈបូជាចំពោះទន្សាយព្រះពោធិសត្វដែលរូបព្រះឆាយាល័ក្ខណ៍របស់ព្រះអង្គផ្តិតជាប់នឹងលោកខែ ដើម្បីបំភ្លឺសត្វលោករៀងមក ។

\+ ដើម្បីឧទ្ទិសថ្វាយព្រះពោធិសត្វនូវផល្លានុផល ដែលជាចំណីរបស់ព្រះអង្គកំពុងតែបញ្ចេញភោគផលយ៉ាងល្អប្រសើរ ក្នុងវេលាយប់ពេញបូណ៌មីនៃខែកត្តិក ជាពេលព្រះខែលេចរូបរាងច្បាស់ដើម្បីថ្វាយចំណីទាំងនោះមានត្រាវ ដំឡូង ដូង ចេក អំបុក។ល។

\+ ដើម្បីអបអរសាទរនូវទិន្នផល ដែលបានមកពីការបង្កបង្កើនផលរបស់ប្រជាជាតិកម្ពុជា ដែលខិតខំធ្វើពលកម្មយ៉ាងខ្លាំងតាំងពីរដូវភ្លៀងធ្លាក់កន្លងមក និងជាសញ្ញាប្រាប់ថារដូវស្រូវទុំ ព្រមទាំងផល្លានុផលទាំងឡាយបានមកដល់ហើយ។

## ៣. ពិធីបុណ្យភ្ជុំបិណ្ឌ

បុណ្យភ្ជុំបិណ្ឌ គឺជាពិធីបុណ្យមួយដែលធំជាងគេនៅក្នុងចំណោមពិធីបុណ្យទាំងអស់ ចំពោះអ្នកកាន់ព្រះពុទ្ធសាសនា។ ជារៀងរាល់ឆ្នាំនៅពេលដល់ថ្ងៃខែដែលត្រូវប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ គ្រប់បងប្អូន កូនចៅ សាច់ញាតិសន្តានទាំងអស់ ទោះនៅទីជិត ឬទីឆ្ងាយតែងតែធ្វើដំណើរទៅជួបជុំគ្នាជាពិសេសឪពុកម្តាយ ដើម្បីរៀបចំម្ហូបអាហារ បាយសម្ល ចង្ហាន់យកទៅប្រគេនព្រះសង្ឃដែលគង់នៅវត្តអារាម។ ទាំងនេះគឺជាទម្លាប់មួយដែលគេនិយមធ្វើតៗគ្នា។

ពាក្យថា «**បិណ្ឌ**» មានន័យថា ពំនូតបាយ ដែលគេឧទ្ទិសដល់ខ្មោចដែលបានស្លាប់ទៅ។ សព្វថ្ងៃបាយបិណ្ឌ គឺពំនូតបាយដំណើបចម្អិនជាមួយខ្ទិះដូង ហើយលាយជាមួយគ្រឿងផ្សំផ្សេងៗទៀតទៅតាមការនិយមរបស់អ្នកស្រុកក្នុងតំបន់នីមួយៗ។

### ៣.១. ប្រវត្តិបុណ្យភ្ជុំបិណ្ឌ

បើតាមប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាយើង បានបង្ហាញថា ពិធីបុណ្យភ្ជុំបិណ្ឌគឺកើតមានតាំងពីបុរាណកាលមកម្ល៉េះ។ ប៉ុន្តែទាស់ត្រង់ថា កាលពីសម័យមុនគេមិនហៅថា បុណ្យភ្ជុំបិណ្ឌទេដោយនៅក្នុងពិធីនេះគេមានបែងចែកចេញជាពីរថ្នាក់។ ថ្នាក់ដំបូង គឺគេចាប់ផ្តើមធ្វើចាប់ពីថ្ងៃ១រោច រហូតដល់ថ្ងៃ១៤រោច ហៅថា «**វារភត្ត ឬថ្ងៃកាន់បិណ្ឌ**» (ភត្តធ្វើតាមថ្ងៃ) ជាបន្តបន្ទាប់។ ចំណែកមួយថ្នាក់ទៀតគេធ្វើនៅថ្ងៃ១៥រោច ដែលគេហៅថា «**ភ្ជុំបិណ្ឌ**»។ ពិធីបុណ្យទាំងពីរថ្នាក់នេះ បច្ចុប្បន្នត្រូវបានយើងបូកបញ្ចូលគ្នា ហើយហៅកាត់ថា ពិធីបុណ្យភ្ជុំបិណ្ឌនេះឯង។

គេប្រទះឃើញរាជពង្សាវតារក្រុងកម្ពុជា ក្នុងរាជ្ជកាលព្រះបាទអង្គឌួង (១៨៤៨-១៨៥៩) ដែលបាននិយាយអំពីរឿងបុណ្យភ្ជុំបិណ្ឌបន្តិចថា « ថ្ងៃ១រោច ខែភទ្របទ កាន់បិណ្ឌក្នុងរាជវាំង ថ្ងៃ១៤រោច ខែភទ្របទ ព្រះរាជាទ្រង់ចេញថ្វាយព្រះបិតរ ថ្ងៃ១៥រោច ខែភទ្របទ ទេសនាគាថាពាន់»។

<u>**មូលហេតុដែលប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ**</u>

កាលពីសម័យបុរាណ គេធ្វើពិធីបុណ្យនេះគឺដើម្បីរៀបចំធ្វើសង្ឃភត្ត ទំនុកបម្រុងព្រះសង្ឃដែលគង់ចាំព្រះវស្សាក្នុងវត្តរយៈពេល៣ខែ ចាប់តាំងពីថ្ងៃចូលវស្សារហូតដល់ថ្ងៃចេញវស្សា។ នៅក្នុងចំណោរកាលបុរាណបានចារថា ដោយនៅក្នុងរដូវវស្សាមានភ្លៀងធ្លាក់ជោកជាំ រលឹមពព្រិច ធ្វើឱ្យមានការលំបាកដល់ព្រះសង្ឃក្នុងពេលធ្វើគោចរបិណ្ឌបាត។ ហេតុដូច្នេះ ទើបបណ្តាពុទ្ធបរិស័ទនាំគ្នារៀបចំពិធីនេះ ដើម្បីផ្គត់ផ្គង់ព្រះសង្ឃប្រចាំថ្ងៃរហូតដល់ថ្ងៃចេញវស្សា។ ម្យ៉ាងវិញទៀត នៅក្នុងពិធីបុណ្យនេះគឺធ្វើឡើងដើម្បីផ្សាយឧទ្ទិសកុសលដល់ពពួកប្រេតជនញាតិ និងញាតិទាំង៧សន្តាន ព្រមទាំងតំណញាតិច្រើនមហាកប្បនោះផងដែរ តាមរយៈអនុភាពនៃសង្ឃភត្តាទក្ខិណាទាន ដែលរស់រងទុក្ខវេទនាកើតជាប្រេតមានកម្មពៀរ ជាប់ទោសធ្ងន់ រងកម្មក្រហល់ក្រហាយអត់ឃ្លានទាំងអស់នោះ បានរួចផុតពីក្តីលំបាកសោកសៅ។

### ៣.២. រដូវបុណ្យភ្ជុំបិណ្ឌ

ចាប់តាំងពីសម័យបុរាណកាលរហូតមកដល់បច្ចុប្បន្ននេះ ពិធីបុណ្យភ្ជុំបិណ្ឌនេះ គេតែងតែប្រារព្ធនៅក្នុងរដូវវស្សា ព្រោះនៅក្នុងរដូវនេះពពួកប្រេតអាចមានឱកាសច្រើនក្នុងការស្វែងរកចំណីអាហារ ជាងរដូវផ្សេងៗទាំងអស់។ ម្យ៉ាងវិញទៀតនៅក្នុងវស្សានរដូវ អាហាររបស់ពួកប្រេត ដូចជាភក់ជ្រាំ ស្លេស្ម កំហាក សាកសព និងកាកសំណល់អសោច សម្បូរនៅក្នុងខែភ្លៀងធ្លាក់ពព្រិច។ នៅក្នុងរដូវបុណ្យភ្ជុំបិណ្ឌរយៈពេល១៥ថ្ងៃនេះ មានពពួកបេតជន (ពួកប្រេត) សាច់ញាតិទាំងប្រាំពីរសន្តាន ព្រមទាំងតំណញាតិច្រើនមហាកប្ប ដែលអត់ឃ្លានអាហារអស់រយៈពេលជាច្រើនខែមកហើយនោះ ត្រូវបានរួចផុតពីការឃុំឃាំងអនុញ្ញាតឱ្យមកស្វែងរកសាច់ញាតិនៅតាមវត្តអារាមផ្សេងៗ ដែលនាំយកចំណី

អាហារផ្សេងៗ មកឧទ្ទិសកុសលឱ្យខ្លួន។ ម្យ៉ាងវិញទៀត បើតាមសម្ដីចាស់ៗបុរាណនិយាយតៗគ្នាថា ក្នុងរយៈពេល១៥ថ្ងៃ បើពពួកបេតជនទាំងអស់នោះដើរស្វែងរកញាតិចំនួន៧វត្ត នៅតែមិនឃើញនោះ ពពួកប្រេតទាំងអស់នោះនឹងស្រែកយំទន្ទ្រាំជើង ព្រោះតែការខកបំណង និងភាពស្រេកឃ្លានក្រហល់ក្រហាយក្នុងចិត្ត។ ជាពិសេសពពួកបេតជនទាំងអស់នោះ នឹងដេរដាក់បណ្ដាសាដល់សាច់ញាតិ កូនចៅជាមិនខាន។

**តាមគម្ពីរមិលិន្ទបញ្ហា សម្ដែងថា ប្រេតមាន៤ ពួកគឺះ**

១. ប្រេតចិញ្ចឹមជីវិតដោយខ្ទុះឈាម

២. ប្រេតដែលស្រេកឃ្លានអាហារជានិច្ច

៣. ប្រេតដែលភ្លើងឆេះជានិច្ច

៤. ប្រេតដែលចិញ្ចឹមជីវិតដោយបុគ្គលដទៃឧទ្ទិសឱ្យ។



**ប្រេតទាំង១២ ក្នុងតម្រាខ្មែរ** (www. cen.com.kh)

## ៣.៣. ការប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ

ចំពោះបុណ្យភ្ជុំបិណ្ឌនេះ បុរាណាចារ្យរាជបណ្ឌិតខ្មែរយើងបានរៀបចំរយៈពេល១៥ថ្ងៃ ដោយចាប់គិតពីថ្ងៃទី១រោច ដល់ថ្ងៃទី១៥រោច ខែភទ្របទ ជាពិធីមួយសម្រាប់ឧទ្ទិសកុសលទៅដល់បេតជនញាតិដែលបានស្លាប់ទៅ។ នៅក្នុងរយៈពេល១៤ថ្ងៃ នៃការកាន់បិណ្ឌ ឬដាក់បិណ្ឌនេះ ពុទ្ធបរិស័ទចំណុះជើងវត្តទាំងអស់ ជាពិសេសក្រុមនីមួយៗដែលបានរៀបចំជាក្រុមដោយលោកតាអាចារ្យចាត់ចែងនោះ ត្រូវបែងចែកចេញជា៣ ឬ៤ក្រុមតូចៗ ដើម្បីរៀបចំធ្វើយាគូ ឬធ្វើភត្តាហារជាដើម។

មុនថ្ងៃភ្ជុំបិណ្ឌមួយថ្ងៃ គឺនៅថ្ងៃទី១៤រោច នៅតាមផ្ទះនីមួយៗ គេនិយមធ្វើនំអន្សម នំគមសម្រាប់យកទៅប្រគេនព្រះសង្ឃ ឧទ្ទិសដល់អ្នកដែលបានស្លាប់ទៅផង ចែកចាយដល់អ្នកជិតខាង ឬមិត្តភក្ដិផង។ នៅវេលាយប់ថ្ងៃនេះ នៅឯវត្តមានធ្វើពិធីបង្សុកូលដល់វិញ្ញាណក្ខន្ធដល់អ្នកដែលបានបាត់បង់ជីវិតទៅហើយ ដោយមានការសូត្រធម៌ និងសម្ដែងធម៌ទេសនារហូតដល់ភ្លឺ។ លុះស្អែកឡើងថ្ងៃ១៥រោច ខែភទ្របទ ដែលជាថ្ងៃចុងក្រោយនៃពិធីកាន់បិណ្ឌ ហើយដែលជាថ្ងៃសំខាន់ជាងគេ អ្នកស្រុកគ្រប់ផ្ទះនាំគ្នាធ្វើដំណើរទៅប្រជុំនៅវត្ត។ អ្នកខ្លះកាន់បាយបិណ្ឌ បាយបិតបូរ ខ្លះកាន់នំអន្សម នំគម និងនំចំណីផ្សេងៗ ខ្លះទៀតកាន់ចានស្រាក់ដាក់ចង្ហាន់ទៅប្រគេនព្រះសង្ឃ។

ក្រៅពិធីកាន់បិណ្ឌដែលធ្វើនៅវត្ត មានពិធីសែនព្រេននៅតាមផ្ទះនីមួយៗនៅវេលាយប់នៃថ្ងៃបង្ហើយនេះ។ លុះព្រឹកព្រហាមឡើង គេរៀបចំនំចំណីក្នុងកូនទូកធ្វើអំពីដើមចេក ហើយបណ្ដែតលើទឹកដើម្បីជូនដំណើរដូនតាទៅវិញ។

## ៤. ពិធីបុណ្យច្រត់ព្រះនង្គ័ល

ពិធីច្រត់ព្រះនង្គ័ល ជាព្រះរាជប្រវេណីមួយរបស់ព្រះរាជមហាក្សត្រម្ចាស់ផែនដីខ្មែរយើងតាំងពីបុរាណកាលមក ប៉ុន្តែមិនជារបស់ព្រះមហាក្សត្រដោយត្រង់ៗទេ គឺព្រះអង្គគ្រាន់តែជាម្ចាស់ដី។ ព្រះអង្គបានបើកអំណាចអនុញ្ញាតឱ្យប្រជារាស្ត្រ កាប់គាស់រានធ្វើរបរកសិកម្ម។ ពេលប្រជារាស្ត្រធ្វើរបរបានទទួលផលហើយ តែងបែងចែកផលនោះថ្វាយរាជពាលី (ស្តេចម្ចាស់ទឹកដី) គឺថ្វាយសួយសារអាករដល់ស្តេចជាគ្រឿងចិញ្ចឹមជីវិត។

ពេលដល់រដូវចម្រូត ភ្នាក់ងារពលទេពក៏ចេញទៅរួបរួម និងចៅហ្វាយស្រុកគ្រប់ៗស្រុកធ្វើការកត់ត្រាយកពន្ធស្រូវដាក់ឃ្លាំង។

នៅក្នុងច្បាប់ «ក្រមពហនុពលទេព» ព្រះរាជាតែងបញ្ជាជាចុតហ្មាយប្រកាសអស់ប្រជានុរាស្ត្រដែលនៅក្នុងប្រទេសកម្ពុជាឱ្យបានដឹងគ្រប់ៗគ្នា ឱ្យភ្នាក់ងារក្រុមស្រែ ប៉ាវគង ទូងភារី ឃោសនាប្រាប់អ្នកស្រែឱ្យបោះនង្គ័ល រនាស់ ស្រះរបង ចងគោក្របី...។

រវាងពាក់កណ្តាលខែពិសាខ រាល់ៗឆ្នាំ ឱ្យពួកព្រាហ្មណ៍តាំងពិធីព្រត (បួស) ៣ថ្ងៃ៣យប់ នៅទីព្រះស្រែ ដល់ថ្ងៃទី៤ ឱ្យធ្វើពិធីវប្បមង្គលច្រត់ព្រះនង្គ័ល។ បើគ្មានភ្លៀងធ្លាក់តាមរដូវកាល ព្រះអង្គឱ្យគេរៀបចំពិធីកិរុណសាស្ត្រទៀត។

### ៤.១. ប្រវត្តិពិធីច្រត់ព្រះនង្គ័ល

តាមកាលយល់របស់ខ្មែរថា ពិធីច្រត់ព្រះនង្គ័លនេះ មានតាំងពីបុរាណកាលមក គឺតាំងពីសម័យនគរភ្នំ ដោយគេយល់ថា កៅណ្ឌិន្យ ដែលចុះមកស្ថាបនាឥស្សរភាពនៅប្រទេសខ្មែរ បាននាំយកអរិយធម៌ វប្បធម៌ លទ្ធិសាសនា ទំនៀមទម្លាប់ផ្សេងៗមកជាមួយ ដូចនេះប្រហែលជានាំយកពិធីច្រត់ព្រះនង្គ័លនេះ មកអនុវត្តនៅស្រុកខ្មែរជាប្រាកដ ហើយទំនៀមទម្លាប់នេះ ក៏មាននៅក្នុងប្រទេសឥណ្ឌាដែរ ដូចមាននៅក្នុងរឿងរាមកេរ្តិ៍ រឿងមហាភារតយុទ្ធស្រាប់។

<u>ព្រះស្រែ</u>

ពាក្យថា «**ព្រះស្រែ**» មានន័យ២យ៉ាងគឺ:

-ស្រែដែលព្រះមហាក្សត្រទ្រង់ច្រត់ព្រះនង្គ័លរៀងរាល់ឆ្នាំ។

-ស្រែដែលគេថ្វាយជាសម្បត្តិសាសនា (ព្រហ្មញ្ញសាសនាក្តី ពុទ្ធសាសនាក្តី) ហេតុនេះកាលបើឮគេនិយាយចេញឈ្មោះព្រះស្រែនៅតំបន់ណាៗក្តី កុំអាលយល់ថាជាស្រែហ្លួង គួរពិចារណាថា បើនៅជិតប្រាសាទទេវស្ថាន ឬវត្តបុរាណគឺជាស្រែដង្វាយព្រះ តែបើនៅជិតរាជវាំងបុរាណនោះវិញ គឺជាស្រែហ្លួង។

នៅសម័យឧត្តុង្គការចាំកន្លែងស្រែហ្លួងរកមិនឃើញមានទេ តែចាប់ពីសម័យឧត្តុង្គមកគេបានចងចាំថា ព្រះស្រែហ្លួងនៅខាងទិសនិរតីនៃរាជវាំងព្រះរាជា គឺជិតវត្តឈូកស។ ព្រះស្រែនេះពីដើមមានលក្ខណៈជាស្រែមែន ដូចព្រះស្រែធម្មតា គឺជាទំនាបល្មមទឹកដក់បាន ដូចស្រែធម្មតាដែរ។

នៅភ្នំពេញ ព្រះស្រែហ្លួងធ្វើខាងលិចវត្តប្រយូរវង្ស។ នៅក្នុងរាជ្យព្រះបាទស៊ីសុវត្ថិទ្រង់ច្រត់ព្រះនង្គ័លនៅវាលព្រះមេរុ ពិតមែនតែទីនោះជាទីវាបធម្មតាមិនមានលក្ខណៈជាព្រះស្រែ តែក្រោយពេលច្រត់ព្រះនង្គ័លរួច ទ្រង់ឱ្យគេភ្ជួរដីមួយអន្លើ ប្រមាណប៉ុនស្រែតូចមួយ បើកទឹកម៉ាស៊ីនដាក់ស្ទូងស្រូវ។

ដូចនេះព្រះមហាក្សត្របុរាណទ្រង់ធ្វើព្រះស្រែ ឱ្យកើតជាផល មិនមែនគ្រាន់តែឧបកិច្ចដូចសព្វថ្ងៃនេះទេ។

**ឫក្សច្រត់ព្រះនង្គ័ល:** ពីដើមមានទំនៀមរើសរកឫក្សល្អ ថ្ងៃល្អដូចពិធីដទៃៗដែរ។ តែក្រោយមកគេកំណត់យកថ្ងៃ៤រោច ខែពិសាខ ទោះថ្ងៃនោះមានឫក្សល្អ ឬមិនល្អក៏ដោយ។

**អ្នកតំណាងព្រះមហាក្សត្រពេលច្រត់ព្រះនង្គ័ល:** ពេលធ្វើហោមពិធីគ្រប់៣ថ្ងៃហើយ ក្នុងថ្ងៃទី៤ពេលព្រឹកព្រះរាជាព្រះអង្គឯង ឬចាត់តំណាងឱ្យព្រះអង្គចេញច្រត់ព្រះនង្គ័ល។ អ្នកត្រូវចាត់តំណាង គឺឧកញ៉ា ពហុលទេពក្សេត្រធិបតី។ បើវល់ត្រូវចាត់ឧកញ៉ា ពិធីសាលី ឬឧកញ៉ា ក្សេត្រភោជនាហារឱ្យជំនួសមួយដងមួយកាលក៏មាន។ អ្នកទទួលតំណែងច្រត់ព្រះនង្គ័លពីព្រះអង្គ គេហៅថា «**ស្តេចមាឃ**» ភរិយាស្តេចមាឃ ហៅថា «**ព្រះមេហួ**» មានមុខការជាអ្នកព្រោះស្រូវ។





ការដង្ហែព្រះមេហួនិងការច្រត់ព្រះនង្គ័លនៅវាលព្រះមេរុ

## ៤.២. អ្នកតែងខ្លួនតំណាងឱ្យព្រះអង្គ

<u>ស្តេចមាឃ:</u>

- ស្លៀកសំពត់សារបាប់ពណ៌លឿងទុំ សំឡុយ
- ពាក់អាវសារបាប់ពណ៌លឿងទុំ
- ពាក់មួកប្រពាតពណ៌លឿងទុំ

<u>សម្គាល់:</u> ក្នុងរាជ្យព្រះបាទស៊ីសុវត្ថិ និងព្រះបាទស៊ីហនុ មានពាក់ស្រោមជើង និងពាក់ស្បែកជើងខ្មៅ។

<u>មេហួ:</u>

ក្នុងរជ្ជកាលព្រះបាទនរោត្តម

- ស្លៀកសំពត់សារបាប់សំឡុយ

- ពាក់អាវព្រៃបំពង់វែង លឿងទុំ
- ពានាក្រមាព្រៃពណ៌បៃតង
- ប្រដាប់គ្រឿងមាស ពេជ្រ ទំហូ ឆៀងខ្លួន ពាក់ចិញ្ចៀន ក្បាលទទេឥតមានពាក់អ្វី

ក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ

- ស្លៀកសំពត់ហូលមានជរ
- ពានាផាហ៊ុំខាងក្នុង ស្បៃសារបាប់ខាងក្រៅ

សម័យបច្ចុប្បន្ន

- ស្លៀកសំពត់សារបាប់សំឡុយ
- ពាក់អាវទ្រនាប់ពណ៌លឿងរឹតខ្លួន
- ពាក់ស្បៃឆៀងបែបតួល្ខោន និងគ្រឿងអលង្ការផ្សេងៗ

<u>មហាតលិកទាំង៤ របស់ស្តេចមាឃ:</u>

- ស្លៀកសំពត់ពណ៌ចងក្បិន
- ពាក់អាវផ្កាមាស
- ពាក់មួកប្រពាតដូចគ្នា
- ក្បាលទទេ។

## ៤.៣. ក្បួនហែច្រត់ព្រះនង្គ័ល

ពេលហែទៅដល់ទីព្រះស្រែ ស្តេចមាឃនិងមេហួ ចូលទៅថ្វាយបង្គំព្រះទេវរូប នៅរោងពិធីទិសនិរតី បាគូផ្លុំស័ង្ខ៣បទ រួចចេញច្រត់ព្រះនង្គ័ល។ ភ្នាក់ងារកាន់ព្រះនង្គ័លស្តេចមាឃ ក៏ប្រគល់ឱ្យស្តេចមាឃ ហើយចេញទៅដើរនាំមុខ។ នង្គ័លស្តេចមាឃនៅកណ្តាល មានម្នាក់បាំងក្លស់និងមហាតលិក៤នាក់ កាន់គ្រឿងដើរតាមក្រោយ មេហួដើរក្រោយនង្គ័លទី៣ មានម្នាក់បាំងក្លស់និងសាវឡិកទាំង៤នាក់ កាន់គ្រឿងដើរហែតាមក្រោយ។ ក្បួនច្រត់ព្រះនង្គ័លចេញច្រត់ជាទក្ខិណាព័ទ្ធ៣ជុំ។ ពេលកំពុងច្រត់នោះ មេហួចាប់ស្រូវហៅថា «**ក្រយាសំពាន់**» ក្នុងកញ្ជើព្រាចសាចទៅឆ្វេងទៅស្តាំ ដរាបដល់ឈប់ច្រត់ក្នុងមួយជុំ បាគូផ្លុំស័ង្ខម្តង។ ពេលគ្រប់៣ជុំ ភ្នាក់ងារអ្នកដើរម្នាក់ ដើរនាំក្បួនព្រះនង្គ័លទៅឈប់នៅក្បែររោងពិធីទិសបូព៌ា រួចដោះគោចេញ។

## ៤.៤. ការផ្សងគោឧសភរាជ

គោមួយនឹមដែលគេទឹមច្រត់ព្រះនង្គ័លនោះ គេហៅថា «**ព្រះគោ**» ឬ«**គោឧសភរាជ**»។ តាមបែបនិយមបច្ចុប្បន្ន គេកំណត់យកគោសម្បុរខ្មៅឬត្នោត ស្នែងប្រក់នាគ គឺរាងខុបទៅមុខ ហើយបត់ចុងឡើងបន្តិច។ គោពីរនឹមទៀត គ្មានកំណត់លក្ខណៈទេ។ ឯព្រះគោទឹមច្រត់ព្រះនង្គ័ល គេតុបតែងពាក់

ស្រោមមុខ ស្រោមស្នែង។ នង្គ័លទាំង៣គេលាបពណ៌ខ្មៅ ចន្ទល់មានលក្ខណៈពិសេស គឺរូបក្បាលនាគលាបពណ៌មាស នៅត្រង់កនាគមានភួយធ្វើពីរោមសត្វ។

<u>សម្គាល់</u>:

-ព្រះគោទាំងគូនិងនង្គ័លនោះ តាមទំនៀមដើម គេយកទៅតាំងក្នុងរោងមួយដែលទើបតែសង់ថ្មីនៅក្នុងទីព្រះស្រែនោះវេលាមុនច្រត់ព្រះនង្គ័ល៣ថ្ងៃ ហើយហាមមិនឱ្យយកទៅក្រៅទីព្រះស្រែទេ។

-ព្រះគោនិងព្រះនង្គ័លជាព្រះរាជទ្រព្យមកតាំងពីបុរាណ (បាត់ក្នុងរាជ្យព្រះបាទស៊ីសុវត្ថិ) គេយកនង្គ័លទៅដាក់ក្នុងរោងទិសនិរតី។

ពេលដោះគោចេញ ព្រាហ្មណ៍ព្រះរាជគ្រូ សូត្រពាក្យអធិដ្ឋានផ្សងគោឧសភរាជដែលទឹមច្រត់ព្រះនង្គ័លឱ្យស៊ីផឹកអាហារ៧យ៉ាង ដែលគេរៀបដាក់មុខព្រះពន្លា។ ម្ហូបអាហារមាន ស្រូវ១គុ គ្រាប់សណ្តែក១គុ គ្រាប់ល្ង១គុ ពោត១គុ ស្មៅស្រស់១គុ ទឹក១គុ ស្រា១គុ។ សូត្រចប់ ព្រាហ្មណ៍ព្រះរាជគ្រូយកទឹកមន្តប្រោះក្បាលព្រះគោទាំងពីរ។ រួចមន្ត្រីម្នាក់ដែលកាន់នង្គ័លស្តេចមាឃ ដឹកគោឧសភរាជទៅឱ្យស៊ីផឹករបស់ទាំង៧យ៉ាងនោះ។ បើព្រះគោស៊ីអ្វី គេទាយថាឆ្នាំនេះសម្បូររបស់នោះ ប្លែកតែបើស៊ីស្មៅគឺកើតជំងឺគោ បើផឹកស្រាកើតមនុស្សពាល ចោរលួចប្លន់ច្រើន។ បន្ទាប់មកទៀត ស្តេចមាឃ និងមេហួចូលទៅថ្វាយបង្គំព្រះទេវរូបនៅក្នុងរោងមណ្ឌលទិសខាងកើត ពួកបាគូក៏ចូលទៅផ្លុំស័ង្ខ ព្រះរាជគ្រូយកទឹកមន្តប្រោះព្រំនិងឱ្យស័ព្ទសាធុការដល់អ្នកទាំងពីររូប ហើយជាការចប់ពិធី។

# មេរៀនទី៧ សុជីវធម៌ក្នុងសង្គម «ពិធីការខ្មែរ»

## ១. ការងារពិធីការ[31]

### ១.១. និយមន័យ

-ពិធីការ (ពិធីសារ = Protocol) ជាកិច្ចព្រមព្រៀងបន្ថែម ឬជាកំណត់ហេតុនៃកិច្ចការទូត។

-ពិធីការ គឺជាទំនៀមទម្លាប់ដែលសង្គមយល់ថា មិនធ្គងដើម្បីប្រើប្រាស់ក្នុងពិធីនានា ឬជាក្រមសីលធម៌របស់អង្គទូត និងជនដទៃទៀត។

ឧទាហរណ៍៖

-របៀបគារវកិច្ច (សំពះ ថ្វាយបង្គំ ចាប់ដៃ ងក់ក្បាល ឱបថើប...)

-របៀបបដិសណ្ឋាកិច្ច (ទទួលភ្ញៀវ ជូនដំណើរភ្ញៀវក្នុងការិយាល័យ រថយន្ត យន្តហោះ...)

-របៀបរៀបចំជប់លៀង ប្រជុំ សិក្ខាសាលា សន្និសីទជាតិ និងអន្តរជាតិ

-របៀបរៀបចំតុ សម្ភារៈលើតុជប់លៀង ឬតុប្រជុំ

-របៀបស្លៀកពាក់តាមបែបប្រពៃណីជាតិ ឬបែបអន្តរជាតិ

-របៀបប្រើប្រាស់ភាសាក្នុងការទាក់ទង (និយាយ សរសេរ កាយវិការ)

-របៀបធ្វើការក្នុងការិយាល័យ។ល។

### ១.២. ប្រភេទពិធីការ

-ពិធីការព្រះបរមរាជវាំង

-ពិធីការរដ្ឋ ឬពិធីការការទូត: ទទួលបន្ទុកដោយ៖

- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- គណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិនិងអន្តរជាតិ

-ពិធីការថ្នាក់ដឹកនាំកំពូល

- ពិធីការប្រធានព្រឹទ្ធសភា
- ពិធីការប្រធានរដ្ឋសភា
- ពិធីការនាយករដ្ឋមន្ត្រី

-ពិធីការអង្គភាព(តាមក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ)

-ពិធីការប្រពៃណី(ក្នុងអាពាហ៍ពិពាហ៍)

-ពិធីការសាសនា (ក្នុងពិធីបុណ្យសាសនាផ្សេងៗ)។

---

[31] កុក រស់, ការងារពិធីការ, ២០០១។

## ១.៣. តួនាទីរបស់ពិធីការ

មានពីររូបភាពគឺ៖

- សប្បាយរីករាយ
- ហត់នឿយ

-បង្ហាញតាមទំនៀមទម្លាប់ប្រពៃណីជាតិ

ឧ. គារវកិច្ចខ្មែរ គឺការសំពះ

- គារវកិច្ចខ្មែរ គឺទន់ភ្លន់ សុភាពរាបសារ
- ប្រពៃណីខ្មែរ គឺការស្លៀកពាក់ហូល ផាមួង អាវប៉ាក់ ពានាកន្សែងពណ៌តាមថ្ងៃ។

-បង្ហាញភាពថ្លៃថ្នូររបស់ជាតិ

-បង្ហាញភាពទន់ភ្លន់តែរឹងប៉ឹង ម៉ឺងម៉ាត់

## ១.៤. សារប្រយោជន៍នៃពិធីការ

- សេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន (សុជីវធម៌ សីលធម៌ គុណធម៌)
- ប្រសិទ្ធភាពក្នុងទំនាក់ទំនង
- វិសាលភាពរបស់ជាតិ (ទំនៀមទម្លាប់ ប្រពៃណី)។

## ២. ពិធីការក្នុងគារវកិច្ច

## ២.១. ប្រភពសំពះនិងថ្វាយបង្គំ

- មានអាយុកាលប្រហែលជា២០០០ឆ្នាំមកហើយ
- មកពីប្រទេសឥណ្ឌាតាមរយៈព្រះពុទ្ធសាសនា
- ស.វទី៣ មុនគ.ស ដោយ**ព្រះមហាមោគ្គលីបុត្តស្សត្ថេរ** ចាត់បញ្ជូន **ព្រះសោណត្ថេរ** និង**ព្រះឧត្តមត្ថេរ** មកដែនដីសុវណ្ណភូមិ។

## ២.២. អត្ថន័យនិងសារប្រយោជន៍

**+អត្ថន័យ៖**

- ការគោរពសក្ការបូជា(ទម្រង់ដូចផ្កាឈូកក្រពុំ)
- ភាពត្រជាក់ត្រជុំសុខដុមរមនា(ទម្រង់ដូចផ្កាឈូកក្រពុំ)
- ការដឹងគុណ (ទម្រង់ដូចដោះម្តាយ)

**+សារប្រយោជន៍៖**

- ចំណេញពេលវេលា(លើកដៃម្តងមនុស្សរាប់ពាន់នាក់បានឃើញនិងស្តាប់ឮ)

- កាត់បន្ថយអវិភាព អធិករណ៍ និងអំពើហិង្សាក្នុងគ្រួសារ
- រក្សាអនាម័យ
- រក្សាបានសុវត្ថិភាពផ្ទាល់ខ្លួន
- រក្សាបាននូវទំនៀមទម្លាប់ដ៏ល្អផូរផង់របស់ជាតិខ្មែរ

## ២.៣. ប្រភេទនិងខ្នាតនៃសំពះខ្មែរ

- សំពះឈរ(ឈរសំពះ)៖ ៣-៤-៥ខ្នាត (ទ្រូង មាត់ ច្រមុះ ចិញ្ចើម)
- សំពះអង្គុយ (អង្គុយសំពះ) ៣បែប(អង្គុយបត់ជើង លុតជង្គង់ និងបញ្ឈរជង្គង់)
- សំពះក្រាប(ក្រាបសំពះ) ២បែប(ក្រាបបត់ជើងនិងក្រាបលុតជង្គង់)។

-ទីតាំង (កន្លែងធ្វើការ ទីពិធី ទីសាធារណៈ)

-ពេលវេលា(ពេលប្រជុំ ពេលសវនការ ពេលជួប លាគ្នា)

-វ័យ(ក្មេង ចាស់ ស្មើ)

-ឋានៈ តំណែង តួនាទី(ធំ តូច ស្មើ)។

## ២.៤. ខ្នាតសំពះខ្មែរ

-ខ្នាតដៃ៖ ប្រណមត្រឹមដើមទ្រូង មាត់ ច្រមុះ ចិញ្ចើម...។

-ខ្នាតជើង៖ ផ្ទុំស្មើ ឬជើងស្ដាំថយក្រោយតាមខ្នាតជាក់លាក់។

-ខ្នាតក្បាល៖ ងើបត្រង់ធម្មតា ឬឱនបន្តិច-ខ្លាំង តាមអ្នកដែលត្រូវសំពះ។

## ៣. ពិធីការក្នុងបដិសណ្ឋារកិច្ច

-ទីកន្លែងរៀបចំពិធីបដិសណ្ឋាកិច្ច

- ប្រទេសខ្លះធ្វើនៅវិមានរដ្ឋាភិបាល
- ប្រទេសខ្លះធ្វើនៅប្រាសាទបុរាណ
- កម្ពុជាធ្វើនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ

-មានពិធីគោរពភ្លេងជាតិនៃប្រទេសទាំងពីរ និងដើរត្រួតពល។

-មានឧទ្ទេសនាមភ្ញៀវជាតិនិងអន្តរជាតិ

-មាននារីស្លៀកពាក់ចងក្បិនតាមប្រពៃណីខ្មែរ បំពាក់ភួងផ្កា និងរោយផ្កាលើកម្រាលព្រំ

-មានមន្ត្រីរាជការ មហាជន សិស្ស និស្សិត ទទួលស្វាគមន៍ប្រធានគណៈប្រតិភូទៅតាមឋានៈរបស់ប្រធានគណៈប្រតិភូ។

## ៤. ពិធីការក្នុងការទំនាក់ទំនង

### ៤.១. ទំនាក់ទំនងផ្ទៃក្នុង (ក្នុងស្ថាប័ន អង្គភាពរបស់ខ្លួន)

លេខាធិការ៖

-ត្រូវចេះធ្វើយ៉ាងណាឱ្យការងារមានប្រសិទ្ធភាព

-ត្រូវចេះគោរពឋានានុក្រមការងារ

-ត្រូវចេះសម្របខ្លួនដើម្បីទំនាក់ទំនងឱ្យបានល្អ

### ៤.២. ទំនាក់ទំនងការងារខាងក្រៅ (នៅខាងក្រៅអង្គភាព ស្ថាប័ន)

**លេខាធិការ៖**

-ត្រូវស្គាល់ឱ្យបានច្បាស់អំពីបុគ្គលិកលក្ខណៈអ្នករួមការងាររបស់ខ្លួន និងភ្ញៀវមកពីខាងក្រៅ។

-ត្រូវឆ្លាតវៀងវៃក្នុងការទំនាក់ទំនងជាមួយភ្ញៀវ

### ៤.៣. ទំនាក់ទំនងជាផ្លូវការ ឬពាក់កណ្តាលផ្លូវការ

-ក្នុងការទំនាក់ទំនងត្រូវមានការកោតសសើរ និងលើកទឹកចិត្ត

-ក្នុងការទំនាក់ទំនងត្រូវមានគោលដៅប្រាកដនិយមដើម្បីឆ្ពោះទៅរកការអភិវឌ្ឍយូរអង្វែង

ចំណាំ៖

**ដំណាក់កាលទំនាក់ទំនង** → { ការទទួល, ទីកន្លែង, ពេលវេលា } → លេខាជាអ្នកចាត់ចែង

## ៥. ពិធីការក្នុងការប្រើប្រាស់ភាសា

-ភាសានិយាយ

-ភាសាសរសេរ

-ភាសាគឬកាយវិការ

### ៥.១. ការប្រើប្រាស់ភាសានិយាយ

គោលបំណងនៃការនិយាយមាន៖

-បញ្ចេញទុកសោកកង្វល់ក្នុងចិត្តឱ្យបានធូរស្រាល

-លួងលោម និងទាក់ទាញទឹកចិត្តអ្នកស្តាប់

-ធ្វើឱ្យអ្នកស្តាប់គេចូលចិត្ត ហើយជឿជាក់

-បង្កើនចំណេះដឹង

-ធ្វើឱ្យមានភាពសប្បាយរីករាយ

-ធ្វើឱ្យមានការយោគយល់គ្នា

-បើកឱកាសឱ្យអ្នកស្តាប់សួរកុំឱ្យនៅមានមន្ទិល

## ៥.២. ធាតុសំខាន់ៗក្នុងការនិយាយ

-អ្នកនិយាយ -អ្នកស្តាប់ -ប្រធានបទ

### ក. អ្នកនិយាយ

ក.១. ប្រភេទនៃអ្នកនិយាយ

- និយាយម្នាក់ឯង
- និយាយជាក្រុម

ក.២. វិធីនៃការនិយាយ

- វិធីទន្ទេញចាំមាត់
- បែបអានអត្ថបទ
- យល់ច្បាស់ហើយមើលគោលបំណងសំខាន់ៗ
- រៀបចំរួចជាស្រេចហើយចងចាំ ព្រមទាំងយល់
- ឥតព្រៀងទុក

**+ដំណាក់កាលក្នុងការនិយាយ៖**

**-ដំណាក់កាលទី១:**

- ត្រៀមខ្លួននិយាយ ( ឱ្យចំប្រធានបទ )

**-ដំណាក់កាលទី២: កំពុងនិយាយ**

- ការគោរពពេលវេលា
- ការឈានឡើងលើវេទិកា
- ប្រុងប្រយ័ត្នក្នុងការតុបតែងខ្លួន
- ផ្តល់កិត្តិយលដល់អ្នកស្តាប់
- សម្លឹងមើលទៅអ្នកស្តាប់ទូទៅ
- ចេះប្រើភាសាក្នុងការនិយាយ
- អំណះអំណាងត្រូវតែច្បាស់លាស់
- កាយវិការស្របនឹងរឿង
- រង់ចាំសង្កេតប្រតិកម្មអ្នកស្តាប់
- កុំប្រកែកយកឈ្នះអ្នកស្តាប់
- និយាយចុងក្រោយឱ្យអ្នកស្តាប់យកទៅគិត

- និយាយតាមការតាំងចិត្ត។

**-ដំណាក់កាលទី៣: ក្រោយពីនិយាយចប់**

- ត្រូវទុកពេលឱ្យអ្នកស្តាប់សួរបំបាត់សង្ស័យ
- ពេលនិយាយចប់ត្រូវត្រលប់ទៅកន្លែងដើមវិញ

**+ អ្នកដែលចេះនិយាយគឺះ**

- មានខ្លឹមសារគួរឱ្យចាប់អារម្មណ៍ មានទិន្នន័យត្រឹមត្រូវ
- មានអត្តចរិតល្អ ហ្មត់ចត់ច្បាស់លាស់ មិនឆេវឆាវ
- ស្មោះត្រង់ជាមួយអ្នកស្តាប់។

**+ អ្នកមិនចេះនិយាយគឺះ**

- និយាយវែងពេក (បំផ្លាញពេលវេលា)
- ខ្លីពេកខ្វះខ្លឹមសារ (គ្មានហេតុផលច្បាស់លាស់)
- មិនគួរឱ្យចង់ស្តាប់ (ពាក្យអសុរោះ អាសអាភាស)
- ត្រឡប់ត្រឡិន(មិនដឹងក្បាលកន្ទុយ)។

**ខ. អ្នកស្តាប់**

ខ.១. ប្រភេទអ្នកស្តាប់

- អ្នកស្តាប់ជាមិត្ត
- អ្នកស្តាប់ដែលមិនយកចិត្តទុកដាក់
- អ្នកស្តាប់ដែលគ្មានការយល់ដឹង
- អ្នកស្តាប់ដែលជាសត្រូវ
- អ្នកស្តាប់ជួយជ្រោមជ្រែង
- អ្នកស្តាប់ចេះសព្វ
- អ្នកស្តាប់អៀនខ្មាស
- អ្នកស្តាប់ប្រឆាំងជំទាស់។

ខ.២. គុណសម្បត្តិអ្នកស្តាប់

- យកចិត្តទុកដាក់ស្តាប់ (កត់ត្រាចំណុចសំខាន់ៗទុក)
- ស្តាប់ហើយគិត (មានប្រយោជន៍ គួរជឿ ឬមិនជឿ)
- មិននិយាយកាត់គូសន្ទនា។

ខ.៣. ប្រភេទនៃការសួរ: មាន៦ប្រភេទគឺៈ

- សួរព្រោះចង់ដឹង
- សួរព្រោះចង់អួតចំណេះដឹង
- សួរដើម្បីផ្តួលរំលំ
- សួរបែបខ្ចីមាត់
- សួរបែបញុះញង់
- សួរបែបបន្ធូរអារម្មណ៍។

**គ. ប្រភេទប្រធានបទ**

គ.១. <u>សេចក្តីផ្តើម</u>: ការផ្តើមដែលល្អគួរផ្តើមដោយការធ្វើឱ្យអ្នកស្តាប់ឆ្ងល់ ហើយចង់ដឹងស្រដៀងគ្នា និងការសរសេរចំណងជើងនៃសារព័ត៌មានដែរ។

គ.២. <u>តួសេចក្តី</u>: ជាផ្នែកមួយសំខាន់បំផុតដែលត្រូវតែយកចិត្តទុកដាក់។ អ្នកនិយាយធ្វើយ៉ាងណាឱ្យខ្លឹមសារស្របទៅនឹងប្រធានបទ ស្របនឹងពេលវេលាកាលៈទេសៈ និយាយដោយមានហេតុផលត្រឹមត្រូវ ព្រមទាំងផ្តល់ចំណេះដឹងដល់អ្នកស្តាប់។ ត្រូវគិតទុកជាមុនថា ក្រោយពីការនិយាយ តើគំនិតរបស់ខ្លួននឹងផ្តល់សារប្រយោជន៍អ្វីខ្លះដល់អ្នកស្តាប់? មុននឹងបញ្ចប់ ត្រូវចេះសរុបសេចក្តី ឬទុកឱកាសឱ្យអ្នកស្តាប់សួរដេញដោលផង។

គ.៣. <u>សេចក្តីបញ្ចប់</u>: ជាសិល្បៈមួយដែលអាចទាញអារម្មណ៍អ្នកស្តាប់មានការចាប់អារម្មណ៍។ ការបញ្ចប់ដែលល្អ គួរបញ្ជាក់ចំណុចសំខាន់ៗឱ្យអ្នកស្តាប់យកទៅពិចារណាដូចជា សុភាសិត ពាក្យស្លោក ទស្សនវិជ្ជា ឬពាក្យពេចន៍ពិសេសដែលយើងបានសម្រិតសម្រាំង។

សរុបមក ការនិយាយស្តីចំទិសដៅ (ចំបញ្ហា) ត្រូវរៀបចំទុកជាមុនឱ្យបានច្បាស់លាស់ទើបអាចទទួលបានលទ្ធផលល្អប្រសើរ។

## ៦. ពិធីការក្នុងការងារ

### ៦.១. ពីអ្នកធំទៅអ្នកតូច

<u>**គួរៈ**</u>

+និយាយដោយបោរីភាព(សំដីអ្នកក្រុង)ជានិច្ច

+និយាយសាច់ការ

+ចេះស្តាប់យោបល់អ្នកក្រោមបង្គាប់

+លើកទឹកចិត្តដោយការសរសើរ និងជូនរង្វាន់

**<u>មិនគួរ៖</u>**

+ស្និទ្ធស្នាលហួសប្រមាណ

+ប្រើភាសាមិនសមរម្យ

+ជជែកខ្វែងយោបល់ជាមួយអ្នកតូចជាង

+រំខានដល់ការងារអ្នកក្រោមបង្គាប់។

### ៦.២. ពីអ្នកតូចទៅអ្នកធំ

**<u>គួរ៖</u>**

+ប្រកាន់សេចក្តីគោរពជានិច្ច

+និយាយតែការណាមានប្រយោជន៍ ខ្លីហើយខ្លឹម

+គោរពការសម្រេចចុងក្រោយរបស់ចៅហ្វាយ។

**<u>មិនគួរ៖</u>**

+តវ៉ាប្រឆាំង ឥតហេតុផល

+រំខានពេលវេលារបស់ចៅហ្វាយ

+សួរដេញដោលច្រើនហួសប្រមាណ។

### ៦.៣. រវាងអ្នកស្មើគ្នា

+សហប្រតិបត្តិការ

+មិនរំលោភបំពានការងារគ្នា

+សោមនស្សភាព ភាតរភាព

+បុរសត្រូវសន្តោសនារី។

## ៧. ពិធីការក្នុងការប្រជុំ

ការប្រជុំ គឺជាការដែលមនុស្សមួយក្រុមមកជួបជុំគ្នាដើម្បីផ្លាស់ប្តូរវេន គំនិត មតិយោបល់គ្នា រហូតដល់ការវិនិច្ឆ័យដើម្បីចេញសេចក្តីសម្រេច។

ក្នុងអង្គប្រជុំទូទៅមានសមាសភាពចូលរួម (ជាតុ) ៣គឺ៖

-ប្រធានអង្គប្រជុំ -លេខា -អ្នកចូលរួម

ក្រៅពីជាតុទាំង៣ខាងលើ អ្នកពិធីការក៏ជាជាតុមួយយ៉ាងសំខាន់ណាស់ដែរ សម្រាប់ចូលរួមកិច្ចដំណើរការសម្របសម្រួល និងចាត់ចែងកម្មវិធី ព្រមទាំងរៀបចំកម្មវិធីឱ្យមានសកម្មភាពរស់រវើក។

## ៧.១. មុនពេលប្រជុំ

- កំណត់ឱ្យបានច្បាស់ពីគោលដៅនៃការប្រជុំ
- រៀបចំរបៀបវារៈឱ្យបានត្រឹមត្រូវ
- ត្រូវចេះជ្រើសរើសអ្នកចូលរួម (លិខិតអញ្ជើញ)
- ជ្រើសរើសនិងរៀបចំទីកន្លែងឱ្យបានសមរម្យ
- រៀបចំសម្ភារៈដែលពាក់ព័ន្ធការប្រជុំ។

## ៧.២. ពេលប្រជុំ

- ពិធីការគួរតែដឹងនូវទិន្នន័យទូទៅដែលទាក់ទងនឹងពិធីឱ្យបានច្រើន
- អ្នកពិធីការជាអ្នកចាត់តាំងនិងសម្របសម្រួល
- ធ្វើតាមជំហានៗប្រព្រឹត្តទៅបានល្អ
- ត្រូវមានភាពស្មោះត្រង់ រឹងប៉ឹង និងភាពឱនលំទោនជានិច្ច។

ក. <u>ប្រធានប្រជុំ</u>

+លក្ខណៈសម្បត្តិ៖

- មានសមត្ថភាពគ្រប់គ្រាន់និងចងចាំល្អ
- មានសំនួនវោហារនិងសិល្បៈនិយាយ
- ចេះសម្របសម្រួលនិងបរិយាកាសជុំវិញ។

+ភារកិច្ចរបស់ប្រធានអង្គប្រជុំ

- ដឹកនាំអង្គប្រជុំចូលរបៀបវារៈ
- ដឹកនាំអង្គប្រជុំទៅតាមរបៀបវារៈ
- ប្រកាសលទ្ធផលនិងសេចក្ដីសម្រេច។

<u>ខ. លេខាអង្គប្រជុំ</u>

- ត្រូវតាមដានដោយយកចិត្តទុកដាក់
- ទទួលបន្ទុកធ្វើកំណត់ហេតុរបស់វាគ្មិន
- ផ្ដល់កំណត់ហេតុ ឬរបាយការណ៍ដល់អ្នកពាក់ព័ន្ធយ៉ាងយូរ១សប្ដាហ៍។

<u>គ. អ្នកចូលរួម</u>

- តាមដានស្ដាប់ខ្លឹមសារនៃកិច្ចប្រជុំដោយយកចិត្តទុកដាក់ ជៀសវាងការភ័ន្តច្រឡំ

- លើកទស្សនៈ យោបល់ណាដែលមានការពាក់ព័ន្ធអង្គប្រជុំ មកនិយាយ។

## ៧.៣. ក្រោយពេលប្រជុំ

- ពិធីការជួបជុំសំណេះសំណាល
- ពិសាភេសជ្ជៈ ឬអាហារមិត្តភាព
- ត្រឡប់ទៅលំនៅដ្ឋានវិញ។

<u>របៀបរៀបចំបន្ទប់ប្រជុំ</u>

- អ្នកចូលរួមត្រូវមើលឃើញមុខគ្នាទៅវិញទៅមក
- គួររៀបជារង្វង់ (អក្សរO)
- ប្រការល្អគួររៀបចំកន្លែងប្រជុំរាងក្រចកជើងសេះ ទើបងាយស្រួលមើលអ្វីៗដែលនៅក្តារខៀន៕

# ឯកសារពិគ្រោះ


១. កុក រស់ (២០០១) *ការងារពិធីការ*, ការផ្សាយរបស់អ្នកនិពន្ធ។

២. កែប វ៉ាន់ឌី (១៩៧១) *អរិយធម៌ខ្មែរ-មន*, ភ្នំពេញ។

៣. កែវ ណារុំ (១៩៩៥) *តន្ត្រីនិងជីវិតខ្មែរ*។

៤. ក្រសួងអប់រំ យុវជន និងកីឡា (១៩៩៦) *អរិយធម៌ខ្មែរ*។

៥. ក្រសួងទេសចរណ៍ (២០០៦) *មគ្គុទ្ទេសក៍ទេសចរណ៍តំបន់អង្គរនិងសៀមរាបអង្គរ*។

៦. គង់ នឿន (១៩៧១) *វប្បធម៌ឥណ្ឌា-ខ្មែរ*។

៧. ជុច ភឿន (១៩៩៣) *មនុស្ស-សិល្បៈ-ជំនឿ*។

៨. ជួន ណាត (១៩៦៧) *វចនានុក្រមខ្មែរភាគ១&២*, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ។

៩. ញាណ ភឿន និងម៉ម ផៃ (២០០៤) *លំអានទំនៀមខ្មែរបុរាណ* (ទម្លាប់អាចារ្យ)។

១០. ត្រឹង ងា (១៩៧៣) *ប្រវត្តិសាស្ត្រខ្មែរភាគ១&២*។

១១. ពន់ ឆាយ (២០០៨) *ទ្រឹស្តីនិងអក្សរសិល្ប៍*, ឯកសារប្រើប្រាស់ផ្ទៃក្នុង។

១២. ពុទ្ធសាសនបណ្ឌិត្យ (១៩៥៧) *ពុទ្ធសាសនា២៥០០ឆ្នាំ*។

១៣. ពេជ្រ ទុំក្រវិល (២០១០) *តន្ត្រី របាំ និងល្ខោនខ្មែរ*, គ្រឹះស្ថានបោះពុម្ពផ្សាយសាស្ត្រា។

១៤. មៀច ប៉ុណ្ណ (២០០៧) *ប្រពៃណីនិងទំនៀមទម្លាប់ខ្មែរភាគ១*។

១៥. មីសែល ត្រាណេ (២០០៣) *ប្រវត្តិសាស្ត្រកម្ពុជា(សង្ខេប)*។

១៦. វ៉ៃយំ (២០០៥) *ក្បាច់ខ្មែរ*។

១៧. វ៉ៃយំ (២០០១) *ខ្មែរប្រឈមមុខនឹងវប្បធម៌*។

១៨. សរ សារុន (?) *វប្បធម៌និងអរិយធម៌ខ្មែរសម្រាប់ថ្នាក់ទីបញ្ចប់*, បណ្ណាគារពន្លឺវិទ្យា។

១៩. សុខ សុត្ថាល (១៩៧២) *ទស្សនវិជ្ជាឥណ្ឌានិងពហុទេពនិយម*។

២០. សេង គឹមលី (២០០២) *ប្រវត្តិសិល្បៈខ្មែរ*។

២១. សែម សូរ (១៩៧១) *វប្បធម៌ឥណ្ឌា-ខ្មែរថ្នាក់ទីបញ្ចប់*។

២២. ហ៊ិន សារិន (២០០០) *តន្ត្រីបុរាណកម្ពុជា*។

២៣. អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, ស៊ុន ចាន់ដឹប (២០០៧) *ដំណើរជីវិតមនុស្សខ្មែរមើលតាមពិធីឆ្លងវ័យ*, ហនុមានទេសចរណ៍។

២៤. អាំង ជូលាន, អេរិក ប្រេណូរិត្យ, អាស្លីថមសុន (១៩៩៨) *អង្គរ អតីត-បច្ចុប្បន្ន-អនាគត*, អាជ្ញាធរអប្សរា។

២៥. អ្នកស្រី ត្រឹង ងា (១៩៧៤) *អរិយធម៌ខ្មែរសម្រាប់ថ្នាក់ទីបញ្ចប់*។

២៦. អ្នកស្រី ពេជ សល់ (១៩៦៧) *លំនាំសង្ខេបនៃភ្លេងខ្មែរ*។

២៧. Haviliand. 2006. *Cultural Anthropology.*

២៨. វិបសាយ www. khmerenaissance.info

២៩. វិបសាយ www. cen.com.kh

៣០. វិបសាយ www.google.com